សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងវិស័យសំណង់នៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ក. **អ៊ឹម ស៊ីម៉ី**

ក. **តាន់ សម្បត្តិម៉ារីណា**

សាស្ត្រាចារ្យណែនាំ

លោកបណ្ឌិត **អ៊ុន សភក្តិជា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៥ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងវិស័យសំណង់នៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ក. **អ៊ឹម ស៊ីម៉ី**

ក. **តាន់ សម្បត្តិម៉ារីណា**

សាស្ត្រាចារ្យណែនាំ

លោកបណ្ឌិត **អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៥ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# លិខិតថ្លែងអំណរគុណ

នាងខ្ញុំ **តាន់ សម្បត្តិម៉ារីណា** និង **អ៊ឹម ស៊ីម៉ី** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៥ (អាហារូបករណ៍) នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាដំបូងសូមលើកដៃក្រាបបង្គំអ្នកមានគុណទាំងទ្វេ គឺលោកឪពុក **តាន់ ចរិយា** អ្នកម្តាយ **ហ៊ី តារាឈេង** ព្រមទាំងលោកឪពុក **អ៊ឹម សុភាព** អ្នកម្តាយ **ហ៊ុន គុន្ធា**។ នាងខ្ញុំទាំងពីរ សូមអនុញ្ញាតសម្តែងនូវការគោរពប្រតិបត្តិ ដឹងគុណ យ៉ាងជ្រាលជ្រៅចំពោះអ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើតដល់រូបនាងខ្ញុំ និងបានខិតខំពុះពារ ចិញ្ចឹមបីបាច់ការពារ និងថែរក្សាកូនយ៉ាងប្រុងប្រយ័ត្ន។ លោកបានផ្តល់នូវទំនុកបំរុងយ៉ាងល្អបំផុតដល់កូនរហូតមកទាំងផ្លូវកាយ ផ្លូវចិត្ត សម្ភារៈ អាហារូបត្ថម្ភសម្រាប់រស់នៅ និងជាពិសេសគឺការឧបត្ថម្ភជ្រោមជ្រែង លើកទឹកចិត្តឱ្យនាងខ្ញុំបានបន្តការសិក្សាតាំងពីបឋមសិក្សា រហូតដល់ឧត្តមសិក្សាបានខ្ពង់ខ្ពស់រហូតដល់ថ្ងៃនេះ។ កូនមិនភ្លេចឡើយនូវគុណនូបការៈនៃលោកទាំងបួន ដែលបានអប់រំទូន្មានឱ្យកូនក្លាយជាកោសិកាសង្គមដ៏មានតម្លៃក្នុងការអភិវឌ្ឍសង្គមគ្រួសារ និងសង្គមជាតិនេះ។

ជាបន្ទាប់ នាងខ្ញុំទាំងពីរសូមសម្តែងនូវការគោរពដល់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និង លោក លោកស្រីសាស្ត្រាចារ្យ** ទាំងអស់ដែលបានខិតខំទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការដឹកនាំ គ្រប់គ្រង បង្ហាត់បង្រៀនដល់ក្រុមនាងខ្ញុំជាច្រើន ទាក់ទងក្នុងវិស័យច្បាប់ និងស្ថានភាពសង្គមជាក់ស្តែង ជាពិសេសបានផ្តល់នូវដំបូន្មានដល់ពួកយើងជាច្រើនរហូតមក ដើម្បីជាទុនដល់ការស្រាវជ្រាវ និងគំនិតក្នុងការតាក់តែងស្នាដៃនេះឡើង។

ជាពិសេស នាងខ្ញុំទាំងពីរសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **លោកបណ្ឌិត អ៊ុំន សកក្កដា** ដែលបានជួយដឹកនាំជ្រោមជ្រែង នាងខ្ញុំក្នុងរយៈពេលសរសេរសារណាបញ្ចប់ឆ្នាំមួយនេះរហូតមក។ លោកបានចំណាយពេលដ៏មានតម្លៃក្នុងការផ្តល់យោបល់ និងកែលម្អនូវស្នាដៃនេះរហូតនាងខ្ញុំបានសម្រេចដោយជោគជ័យនូវពេលនេះ។

ជាទីបញ្ចប់ ក្រុមនាងខ្ញុំសូមលើកដៃបួងសួង ដល់រាល់វត្ថុស័ក្តិសិទ្ធទាំងអស់នៅក្នុងប្រទេសកម្ពុជា សូមឱ្យជួយថែរក្សាការពារលោកទាំងឡាយខាងលើ ឱ្យទទួលបានសេចក្តីសុខគ្រប់ប្រការ អាយុយឺនយូរ និងទទួលបានជោគជ័យគ្រប់ភារកិច្ចការងារ និងគ្រប់ពេលវេលា។

# អារម្ភកថា

ក្រុមនាងខ្ញុំមានសេចក្តីសោមនស្សក្នុងការស្រាវជ្រាវលើប្រធានបទមួយស្តីពី **ការគ្រប់គ្រងវិស័យសំណង់នៅកម្ពុជា។** កិច្ចការស្រាវជ្រាវនេះ កើតចេញពីការខិតខំប្រឹងប្រែងព្យាយាមរបស់នាងខ្ញុំទាំងពីរ នៅក្រោមការដឹកនាំប្រកបដោយការយកចិត្តទុកដាក់ខ្ពស់បំផុតពីសំណាក់ **លោកបណ្ឌិត អ៊ុន សកក្កដា។** ក្រុមនាងខ្ញុំ បានស្រាវជ្រាវរកឯកសារនានាដែលពាក់ព័ន្ធនឹងសារណានេះ ព្រមទាំងទទួលបានចំណេះដឹងពីសាស្ត្រាចារ្យ បូករួមនឹងការឆ្វេងយល់នូវចំណេះដឹងទូទៅបន្ថែមដោយខ្លួនឯង ធ្វើឱ្យស្នាដៃស្រាវជ្រាវនេះលេចជារូបរាងឡើងនាពេលនេះ។ នៅក្នុងការស្រាវជ្រាវលើប្រធានបទ វាមិនមែនជាការងាយស្រួលឡើយដោយហេតុថា ការស្រាវជ្រាវទាមទារនូវការស្វែងរកឯកសារដែលអាចជឿទុកចិត្តបាន ដើម្បីយកមកធ្វើការតាក់តែងអត្ថបទជាលាយលក្ខណ៍អក្សរ។ ការស្រាវជ្រាវមួយនេះបានបង្កើនចំណេះដឹងយ៉ាងច្រើនដល់នាងខ្ញុំទាំងពីរនាក់អំពី **ការគ្រប់គ្រងវិស័យសំណង់នៅកម្ពុជា** ដែលមានដូចជា៖ ទិដ្ឋភាពរួមនៃសំណង់ ការគ្រប់គ្រងសំណង់ទៅតាមប្រព័ន្ធច្បាប់ដែលបានបង្កើតឡើង ជាពិសេសស្ថានភាពជាក់ស្តែងនៃការអនុវត្តទៅតាមច្បាប់កំណត់។

ការសម្រេចចិត្តជ្រើសរើសនូវប្រធានបទនេះ គឺធ្វើឡើងក្នុងគោលបំណងបង្ហាញពីសញ្ញាណទូទៅមួយចំនួនដែលគួរយល់ដឹងនៅក្នុងវិស័យសំណង់ ដោយចង្អុលពីគោលការណ៍ទូទៅនៃសំណង់ សមត្ថកិច្ចនិងតួនាទីនៃស្ថាប័ន ការបែងចែកប្រភេទនីមួយៗនៃសំណង់ ជាពិសេសនីតិវិធីនៅក្នុងការសាងសង់។ បន្ថែមពីលើការស្រាវជ្រាវនេះ យើងក៏បានលើកឡើងពីការគ្រប់គ្រងលើវិស័យសំណង់នៅមុន និងក្រោយពេលច្បាប់ស្តីពីសំណង់ចូលជាធរមាន ដើម្បីបង្ហាញអំពីភាពខុសគ្នាព្រមទាំងប្រសិទ្ធភាពក្នុងការគ្រប់គ្រង រួមទាំងការអនុវត្តការងាររបស់បុគ្គលដែលពាក់ព័ន្ធក្នុងវិស័យនេះ។ ម្យ៉ាងវិញទៀត ការចងក្រងធ្វើជាសារណាបញ្ចប់ការសិក្សានេះឡើង មានគោលដៅចង់ឱ្យសិស្សានុសិស្ស និស្សិត និងមិត្តៗអ្នកអាន ក៏ដូចជាអ្នកស្រាវជ្រាវទាំងអស់បានយល់ដឹងបន្ថែមទៅលើចំណេះដឹងដែលខ្លួនមានស្រាប់នៅក្នុងវិស័យសំណង់នៅព្រះរាជាណាចក្រកម្ពុជា។

សារណាបញ្ចប់ការសិក្សាមួយនេះ គឺជាសមិទ្ធិផលមួយដែលក្រុមនាងខ្ញុំបានខិតខំស្វះស្វែងស្រាវជ្រាវ ព្រមទាំងធ្វើការវិភាគទៅលើដំណើរការនីមួយៗ ប្រកបដោយការយកចិត្តទុកដាក់បំផុត។ ប៉ុន្តែបើទោះបីជាមានការខិតខំស្រាវជ្រាវយ៉ាងណាក៏ដោយ ក៏កិច្ចការស្រាវជ្រាវនីមួយៗ រមែងតែងតែជួបប្រទះនូវភាពខ្វះចន្លោះ និងមិនទាន់មានន័យគ្រប់ជ្រុងជ្រោយមួយរយភាគរយនៅឡើយនោះទេ។ ហេតុដូចនេះហើយ នាងខ្ញុំទាំងពីរសង្ឃឹមថាអ្នកអាននិងអ្នកស្រាវជ្រាវទាំងអស់ធ្វើការអភ័យទោសដល់ក្រុមនាងខ្ញុំ ចំពោះកំហុសដោយអចេតនានៅក្នុងប្រការណាមួយ ហើយក្រុមនាងខ្ញុំក៏សូមធ្វើការស្វាគមន៍ជានិច្ចនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាទាំងឡាយពីសំណាក់អ្នកអាន និងអ្នកស្រាវជ្រាវ ដើម្បីជាជំនួយឱ្យក្រុមនាងខ្ញុំមានការអភិវឌ្ឍខ្លួនកាន់តែប្រសើរនិងមានភាពរីកចម្រើនជាងមុន។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ **១**

**ជំពូកទី ១**

**សញ្ញាណទូទៅក្នុងការគ្រប់គ្រងសំណង់**

**១.១. និដ្ឋភាពរួមនៃសំណង់** ........ **៣**

**១.១.១. គោលការណ៍ទូទៅនៃសំណង់** ........ ៣

**១.១.២. ស្ថាប័នមានសមត្ថកិច្ចនិងតួនាទីនៃស្ថាប័ននីមួយៗក្នុងវិស័យសំណង់** ........ ៤

១.១.២.១. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ........ ៤

១.១.២.២. ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ........ ១០

១.១.២.៣. ក្រសួងមហាផ្ទៃ ........ ១០

**១.១.៣. បំណែងចែក នៃប្រភេទសំណង់** ........ ១៣

**១.២. នីតិវិធីក្នុងការសាងសង់សំណង់** ........ **១២**

**១.២.១. នីតិវិធីមុនពេលចាប់ផ្តើមសាងសង់** ........ ១២

១.២.១.១. ការស្នើសុំលិខិតអនុញ្ញាតសាងសង់ ........ ១៣

១.២.១.២. ការស្នើសុំលិខិតបើកការដ្ឋានសាងសង់ ........ ១៨

**១.២.២. នីតិវិធីនៅក្នុងអំឡុងពេល និងក្រោយពេលសាងសង់** ........ ១៩

១.២.២.១. ការត្រួតពិនិត្យដំណើរការនៃការសាងសង់សំណង់ ........ ១៩

១.២.២.២. ការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ........ ១៩

១.២.២.៣. លិខិតអនុញ្ញាតរុះរើសំណង់ ........ ២៣

**ជំពូកទី ២**

**ការគ្រប់គ្រងវិស័យសំណង់នៅកម្ពុជា**

**២.១. ការគ្រប់គ្រងសំណង់មុនច្បាប់សំណង់ចូលជាធរមាន** ........ **២៤**

**២.១.១. ការគ្រប់គ្រងទូទៅ** ........ ២៤

២.១.១.១. លិខិតអនុញ្ញាតសាងសង់ ឬ លិខិតអនុញ្ញាតរុះរើ ........ ២៤

២.១.១.២. ការគ្រប់គ្រងការដ្ឋានសំណង់ ........ ២៦

**២.១.២. ការគ្រប់គ្រងបុគ្គលពាក់ព័ន្ធក្នុងវិស័យសំណង់** ........ ៣០

២.១.២.១. អ្នកវិជ្ជាជីវៈ សិក្សាគម្រោងប្លង់ ........ ៣០

២.១.២.២. ការប្រកបវិជ្ជាជីវៈនិងការប្រកបអាជីវកម្មក្នុងវិស័យសំណង់ ........ ៣១

**២.១.៣. ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់** ........ ៣៤

**២.២. ការគ្រប់គ្រងសំណង់ក្រោយច្បាប់ចូលជាធរមាន ........ ៣៦**

**២.២.១. ការគ្រប់គ្រងទូទៅ** ........ ៣៦

២.២.១.១. លិខិតអនុញ្ញាតសាងសង់ ជួលជុល ឬរុះរើ ........ ៣៦

២.២.១.២. ការគ្រប់គ្រងគម្រោងប្លង់ ........ ៣៧

២.២.១.៣. ការគ្រប់គ្រងការងារសាងសង់ឬរុះរើ ........ ៣៨

២.២.១.៤. ការប្រើប្រាស់សំណង់ ........ ៤០

២.២.១.៥. អធិការកិច្ចសំណង់ ........ ៤២

២.២.១.៦. វិសមិតភាព ........ ៤៣

**២.២.២. បទប្បញ្ញត្តិបច្ចេកទេសសំណង់** ........ ៤៤

**២.២.៣. ការគ្រប់គ្រងបុគ្គលពាក់ព័ន្ធក្នុងវិស័យសំណង់** ........ ៤៥

២.២.៣.១. អ្នកវិជ្ជាជីវៈ ........ ៤៥

២.២.៣.២. ការប្រកបវិជ្ជាជីវៈនិងការប្រកបអាជីវកម្មក្នុងវិស័យសំណង់ ........ ៤៦

**២.២.៤. ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់** ........ ៤៨

**សេចក្តីសន្និដ្ឋាន ........ ៥១**

**អនុសាសន៍ ........ ៥២**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ជាការពិតប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍន៍ ហើយការអភិវឌ្ឍនេះទៀតសោត គឺលើគ្រប់វិស័យ ក្នុងនោះវិស័យសំណង់ក៏បាននឹងកំពុងរីកលូតលាស់យ៉ាងឆាប់រហ័សផងដែរ។ ជាមួយនឹងសន្ទុះនៃការរីកចម្រើននេះ ធ្វើឱ្យតម្រូវការនៃការពង្រឹងការគ្រប់គ្រងរាល់ដំណើរការ និងប្រតិបត្តិការក្នុងវិស័យសំណង់ និងអ្នកពាក់ព័ន្ធនឹងការងារសំណង់កាន់តែមានភាពចាំបាច់ជាសារវ័ន្ត។ សំណង់កាន់តែធំ កាន់តែខ្ពស់ និងកាន់តែស្មុគស្មាញ កាន់តែទាមទារឱ្យការអនុវត្តបានត្រឹមត្រូវតាមបទដ្ឋានគតិយុត្ត បច្ចេកវិទ្យា ស្តង់ដារ និងបទប្បញ្ញត្តិបច្ចេកទេស ដើម្បីធានាភាពរឹងមាំ គុណភាព សោភ័ណភាព និងចីរភាពនៃសំណង់។ ដូចនេះដើម្បីរៀបចំសំណង់ទាំងនោះឱ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយល្អ រាជរដ្ឋាភិបាលបានបង្កើតឱ្យមាននូវក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឡើង ដើម្បីគ្រប់គ្រងទៅលើវិស័យសំណង់នេះ និងជួយឱ្យប្រជាពលរដ្ឋឬវិនិយោគិនដែលធ្វើការវិនិយោគនៅកម្ពុជាងាយស្រួលក្នុងការទំនាក់ទំនង ដើម្បីស្នើសុំសាងសង់នូវសំណង់ដូចជា លំនៅឋាន ក្រុមហ៊ុន រោងចក្រ ឬអគារផ្សេងៗទៀត។

បន្ថែមពីនេះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្របខណ្ឌគតិយុត្តិពាក់ព័ន្ធនឹងវិស័យសំណង់ និងអចលនទ្រព្យនៅកម្ពុជា ជាពិសេសទៅលើវិស័យសំណង់អគារ និងហេដ្ឋារចនាសម្ព័ន្ធ រូបវន្តកំពុងកើនឡើងជាបន្តបន្ទាប់ និងដើម្បីរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល បដិវត្តន៍ឧស្សាហកម្មទី៤ និងដើម្បីលើកកម្ពស់អត្តសញ្ញាណជាតិ និងភាពសុខដុមរមនានៅក្នុងសង្គម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានរៀបចំច្បាប់ស្តីពីសំណង់មួយ ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលគោលដៅកំណត់គោលការណ៍ បទប្បញ្ញត្តិបច្ចេកទេសសំណង់ វិធាន និងនីតិវិធីក្នុងការគ្រប់គ្រងវិស័យសំណង់ក្នុងព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងការអនុវត្តការងារប្រចាំថ្ងៃមិនថា ចំពោះជីវភាពរស់នៅធម្មតា ឬ ការងារក្នុងវិស័យឯកជន ឬ រដ្ឋបាលសាធារណៈនោះទេ គេរមែងសង្កេតឃើញថា ការអនុវត្តក៏ដូចជាការគ្រប់គ្រងទៅលើវិស័យសំណង់នៅមានភាពខ្វះចន្លោះបន្តិចបន្តួចនៅឡើយ។ ម៉្យាងវិញទៀត ប្រជាពលរដ្ឋមួយចំនួន ក៏ដូចជាវិនិយោគិននៅក៏ពុំទាន់បានយល់ដឹងច្បាស់អំពី សិទ្ធិនិងកាតព្វកិច្ចរបស់គាត់ក្នុងវិស័យនេះនៅឡើយ។ ដោយសារតែភាពខ្វះចន្លោះក្នុងការយល់ដឹងនេះ បូករួមនឹងការធ្វេសប្រហែសក្នុងបច្ចេកទេសសំណង់ ជាហេតុនាំឱ្យរាជរដ្ឋាភិបាលមានការពិបាកក្នុងការរៀបចំនគរូបនីយកម្ម[1] និងសំណង់ដែលសាងសង់នៅក្នុងប្រទេស។ ជាលទ្ធផល បញ្ហាសំណង់អនាធិបតេយ្យកើតមានឡើង ព្រមទាំងមានការបាក់រលំអគារ នាំឱ្យបាត់បង់ជីវិតមនុស្ស ខូចខាតទ្រព្យសម្បត្តិ រួមទាំងហេដ្ឋារចនាសម្ព័ន្ធផងដែរ។ ជាក់ស្តែងដូចជាការបាក់រលំអគារនៅខេត្តព្រះសីហនុ និងខេត្តកែប ដែលសម្លាប់ជីវិតមនុស្ស និងមានអ្នករងរបួសជាច្រើននាក់ ដែលកើតឡើងមកពីបញ្ហាបច្ចេកទេសនៃការសាងសង់ ដែលមាន

[1] នគរូបនីយកម្ម សំដៅលើការរៀបចំ និងការអភិវឌ្ឍទីក្រុង ឬខេត្តក្នុងបំណងដើម្បីបម្រើប្រយោជន៍ទូទៅ ។

ដូចជា ការគូសប្លង់ដែលប្រើប្រាស់ទំហំដែកខុស ព្រមទាំងបញ្ហាប្លង់សេនៃសំណង់។

ដោយមើលឃើញពី សារៈសំខាន់នៃការយល់ដឹងពីវិស័យសំណង់ បូករួមនឹងការប្រកាសឱ្យប្រើនូវច្បាប់ស្តីពីសំណង់នាពេលថ្មីៗនេះ ទើបក្រុមនាងខ្ញុំសម្រេចជ្រើសរើសយកប្រធានបទ "**ការគ្រប់គ្រងវិស័យសំណង់នៅកម្ពុជា**" មកធ្វើជាប្រធានបទសារណាបញ្ចប់ការសិក្សានេះ ដើម្បីបង្ហាញពីទិដ្ឋភាពរួមនៃការគ្រប់គ្រងសំណង់ នីតិវិធីក្នុងការសាងសង់ ព្រមទាំងការគ្រប់គ្រងនិងអនុវត្តសំណង់ឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់។ ដូចនេះដើម្បីធ្វើការបកស្រាយឱ្យបានក្បោះក្បាយនូវប្រធានបទខាងលើ សារណានេះនឹងធ្វើការបែងចែកជា ២ ជំពូកធំៗ គឺ៖

ជំពូកទី១៖ សញ្ញាណទូទៅក្នុងការគ្រប់គ្រងសំណង់

ជំពូកទី២ ៖ការគ្រប់គ្រងវិស័យសំណង់នៅកម្ពុជា។

# ជំពូកទី១

# សញ្ញាណទូទៅ

# ក្នុងការគ្រប់គ្រងសំណង់

# ជំពូកទី ១

# សញ្ញាណទូទៅក្នុងការគ្រប់គ្រងសំណង់

ការគ្រប់គ្រងសំណង់នៅកម្ពុជា បានធ្វើឡើងជាដំណាក់កាលៗ ដោយស្របទៅនឹងដំណើរនៃការវិវឌ្ឍន៍នៃវិស័យនេះ។ តួយ៉ាងនៅមុនពេល ច្បាប់ស្តីពីសំណង់ ត្រូវបានប្រកាសឱ្យប្រើនិងចូលជាធរមាន ការអនុវត្តនៅក្នុងវិស័យសំណង់មិនទាន់មានច្បាប់ណាមួយជាក់លាក់ដើម្បីគ្រប់គ្រងឡើយ គឺដំណើរការគ្រប់គ្រងដោយអនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗប៉ុណ្ណោះ។ ដូច្នេះហើយដើម្បីឆ្លើយតប និងដើម្បីពង្រឹងដល់ការគ្រប់គ្រងសំណង់កាន់តែមានប្រសិទ្ធិភាពជាមុន រាជរដ្ឋាភិបាលបានបង្កើតនិងប្រកាសឱ្យប្រើនូវ ច្បាប់ស្តីពីសំណង់ កាលពីថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលមាន ១១១ មាត្រា និង ២២ ជំពូក ក្នុងគោលបំណងដើម្បីធានានូវគុណភាព សន្តិសុខ សុវត្ថិភាពនៅក្នុងវិស័យសំណង់ ព្រមទាំងសោភ័ណភាពនិងបរិស្ថានសំដៅលើកកម្ពស់សុខមាលភាពសាធារណៈ គណនេយ្យភាព ប្រសិទ្ធភាពក្នុងការប្រកបការងារនិងវិជ្ជាជីវៈក្នុងវិស័យសំណង់។ ច្បាប់នេះក៏បង្កើតឡើងក្នុងគោលដៅដើម្បីបង្កើនការជឿទុកចិត្តរបស់វិនិយោគិនក្នុងវិស័យនេះ និងក្នុងពេលតែមួយជំរុញទីផ្សារអចលនវត្ថុប្រកបដោយប្រសិទ្ធភាព។ ដើម្បីបកស្រាយឱ្យបានក្បោះក្បាយនៅក្នុងជំពូកនៃសញ្ញាណទូទៅនៃការគ្រប់គ្រងវិស័យសំណង់នេះ នាងខ្ញុំនឹងធ្វើការចែកជំពូកនេះជា ២ កថាខណ្ឌគឺៈ ទី១ ទិដ្ឋភាពរួមនៃសំណង់ និងទី២ នីតិវិធីនៅក្នុងការសាងសង់។

## ១.១. ទិដ្ឋភាពរួមនៃសំណង់

ការរីកលូតលាស់នៃសំណង់ គឺជាបញ្ហាមួយមិនអាចចៀសវាងបាននៅគ្រប់ប្រទេសនៅលើពិភពលោក ព្រោះថាចំនួនមនុស្សតែងតែកើនឡើងជារៀងរាល់វិនាទី ស្របពេលជាមួយគ្នា តម្រូវការរបស់មនុស្សក៏មានការកើនឡើងផងដែរ។ ដូចនេះសំណង់ថ្មីៗ ត្រូវតែកើតមានជានិច្ចដើម្បីបំពេញនូវតម្រូវការដ៏ចាំបាច់ទាំងនេះ។ តួយ៉ាងនៅក្នុងប្រទេសកម្ពុជាប៉ុន្មានឆ្នាំចុងក្រោយនេះ សំណង់ជាច្រើនបានរីកដុះដាលដូចផ្សិត មិនថានៅរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តផ្សេងៗឡើយ ជាពិសេសខេត្តដែលគួរឱ្យកត់សម្គាល់ជាងគេនោះ គឺខេត្តព្រះសីហនុ។ ទន្ទឹមនឹងការរីកចម្រើននៃវិស័យសំណង់នេះ បញ្ហាទាក់ទងនឹងសំណង់ក៏តែងតែកើតមានឡើងស្របជាមួយគ្នាផងដែរ។ ជាក់ស្តែងការដួលរលំសំណង់អគារចំនួន ២ នៅខេត្តព្រះសីហនុ ខេត្តសៀមរាប និងខេត្តកែប នៅពាក់កណ្តាលឆ្នាំ២០១៩ ចុងឆ្នាំ២០១៩ និងដើមឆ្នាំ២០២០ជាបន្តបន្ទាប់។ ជាលទ្ធផល ច្បាប់ស្តីពីសំណង់ដែលចេញនៅចុងឆ្នាំ២០១៩ បានកំណត់យ៉ាងច្បាស់លាស់ពីការគ្រប់គ្រងនៃវិស័យនេះ បន្ថែមលើលិខិតបទដ្ឋានគតិយុត្តិទាំងឡាយដែលមានស្រាប់។

### ១.១.១. គោលការណ៍ទូទៅនៃសំណង់

ដោយហេតុថា កំណើននៃសំណង់នៅតែបន្តកើនឡើងនៅគ្រប់ទីកន្លែង រាជរដ្ឋាភិបាល ឬរដ្ឋាភិបាលនៃប្រទេសនីមួយៗ ត្រូវតែធានាឱ្យបាននូវការស្របគ្នារវាងសំណង់ទាំងនោះជាមួយនឹងនគរូបនីយកម្មរបស់ជាតិ

របស់ខ្លួនផងដែរ។ តួយ៉ាងដើម្បីធានានូវឱ្យបាននូវស្តង់ដាជាអប្បបរមាមួយនៃសំណង់ ស្ថេរភាពនៃការអភិវឌ្ឍន៍ព្រមជាមួយនឹងទិសដៅនគរូបនីយកម្មនៅក្នុងប្រទេស ព្រះរាជាណាចក្រកម្ពុជាបានកំណត់យកនូវគោលការណ៍ទូទៅចំនួនប្រាំនៃសំណង់ ដែលត្រូវធ្វើការប្រកាន់យកជាកំហិតនៅលើរាល់សំណង់ទាំងអស់នៅក្នុងប្រទេសនេះរួមមានដូចជា៖[2]

- ការពារផលប្រយោជន៍សាធារណៈនិងសិទ្ធិបុគ្គល
- ប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន
- រៀបចំដែនដីនិងនគរូបនីយកម្ម
- អភិវឌ្ឍបៃតង ការពារធនធានធម្មជាតិ និងបរិស្ថាន
- រក្សានិងលើកកម្ពស់អត្តសញ្ញាណជាតិ។

គ្រប់សំណង់ទាំងអស់ចាំបាច់ត្រូវគោរពតាមគោលការណ៍ទាំងប្រាំនេះ ទើបទទួលបានការអនុញ្ញាតក្នុងការសាងសង់សំណង់ស្របទៅតាមច្បាប់កំណត់។ បន្ទាប់ពីធានាថាសំណង់របស់ខ្លួនបានបំពេញទៅតាមគោលការណ៍ទាំងនេះហើយ ម្ចាស់សំណង់ត្រូវធ្វើការស្នើសុំទៅកាន់ដែលស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងដើម្បីអាចចាប់ផ្តើមការសាងសង់បាន។

### ១.១.២. ស្ថាប័នមានសមត្ថកិច្ចនិងតួនាទីនៃស្ថាប័ននីមួយៗក្នុងវិស័យសំណង់

មិនខុសពីវិស័យដទៃទៀតដែរ នៅក្នុងវិស័យសំណង់មានស្ថាប័ននិងអង្គភាពជាច្រើនដែលមានសមត្ថកិច្ចពាក់ព័ន្ធដែលមាននូវសមត្ថកិច្ចគ្រប់គ្រង និងត្រួតពិនិត្យតាមផ្នែកផ្សេងៗគ្នា។ ប៉ុន្តែស្ថាប័នមួយដែលបានសមត្ថកិច្ចផ្ទាល់ និងគ្រប់គ្រងលើការងារសំណង់ទាំងមូលគឺ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ រីឯស្ថាប័នដែលមានសមត្ថកិច្ចលើផ្នែកមួយចំនួនរបស់វិស័យសំណង់ដែរនោះមានដូចជា ក្រុមប្រឹក្សាជាតិបទបញ្ញត្តិបច្ចេកទេសសំណង់ ដែលមានសមត្ថកិច្ចទាក់ទងនឹងបទដ្ឋានបច្ចេកទេសនៃសំណង់ និង ក្រសួងមហាផ្ទៃដែលមានសមត្ថកិច្ចទាក់ទងនឹងសុវត្ថិភាពអគ្គិភ័យនៃសំណង់។ ក្រៅពីនេះមានស្ថាប័នផ្សេងទៀត ដែលអាចមានសមត្ថកិច្ចលើវិស័យសំណង់ផងដែរ ដោយផ្អែកទៅលើប្រភេទនៃសំណង់នីមួយៗ។ ឧទាហរណ៍ ចំពោះសំណង់ណាដែលតម្រូវឱ្យមានការអនុញ្ញាតពីក្រសួងបរិស្ថាន ក្រសួងបរិស្ថាននឹងក្លាយជាស្ថាប័នមានសមត្ថកិច្ច ប៉ុន្តែមិនមែនគ្រប់សំណង់ចាំបាច់ត្រូវតែត្រូវមានការអនុញ្ញាតនេះទេ។

#### ១.១.២.១. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានបង្កើតឡើងនៅឆ្នាំ១៩៩៩ តាមរយៈច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយមាននូវសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យ

[2] មាត្រា ៦ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅទូទាំងប្រទេសកម្ពុជា។[3] មិនតែប៉ុណ្ណោះ ដើម្បីងាយស្រួលនៅក្នុងការគ្រប់គ្រងកិច្ចការ និងពន្លឿននូវដំណើរការការងារ ច្បាប់ស្តីពីសំណង់ បានអនុញ្ញាតឱ្យក្រសួងនេះ អាចប្រគល់ ឬធ្វើប្រតិភូកម្មសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់ដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផងដែរ។[4] សមត្ថកិច្ចរបស់ក្រសួង ក្នុងការគ្រប់គ្រងនេះចែកចេញជាពីរថ្នាក់គឺ សមត្ថកិច្ចថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**ក. សមត្ថកិច្ចថ្នាក់ជាតិ**

សមត្ថកិច្ចថ្នាក់ជាតិនៅក្នុងន័យនេះ សំដៅលើសមត្ថកិច្ចនៅថ្នាក់ក្រសួង ជារួមគឺក្រសួងដែនដី នគរូបនីយកម្ម និងសំណង់។ នៅក្នុងក្រសួងនេះ អគ្គនាយកដ្ឋានមួយដែលជាសេនាធិការមានសមត្ថកិច្ចសម្រាប់គ្រប់គ្រងវិស័យសំណង់ទាំងមូល គឺអគ្គនាយកដ្ឋានសំណង់ ដែលនៅក្នុងនោះចំណុះដោយ នាយកដ្ឋានចំនួន ៣ គឺ នាយកដ្ឋានស្រាវជ្រាវ នាយកដ្ឋានសិក្សាគម្រោងប្លង់ និង នាយកដ្ឋានសំណង់ ដែលមានទទួលខុសត្រូវការងារផ្សេងៗគ្នា។[5] អគ្គនាយកដ្ឋាននេះ មានតួនាទីជាសេនាធិការឱ្យក្រសួងលើការងារទាំងឡាយពាក់ព័ន្ធនឹងវិស័យសំណង់។ តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋាននេះមានដូចជា៖[6]

- ធ្វើការរៀបចំ និងកំណត់ លក្ខណៈវិនិច្ឆ័យបច្ចេកទេសបច្ចេកវិទ្យា បទដ្ឋានបច្ចេកទេសផ្នែកសំណង់ និងស្ថាបត្យកម្ម រួមទាំងស្តង់ដារសម្ភារៈបរិក្ខារសំណង់ឱ្យមានឯកភាព
- ធ្វើការតម្រង់ទិស ណែនាំ តាមដាន ត្រួតពិនិត្យការសាងសង់ ជួសជុល ថែទាំ និង រុះរើ រាល់បណ្តាគម្រោងសំណង់ដែលកំណត់ដោយច្បាប់ និងដោយប្រកាសអន្តរក្រសួង
- ធ្វើការគ្រប់គ្រងបច្ចេកទេសវិជ្ជាជីវៈ និងចេញលិខិតអនុញ្ញាអាជីវកម្មទាក់ទងនឹងការសាងសង់ និងការសិក្សាគម្រោងប្លង់
- ធ្វើការត្រួតពិនិត្យ ធ្វើការពិសោធន៍ និងធ្វើការកំណត់ស្តង់ដារគុណភាព គ្រប់សម្ភារៈ និងបរិក្ខារសំណង់

បន្ថែមពីនេះ អគ្គនាយកដ្ឋានក៏មានតួនាទីក្នុងការ លើកស្ទួយខឿនស្ថាបត្យកម្មក្នុងវិស័យសំណង់ឱ្យមានលក្ខណៈជាតិ និងទំនើបទាន់សម័យ សម្របសម្រួលជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីត្រួតពិនិត្យបណ្តាគម្រោងវិនិយោគសំណង់ ព្រមទាំងលើផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់បុគ្គលិកទាំងអស់ និងណែនាំបច្ចេកទេសដល់បណ្តាគ្រឹះស្ថានបណ្តុះបណ្តាលមុខវិជ្ជាសំណង់ និងស្ថាបត្យកម្មនៅក្នុងប្រទេស។

បន្ទាប់ពីនេះនាយកដ្ឋានទី១ ដែលនឹងលើកយកមកបកស្រាយនោះគឺ នាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់។ តួនាទី និងភារកិច្ចរបស់នាយកដ្ឋាននេះមានដូចជា៖[7]

---

[3] មាត្រា ១ និង ២ នៃច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៩

[4] មាត្រា ៥ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[5] សូមមើលនៅ ឧបសម្ព័ន្ធ៣.ក

[6] មាត្រា ១៧ នៃអនុក្រឹត្យលេខ ៦២ អនក្រ.បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

[7] មាត្រា ១៨ នៃអនុក្រឹត្យលេខ ៦២ អនក្រ.បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- ធ្វើការស្រាវជ្រាវ កសាង បទប្បញ្ញត្តិ ទម្រង់បែបបទ ក្បួនខ្នាត លក្ខណៈវិនិច្ឆ័យបច្ចេកទេស បច្ចេកវិទ្យា បទដ្ឋានបច្ចេកទេសផ្នែកសំណង់ និងស្ថាបត្យកម្ម រួមមាន៖ សំភារៈ បរិក្ខារសំណង់ជាដើម
- ធ្វើការកំណត់ស្តង់ដារ ប្រភេទ សំភារៈ បរិក្ខារសំណង់ និងលក្ខណៈវិនិច្ឆ័យបច្ចេកទេស គុណភាពការងារសំណង់ និងចូលរួមផ្តល់យោបល់អំពីគុណភាពសំណង់ តម្រូវការគុណភាព សំភារៈ បរិក្ខារ គ្រឿងចក្រសំណង់ ដែលនាំចូលពីបរទេសតាមការផ្លាស់ប្តូរពាណិជ្ជកម្ម និងផលិតផលក្នុងស្រុក
- ធ្វើការចងក្រងបណ្តាបញ្ជីតម្លៃសំភារៈសំណង់ គ្រឿងចក្រសំណង់ និងពលកម្ម ដែលប្រែប្រួលតាមខេត្ត ក្រុង និងតាមដានជាប្រចាំនូវការកែប្រែប្រួលថ្លៃនៅតាមទីផ្សារទាំងនោះ
- ធ្វើការត្រួតពិនិត្យ និងដាក់ឱ្យធ្វើការពិសោធន៍សំភារៈសំណង់ គ្រឿងផ្គុំសំណង់ ដី ព្រមទាំងស្រាវជ្រាវ បង្កើតមុខសំភារៈសំណង់ថ្មីៗ ដោយប្រើប្រាស់វត្ថុធាតុដើមក្នុងប្រទេសបម្រើឱ្យ លំនៅឋានរបស់ប្រជាពលរដ្ឋ និងដោយស្រាវជ្រាវជាប្រចាំនូវមុខសំភារៈផលិតផលចេញថ្មីៗ គ្រឿងចក្រ បរិក្ខារបម្រើឱ្យការងារសាងសង់ទំនើបៗ លើទីផ្សារជាតិ និងអន្តរជាតិ
- ធ្វើការសហការជាមួយនាយកដ្ឋានបុគ្គលិក និង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបណ្តុះបណ្តាលជំនាញបច្ចេកទេសសំណង់ដល់បុគ្គលិកក្រសួង និងបណ្តាមន្ទីរខេត្តក្រុង

មិនតែប៉ុណ្ណោះ នាយកដ្ឋាននេះត្រូវធ្វើការចាត់ចែងអប់រំ ផ្សព្វផ្សាយឯកសារបច្ចេកទេសសំណង់ដល់គ្រប់មជ្ឈដ្ឋាន ដើម្បីលើកស្ទួយប្រសិទ្ធភាព សេដ្ឋកិច្ច សុវត្ថិភាព និងសុខុមាលភាពសាធារណៈ ព្រមទាំងណែនាំបច្ចេកទេសដល់បណ្តាគ្រឹះស្ថានបណ្តុះបណ្តាលមុខវិជ្ជាសំណង់ និងស្ថាបត្យកម្ម។

នាយកដ្ឋានទី២ គឺ នាយកដ្ឋានសិក្សាគម្រោងប្លង់។ តួនាទី និងភារកិច្ចមានដូចជា៖[8]

- ធ្វើការសិក្សាគម្រោងប្លង់សាងសង់ថ្មី ជួសជុស កែលំអរ ពង្រីកបើកទូលាយអគាររបស់បណ្តាក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីខេត្ត ក្រុង ដែលប្រើប្រាស់ថវិការបស់រដ្ឋ ឯកជន អង្គការនានា អ្នកវិនិយោគទុនក្នុងប្រទេស ឬក្រៅប្រទេស និងអង្គការអន្តរជាតិ
- ធ្វើការសិក្សា ស្រាវជ្រាវ ធ្វើគម្រោងប្លង់ ដែលចែកចេញជាផ្នែកឯកសារបច្ចេកទេស ស្ថាបត្យកម្ម និងផ្នែកគំនូរប្លង់
- ធ្វើការសិក្សាស្រាវជ្រាវគម្រោងប្លង់ និងធ្វើបញ្ជីប៉ាន់ស្មានសម្ភារៈនៃគម្រោងសំណង់សាធារណៈ
- ធ្វើការត្រួតពិនិត្យ គម្រោងប្លង់ស្ថាបត្យកម្ម និងបច្ចេកទេសសំណង់អគារ សៀវភៅបន្ទុកនៃការដ្ឋានសាងសង់ និងបណ្តាគម្រោងប្លង់អ្នកវិនិយោគនានា អំពីតម្រូវការពិតនៃសម្ភារៈសំណង់នាំចូលជារូបិយបណ្ណ
- ធ្វើការគ្រប់គ្រង ត្រួតពិនិត្យ កំណត់សមត្ថភាពបច្ចេកទេស ព្រមទាំងចេញលិខិតអនុញ្ញាតបើកអាជីវកម្ម

[8] មាត្រា ១៩ នៃអនុក្រឹត្យលេខ ៦២ អនក្រ.បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ដល់រូបវន្តបុគ្គល និងនីតិបុគ្គលដែលធ្វើអាជីវកម្មទាក់ទងនឹងការសិក្សាធ្វើគម្រោងប្លង់ និងការសាងសង់។ នាយកដ្ឋានទី៣ នោះគឺ នាយកដ្ឋានសំណង់។ តួនាទី និងភារកិច្ចមានដូចជាៈ[9]

- ធ្វើការណែនាំ តាមដាន ត្រួតពិនិត្យរាល់ការងារបច្ចេកទេសក្នុងការសាងសង់ រុះរើ តាមដំណាក់កាលនីមួយៗ ដើម្បីធានាសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ គុណភាពសំណង់
- ធ្វើការចេញលិខិតអនុញ្ញាតបើកនិងបិទការដ្ឋានរបស់បណ្តាសហគ្រាស ក្រុមហ៊ុន អង្គភាពសាងសង់នានា
- ធ្វើការចូលរួមធ្វើកោសល្យវិច័យនានា ផ្តល់សំណុំឯកសារបច្ចេកទេសសល់ស្ថាប័នមានសមត្ថកិច្ចក្នុងករណីវិវាទបញ្ហាសាងសង់ រុះរើ បាក់ស្រុត និងករណីបទល្មើសផ្សេងទៀត ដែលផ្ទុយនឹងបទដ្ឋានបច្ចេកទេស
- ធ្វើការសិក្សាលើបច្ចេកទេសសាងសង់ទំនើប រឹងមាំ មានប្រសិទ្ធិភាព ជាសកល និងឆាប់រហ័សដែលកំពុងត្រូវប្រើប្រាស់នៅប្រទេសនានា ពិសេសបណ្តាប្រទេសអាស៊ាន
- ធ្វើការតាក់តែងកម្មវិធី និងកសាងគម្រោងថវិការជួសជុល ថែទាំធំៗ ព្រមទាំងធានាអំពីលក្ខណៈបច្ចេកទេសសំណង់តាមកិច្ចសន្យា
- ធ្វើការស្រង់ស្ថិតិ វិភាគទិន្នន័យសេដ្ឋកិច្ច តម្លៃវប្បធម៌ក្នុងការប្រើប្រាស់អគារសាធារណៈ និងបេតិកភណ្ឌ

ជាចុងក្រោយនាយកដ្ឋាននេះក៏មានភារកិច្ចណែនាំត្រួតពិនិត្យរាល់ការងារបច្ចេកទេសក្នុងការជួសជុល កែសម្រួល ដើម្បីធានាសុវត្ថិភាពសណ្តាប់ធ្នាប់សាធារណៈ ប្រសិទ្ធភាពសេដ្ឋកិច្ច សោភ័ណភាព គុណភាពសំណង់ នៃគ្រប់បណ្តាសំណង់សាធារណៈ និងសំណង់បេតិកភណ្ឌ ។

### ខ. សមត្ថកិច្ចថ្នាក់ក្រោមជាតិ

សមត្ថកិច្ចនៅថ្នាក់ក្រោមជាតិ នៅក្នុងវិស័យសំណង់ ត្រូវបានគ្រប់គ្រងដោយ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត ២៥ រាជធានី-ខេត្ត។ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត មានសមត្ថកិច្ចសំខាន់ៗទាក់ទងនឹងវិស័យសំណង់ដូចតទៅដូចតទៅៈ[10] (១)ផ្តល់មតិយោបល់ និង ពិនិត្យលើការស្នើសុំទីតាំងសាងសង់ ដោយផ្អែកលើលិខិតអនញ្ញាតរបស់ក្រសួង (២)ធ្វើការសហការជាមួយអាជ្ញាធរដែនដី អង្គការជាតិ និងអង្គការអន្តរជាតិ (៣)ធ្វើការចូលរួមផ្តល់យោបល់អំពីគុណភាពសំណង់ បរិក្ខារ និង គ្រឿងចក្រ ព្រមទាំងដាក់ឱ្យពិសោធសម្ភារៈ គ្រឿងផ្គុំសំណង់ និង ភូគព្ភសាស្ត្រ (៤)ធ្វើការគ្រប់គ្រង តាមដាន ត្រួតពិនិត្យការសិក្សាស្រាវជ្រាវ គម្រោងប្លង់ និង សំណង់ តាមបណ្តាខេត្ត ក្រុង ស្រុក ខណ្ឌ

[9] មាត្រា ២០ នៃអនុក្រឹត្យលេខ ៦២ អនក្រ.បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

[10] ប្រការ ១ នៃប្រកាសលេខ៧៦ ប្រក/ដ.ន.ស ស្តីពី តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ របស់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានី-ខេត្ត និង តួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ

ឃុំ សង្កាត់ ក្នុងសមត្ថកិច្ចរបស់ខ្លួន និងតាមការប្រគល់ភារកិច្ចរបស់ក្រសួង (៥)ធ្វើការចេញលិខិតអនុញ្ញាតបើកផ្អាក និង បិទ អាជីវកម្មសិក្សាគំរោងប្លង់ និងសាងសង់ដល់រូបវន្តបុគ្គល និងក្រុមជាងសំណង់ និង ពិនិត្យ តាមដាន សមត្ថភាពបច្ចេកទេសអាជីវកម្ម (៦)ធ្វើការចេញលិខិតអនុញ្ញាតសាងសង់ (៧)ធ្វើការណែនាំការងាររៀបចំការដ្ឋានសំណង់ បើកនិងបិទការដ្ឋាន (៨)ធ្វើការចេញលិខិតអនុញ្ញាតសាងសង់ និងពិសេស (៩)ធ្វើការតាមដានអនុវត្តបទប្បញ្ញត្តិ សេចក្តីណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការជួសជុល ថែទាំប្រើប្រាស់សំណង់អគារ សំណង់ការ្យ និងបេតិកភ័ណ្ឌ ក្នុងខេត្ត ក្រុង។

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត មានការិយាល័យចំនួន ៣ គឺ ការិយាល័យរដ្ឋបាល ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និង ការិយាល័យសុរិយោដី និងភូមិសាស្ត្រ និង រីឯនៅថ្នាក់ស្រុក ខណ្ឌវិញ មានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល។[11] ក្នុងចំណោមការិយាល័យនេះ ការិយាល័យដែលមានសមត្ថកិច្ចលើវិស័យសំណង់គឺ ការិយាល័យរៀបចំដែនដី។ តួនាទី និងភារកិច្ចនៃការិយាល័យនេះលើការងារសំណង់មានដូចជាៈ[12]

- ធ្វើការប្រមូលទិន្នន័យតាមខេត្ត ក្រុង ដើម្បីចងក្រងបទប្បញ្ញត្តិពលកម្មសំណង់ សម្ភារៈ បរិក្ខារ និងគ្រឿងចក្រសំណង់ និងប្រព័ន្ធវិស្វកម្ម
- ធ្វើការពិនិត្យ និងដាក់ឱ្យពិសោធសម្ភារៈ គ្រឿងផ្គុំសំណង់ និងភូគព្ភសាស្ត្រ
- ធ្វើការចូលរួមផ្តល់យោបល់អំពីគុណភាពសំណង់ បរិក្ខារ និងគ្រឿងចក្រសំណង់
- ធ្វើការប្រមូលចងក្រងទិន្នន័យតាមខេត្ត ក្រុង នូវការងារឧត្តុនិយម ភូគព្ភសាស្ត្រ និងជលសាស្ត្រលើកិច្ចការសំណង់
- ធ្វើការចងក្រងបញ្ជីតម្លៃពលកម្ម សម្ភារៈ បរិក្ខារ និងគ្រឿងចក្រសំណង់ ដែលប្រែប្រួលតាមខេត្ត ក្រុង
- ធ្វើការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានតាមខេត្ត ក្រុង ដើម្បីធ្វើគម្រោងសំណង់
- ធ្វើការសិក្សាស្រាវជ្រាវគម្រោងប្លង់ និងធ្វើបញ្ជីប៉ាន់ស្មានសម្ភារៈ និងតម្លៃតាមសមត្ថកិច្ចរបស់ខ្លួន
- ធ្វើការចេញលិខិតអនុញ្ញាតបើកអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ ដល់រូបវន្តបុគ្គល និងក្រុមជាងសំណង់
- ធ្វើការពិនិត្យតាមដានសមត្ថភាពបច្ចេកទេសរបស់រូបវន្តបុគ្គល និងក្រុមជាងសំណង់ដែលប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់

[11] ប្រការ ២ នៃប្រកាសលេខ៧៦ ប្រក/ដ.ន.ស ស្តីពី តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ របស់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានី-ខេត្ត និង តួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ។ សូមមើលនៅឧបសម្ព័ន្ធ៣.ខ

[12] ប្រការ ៣ នៃប្រកាសលេខ៧៦ ប្រក/ដ.ន.ស ស្តីពី តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ របស់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានី-ខេត្ត និង តួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ

- ចេញលិខិតអនុញ្ញាតជួសជុល និងរុះរើអគារ លំនៅឋាន និងអគារសាធារណៈ
- ធ្វើការធ្វើកោសល្យវិច័យនិងដោះស្រាយវិវាទពាក់ព័ន្ធនឹងសំណង់
- ធ្វើការចូលរួមលើកផែនការបណ្ដុះបណ្ដាលជំនាញបច្ចេកទេសសំណង់
- ធ្វើការណែនាំការងាររៀបចំការដ្ឋាន ការការពារសុវត្ថិភាពពលកម្ម និងសណ្ដាប់ធ្នាប់សាធារណៈ
- ធ្វើការពិនិត្យសៀវភៅបន្ទុកនៃការដ្ឋានសាងសង់។

មិនតែប៉ុណ្ណោះ ការិយាល័យនេះក៏ជាអ្នកតាមដានអនុវត្តន៍បទប្បញ្ញត្តិ លិខិតបទដ្ឋាន សេចក្ដីណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្នុងការជួសជុល ថែទាំ ប្រើប្រាស់សំណង់អគារ សំណង់ការ្យ និងបេតិកភណ្ឌក្នុងខេត្ត-ក្រុង ធ្វើការតាក់តែងកម្មវិធី និងកសាងគម្រោងថវិកាជួសជុល ថែទាំអគារសាធារណៈ របស់ខេត្ត-ក្រុង ស្រង់ស្ថិតិ វិភាគទិន្នន័យសេដ្ឋកិច្ច តម្លៃវប្បធម៌ ក្នុងការប្រើប្រាស់អគារសាធារណៈ និង បេតិកភណ្ឌ ព្រមទាំងណែនាំ ពិនិត្យសុវត្ថភាព សណ្ដាប់ធ្នាប់សាធារណៈ សោភ័ណភាព គុណភាពសំណង់ និង ហេតុប៉ះពាល់ផ្សេងៗ ក្នុងការជួសជុល និងកែសម្រួលបណ្ដាសំណង់សាធារណៈ និងបេតិកភណ្ឌផងដែរ។

ក្រៅពីនេះ ចំពោះសមត្ថកិច្ចលើសំណង់នៅថ្នាក់ស្រុក ខណ្ឌ ត្រូវបានគ្រប់គ្រងដោយ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល ខណ្ឌ ស្រុក ដែលជាសេនាធិការឱ្យមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត ក្នុងការអនុវត្តផ្ទាល់ និងជាក់ស្ដែងលើការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិសាស្ត្រ និងដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ដែលមានតួនាទី និងភារកិច្ចដូចជាៈ[13]

- ចុះពិនិត្យជាក់ស្ដែងរាល់សំណើសុំសាងសង់ និងជួសជុលសំណង់ ដើម្បីធ្វើរបាយការណ៍បច្ចេកទេស
- តាមដាន ត្រួតពិនិត្យការអនុវត្តលិខិតសាងសង់ រុះរើ និងជួសជុល
- ផ្សព្វផ្សាយលិខិតបទដ្ឋានពាក់ព័ន្ធនឹងការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិសាស្ត្រ
- អង្កេត វាស់វែងដីធ្លី ប្រមូលផ្ដុំចងក្រងឯកសារ ក្នុងក្របខណ្ឌសមត្ថកិច្ចដែលបានកំណត់
- ចុះបញ្ជីអចលនវត្ថុតាមស្រុក ខណ្ឌ ឃុំ សង្កាត់
- អនុវត្តគម្រោងចំណូលដែលថ្នាក់លើសម្រេច ប្រថាប់ត្រា ផ្ទេរសិទ្ធិផ្សេងៗពាក់ព័ន្ធសំណង់ និងដីធ្លី
- គ្រប់គ្រងការងារលិខិតចេញចូល បញ្ជូនឯកសារ សរុបរបាយការណ៍តាមរបបកំណត់។

ជារួមមកយើងឃើញថារចនាសម្ព័ន្ធនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះវិស័យសំណង់មានការបែងចែកទៅតាមផ្នែកបច្ចេកទេសរបស់ស្ថាប័ននីមួយៗ និងតាមសមត្ថកិច្ចរបស់ខ្លួន ដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងវិស័យនេះ។

[13] ប្រការ ៤ នៃប្រកាសលេខ៧៦ ប្រក/ដ.ន.ស ស្ដីពី តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ របស់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានី-ខេត្ត និងតួនាទី ភារកិច្ចរបស់បណ្ដាការិយាល័យក្រោមឱវាទ

### ១.១.២.២. ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់

ក្រុមប្រឹក្សាជាតិបទបញ្ញប្បត្តិបច្ចេកទេសសំណង់មួយត្រូវបានបង្កើតឡើង ដោយមានរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ជាប្រធាន ព្រមទាំងមានតំណាងក្រសួងស្ថាប័ននិងវិស័យឯកជនពាក់ព័ន្ធជាសមាជិក។ ក្រុមប្រឹក្សានេះត្រូវមាននូវអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ។ បច្ចុប្បន្ននេះ ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់បានបង្កើតរួចហើយ ប៉ុន្តែរងចាំអនុក្រឹត្យមួយទៀតដើម្បីដាក់ឱ្យដំណើរការ។ ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ជាអ្នកអនុម័តនូវរាល់បទប្បញ្ញត្តិបច្ចេកទេសសំណង់ ប៉ុន្តែពុំមានអំណាចដាក់ឱ្យប្រើប្រាស់បទប្បញ្ញត្តិនេះឡើយ ដោយការដាក់ឱ្យប្រើប្រាស់នេះ ជាសិទ្ធិរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

### ១.១.២.៣. ក្រសួងមហាផ្ទៃ

ក្រៅពីក្រសួងរៀបចំដែនដី ដែលមានសមត្ថកិច្ចគ្រប់គ្រងលើការងារទូទៅនៅក្នុងវិស័យសំណង់ ក្រសួងមហាផ្ទៃ ក៏មានសមត្ថកិច្ចពាក់ព័ន្ធនឹងវិស័យសំណង់នេះផងដែរ ដោយមានសមត្ថកិច្ចលើការធានាឱ្យបាននូវសុវត្ថិភាពអគ្គិភ័យនៃសំណង់។ អនុឡោមតាមអនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្ដីពី ចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ ក្រសួងមហាផ្ទៃមាននូវសមត្ថកិច្ចគ្រប់គ្រង និង ត្រួតពិនិត្យលើបញ្ហាប្រព័ន្ធសុវត្ថិភាពអគ្គិភ័យរបស់សំណង់។ សមត្ថកិច្ចទាំងនោះរួមមាន[14]៖ ធ្វើការត្រួតពិនិត្យលើ ប្លង់ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យនៃសំណង់ ឧបករណ៍ សម្ភារៈ និងបរិក្ខារសម្រាប់ប្រើប្រាស់ក្នុងប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យឱ្យបានត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេស ត្រួតពិនិត្យទីតាំងស្តុកដាក់លក់ឧបករណ៍ សម្ភារៈ បរិក្ខារបង្ការ និងពន្លត់អគ្គិភ័យ។ បន្ថែមពីនេះ ក្រសួងមហាផ្ទៃ ក៏ជាស្ថាប័នដែលចេញលិខិតបញ្ជាក់ទទួលស្គាល់លើគំនូរប្លង់ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យរបស់សំណង់ទាំងឡាយផងដែរ និង មានសមត្ថកិច្ចចេញលិខិតផ្អាកសកម្មភាពបណ្ដោះអាសន្ន ដល់ផ្នែកណាមួយនៃសំណង់ ដែលមិនបំពេញតាមលក្ខខណ្ឌ និងវិធានការបច្ចេកទេសនៃប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យនេះផងដែរ។ នៅក្នុងន័យនេះ អគ្គិភ័យសំដៅលើករណីមានភ្លើងឆេះមិនអាចគ្រប់គ្រងបានដែលអាចបង្កមហន្តរាយដល់អាយុជីវិត ទ្រព្យសម្បត្តិ និង បរិស្ថាន។ ប្លង់ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ សំដៅដល់គំនូសដែលត្រូវបានកំណត់លំអិតពីការបំពាក់ឧបករណ៍ សម្ភារៈ បរិក្ខារសម្រាប់ការបង្ការនិងពន្លត់អគ្គិភ័យ។ ដើម្បីសម្រួលដល់ការគ្រប់គ្រង និង ពន្លឿនចរន្តនៃការងារ ក្រសួងអាចធ្វើប្រតិភូកម្មអំណាចក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើប្រព័ន្ធសុវត្ថិភាពនេះនូវសមត្ថកិច្ចរបស់ខ្លួនខាងលើ ទៅកាន់អគ្គស្នងការនគរបាលជាតិ និងស្នងការនគរបាលរាជធានីខេត្តបាន។[15] អគ្គស្នងការនគរបាល

[14] មាត្រា ៥ នៃអនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្ដីពី ចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

[15] មាត្រា ៦ នៃអនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្ដីពី ចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

ជាតិ និងស្នងការនគរបាលរាជធានី ខេត្ត មានសមត្ថកិច្ចចេញលិខិតព្រមាននិងពិន័យអន្តរការណ៍ចំពោះម្ចាស់សំណង់ទាំងឡាយណាដែលមិនគោរពនិងអនុវត្តតាមបទដ្ឋានបច្ចេកទេសនៃប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ។[16]

ដោយសារតែក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គឺជាស្ថាប័នដែលគ្រប់គ្រងលើការងារនៃវិស័យសំណង់ទាំងមូល ហើយក្រសួងមហាផ្ទៃមានសមត្ថកិច្ចលើបញ្ហាសុវត្ថិភាពអគ្គិភ័យ នោះចំណាត់ថ្នាក់ប្រភេទ និងទំហំនៃសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពអគ្គិភ័យលើសំណង់ត្រូវបានកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីនៃក្រសួងទាំងពីរ។[17]

**កំណត់សម្គាល់៖** បច្ចុប្បន្នប្រកាសអន្តរក្រសួងនេះ មិនទាន់មាននៅឡើយទេ។

**ក. សមត្ថកិច្ចរបស់អគ្គស្នងការនគរបាលជាតិ**

សំណង់ដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អគ្គស្នងការនគរបាលជាតិមានដូចជា៖[18] សំណង់ដែលមានផ្ទៃក្រឡាកម្រាលចាប់ពី ៣០០០ (បីពាន់) ម៉ែត្រការ៉េ សំណង់ដែលមានកម្ពស់ចាប់ពី ៥ ជាន់ឡើងទៅ (រាប់ទាំងជាន់ផ្ទាល់ដី) សំណង់ដែលផ្ទុកចំនួនមនុស្សចាប់ពី ២០០ នាក់ឡើង សំណង់ចាប់ពី ២៥ បន្ទប់ឡើង ចំណតរថយន្តចាប់ពី ១០០ គ្រឿងឡើង គ្រប់ទីតាំងដែលមានស្តុកទុកវត្ថុងាយឆេះនិងងាយផ្ទុះឆេះគ្រប់ប្រភេទ ចំណុះចាប់ពី ១០.០០០ លីត្រ និង/ឬ ៥.០០០ គីឡូក្រាមឡើង និងគ្រប់សំណង់សំខាន់ៗក្នុងតំបន់ការពារបរិស្ថានធម្មជាតិ បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ រមណីយដ្ឋានទេសចរណ៍ និងសាសនា។

**ខ. សមត្ថកិច្ចរបស់ស្នងការនគរបាលរាជធានី ខេត្ត**

រីឯចំពោះសំណង់ដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អគ្គស្នងការនគរបាលជាតិមានដូចជា៖[19] សំណង់ដែលមានផ្ទៃក្រឡាកម្រាលតិចជាង ៣០០០ (បីពាន់) ម៉ែត្រការ៉េ សំណង់ដែលមានកម្ពស់ចាប់ពី ៤ ជាន់ចុះ (រាប់ទាំងជាន់ផ្ទាល់ដី) សំណង់ដែលផ្ទុកចំនួនមនុស្សក្រោម ២០០ នាក់ សំណង់ដែលមានបន្ទប់ក្រោម ២៥ បន្ទប់ ចំណតរថយន្តក្រោម ១០០ គ្រឿង និងរាល់ទីតាំងដែលមានស្តុកទុកវត្ថុងាយឆេះនិងងាយផ្ទុះឆេះគ្រប់ប្រភេទ ចំណុះក្រោម ១០.០០០ លីត្រ និង/ឬ ៥.០០០ គីឡូក្រាម។

**១.១.៣. ចំណែកចែក នៃប្រភេទសំណង់**

ជាទូទៅសំណង់ មានរូបរាងច្រើនបែប ច្រើនប្រភេទ និងសាងសង់ឡើងដើម្បីបម្រើតាមតម្រូវការខុសៗគ្នា

[16] មាត្រា ១១ នៃអនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពី ចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

[17] មាត្រា ៩ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[18] មាត្រា ១៣ នៃអនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពី ចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

[19] មាត្រា ១៤ នៃអនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពី ចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

ឧទាហរណ៍៖ សំណង់គេហដ្ឋាន សំណង់អគារសហកម្មសិទ្ធិ សំណង់សាលារៀន មន្ទីរពេទ្យ និងសំណង់អគារពាណិជ្ជកម្ម ជាដើម។ល។ តួយ៉ាងនៅពេលបច្ចុប្បន្ន មិនទាន់មាននូវការបែងចែកជាផ្លូវការណាមួយអំពីប្រភេទនៃសំណង់ឡើយ។ ប៉ុន្តែយោងតាម អនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពី ចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ សំណង់ត្រូវបានចែកជាប្រាំ (៥) ចំណាត់ថ្នាក់គឺ៖ ទី១៖ សំណង់ពាណិជ្ជកម្មទាក់ទងនឹងការផលិត ការលក់ ការកែច្នៃ ការស្តុក ស្ថានីយប្រេង និងការប្រើប្រាស់ឧស្ម័នចំហេះ សារធាតុងាយឆេះ ងាយផ្ទុះ និងងាយផ្ទុះឆេះ។ ទី២៖ ក្រសួង ស្ថាប័ន មន្ទីរអង្គភាពរបស់រដ្ឋ គ្រឹះស្ថានសាធារណៈ និងឯកជន។ ទី៣៖ សំណង់នៃទីប្រជុំជន អគារសហកម្មសិទ្ធិ បុរីលំនៅឋាន ឬលំនៅឋានមានលក្ខណៈបុរី អគារពាណិជ្ជកម្មធំៗ រោងកុនភាពយន្ត រោងមហោស្រព សារមន្ទីរជាតិ បណ្ណសារជាតិ បណ្ណាល័យជាតិ ទីកន្លែងសប្បាយភាព ក្លឹបកម្សាន្ត ស្ថានីយវិទ្យុ ស្ថានីយទូរទស្សន៍ ស្ថានីយទូរគមនាគមន៍ ក្រុមហ៊ុនគោលដៅស្រាវជ្រាវវិទ្យាសាស្ត្រ អាកាសយានដ្ឋាន ស្ថានីយរំាជាយស្ម័យយាន កំពង់ផែយានដ្ឋាន និងចំណតយានយន្ត។ ទី៤៖ សំណង់ដែលស្ថិតនៅតំបន់ភ្នំ តំបន់ព្រៃ តំបន់អភិរក្ស រមណីយដ្ឋាន ស្ថានីយអគ្គិសនី វារីអគ្គិសនី រោងចក្រ សហគ្រាស ឧស្សាហកម្ម សិប្បកម្ម និងការដ្ឋានផ្សេងៗ។ ទី៥៖ អគារពាណិជ្ជកម្មខ្នាតតូច និងផ្សារ។

ប្រសិនបើបែងចែកតាមសមត្ថកិច្ចនៃការចេញលិខិតអនុញ្ញាតសាងសង់សំណង់ សំណង់ចែកចេញជា ៣ ប្រភេទគឺ៖ សំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតូចជាងឬស្មើ ៥០០ម៉ែត្រក្រឡា សំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបធំជាង៥០០ម៉ែត្រក្រឡា ដល់៣០០០ម៉ែត្រក្រឡា និង សំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបធំជាង៣០០០ម៉ែត្រក្រឡា និងគ្រប់សំណង់ស្ថានីយប្រេងឥន្ធនៈទាំងអស់។[20]

## ១.២. នីតិវិធីក្នុងការសាងសង់សំណង់

ជាទូទៅនីតិវិធីក្នុងការសាងសង់ត្រូវបានបែងចែកជា ២ ដំណាក់កាលធំៗរួមមាន៖ នីតិវិធីនៅមុនពេលចាប់ផ្តើមសាងសង់ និងនីតិវិធីនៅក្នុងអំឡុងពេល និងក្រោយពេលសាងសង់។ ម្ចាស់សំណង់ត្រូវអនុវត្តតាមនីតិវិធីទាំងនេះដើម្បីធ្វើឱ្យសំណង់របស់ខ្លួនស្របតាមច្បាប់។

### ១.២.១. នីតិវិធីមុនពេលចាប់ផ្តើមសាងសង់

យោងតាមមាត្រា២៦ នៃច្បាប់ស្តីពីសំណង់ រាល់ការសាងសង់ត្រូវមានការអនុញ្ញាតជាមុនដោយអាជ្ញាធរមានសមត្ថកិច្ច តាមរយៈលិខិតអនុញ្ញាតសាងសង់។ ការសាងសង់សំណង់ថ្មី ការសាងសង់ឡើងវិញ ការពង្រីក និងការសង់បន្ថែមពីលើអគារដែលមានស្រាប់ ត្រូវតែមានលិខិតអនុញ្ញាតសាងសង់។ ចំពោះការប្តូរទ្រង់ទ្រាយអគារមានស្រាប់ ក៏តម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ផងដែរ តែលក្ខខណ្ឌតម្រូវនេះអនុវត្តតែនៅ

---

[20] គេហទំព័រ http://www.mlmupc.gov.kh/?page=detail&menu1=373&menu2=424&menu3=440&ctype=article&id=440&lg=kh

ក្នុងករណីមួយចំនួនដែលមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យ ស្តីពីលិខិតអនុញ្ញាតសាងសង់ប៉ុណ្ណោះដែលមានដូចជាការកែប្រែ ការប្រើប្រាស់របស់ផ្នែកអគារ ទិដ្ឋភាពនៃអគារ ការធ្វើបង្គន់អានាម័យ និងការបន្តភ្ជាប់ទៅបំពង់លូ ការធ្វើអាងប្រព្រឹត្តិកម្មទឹកកខ្វក់តភ្ជាប់ទៅបំពង់លូ បង្កើនផ្ទៃក្រឡាកម្រាលសំណង់ កន្លែងទទួលសាធារណៈ និងការកែប្រែទម្រង់ដីរួមមាន ការចាក់ដីបំពេញ ជីកយកដីចេញ ប្តូរប្រភេទដីស្រែចម្ការជាដីសាងសង់។ ចំណែកឯសំណង់តូចដែលមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ លំនៅឋានធ្វើពីឈើ ឬថ្មក្រោមឈើលើ ឬផ្ទះគ្រៀមធ្វើនៅទីជនបទឬស្រែចម្ការ ដែលមិនប៉ះពាល់ដល់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ និងសំណង់ដែលបម្រើដល់សន្តិសុខជាតិ និងការពារជាតិ មិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់នោះទេ។[21] ម្ចាស់សំណង់ មិនតម្រូវឱ្យមានការអនុញ្ញាតឡើយ ក្នុងករណីដែលការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់នោះ មិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រទម្ងន់ សោភ័ណភាពខាងក្រៅ ឬមុខងារប្រើប្រាស់ទាំងមូល ឬផ្នែកណាមួយនៃសំណង់ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។ ប៉ុន្តែ ម្ចាស់សំណង់ ត្រូវជូនដំណឹងជាមុនទៅកាន់អាជ្ញាធរមានសមត្ថកិច្ច។[22]

### ១.២.១.១. ការស្នើសុំលិខិតអនុញ្ញាតសាងសង់

រាល់រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយ ដែលចង់ធ្វើការសាងសង់សំណង់នានាដោយតម្រូវឱ្យមានលិខិតអនុញ្ញាត ត្រូវធ្វើការដាក់ពាក្យស្នើសុំធ្វើលិខិតអនុញ្ញាតសាងសង់មុននឹងដំណើរការសាងសង់សំណង់របស់ខ្លួន។

**ក. លក្ខខណ្ឌក្នុងការស្នើសុំ**

ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើលើគំរូលិខិតជាផ្លូវការ ហើយត្រូវមានភ្ជាប់សំណុំលិខិត ដែលមានយ៉ាងតិចបំផុតនូវបណ្តាប្លង់ដូចបញ្ជាក់ខាងក្រោមនេះ ជា១០ច្បាប់ ដោយបត់ទំហំ (២១x២៩.៧ ស.ម)៖[23]

ក. វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ឬបណ្ណសំគាល់សិទ្ធកាន់កាប់ប្រើប្រាស់ អចលនវត្ថុ ឬលិខិតកាន់កាប់ដីជាបណ្តោះអាសន្ន។

ខ. សលាកបត្រដីឡូត៍ ដោយធ្វើឡើងដោយភ្នាក់ងារមន្ទីរសុរិយោដី ឬដោយវេខាគណិតឯកជន និងត្រូវចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយអ្នកធ្វើ និងអនុម័តដោយមន្ទីរសុរិយោដី។ នៅលើប្លង់នេះ មានបញ្ជាក់អំពី៖

- ទីតាំងដីឡូត៍ដែលជាកម្មវត្ថុនៃពាក្យសុំ ទីតាំងនៃដីឡូត៍ដែលនៅជាប់គ្នា ផ្លូវចូលទៅដីឡូត៍នោះ ហើយ និងលក្ខណៈរបស់ផ្លូវនោះ សាធារណៈ ឬឯកជន (ឈ្មោះម្ចាស់កម្មសិទ្ធិ)
- ឈ្មោះ ឬលេខ ផ្លូវធំ និងផ្លូវតូច

[21] មាត្រា ២៨ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[22] មាត្រា ២៩ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[23] មាត្រា៩ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់

- ផ្ទៃក្រឡាដីឡូត៍
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូត៍ (ទីតាំង និងកម្ពស់)
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូត៍ជាប់គ្នា ផ្ទៃបាត និងកម្ពស់របស់វា
- មាត្រដ្ឋានប្លង់រង្វាស់ជ្រុង និងមុំនីមួយៗ ការកំណត់ទិស
- ចំនុចនឹងថ្កល់សំរាប់ជាគោលសំគាល់កម្ពស់ ដែលបោះនៅលើដីឡូត៍
- បន្ទាត់ជួរតម្រង់ផ្លូវសាធារណៈ។

គ. ប្លង់ទីតាំងអគារក្នុងដីឡូត៍៖ មាត្រដ្ឋាន ១:២០០ (ឬ១:៥០០ ក្រោយទទួលការយល់ព្រមពីបណ្តាមន្ទីរទទួលបន្ទុកដីឡូត៍ធំៗ)។ នៅលើប្លង់នេះ មានបញ្ជាប់អំពី៖

- ការបោះទីតាំងនៃសំណង់ក្នុងដីឡូត៍ដែលជាកម្មវត្ថុនៃពាក្យសុំ ដោយមានការបញ្ជាក់អំពីចំងាយរវាងអគារមួយ ឬច្រើន និងព្រំប្រទល់ដីឡូត៍ ហើយនិងចំណាយទៅបណ្តាអគារនៅជិតខាងដែលមានស្រាប់។
- រាល់ការរៀបចំផ្នែកផ្សេងៗ នៃដីទំនេរ ដោយបញ្ជាក់ប្រភេទដី និងដំណាំមានស្រាប់ និងទៅអនាគតបណ្តាកន្លែងចតរថយន្ត និងរបប (ទីតាំង និងកម្ពស់)
- បំពង់លូក្រៅអគារ រហូតដល់កន្លែងតភ្ជាប់ទៅ (រូបធាតុ វិជ្ជមាត្រ ចំណោត កំរិតកម្ពស់ រណ្តៅពិនិត្យ) បណ្តាញសាធារណៈ សម្រាប់បញ្ចេញទឹកស្អុយ និងសម្រាប់ទឹកស្អាត អាងបង្គន់អនាម័យ អណ្តូង
- ចំនុចនឹងថ្កល់នៃកម្ពស់ដីឡូត៍ ក្រោយការងាររៀបចំហើយ

ឃ. ប្លង់អគារគ្រប់ជាន់៖ មាត្រដ្ឋាន ១:១០០។ នៅលើប្លង់នេះ មានបញ្ជាក់អំពី៖

- គោលដៅប្រើប្រាស់រាល់បន្ទប់ និងផ្ទៃក្រឡារបស់វា
- បណ្តាបបនភណ្ឌអនាម័យ និងកន្លែងដាក់បំពង់លូ
- ចំពោះការរៀបចំទីតាំងឧស្សាហកម្ម៖ របៀបរៀបចំទីតាំងគ្រឿងយន្ត។

ង. ប្លង់ផ្នែកបណ្តាញក្រោមដីនានា និងអាងបង្គង់អនាម័យ៖ មាត្រដ្ឋាន ១:១០០។

ច. ប្លង់មុខភាពនៃអគារ៖ មាត្រដ្ឋាន ១:១០០។ នៅលើប្លង់នេះមានបញ្ជាក់ពី៖

- កម្រិតកម្ពស់កម្រាលនីមួយៗ កម្រិតកម្ពស់ដីនៅជើងអគារ ដោយបញ្ជាក់កំរិតកំពង់ដីធម្មជាតិ ដីចាក់បំពេញ ឬដីចូកចេញ
- កម្រិតកម្ពស់ដំបូល និងព្រំដំបូល ឬកម្រិតកម្ពស់នៅពេលសង់ហើយនៃដំបូលតែរ៉ាស់ និងក្បាំងក្បាលជញ្ជាំង
- កម្រិតកម្ពស់សង់ហើយនៃទ្រើងផ្ការ
- រូបធាតុសម្រាប់មុខភាព។

ឆ. ប្លង់ពុះពីរយ៉ាងតិច៖ មាត្រដ្ឋាន ១:១០០។ នៅលើប្លង់នៃ មានការបង្ហាញដូចប្លង់មុខភាព ពុះមួយបង្ហាញអាងបង្គន់អនាម័យ

ជ. តារាងផ្ទៃក្រឡាមួយសំរាប់ជាន់នីមួយៗ

ឈ. សលាកបត្រគណនាផ្ទៃបាតផ្ទាល់ដី និងសន្ទស្សន៍ការប្រើប្រាស់

ញ. ក្រោយពីបានទទួលលិខិតអនុញ្ញាតសាងសង់ហើយ ត្រូវមានប្លង់លំអិតគ្រឿងផ្គុំសំណង់ ដែលត្រូវពិនិត្យដោយក្រសួងសាធារការ និងដឹកជញ្ជូន មុនបើកការដ្ឋានសាងសង់។

រាល់ការផ្លាស់ប្ដូរទ្រង់ទ្រាយ ពង្រីកទំហំ ពង្រីកតឡើងលើប្លង់ ត្រូវបង្ហាញរបៀបខុសពីគ្នាចំពោះផ្នែកមានពីមុន ការរុះរើ និងសភាពគ្រោងធ្វើ។ ចំណែកឯសាលាក្រុង និងសាលាខេត្តនីមួយៗ ត្រូវចេញសារាចរបញ្ជាក់អំពីខ្លឹមសារចាំបាច់ និងឯកសារបន្ថែមពាក់ព័ន្ធនឹងសំណុំលិខិតអនុញ្ញាតសាងសង់។ លើសពីនេះ ស្ថាប័នក៏អាចឱ្យអ្នកស្នើសុំសាងសង់ ផ្ដល់បណ្ដាលិខិតស្នាមបន្ថែម ដោយមូលហេតុផ្នែកធារាសាស្ត្រ ផ្នែកការពារប្រឆាំងធាតុរំខានគ្រប់ប្រភេទ ផ្នែកសណ្ដាប់ធ្នាប់សាធារណៈ ការពារបេតិកភ័ណ្ឌ និងទេសភាព។

សំណុំលិខិតពាក្យសុំលិខិតអនុញ្ញាតសាងសង់ទាំងអស់ ត្រូវជាភាសាខ្មែរ។ អត្ថបទជាភាសាអង់គ្លេស ឬបារាំងអាចផ្ដល់ភ្ជាប់ជាមួយនឹងលិខិតនេះ។[24] ពាក្យសុំលិខិតអនុញ្ញាតសាងសង់ និងបណ្ដាប្លង់ ត្រូវចុះហត្ថលេខាដោយម្ចាស់ដី និងអ្នកធ្វើគម្រោង។ ក្នុងករណីអ្នកស្នើសុំពុំមែនជាម្ចាស់កម្មសិទ្ធិ អ្នកស្នើសុំដែលបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ ក៏ត្រូវចុះហត្ថលេខាលើសំណុំលិខិតពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់នោះដែរ។ ចំពោះអ្នកធ្វើគម្រោង ត្រូវតែជាស្ថាបត្យករខ្មែរ ឬបុគ្គលមានការសហការ ឬរួមចំណែកជាមួយស្ថាបត្យករខ្មែរ ព្រមទាំងត្រូវបានទទួលស្គាល់ពីរាជរដ្ឋាភិបាល តាមរយៈការចុះបញ្ជីនៅគណៈវិជ្ជាជីវៈស្ថាបត្យករ ដើម្បីទទួលបានអាជ្ញាបណ្ណផ្ដល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[25] ចំពោះសំណង់ដែលមានទំហំលើសពី ៥០០ (ប្រាំរយ) ម៉ែត្រទ្វេគុណ គម្រោងអាចធ្វើបានតែដោយស្ថាបត្យករតែប៉ុណ្ណោះ។[26]

### ខ. នីតិវិធី និងរយៈពេលនៃការស្នើសុំ

នៅពេលដែលរូបវន្តបុគ្គល បានបំពេញលិខិតស្នើសុំ ព្រមទាំងបានរៀបចំសំណុំឯកសារភ្ជាប់រួចរាល់ ត្រូវយកសំណុំឯកសារទាំងនោះ ទៅដាក់នៅការិយាល័យទទួលបន្ទុកលិខិតអនុញ្ញាតសាងសង់។ ចំពោះក្រុងភ្នំពេញ និងទីក្រុងដទៃទៀត សំណុំលិខិតស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវយកដាក់នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ ចំណែកចំពោះខេត្តវិញ ត្រូវយកដាក់នៅសាលាខេត្ត-ក្រុង ដូចមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្ដីពីលិខិតអនុញ្ញាតសាងសង់។

---

[24] មាត្រា១០ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្ដីពីលិខិតអនុញ្ញាតសាងសង់

[25] មាត្រា១៥ នៃច្បាប់ស្ដីពីសំណង់ ឆ្នាំ២០១៩

[26] មាត្រា១០ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្ដីពីលិខិតអនុញ្ញាតសាងសង់

នៅពេលដែលមន្ត្រីទទួលបន្ទុកបានទទួលសំណុំលិខិតហើយ អាជ្ញាធរមានសមត្ថកិច្ចនឹងធ្វើការពិនិត្យសំណុំលិខិតទាំងអស់នោះ ដោយធានាថាសំណុំលិខិតទាំងនោះត្រឹមត្រូវ និងគ្រប់គ្រាន់តាមច្បាប់តម្រូវ។ នៅពេលដែលបានដាក់សំណុំលិខិតស្នើសុំលិខិតអនុញ្ញាតសាងសង់រួចរាល់ និងគ្រប់គ្រាន់ហើយ មន្ត្រីទទួលលិខិតនឹងចេញ បង្កាន់ដៃទទួលពាក្យសុំនោះ ឱ្យទៅអ្នកស្នើសុំ។[27]

ក្រោយទទួលបានសំណុំលិខិតស្នើសុំ អាជ្ញាធរមានសមត្ថកិច្ចនឹងធ្វើការផ្សព្វផ្សាយដំណឹងដល់សាធារណៈជន អំពីការដាក់ពាក្យសុំនេះ ដោយបិទប្រកាសផ្សាយនៅសាលាខណ្ឌ ស្រុក ខេត្ត និងនៅកន្លែងសាងសង់គម្រោង។ ម៉្យាងទៀត ចំពោះអគារនិងបណ្ដាការរូធំៗដែលមានប្រភេទអាចធ្វើឱ្យរំខានដល់សុវត្ថិភាព សុខុមាលភាពសាធារណៈ អាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្សព្វផ្សាយដល់សាធារណៈជន ពីការដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដោយវិធីណាមួយផ្សេង ដែលគេយល់ឃើញថាមានប្រសិទ្ធិភាពជាងដោយផ្អែកលើមធ្យោបាយផ្សាយពត៌មាននៅតាមមូលដ្ឋាន។

ពេលនោះ រាល់បុគ្គលពាក់ព័ន្ធ អាចសាកសួរ និងសុំមើលសំណុំលិខិត នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ ឬ សាលាខេត្ត-ក្រុង ក្នុងរយៈពេល ២៥ ថ្ងៃ និងអាចធ្វើការតវ៉ា ឬទាមទារទៅអាជ្ញាធរមានសមត្ថកិច្ច។ បណ្ដឹងតវ៉ាទាំងនេះ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំលិខិតពាក្យសុំ។

នៅពេលទទួលបានបណ្ដឹងតវ៉ា អាជ្ញាធរមូលដ្ឋានត្រូវពិនិត្យមើលការជំទាស់ដែលទទួលបានក្នុងពេលអង្កេត និងធ្វើរបាយការណ៍មួយ ជូនទៅសាលាខេត្ត-ក្រុង ក្នុងរយៈពេល ៥ថ្ងៃ។ សាលាខេត្ត-ក្រុង ឬគណៈកម្មការចេញលិខិតអនុញ្ញាសាងសង់ ត្រូវធ្វើការសម្រេចអំពីសុពលភាពនៃបណ្ដឹងតវ៉ានោះ។[28]

គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (បើមាន) ឬក្នុងករណីផ្សេងទៀត មន្ទីររៀបចំក្រុង និងសំណង់នៃបណ្ដាខេត្ត-ក្រុង ប្រមូលយោគបល់ពីមន្ទីរមានសមត្ថកិច្ច ហើយធ្វើការសំយោគមួយ។ យោគបល់ និងសំយោគទាំងនោះ ត្រូវធ្វើជាលាយល័ក្ខអក្សរ ហើយត្រូវដាក់ជូនអភិបាលខេត្ត ឬប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងពិនិត្យ និងសម្រេច។ ក្នុងករណីពុំទាន់មានគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ មន្ទីរដែលត្រូវចូលរួមពិភាក្សាជាចាំបាច់រួមមាន៖ មន្ទីរសុរិយោដី មន្ទីររៀបចំក្រុង និងសំណង់ មន្ទីរសាធារណៈការ មន្ទីរវប្បធម៌ និងវិចិត្យសិល្បៈ មន្ទីរហិរញ្ញវត្ថុ មន្ទីរបរិស្ថាន និងតំណាងស្ថាប័នពាក់ព័ន្ធនានា។[29]

មន្ត្រីទទួលបន្ទុក មានរយៈពេលសម្រាប់ពិនិត្យសំណុំលិខិតអនុញ្ញាតសាងសង់ត្រឹម ៤៥ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃដែលរាល់លិខិតស្នាមភ្ជាប់ជាមួយនឹងពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់បានបំពេញសព្វគ្រប់។ នៅចុងរយៈពេលកំណត់នេះ អ្នកស្នើសុំនឹងត្រូវបានទទួលដំណឹងអំពីសេចក្ដីសម្រេចជាលាយល័ក្ខអក្សរស្ដីពីការអនុញ្ញាត ឬការមិនអនុញ្ញាត ឬមួយការអនុញ្ញាតដែរ តែស្នើសុំឱ្យកែសម្រួលបន្ថែម។ ក្នុងករណី អ្នកស្នើសុំមិនទទួលបានការឆ្លើយតមពីអាជ្ញាធរនោះទេ ត្រូវចាត់ទុកបានចម្លើយជាវិជ្ជមាន។ កាលបរិច្ឆេទថ្ងៃទី០១ នេះ

[27] មាត្រា៨ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្ដីពីលិខិតអនុញ្ញាតសាងសង់

[28] មាត្រា១២ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្ដីពីលិខិតអនុញ្ញាតសាងសង់

[29] មាត្រា១៣ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្ដីពីលិខិតអនុញ្ញាតសាងសង់

ត្រូវបានកំណត់ដោយគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) ឬដោយមន្ទីររៀបចំក្រុង និងសំណង់ ក្នុងករណីផ្សេងទៀត។ ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ច បានស្នើដល់អ្នកដាក់ពាក្យសុំឱ្យធ្វើការកែប្រែ នោះរយៈពេល ៤៥ ថ្ងៃធ្វើការ នឹងចាប់ផ្តើមគិតសារជាថ្មី ចាប់ពីថ្ងៃដាក់ពាក្យស្នើសុំមានការកែតម្រូវជាផ្លូវការ។ ប្រសិនបើក្នុងករណីអាជ្ញាធរមានសមត្ថកិច្ចបដិសេធផ្តល់លិខិតអនុញ្ញាតសាងសង់ និងការស្នើសុំឱ្យកែសម្រួលអាជ្ញាធរ ត្រូវធ្វើការជូនដំណឹងជាលាយល័ក្ខណ៍អក្សរ ទៅដល់អ្នកដាក់ពាក្យសុំ។[30]

លិខិតអនុញ្ញាតសាងសង់ ត្រូវប្រគល់ឱ្យអ្នកស្នើសុំដោយអាជ្ញាធរដែលបានអនុញ្ញាតឱ្យ។ ក្នុងនោះដែរ លិខិតអនុញ្ញាតសាងសង់ចំនួន ០១ ច្បាប់ អមដោយសំណុំលិខិតគ្រប់សព្វត្រូវរក្សារទុកជាឯកសារដាច់ខាតដោយសាលាខេត្ត ឬសាលាក្រុង។ ដោយឡែកក្នុងករណីដែលលិខិតអនុញ្ញាត ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល នោះគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ត្រូវរក្សាទុកឯកសារចំនួន ០១ ច្បាប់ផងដែរ។

ប៉ុន្តែម្ចាស់សំណង់មិនអាចចាប់ផ្តើមបើកដំណើរការការដ្ឋានមុនពេលដែលទទួលបានលិខិតអនុញ្ញាតសាងសង់ និងមុនពេលទទួលបានការអនុម័តលើប្លង់លំអិតគ្រឿងផ្គុំសំណង់បានឡើយ។ រាល់សហគ្រិនទទួលបន្ទុកស្ថាបនាសំណង់ ត្រូវបញ្ជាក់ឱ្យដឹងច្បាស់ថា លិខិតអនុញ្ញាតសាងសង់ត្រូវបានអនុញ្ញាតរួចហើយ ព្រោះត្រូវជាប់ទទួលខុសត្រូវរួមជាមួយម្ចាស់សំណង់។ អ្នកកាន់លិខិតអនុញ្ញាតសាងសង់ ត្រូវតំកល់ទុកនៅទីតាំងការដ្ឋាន នូវសេចក្តីចម្លងឯកសាររដ្ឋបាលអំពីការចេញលិខិតអនុញ្ញាតសាងសង់ ០១ច្បាប់ សម្រាប់មន្ទីរ ក្រុង ឬខេត្ត ត្រួតពិនិត្យ។ ប្លង់អនុវត្តការសាងសង់ និងប្លង់លំអិតសំណង់ ០១ច្បាប់ ត្រូវតម្កល់ទុកជាប្រចាំនៅការដ្ឋាន សម្រាប់មន្ទីរ ក្រុង ឬខេត្ត ត្រួតពិនិត្យ។[31]

**គ. សុពលភាពនៃលិខិតអនុញ្ញាតសាងសង់**

លិខិតអនុញ្ញាតសាងសង់នេះនឹងអស់សុពលភាព ប្រសិនបើការងារសាងសង់នោះពុំដំណើរការ (សំដៅដល់ការចាប់ផ្តើមបុកគ្រឹះនៃសំណង់) ក្នុងរយៈពេល ១ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាចេញលិខិតអនុញ្ញាតសាងសង់។[32] ក្រោយពេលអស់សុពលភាពលិខិត ម្ចាស់សំណង់អាចធ្វើការស្នើសុំការអនុញ្ញាតឱ្យពន្យារពេលបាន ០១ដងគត់។ ការសាងសង់ចាត់ទុកថាចាប់ផ្តើមដំណើរការ នៅពេលដែលជើងគ្រឹះនៃសំណង់ត្រូវបានធ្វើហើយ សម្រាប់ការសាងសង់សំណង់ថ្មី និងនៅពេលដែលសសរទីមួយនៃការសង់បន្ថែមត្រូវបានធ្វើហើយ សម្រាប់ការសាងសង់បន្ថែមជាន់។ ក្នុងករណីការងារសាងសង់ ត្រូវបានផ្អាកលើសពីមួយឆ្នាំ អាជ្ញាធរក្រុង ឬខេត្ត អាចបង្ខំឱ្យធ្វើបញ្ចប់ ឬបង្ខំឱ្យរុះរើសំណង់ដែលបានចាប់ផ្តើមនោះ និងឱ្យរៀបចំទីកន្លែងនោះឱ្យបានត្រឹមត្រូវដូចដើមវិញ ក្នុងរយៈពេលមួយដែលបានកំណត់ ហើយការចំណាយសោហ៊ុយលើការរុះរើទាំងអស់នោះ ជាបន្ទុករបស់ម្ចាស់

[30] មាត្រា១៤ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់

[31] មាត្រា១៧ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់

[32] មាត្រា១៦ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់

លិខិតអនុញ្ញាតសាងសង់។ យ៉ាងណាមិញ លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ មិននាំឱ្យបុគ្គលដែលទទួលបានលិខិតអនុញ្ញាតនោះរួចផុតពីកាតព្វកិច្ច និងការការទទួលខុសត្រូវតាមច្បាប់ តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ មានន័យថា ក្នុងករណីដែលបុគ្គលទាំងនោះមិនគោរពតាមបទប្បញ្ញត្តិតាមច្បាប់កំណត់ទេនោះ ពួកគេត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។[33]

### ១.២.១.២. ការស្នើសុំលិខិតបើកការដ្ឋានសាងសង់

មុនចាប់ផ្ដើមដំណើរការការដ្ឋាន ម្ចាស់សំណង់ ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានជាមុនសិនមុនពេលបើកការដ្ឋានដើម្បីចាប់ផ្ដើមសាងសង់ ហើយលក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវកំណត់ដោយអនុក្រឹត្យមួយរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[34] ប៉ុន្តែដោយសារតែបច្ចុប្បន្ន អនុក្រឹត្យនេះមិនទាន់មាននៅឡើយ ការស្នើសុំលិខិតបើកការដ្ឋាននេះនឹងអនុវត្តទៅតាមលិខិតបទដ្ឋានមុនៗ។ ដោយយោងតាមប្រការ ៣(ថ្មី) នៃប្រកាស ៩៣ ប្រក.ដនស/អសហ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ ស្តីពីការកែសំរួលប្រការ ២ និងប្រការ ៣ នៃប្រកាសលេខ ៣២ ប្រក/សហ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ ការស្នើសុំលិខិតបើកការដ្ឋានត្រូវធ្វើនៅអគ្គនាយកដ្ឋានសំណង់ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត ស្របតាមសមត្ថកិច្ចចេញលិខិតអនុញ្ញាតសាងសង់។ ដើម្បីស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋាន អ្នកស្នើសុំត្រូវមាននូវឯកសារមួយចំនួនដូចជាៈ សំណុំឯកសារពាក្យសុំរបស់ម្ចាស់សំណង់ លិខិតអនុញ្ញាតសាងសង់ ប្លង់ស្ថាបត្យកម្មដែលបានអនុញ្ញាត និងប្លង់គ្រឿងផ្គុំសំណង់។[35] យ៉ាងណាមិញ នៅក្នុងអំឡុងពេលសាងសង់ ប្រសិនបើការដ្ឋាននោះមិនគោរពតាមលក្ខខណ្ឌតម្រូវដែលបានកំណត់ដែលមានដូចជា ការបំពាក់ប្រព័ន្ធការពារសុវត្ថិភាពនៅការដ្ឋានសំណង់ ការរារាំងមន្ត្រីមានសមត្ថកិច្ចបំពេញការងារត្រួតពិនិត្យជាដើម។ល។ អាជ្ញាធរមានសមត្ថកិច្ចអាចផ្អាកការងារការដ្ឋាននោះជាបណ្ដោះអាសន្ន។[36] ក្រោយពីត្រូវបានផ្អាកការងារ ម្ចាស់សំណង់អាចស្នើសុំបើកការដ្ឋានឡើងវិញបាន ប៉ុន្តែត្រូវបំពេញតាមលក្ខខណ្ឌតម្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចឱ្យបានត្រឹមត្រូវឡើង និងត្រូវដាក់ពាក្យស្នើសុំបើកការដ្ឋានឡើងវិញ ដោយភ្ជាប់មកជាមួយនឹង លិខិតអនុញ្ញាតបើកការដ្ឋានចាស់ លិខិតផ្អាកការដ្ឋាន រួមជាមួយនិងលិខិតបញ្ជាក់អំពីការបំពេញបានសព្វគ្រប់ នៃលក្ខខណ្ឌខ្វះខាតពីមុននោះ។[37]

---

[33] មាត្រា៣១ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[34] មាត្រា៣៨ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[35] ប្រការ ៣(ថ្មី) នៃប្រកាស ៩៣ ប្រក.ដនស/អសហ ស្តីពីការកែសំរួលប្រការ ២ និងប្រការ ៣ នៃប្រកាសលេខ ៣២ ប្រក/សហ ស្តីពីការគ្រប់គ្រងងការដ្ឋានសំណង់

[36] ប្រការ១៤ នៃប្រកាសលេខ ៣២ ប្រក/សហ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

[37] ប្រការ១៥ នៃប្រកាសលេខ ៣២ ប្រក/សហ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

### ១.២.២. នីតិវិធីនៅក្នុងអំឡុងពេល និងក្រោយពេលសាងសង់

បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតសាងសង់ ប្លង់លម្អិតគ្រឿងផ្គុំសំណង់ និងលិខិតអនុញ្ញាតបើកការដ្ឋាន ម្ចាស់សំណង់អាចចាប់ផ្ដើមដំណើរការការសាងសង់របស់ខ្លួនបាន។ នីតិវិធីនៅក្នុងដំណាក់កាលនេះចែកចេញជា ២ គឺៈ នីតិវិធីនៅក្នុងអំឡុងពេល និងក្រោយពេលការសាងសង់បានបញ្ចប់។

#### ១.២.២.១. ការត្រួតពិនិត្យដំណើរការនៃការសាងសង់សំណង់

នៅក្នុងដំណាក់កាលនេះ ការងារសាងសង់ត្រូវមានការត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យដែលមានអាជ្ញាបណ្ណ ឬអនុញ្ញាតដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[38] បន្ថែមពីនេះនៅក្នុងករណីចាំបាច់ អាជ្ញាធរមានសមត្ថកិច្ចអាចចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីធ្វើការត្រួតពិនិត្យការងារសាងសង់នោះទៀតបាន។ [39] ម្ចាស់សំណង់ក៏ត្រូវផ្ដល់នូវរបាយការណ៍ស្ដីពីវឌ្ឍនភាពនៃការងារសាងសង់ដែលត្រូវរៀបចំដោយអ្នកសាងសង់ និងឯកភាពដោយម្ចាស់សំណង់ជូនអាជ្ញាធរមានសមត្ថកិច្ចផងដែរ។[40] លើសពីនេះ យោងតាមមាត្រា៤៣ នៃច្បាប់ស្ដីពីសំណង់ ឆ្នាំ២០១៩ ការគ្រប់គ្រង និងពិនិត្យការងារសាងសង់នេះ នឹងត្រូវកំណត់នៅក្នុងអនុក្រឹត្យរបស់ក្រសួងរៀបចំដែនដី។ យ៉ាងណាមិញបច្ចុប្បន្ននេះ អនុក្រឹត្យនេះមិនទាន់ត្រូវបានប្រកាសឱ្យប្រើនៅឡើយទេ។

#### ១.២.២.២. ការស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

វិញ្ញាបនបត្រប្រើប្រាស់សំណង់ សំដៅលើលិខិតអនុញ្ញាតផ្ដល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។[41] ម្ចាស់សំណង់ត្រូវធ្វើការស្នើសុំវិញ្ញាបនបត្រនេះនៅស្ថាប័នមានសមត្ថកិច្ច មុនពេលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់។[42] បែបបទនិងនីតិវិធីនៃការស្នើសុំវិញ្ញាបនបត្រនេះត្រូវបែងចែកជា ២ គឺៈ នៅមុនពេលច្បាប់ស្ដីពីសំណង់ចូលជាធរមាន និងក្រោយពេលច្បាប់សំណង់ចូលជាធរមាន។ បច្ចុប្បន្នបែបបទនិងនីតិវិធីនៃការផ្ដល់វិញ្ញាបនបត្រនេះ មានតែចំពោះសំណង់ដែលបានសាងសង់រួចមុនពេលច្បាប់ស្ដីពីសំណង់ចូលជាធរមានប៉ុណ្ណោះ ដោយចំពោះសំណង់ដែលសាងសង់រួចនៅក្រោយពេលច្បាប់សំណង់ចូលជាធរមាន ត្រូវកំណត់ដោយអនុក្រឹត្យ ប៉ុន្តែអនុក្រឹត្យនេះកំពុងស្ថិតនៅក្នុងដំណើរការព្រាងនៅឡើយ។

យោងតាមប្រកាសលេខ ១៧៧ ដនស/ប្រក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពី បែបបទនិងនីតិវិធីនៃការផ្ដល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលបានសាងសង់រួចមុនពេលច្បាប់ស្ដីពីសំណង់ចូលជាធរមាន សំណង់

[38] មាត្រា ៤១ នៃច្បាប់ស្ដីពីសំណង់ ឆ្នាំ២០១៩

[39] មាត្រា ៤២ នៃច្បាប់ស្ដីពីសំណង់ ឆ្នាំ២០១៩

[40] មាត្រា ៤០ នៃច្បាប់ស្ដីពីសំណង់ ឆ្នាំ២០១៩

[41] លេខ ២៥ នៅក្នុងសន្ទានុក្រមនៃច្បាប់ស្ដីពីសំណង់ ឆ្នាំ២០១៩

[42] មាត្រា ៤៤ នៃច្បាប់ស្ដីពីសំណង់ ឆ្នាំ២០១៩

គ្រប់ប្រភេទដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ និងដែលសាងសង់រួចមុនពេលច្បាប់ស្តីពីសំណង់ចូលជាធរមាន តែគ្មានលិខិតអនុញ្ញាតសាងសង់ ឬសាងសង់ខុសពីលិខិតអនុញ្ញាតសាងសង់ ឬសំណង់ដែលមានលិខិតអនុញ្ញាតសាងសង់ ប៉ុន្តែគ្មានវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវឬលិខិតបិទការដ្ឋាន ម្ចាស់សំណង់ត្រូវមកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្នុងរយៈពេល ២ឆ្នាំ រាប់ចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃច្បាប់ស្តីពីសំណង់។[43] ចំពោះសំណង់ដែលបានសាងសង់ក្រោយថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ម្ចាស់សំណង់ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ជាមុនសិនទើបអាចទទួលបានទទួលបានវិញ្ញាបនបត្រនេះ ហើយការពិន័យអន្តរការណ៍នេះត្រូវធ្វើឡើងតាមគោលការណ៍ដែលបានកំណត់ដោយអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន (អនុក្រឹត្យលេខ៤២) និងអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែប្រែសម្រួលមាត្រា៣០ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ខាងលើ។ [44]

ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់នេះ ម្ចាស់សំណង់ត្រូវមានឯកសារដូចជា៖[45]

- ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងឯកសារបញ្ជាក់អត្តសញ្ញាណរបស់ម្ចាស់សំណង់ (ត្រូវធ្វើនីត្យានុកូលកម្មនៅអាជ្ញាធរមានសមត្ថកិច្ចឬមន្ទីរសារការី) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់ ចំនួន ០៣ ច្បាប់
- សលាកបត្រក្បាលដីផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត ចំនួន ០៣ ច្បាប់
- សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង (ប្លង់ស្ថាបត្រកម្ម ប្លង់គ្រឿងផ្គុំសំណង់ និងប្លង់អគ្គិភ័យ) ចំនួន ០៣ ច្បាប់
- របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ (បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងកិច្ចសន្យាម៉ៅការសាងសង់ (បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងឯកសារពាក់ព័ន្ធអ្នកម៉ៅការសាងសង់ (បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងរបាយការណ៍សិក្សាពិសោធន៍ដីនិងសំភារៈសំណង់ (បើមាន) ចំនួន ០៣ ច្បាប់

[43]ប្រការ៤ នៃប្រកាសលេខ ១៧៧ ដនស/ប្រក ស្តីពី បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនពេលច្បាប់ស្តីពីសំណង់ចូលជាធរមាន

[44] ប្រការ៥ នៃប្រកាសលេខ ១៧៧ ដនស/ប្រក ស្តីពី បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនពេលច្បាប់ស្តីពីសំណង់ចូលជាធរមាន

[45] ប្រការ១០ នៃប្រកាសលេខ ១៧៧ ដនស/ប្រក ស្តីពី បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនពេលច្បាប់ស្តីពីសំណង់ចូលជាធរមាន

- ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ (បើមាន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងលិខិតអនុញ្ញាតបើកការដ្ឋាន (បើមាន) ចំនួន ០៣ ច្បាប់។

ការដាក់ពាក្យស្នើសុំនេះទៀតសោត ត្រូវប្រព្រឹត្តិទៅតាមរយៈច្រកចេញចូលតែមួយរបស់អាជ្ញាធរមានសមត្ថកិច្ចលើប្រភេទសំណង់នីមួយៗដូចជា៖ ចំពោះសំណង់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នោះរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គឺជាអាជ្ញាធរមានសមត្ថកិច្ច។[46] ដូចគ្នានេះដែរចំពោះសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អាជ្ញាធរមានសមត្ថកិច្ចក្នុងរឿងនេះគឺ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មិនតែប៉ុណ្ណោះប្រការនេះត្រូវបានអនុវត្ត ចំពោះសំណង់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌផងដែរ ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ គឺជាអាជ្ញាធរមានសមត្ថកិច្ច។[47]

ការពិនិត្យសម្រេចលើសំណុំឯកសារស្នើសុំនីមួយៗ មានរយៈពេលខុសៗគ្នាទៅតាមអាជ្ញាធរសមត្ថកិច្ច។ ជាក់ស្តែង ចំពោះការពិនិត្យសម្រេចសម្រាប់ការស្នើសុំដែលជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវមានរយៈពេលយ៉ាងយូរ ៣០ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក់ស្នើសុំ។[48] ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំនៅច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី។ ក្នុងរយៈពេលយ៉ាងយូរ ២ ថ្ងៃនៃថ្ងៃធ្វើការ ច្រកចេញចូលតែមួយនេះនឹងបញ្ជូនសំណុំឯកសារស្នើសុំទាំងនោះ ទៅកាន់អគ្គនាយកដ្ឋានសំណង់ដោយមាននាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ជាសេនាធិការ ដើម្បីធ្វើការពិនិត្យនិងផ្តល់យោបល់ ព្រមទាំងធ្វើកំណត់បង្ហាញសរុបលទ្ធផលនៃការពិនិត្យនិងផ្តល់យោបល់ផង មុននឹងបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងដើម្បីពិនិត្យសម្រេច។[49] រីឯសម្រាប់ការស្នើសុំដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្តវិញ មានរយៈពេលយ៉ាងយូរ ១៥ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក់ស្នើសុំ។ បន្ទាប់ពីម្ចាស់សំណង់បានដាក់ពាក្យស្នើសុំនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្តរួចមក អង្គភាពនេះត្រូវបញ្ជូនសំណុំឯកសារនោះទៅកាន់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត ក្នុងរយៈពេល ២ ថ្ងៃនៃថ្ងៃធ្វើការ និងក្នុងរយៈពេល ៧ ថ្ងៃនៃថ្ងៃធ្វើការ មន្ទីររៀបចំដែនដីដោយមានការិយាល័យសំណង់ជាសេនាធិការ ត្រូវធ្វើការពិនិត្យនិងផ្តល់យោបល់ ព្រមទាំងបញ្ជូនសំណុំឯកសារ

[46] ប្រការ ៩ និងប្រការ ១២ នៃប្រកាសលេខ ១៧៧ ដនស/ប្រក ស្តីពី បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនពេលច្បាប់ស្តីពីសំណង់ចូលជាធរមាន

[47] ប្រការ ១២ នៃប្រកាសលេខ ១៧៧ ដនស/ប្រក ស្តីពី បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនពេលច្បាប់ស្តីពីសំណង់ចូលជាធរមាន

[48] ប្រការ ១២ នៃប្រកាសលេខ ១៧៧ ដនស/ប្រក ស្តីពី បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនពេលច្បាប់ស្តីពីសំណង់ចូលជាធរមាន

[49] ប្រការ ១៥ និងប្រការ ១៥ នៃប្រកាសលេខ ១៧៧ ដនស/ប្រក ស្តីពី បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនពេលច្បាប់ស្តីពីសំណង់ចូលជាធរមាន

ទៅអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត។[50] អភិបាលត្រូវពិនិត្យសម្រេច និងបញ្ជូនសំណុំឯកសារដែលបានសម្រេចរួចមកមន្ទីរវិញក្នុងរយៈពេលយ៉ាងយូរ ៣ ថ្ងៃនៃថ្ងៃធ្វើការ ហើយមន្ទីរត្រូវបញ្ជូនបន្តនូវសំណុំឯកសារទាំងនោះទៅកាន់ច្រកចេញចូលតែមួយក្នុងរយៈពេលយ៉ាងយូរ ៣ ថ្ងៃនៃថ្ងៃធ្វើការដូចគ្នាដែរ ដើម្បីប្រគល់ជូនម្ចាស់សំណង់។[51] ចំពោះការស្នើសុំទៅអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ការពិនិត្យសម្រេចត្រូវធ្វើឡើងក្នុងរយៈពេល ១៥ ថ្ងៃនៃថ្ងៃធ្វើការដូចគ្នា ដោយក្នុងនោះបន្ទាប់ពីការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានទទួលពាក្យស្នើសុំរួច ក្នុងរយៈពេលយ៉ាងយូរ ២ ថ្ងៃនៃថ្ងៃធ្វើការ ការិយាល័យនេះត្រូវបញ្ជូនសំណុំឯកសារនេះទៅការិយល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រួតពិនិត្យ និងផ្តល់យោបល់ រួចបញ្ជូនទៅអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ ៧ ថ្ងៃនៃថ្ងៃធ្វើការ។[52] ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃនៃថ្ងៃធ្វើការ អភិបាលត្រូវពិនិត្យសម្រេច និងបញ្ជូនសំណុំឯកសារដែលបានសម្រេចរួចត្រឡប់ទៅការិយាល័យរៀបចំដែនដីវិញ ដោយការិយាល័យនេះមានរយៈពេល ៣ ថ្ងៃយ៉ាងយូរក្នុងការបញ្ជូនសំណុំឯកសារដែលបានសម្រេចរួចនោះទៅកាន់ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុកខណ្ឌវិញ ដើម្បីប្រគល់ជូនម្ចាស់សំណង់។[53]

ក្នុងដំណើរការពិនិត្យសម្រេចនេះអាចមានរយៈពេលយូរជាងរយៈពេលដែលបានកំណត់ ក្នុងករណីដែលសំណុំនៃពាក្យស្នើសុំនោះមិនមានភ្ជាប់នូវរបាយការណ៍ត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ផ្តល់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ទេនោះ ព្រោះក្នុងករណីនេះអាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍ត្រួតពិនិត្យដែលខ្វះនោះ ដោយរយៈពេលនៃការចុះត្រួតពិនិត្យនិងធ្វើរបាយការណ៍នេះមិនរាប់បញ្ចូលទៅក្នុងរយៈពេលនៃការពិនិត្យសម្រេចឡើយ។[54]

លទ្ធផលនៃការពិនិត្យសម្រេចមាន ២ គឺយល់ព្រមផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់តាមសំណើរ ក្នុងករណីពិនិត្យឃើញថា សំណង់បានគោរពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទដ្ឋានគតិយុត្តិជាធរមានមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ ឬសាធារណៈជន ព្រមទាំងមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និង

[50] ប្រការ ១៨ ប្រការ១៩ និងប្រការ ២០ នៃប្រកាសលេខ ១៧៧ ដនស/ប្រក ស្តីពី បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនពេលច្បាប់ស្តីពីសំណង់ចូលជាធរមាន

[51] ប្រការ ២១ និងប្រការ ២២ នៃប្រកាសលេខ ១៧៧ ដនស/ប្រក ស្តីពី បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនពេលច្បាប់ស្តីពីសំណង់ចូលជាធរមាន

[52] ប្រការ ២៤ ប្រការ ២៥ និងប្រការ ២៦ នៃប្រកាសលេខ ១៧៧ ដនស/ប្រក ស្តីពី បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនពេលច្បាប់ស្តីពីសំណង់ចូលជាធរមាន

[53] ប្រការ ២៦ និងប្រការ ២៧ នៃប្រកាសលេខ ១៧៧ ដនស/ប្រក ស្តីពី បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនពេលច្បាប់ស្តីពីសំណង់ចូលជាធរមាន

[54] ប្រការ១៦ នៃប្រកាសលេខ ១៧៧ ដនស/ប្រក ស្តីពី បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនពេលច្បាប់ស្តីពីសំណង់ចូលជាធរមាន

ការសម្រេចមួយទៀតគឺ បដិសេធការផ្តល់វិញ្ញាបនបត្រដោយចេញនូវ លិខិតបង្គាប់ឱ្យកែតម្រូវឬរុះរើសំណង់ ក្នុងករណីពិនិត្យឃើញថា សំណង់មិនគោរពបានតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទដ្ឋានគតិយុត្តិជាធរមានទេនោះ ដោយយោងតាមប្រការ១៧ ប្រការ២១ និងប្រការ ២៧ នៃប្រកាសលេខ ១៧៧ នេះ។

### ១.២.២.៣. លិខិតអនុញ្ញាតរុះរើសំណង់

មិនខុសគ្នាដែរ ក្នុងករណីដែលម្ចាស់សំណង់មានបំណងរុះរើសំណង់ណាមួយ លើកលែងតែសំណង់ទំហំតូចដែលមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬ លំនៅឋានដែលធ្វើពីឈើ ផ្ទះថ្មក្រោមឈើលើ ផ្ទះតៀមធ្វើពីឈើឬថ្មនៅទៅជនបទឬស្រែចម្ការ ដែលមិនប៉ះពាល់ដល់រមណីយដ្ឋានទេសចរណ៍តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ ឬសំណង់បម្រើដល់សន្តិសុខជាតិនិងការពារជាតិ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតរុះរើ។[55] យោងតាមមាត្រា ២២ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ ការដាក់ពាក្យស្នើសុំនេះត្រូវធ្វើទៅកាន់អាជ្ញាធរមានសមត្ថកិច្ចដែលចេញលិខិតអនុញ្ញាតសាងសង់នៃសំណង់នោះ ដោយភ្ជាប់មកជាមួយនូវសំណុំពាក្យស្នើសុំរួមមាន៖ ប្លង់ដីឡូត៍ ប្លង់អគារ រូបថតអគារ និងឯកសារផ្សេងៗទៀតដែលតម្រូវដោយអាជ្ញាធរមានសមត្ថកិច្ច។ រីឯចំពោះអគារដែលមានចុះក្នុងបញ្ជីបេតិកភ័ណ្ឌ ពាក្យស្នើសុំត្រូវឆ្លងតាមគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ ហើយត្រូវបានអនុញ្ញាតដោយអភិបាលរាជធានី-ខេត្ត ឬប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង។ ក្រោយពីថ្ងៃដាក់ពាក្យស្នើសុំ ៣ខែ ប្រសិនបើពុំមានចម្លើយណាមួយត្រូវបានផ្តល់ឱ្យអ្នកដាក់ពាក្យស្នើសុំទេនោះ ការស្នើសុំនេះត្រូវចាត់ទុកថាយល់ព្រម។ លើសពីនេះចំពោះការរុះរើសំណង់ក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះឬការពារអាយុជីវិតឬបង្ការ មិនឱ្យមានការប៉ះពាល់ឬខូចខាតធ្ងន់ធ្ងរដល់សុខភាពឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនទេ តែក្នុងរយៈពេល ៣០ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នបានបញ្ចប់ ម្ចាស់សំណង់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមានសមត្ថកិច្ច។[56]

[55] មាត្រា ២៦ និងមាត្រា ២៨ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[56] មាត្រា ២៧ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

# ជំពូកទី ២
# ការគ្រប់គ្រងវិស័យសំណង់នៅកម្ពុជា

# ជំពូកទី ២
# ការគ្រប់គ្រងវិស័យសំណង់នៅកម្ពុជា

## ២.១. ការគ្រប់គ្រងសំណង់មុនច្បាប់សំណង់ចូលជាធរមាន

នៅប្រទេសកម្ពុជាយើងនេះមិនថាតាំងពីសម័យកាលណាទេ ការវិវត្តនៃប្រទេសបានកើនឡើងជាបន្តបន្ទាប់ហូតដល់បច្ចុប្បន្នគួរឱ្យកត់សម្គាល់។ ការវិវត្តតាមវិស័យនីមួយៗ ក្នុងនោះក៏មានវិស័យសំណង់ផងដែរ ដែលជាផ្នែកមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេស។ បើយើងក្រឡេកមើលពីភាពជាក់ស្តែងវិស័យសំណង់ពិតជារីកចម្រើនពិតមែន ជាពិសេសក្នុងឆ្នាំ២០១៩-២០២០ នេះមិនថាតាមបណ្តាលខេត្ត រាជធានី សុទ្ធតែមានសំណង់អគារធំៗ ខ្ពស់ៗ ដែលអ្នកវិនិយោគបានមកវិនិយោគក្នុងប្រទេសកម្ពុជា ម្យ៉ាងទៀតវិស័យសំណង់នេះបានបន្តទាក់ទាញអ្នកវិនិយោគគ្រប់ប្រទេសផ្សេងទៀតមកវិនិយោគជាបន្តបន្ទាប់ហូតដល់សំណង់រីកស្គុះស្គាយពេញប្រទេស។ ការរីកចម្រើនបានផ្តល់ប្រយោជន៍ជូនប្រទេសជាតិយ៉ាងខ្លាំង តែក្នុងនោះក៏ធ្វើឱ្យក្រសួងស្ថាប័នដែលមានសមត្ថកិច្ចគ្រប់គ្រង មានការមមារញឹកក្នុងការតាមដានអនុវត្ត និងសម្របសម្រួលឱ្យមានភាពងាយស្រួល ជាពិសេសគឺការបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋឱ្យបានតាមតម្រូវការ រហ័ស និងត្រឹមត្រូវស្របទៅតាមច្បាប់ដែលបានកំណត់។ ចំពោះការគ្រប់គ្រងទៅលើវិស័យសំណង់នេះ រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចនោះជូនទៅដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីទទួលអនុវត្តទៅលើវិស័យនេះ។[57] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានបែងចែកការគ្រប់គ្រងសំណង់ទៅតាមផ្នែកនីមួយៗ និងបានកំណត់យ៉ាងច្បាស់អំពី សមត្ថកិច្ចគ្រប់គ្រង លក្ខខណ្ឌ នីតិវិធី ការអនុវត្ត ដែលអនុទ្បោមទៅតាម ព្រះរាជក្រឹត្យ អនុក្រឹត្យ ច្បាប់ ប្រកាស និងសារាចរណែនាំផ្សេងៗជាច្រើន។

### ២.១.១. ការគ្រប់គ្រងទូទៅ

នៅក្នុងការគ្រប់គ្រងសំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលក៏ដូចជាក្រសួងមានសមត្ថកិច្ចបានធ្វើការបែងចែកការគ្រប់គ្រងសំណង់ទៅតាមថ្នាក់នីមួយៗ ដូចជាការគ្រប់គ្រងរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការបែងចែកបែបនេះគឺដើម្បីងាយស្រួលក្នុងការក្តោបក្តាប់ទៅលើការងារសាងសង់ទាំងឡាយ ជាពិសេសការតាមដានការវិវត្តរបស់សំណង់ដែលសាងសង់ក្នុងប្រទេស ក៏ដូចជាដើម្បីធានាដល់សុខមាលភាពនៃសំណង់ និងសុវត្ថិភាពសាធារណៈព្រមទាំងដើម្បីការពារដីធ្លីសាធារណៈសម្រាប់ធានាដល់ដំណើរការរៀបចំទីក្រុង និងតំបន់កសិកម្មបានល្អប្រសើរ លើសពីនេះបទប្បញ្ញត្តិទូទៅនៃសំណង់មានកំណត់អំពីសិទ្ធិ និងករណីកិច្ចប្រជាពលរដ្ឋ រួមទាំងស្ថាប័នសាធារណៈក្នុងការសាងសង់សំណង់សាធារណៈ និងសំណង់ឯកជន។

#### ២.១.១.១. លិខិតអនុញ្ញាតសាងសង់ ឬ លិខិតអនុញ្ញាតរុះរើ

លិខិតអនុញ្ញាតសាងសង់ គឺជាលិខិតមួយដែលមានអត្ថប្រយោជន៍យ៉ាងខ្លាំងសម្រាប់ការងារសាងសង់

[57] ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤

ហើយក៏ជាលិខិតបទដ្ឋានគតិយុត្តមួយ ដែលបង្ហាញពីគ្រឹះស្របច្បាប់សម្រាប់ការងារសាងសង់សំណង់មានន័យថាប្រជាពលរដ្ឋគ្រប់រូបទាំងរូបវន្តបុគ្គល ឬនីតិបុគ្គល សាធារណៈ និងឯកជនមានសិទ្ធិពេញលេញក្នុងការសាងសង់សំណង់គ្រប់ប្រភេទ នៅលើដីធ្លីដែលជាកម្មសិទ្ធិស្របច្បាប់របស់ខ្លួន ដែលមានការការពារ និងទទួលស្គាល់ដោយអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់។ ការផ្តល់លិខិតអនុញ្ញាតសាងសង់ គឺធ្វើឡើងដើម្បីជួយឱ្យការរៀបចំទីក្រុងមាន សោភ័ណភាពល្អ ការពារសណ្តាប់ធ្នាប់សាធារណៈ អនាម័យ ការពារទីធ្លាសាធារណៈ និងការពារតំបន់ហាមឃាត់មួយចំនួនទៀត កុំឱ្យមានការសាងសង់ដោយអនាធិបតេយ្យ និងជៀសវាងកុំឱ្យមានការប្រព្រឹត្តអំពើល្មើសច្បាប់ ទៅលើវិស័យសំណង់បន្តទៀត ហើយថែមទាំងមានគោលដៅការពារប្រយោជន៍ស្របច្បាប់របស់បុគ្គលផងដែរ គឺទាំងអ្នកស្នើសុំ និងទាំងបុគ្គលដែលពាក់ព័ន្ធ។

ដើម្បីធានាដល់សុវត្ថិភាពសាធារណៈ និងទទួលបាននូវការការពារដីធ្លីសាធារណៈ សម្រាប់ដំណើរការរៀបចំទីក្រុង ឱ្យមានរបៀបរៀបរយប្រសើរឡើងនោះ មិនមែនរាល់ការងារសាងសង់ទាំងអស់សុទ្ធតែទាមទារឱ្យមានការផ្តល់លិខិតអនុញ្ញាតសាងសង់ទេ។[58] ដូចនេះហើយទើបអនុក្រឹត្យលេខ៨៦នេះមិនយកទៅអនុវត្តលើសំណង់ទាំងឡាយដែលមានស្រាប់ហើយមានការអនុញ្ញាតនោះទេ តែបើមានស្រាប់ហើយគ្មានការអនុញ្ញាតធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍ សោភ័ណភាព ឬសណ្តាប់ធ្នាប់សាធារណៈ ការរុះរើត្រូវសម្រេចដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសាលាខេត្ត-ក្រុង។

រាល់សំណង់ដែលសាងសង់មួយចំនួនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ជាមុន។[59] ការសាងសង់សំណង់ថ្មីៗ ការសាងសង់ក្នុងទីក្រុង និងទីប្រជុំជន សុទ្ធតែតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ រីឯចំពោះការជួសជុល ឬរុះរើក៏តម្រូវឱ្យមានលិខិតអនុញ្ញាតដែរ។ ប៉ុន្តែរាជរដ្ឋាភិបាលក៏មានករណីលើកលែងចំពោះសំណង់មួយចំនួនតូច ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ ឬរុះរើទេ។

ចំពោះការជួសជុល ឬ រុះរើ សំដៅលើការសាងសង់ឡើងវិញជាថ្មី ការពង្រីក និងការសាងសង់បន្ថែមពីលើអគារដែលមានស្រាប់។ ការប្តូរទ្រង់ទ្រាយអគារដែលមានស្រាប់ តម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ បើការងារនោះកែប្រែទៅលើ៖

- ការប្រើប្រាស់របស់ផ្នែកអគារ
- ទិដ្ឋភាពនៃអគារ
- ការធ្វើបង្គន់អនាម័យ និងការបន្តភ្ជាប់ទៅបំពង់លូ
- ការធ្វើអាងប្រព្រឹត្តកម្មទឹកកខ្វក់ តភ្ជាប់ទៅបំពង់លូ
- ការបង្កើនផ្ទៃក្រឡាកម្រាលសំណង់
- កន្លែងទទួលសាធារណៈជន

[58] មាត្រា ១២ នៃច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤

[59] មាត្រា២ នៃអនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់

- ការចាក់ដីបំពេញ ជីកយកដីចេញ ការប្តូរប្រភេទដីស្រែចំការជាដីសាងសង់ ឬ ប៉ះពាល់ខ្លាំងដល់ទិដ្ឋភាពទីដ្ឋានណាមួយ ដូចជាការលុបបំបាត់បឹង ឬប្រឡាយបង្ហូរទឹក ឬផ្នែកណាមួយនៃប្រព័ន្ធបង្ហូរទឹកចេញ និងការកាប់ដើមឈើដែលមានស្រាប់។

ការសាងសង់ ឬការកែទ្រង់ទ្រាយបបនភណ្ឌ[60]ផ្សេងៗ ដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គិភ័យ ដូចជាការដាក់ស៊ីទែនកន្លែងស្តុកប្រេងឥន្ធនៈ រោងជាងដែលមានផលិតផលគ្រឿងឆេះ និងកន្លែងទទួលសាធារណៈជនក៏តម្រូវឱ្យមានលិខិតអនុញ្ញាតផងដែរ។ លើសពីនេះ ការប្តូរទ្រង់ទ្រាយអគារឧស្សាហកម្ម ការដាក់ប៉ាណូ ផ្សាយពាណិជ្ជកម្ម ការដាក់អង់ទែនទូរទស្សន៍ និងទូរគមនាគមន៍ ប៉ាន់ណូស្រូបពន្លឺព្រះអាទិត្យ ក៏ដូចជារាល់គ្រឿងដទៃទៀតដែលបំពាក់ទៅនឹងអគារ ហើយស្ថិតនៅជិតមាត់ផ្លូវ ឬ តាំងចំទិសដែលគេអាចមើលឃើញ សាលាក្រុង និងសាលាខេត្តនឹងធ្វើការណែនាំដោយឡែក និងតម្រូវឱ្យមានលិខិតអនុញ្ញាត។

សំណង់មួយចំនួនពុំចំណុះឱ្យលិខិតអនុញ្ញាតសាងសង់ពីអាជ្ញាធរ ដោយសារតែសំណង់នោះមានលក្ខណៈតូចតាចដែលធ្វើអំពីឈើ ឬស្លឹករុក្ខជាតិនានា ដែលមិនប៉ះពាល់ដល់សាធារណៈនិងសង្គម ហើយស្ថិតនៅទីជនបទ ឬតំបន់ឆ្ងាយៗពីតំបន់រមនីយដ្ឋាន តំបន់បេតិកភណ្ឌ និងតំបន់រក្សាការពារដោយមិនគិតពីទំហំ ឬ សម្ភារៈសំណង់ប្រើប្រាស់។ មួយវិញទៀតរាល់ការជួសជុល និងថែរក្សាទាំងឡាយណាដែលមិនធ្វើឱ្យមានការផ្លាស់ប្តូរទ្រង់ទ្រាយ ឬទិដ្ឋភាពផ្សេងៗនៃសំណង់ គឺមិនចាំបាច់មានការផ្តល់លិខិតអនុញ្ញាតសាងសង់នោះទេ លើកលែងតែការជួសជុលណាដែលមានការបង្កឱ្យមានគ្រោះថ្នាក់ ឬផលប៉ះពាល់ដល់អ្នកជិតខាង។ លើសពីនេះរាល់សំណង់ដែលសាងសង់ឡើងសម្រាប់ជាផលប្រយោជន៍សាធារណៈក៏មិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ដែរ គឺគ្រាន់តែជូនដំណឹងទៅអាជ្ញាធរមូលដ្ឋានអំពីគម្រោងសាងសង់នោះជាការស្រេច ក្នុងនោះរួមមានដូចជា៖ ទីកន្លែងសក្ការៈបូជា សាលាសំណាក់សាធារណៈ និងបណ្ណាការស្សិល្បៈរបស់រដ្ឋដែលសម្រាប់បម្រើសេវាសាធារណៈ ហើយរដ្ឋធ្វើជាម្ចាស់កិច្ចការ។[61]

### ២.១.១.២. ការគ្រប់គ្រងការដ្ឋានសំណង់

ដើម្បីចូលរួមក្នុងការអភិវឌ្ឍវិស័យសំណង់ប្រកបដោយចីរភាព ទាមទារឱ្យក្រុមហ៊ុនសាងសង់ ក៏ដូចជាម្ចាស់ការដ្ឋានសំណង់គិតគូរអំពីសណ្តាប់ធ្នាប់ សន្តិសុខសាធារណៈ និង សុវត្ថិភាពក្នុងការដ្ឋានសំណង់ តាមរយៈការគ្រប់គ្រងការដ្ឋានសាងសង់ដែលអនុលោមតាមច្បាប់ជាធរមាន។ ផ្អែកតាមប្រកាសលេខ ៣២ របស់ក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និង សំណង់ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ២០០១ ការគ្រប់គ្រងការដ្ឋានសំណង់ដែលអនុលោមតាមច្បាប់ត្រូវអនុវត្តដូចខាងក្រោម៖

ការដ្ឋាននីមួយៗ អាចដំណើរការបានលុះត្រាតែមានលិខិតអនុញ្ញាតបើកការដ្ឋាន ដែលលិខិតអនុញ្ញាត

[60] បបនភណ្ឌ សំដៅដល់គ្រឿងបរិក្ខារ រោងចក្រ បំពង់បង្ហូរ និងទព្វសម្ភារៈផ្សេងៗសម្រាប់ប្រតិបត្តិការ ប្រេងកាត លើកលែងតែកប៉ាល់ដឹកជញ្ជូនប្រេងកាត ឬកប៉ាល់ដឹកសម្ភារៈផ្គត់ផ្គង់និងគាំទ្រផ្សេងៗ

[61] មាត្រា៣ នៃអនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់

បើកការដ្ឋាននេះ ត្រូវស្នើសុំនៅអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត ដោយភ្ជាប់ជាមួយនូវ ពាក្យស្នើសុំរបស់ម្ចាស់សំណង់ លិខិតអនុញ្ញាតសាងសង់ ប្លង់ស្ថាបត្យកម្មដែលបានអនុញ្ញាត និងប្លង់គ្រឿងផ្គុំសំណង់។[62] ករណីបើដំណើរការការដ្ឋានដោយពុំមានលិខិតអនុញ្ញាតសាងសង់ អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្អាកការងារការដ្ឋាននោះជាបណ្តោះអាសន្ន ហើយបើសិនជាម្ចាស់សំណង់នៅតែបន្តការសាងសង់ទៀត អាជ្ញាធរមានសមត្ថកិច្ចនឹងធ្វើការដកហូតសម្ភារៈសាងសង់ទាំងនោះ ហើយប្តឹងទៅតុលាការ។[63] លើសពីនេះចំពោះការដ្ឋានដែលត្រូវបានផ្អាកជាបណ្តោះអាសន្ននេះ អាចដំណើរការជាថ្មីវិញបាន ករណីម្ចាស់សំណង់ស្នើសុំបំពេញបែបបទឡើងវិញ ដោយធ្វើការដាក់ពាក្យស្នើសុំលិខិតបើកការដ្ឋាន ដោយបំបពេញលក្ខខណ្ឌគ្រប់គ្រាន់តាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច។[64]

ម្យ៉ាងវិញទៀតការដ្ឋានសំណង់នីមួយៗត្រូវ៖[65]

- តម្កល់ជាប្រចាំនូវលិខិតបើកការដ្ឋាន គំនូរប្លង់តាមមុខជំនាញការងារសំណង់ ផែនការអនុវត្តការងារក្នុងដំណាក់កាលនីមួយៗនៃការសាងសង់ និងឯកសារពាក់ព័ន្ធ ទុកសម្រាប់ភ្នាក់ងារសំណង់តាមដានពិនិត្យ និងត្រួតពិនិត្យ
- មានអ្នកបច្ចេកទេសសំណង់សម្រាប់ទទួលខុសត្រូវក្នុងការងារសាងសង់ ហើយមានកាតព្វកិច្ចឆ្លើយបំភ្លឺផ្តល់ពត៌មានជូនដល់ភ្នាក់ងារមានសមត្ថកិច្ចត្រួតពិនិត្យ
- ដាក់ផ្ទាំងគំនូរសំណង់ ដែលមានឈ្មោះសំណង់នៃអគារត្រូវសាងសង់ ក្រុមហ៊ុនសំណង់ ម្ចាស់សំណង់ ស្ថាបត្យករ វិស្វករ ផ្ទៃក្រឡាសំណង់ លេខទូរស័ព្ទទាក់ទង និងកន្លែងការដ្ឋានតាំងនៅ
- មានភ្លើងដើម្បីបំភ្លឺ និងប្រដាប់សម្រាប់ពន្លត់អគ្គិភ័យជាប្រចាំ
- បន្ថយការរំខានដោយស្នូរសំឡេង ផ្សែង ធូលី និងផលប៉ះពាល់ដទៃទៀតឱ្យស្ថិតនៅក្នុងកម្រិត និងពេលវេលាមួយដែលអ្នករស់នៅជុំវិញការដ្ឋានអាចទទួលបាន។

ក្នុងការដំណើរការការដ្ឋាន ត្រូវមានការហ៊ុមព័ទ្ធដោយរបងដែលមានកម្ពស់ ២ ម៉ែត្រយ៉ាងទាបបំផុត ហើយមិនអនុញ្ញាតឱ្យធ្វើលើចិញ្ចើមថ្នល់ឡើយ។ ក្នុងករណីទីតាំងការដ្ឋានចង្អៀត ការធ្វើរបងបិទបាំងបណ្តោះអាសន្នលើចិញ្ចើមថ្នល់សាធារណៈ ត្រូវរក្សាឱ្យមានចន្លោះផ្លូវដើរលើចិញ្ចើមថ្នល់ និងធ្វើរបាំងការពារតាមទំហំដែលអនុញ្ញាត ឬកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។ ចំពោះសំណង់ដែលមានកម្ពស់ចាប់ពី ៥ ម៉ែត្រឡើងទៅ

[62] ប្រការ៣(ថ្មី) នៃប្រកាសលេខ ៩៣ ប្រក.ដនស/អសណ ស្តីពីការកែសម្រួលប្រការ២ និងប្រការ៣ នៃប្រកាសលេខ៣២ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

[63] ប្រការ១៤ កថាខណ្ឌទី១ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

[64] ប្រការ១៥ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

[65] ប្រការ៤ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

ត្រូវហ៊ុមព័ទ្ធដោយក្រណាត់កៅស៊ូ ឬសំណាញ់សុវត្ថិភាព។[66] លើសពីនេះការដ្ឋានត្រូវមានសណ្តាប់ធ្នាប់ និង អនាម័យ ជាប្រចាំ គិតតាំងពីពេលចាប់ផ្តើមដំណើរការរហូតដល់ពេលបញ្ចប់ការដ្ឋាន។ ម្ចាស់សំណង់ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំសណ្តាប់ធ្នាប់ និងអនាម័យដែលបណ្តាលមកពីការទុកដាក់សម្ភារៈ ឬកាកសំណល់ដែលប៉ះពាល់ផ្លូវសាធារណៈ ឬហូរធ្លាក់ចូលក្នុងអាង ត្រួតពិនិត្យនៃបណ្តាលូ និងប្រឡាយទឹក។[67] ចំពោះការិយាល័យការងារ ឃ្លាំងផ្ទុកសម្ភារៈ ជម្រកកម្មករ គ្រឿងចក្រ និងសកម្មភាពសាងសង់ត្រូវរៀបចំនិងប្រព្រឹត្តទៅនៅក្នុងរបងហ៊ុនព័ទ្ធនៃការដ្ឋាន ការដ្ឋានរណប ឬទីកន្លែងដែលធានាបាននូវសណ្តាប់ធ្នាប់និងសន្តិសុខសាធារណៈ។[68]

ដោយឡែកចំពោះសំណង់ដែលត្រូវប្រើគ្រឿចក្របរិក្ខារលើកស្ទូច ហើយអាចធ្វើឱ្យប៉ះពាល់ដល់ការធ្វើដំណើរលើផ្លូវសាធារណៈ ម្ចាស់សំណង់ត្រូវសុំការអនុញ្ញាតពីអាជ្ញាធរដែនដី ដើម្បីបិទផ្លូវសម្រាប់ការដំឡើងគ្រឿងចក្រធុំសំណង់ ហើយធ្វើផ្លូវវាងជាបណ្តោះអាសន្ន និងបំពាក់ភ្លើងសញ្ញាសម្គាល់លើផ្លូវដែលបិទ ដើម្បីធានាសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈនៅពេលយប់។[69]

ក្នុងករណីការសាងសង់មានបុកសសរគ្រឹះវិញ ម្ចាស់សំណង់ និង អ្នកម៉ៅការសាងសង់ត្រូវៈ[70]

- មានកាតព្វកិច្ចអនុញ្ញាតឱ្យមន្ត្រីបច្ចេកទេស ដែលមានសមត្ថកិច្ចចូលត្រួតពិនិត្យក្នុងការដ្ឋាន
- ជៀសវាងការប៉ះពាល់ដល់គ្រឿងធុំផ្នែកក្រោមដី
- ធានាសុវត្ថិភាពអគារដែលស្ថិតនៅជុំវិញបរិវេណការដ្ឋាន
- រៀបចំសណ្តាប់ធ្នាប់ការងារឱ្យបានសមស្រប តាមលក្ខណៈបច្ចេកទេស
- បំពាក់ប្រដាប់ការពារសុវត្ថិភាព មានមួកសុវត្ថិភាព ស្រោមដៃ ស្បែកជើង ខ្សែក្រវាត់សុវត្ថិភាពសម្រាប់ឈរនៅទីខ្ពស់ និង ឧបករណ៍ការពារដទៃទៀតដល់បុគ្គលិកកម្មករជាប្រចាំក្នុងការដ្ឋាន។

ក្នុងការអនុវត្តការងារម្ចាស់សំណង់ និង អ្នកម៉ៅការសាងសង់ ត្រូវគោរពច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា។[71] នៅពេលដែលការសាងសង់រួចជាស្ថាពរ ម្ចាស់សំណង់ត្រូវស្នើសុំលិខិតបិទដ្ឋានសំណង់ពីអាជ្ញាធរមានសមត្ថកិច្ច។ ការស្នើសុំលិខិតបិទការដ្ឋាននេះ ម្ចាស់សំណង់ត្រូវភ្ជាប់ជាមួយមកនូវ ពាក្យស្នើសុំ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងរបាយការណ៍ស្តីពីដំណើរការសាងសង់របស់ខ្លួន។[72] នៅពេលដែលទទួលបានលិខិតបិទការដ្ឋានរួចហើយ ម្ចាស់សំណង់ត្រូវបំពេញកាតព្វកិច្ចមួយទៀតគឺស្នើសុំវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនៃសំណង់ (បច្ចុប្បន្ន ហៅថាវិញ្ញាបនបត្រប្រើប្រាស់សំណង់) ដើម្បីអាចប្រើប្រាស់សំណង់របស់ខ្លួនបានត្រឹមត្រូវទៅតាមច្បាប់។

---

[66] ប្រការ៥ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

[67] ប្រការ៦ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

[68] ប្រការ៧ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

[69] ប្រការ៨ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

[70] ប្រការ៩ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

[71] ប្រការ១៦ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

[72] ប្រការ១១ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

ចំពោះការដ្ឋានណាដែលប្រព្រឹត្តល្មើសទៅនឹងលក្ខខណ្ឌដែលបានកំណត់ខាងលើ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តម្រូវឱ្យមន្ត្រីជំនាញមានសមត្ថកិច្ចត្រូវធ្វើការណែនាំដល់ម្ចាស់សំណង់ឱ្យទៅបំពេញលក្ខខណ្ឌដែលខ្វះខាត ឬធ្វើលិខិតជូនដំណឹងទៅឱ្យម្ចាស់សំណង់ធ្វើការកែតម្រូវនូវចំនុចខុសឆ្គងនឹងប្លង់ដែលទទួលបានការអនុញ្ញាត ឬកែតម្រូវនូវចំនុចខុសឆ្គងនឹងនគរូបនីយប្បញ្ញត្តិ។ ប៉ុន្តែប្រសិនបើម្ចាស់សំណង់ក្រោយពីបានទទួលលិខិតជូនដំណឹងរយៈពេល១៥ថ្ងៃ ហើយគ្មានការកែតម្រូវទេនោះអាជ្ញាធរមានសមត្ថកិច្ចត្រូវផ្អាកការដ្ឋានជាបណ្តោះអាសន្ន។ ករណីម្ចាស់សំណង់មិនព្រមអនុវត្តតាមការណែនាំ អាជ្ញាធរមានសមត្ថកិច្ចត្រូវរុះរើរឹបអូសសម្ភារៈសាងសង់ទាំងអស់ ហើយប្តឹងទៅតុលាការ។ រីឯការដ្ឋានដែលប្រព្រឹត្តល្មើសទៅនឹងវិធានសុវត្ថិភាព និងវិធានអនាម័យ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើការផាកពិន័យ ហើយបង្ខំឱ្យម្ចាស់សំណង់អនុវត្តតាមការណែនាំអំពីរបៀបរបបសណ្តាប់ធ្នាប់សន្តិសុខសាធារណៈ ករណីម្ចាស់សំណង់រឹងរូសមិនគោរពតាមការណែនាំ អាជ្ញាធរមានសមត្ថកិច្ចត្រូវរឹបអូសសម្ភារៈសាងសង់ទាំងនោះ។[73]

បន្ថែមពីនេះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញសេចក្តីណែនាំមួយសម្រាប់ដាក់ឱ្យអនុវត្តប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ដោយធ្វើការណែនាំដល់គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត ដូចជា៖[74]

- ត្រូវផ្សព្វផ្សាយ និងណែនាំដល់ក្រុមហ៊ុន សហគ្រាសសំណង់ ឬម្ចាស់សំណង់ឱ្យយល់ច្បាស់អំពីអត្ថប្រយោជន៍នៃការធានារ៉ាប់រង ហើយជំរុញឱ្យមានការទិញវិញ្ញាបនបត្រធានារ៉ាប់រង
- សំណុំឯកសារ ដែលភ្ជាប់ជាមួយពាក្យសុំលិខិតបើកការដ្ឋាន ត្រូវមានរួមទាំងវិញ្ញាបនបត្រធានារ៉ាប់រងផង
- នៅពេលចុះត្រួតពិនិត្យការដ្ឋានសំណង់ ត្រូវត្រួតពិនិត្យលិខិតស្នាមផ្សេងៗរួមទាំងវិញ្ញាបនបត្រធានារ៉ាប់រងផងដែរ។ ត្រូវឃាត់សកម្មភាពការដ្ឋានជាបណ្តោះអាសន្ន ក្នុងករណីដែលការដ្ឋានណាមួយពុំមានវិញ្ញាបនបត្រធានារ៉ាប់រង និងត្រូវណែនាំម្ចាស់សំណង់ឱ្យទទួលតែសហគ្រិន អ្នកម៉ៅការ ឬអ្នកម៉ៅការបន្តដែលមានវិញ្ញាបនបត្រធានារ៉ាប់រងការដ្ឋាន។ ប្រសិនបើម្ចាស់សំណង់នៅតែមិនអនុវត្តតាមការណែនាំ ត្រូវរាយការណ៍ទៅអាជ្ញាធរស្រុក ខណ្ឌ
- ត្រូវចាត់មន្ត្រីចូលរួមក្នុងការងារដើម្បីត្រួតពិនិត្យការដ្ឋានដែលពុំមានវិញ្ញាបនបត្រធានារ៉ាប់រង។

ជាក់ស្តែងនៅក្នុងឆ្នាំ២០១៩កន្លងទៅថ្មីៗនេះ មានការដ្ឋានមួយបានបាក់រលំនៅក្នុងខេត្តព្រះសីហនុ ហេតុការណ៍នេះ បានធ្វើឱ្យរាជរដ្ឋាភិបាលក៏ដូចជាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញសេចក្តីណែនាំថ្មីមួយ ពង្រឹងបន្ថែម និងទប់ស្កាត់នូវរាល់ការដ្ឋានសំណង់ខុសច្បាប់ទាំងឡាយ ដើម្បីធានាអាយុជីវិត

[73] ប្រការ១៤ កថាខណ្ឌទី២និងទី៣ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

[74] សេចក្តីណែនាំលេខ ០៣ ដនស/សណន ស្តីពីអនុវត្តប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន

មនុស្ស ទ្រព្យសម្បត្តិ សុវត្ថិភាព និងគុណភាពសំណង់ទូទាំងប្រទេសដោយសម្រេចចេញនូវវិធានការចាំបាច់ដូចជា៖[75]

១. ក្រសួងរ៉ែ និងថាមពល ចាត់វិធានការមិនឱ្យមានការផ្គត់ផ្គង់ថាមពលអគ្គិសនីដល់ការដ្ឋានសំណង់

២.ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចាត់វិធានការមិនឱ្យមានការផ្គត់ផ្គង់ទឹកស្អាតដល់ការដ្ឋានសំណង់

៣. ក្រសួងសាធារណការ និងដឹកជញ្ជូន មិនត្រូវអនុញ្ញាតឱ្យតភ្ជាប់លូចូលក្នុងបណ្តាញលូសាធារណៈ

៤. ក្រសួង ស្ថាប័ន និងអង្គភាពមានសមត្ថកិច្ច មិនត្រូវផ្តល់លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្ម

៥. ក្រសួងពត៌មាន និងអង្គភាពមានសមត្ថកិច្ច មិនត្រូវអនុញ្ញាតឱ្យផ្សព្វផ្សាយពាណិជ្ជកម្ម។

### ២.១.២. ការគ្រប់គ្រងបុគ្គលពាក់ព័ន្ធក្នុងវិស័យសំណង់

ចំពោះការគ្រប់គ្រងបុគ្គលដែលពាក់ព័ន្ធក្នុងវិស័យសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញនូវប្រកាសមួយចំនួនដែលបែងចែកដាច់ដោយឡែកពីគ្នាចំពោះអ្នកវិជ្ជាជីវៈ និងអ្នកប្រកបអាជីវកម្មក្នុងវិស័យសំណង់។ ក្នុងការអនុវត្តប្រកាសនេះ ក្រសួងក៏បានចេញសារាចរណែនាំបន្ថែមទៅលើការគ្រប់គ្រងបុគ្គលទាំងនោះផងដែរ។

#### ២.១.២.១. អ្នកវិជ្ជាជីវៈ សិក្សាគម្រោងប្លង់

អ្នកវិជ្ជាជីវៈសិក្សាគម្រោងប្លង់ សំដៅដល់រូបវន្តបុគ្គលដែលសិក្សាគម្រោងប្លង់ពាក់ព័ន្ធនឹងការសាងសង់ ហើយមានសញ្ជាតិខ្មែរ ឬបរទេស។[76] អ្នកវិជ្ជាជីវៈសិក្សាគម្រោងប្លង់នេះអាចជាស្ថាបត្យករ ឬវិស្វករដែលធ្វើការសិក្សាគម្រោងប្លង់តាមមុខជំនាញរបស់ខ្លួន។ ដើម្បីក្លាយខ្លួនទៅជារូបវន្តបុគ្គលសិក្សាគម្រោងប្លង់ពួកគេដាច់ខាតត្រូវបំពេញបែបបទស្នើសុំចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់ នៅនាយកដ្ឋានសិក្សាគម្រោងប្លង់នៃអគ្គនាយកដ្ឋានសំណង់ ដើម្បីមានសិទ្ធិក្នុងការសិក្សាគម្រោងប្លង់សំណង់ផ្សេងៗ និងមានការទទួលស្គាល់ពីក្រសួងនូវបទពិសោធន៍នៃវិជ្ជាជីវៈដែលខ្លួនមាន។[77] ម៉្យាងវិញទៀតបុគ្គលដែលមានបំណង ឬកំពុងសិក្សាគម្រោងប្លង់នៅព្រះរាជាណាចក្រកម្ពុជានេះ ទោះបីមានលិខិតអនុញ្ញាតពីស្ថាប័នណាផ្សេងហើយក៏ដោយ ក៏ត្រូវមានការចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់ដែរ។[78]

ការចុះបញ្ជីរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ត្រូវបំពេញលក្ខខណ្ឌដូចជា៖[79]

- ត្រូវមានសញ្ញាបត្រស្ថាបត្យករ ឬវិស្វករ
- មានបទពិសោធន៍ការងារក្នុងមុខជំនាញ ដែលខ្លួនធ្លាប់អនុវត្តការងារសិក្សាគម្រោងប្លង់កន្លងមក មិនថា

[75] លិខិតលេខ ១៩៨១ ដនស/អរប ចុះថ្ងៃទី២៧ មិថុនា ២០១៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសេចក្តីជូនដំណឹងលេខ ៩៤៨ សជណ ចុះថ្ងៃទី៥ កក្កដា ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

[76] ប្រការ ២ នៃប្រកាសលេខ ១៩២ ប្រក.ដនស/អសហ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់

[77] ប្រការ ៣ នៃប្រកាសលេខ ១៩២ ប្រក.ដនស/អសហ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់

[78] ប្រការ ៤ នៃប្រកាសលេខ ១៩២ ប្រក.ដនស/អសហ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់

[79] ប្រការ ៥ នៃប្រកាសលេខ ១៩២ ប្រក.ដនស/អសហ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់

នៅតាមស្ថាប័នរដ្ឋ ឬឯកជន

- ត្រូវមានលិខិតបញ្ជាក់ការសិក្សា ឬវិញ្ញាបនបត្រផ្សេងៗនៃវគ្គបំប៉ន ឬវគ្គបណ្ដុះបណ្ដាលតាមផ្នែកមុខជំនាញផ្សេងៗ។

ចំពោះវិញ្ញាបនបត្រសិក្សាគម្រោងប្លង់ មានសុពលភាពរហូតដល់ ៣ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រ ហើយរូបវន្តបុគ្គលអាចដាក់ពាក្យស្នើសុំបន្តសុពលភាពសិក្សាគម្រោងប្លង់របស់ខ្លួនសារជាថ្មីបាន ក្នុងរយៈពេល ៣០ថ្ងៃ មុនថ្ងៃផុតកំណត់សុពលភាព។[80] លើសពីនេះរូបវន្តបុគ្គលដែលទទួលបានវិញ្ញាបនបត្រសិក្សាគម្រោងប្លង់នេះ អាចចូលរួមក្នុងកម្មវិធីសិក្ខាសាលា ឬវគ្គបណ្ដុះបណ្ដាលនានាបាន តាមការអញ្ជើញរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីលើកកម្ពស់សមត្ថភាពនិងគុណភាពវិជ្ជាជីវៈលើការងារជំនាញរបស់ខ្លួន។[81]

ដោយឡែកចំពោះកម្រិតរបស់ស្ថាបត្យករជារូបវន្តបុគ្គលសិក្សាគម្រោងប្លង់ស្ថាបត្យកម្ម និងវិស្វករជារូបវន្តបុគ្គលសិក្សាគម្រោងប្លង់គ្រឿងផ្គុំសំណង់ឬប្លង់វិស្វកម្មវិញ គេធ្វើការបែងចែកជា ៣ កម្រិត ទៅតាមបទពិសោធន៍ការងារក្នុងមុខជំនាញនីមួយៗដោយមានរយៈពេលដូចៗគ្នាដូចខាងក្រោម៖[82]

- កំរិតទី១ មានបទពិសោធន៍ការងារយ៉ាងតិច ១០ ឆ្នាំ
- កំរិតទី២ មានបទពិសោធន៍ការងារយ៉ាងតិច ៧ ឆ្នាំ
- កំរិតទី៣ មានបទពិសោធន៍ការងារយ៉ាងតិច ៣ ឆ្នាំ។

រូបវន្តបុគ្គលដែលសិក្សាគម្រោងប្លង់ អាចស្នើសុំតម្លើងឋានៈកំរិតរបស់ខ្លួនបាន នៅពេលដែលពួកគាត់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌដែលបានកំណត់ ហើយចំពោះការប្រកបអាជីកម្មសិក្សាគម្រោងប្លង់នេះ ត្រូវធ្វើការបង់ពន្ធអាករទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលការបង់ពន្ធនេះ ជាកាតព្វកិច្ចរបស់រូបវន្តបុគ្គលសិក្សាគម្រោងប្លង់។[83]

### ២.១.២.២. ការប្រកបវិជ្ជាជីវៈនិងការប្រកបអាជីវកម្មក្នុងវិស័យសំណង់

ការប្រកបវិជ្ជាជីវៈ និងការប្រកបអាជីវកម្មក្នុងវិស័យសំណង់ សំដៅដល់ក្រុមជាងសំណង់ ឬសហគ្រាស ក្រុមហ៊ុន ឬរូបវន្តបុគ្គលបរទេស ដែលប្រកបអាជីវកម្មក្នុងការងារសំណង់ ដូចជាការងារសិក្សាគម្រោងប្លង់ ឬ ការងារសាងសង់ក្នុងគោលបំណងស្វែងរកប្រាក់កម្រៃ។ ចំពោះសហគ្រាស ឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ និង សាងសង់ទាំងអស់ដែលមានបំណងចង់ធ្វើអាជីវកម្មសិក្សាគម្រោងប្លង់ឬសាងសង់នោះ ពួកគេត្រូវដាក់ពាក្យស្នើសុំប្រកបអាជីវកម្ម នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ រីឯរូបវន្តបុគ្គល ឬក្រុមជាងសំណង់ដែលមានបំណងចង់ធ្វើអាជីវកម្មក្នុងវិស័យសំណង់នេះ ត្រូវដាក់ពាក្យស្នើសុំប្រកបអាជីវកម្មដែរ តែនៅមន្ទីររៀបចំ

[80] ប្រការ ១៥ នៃប្រកាសលេខ ១៩២ ប្រក.ដនស/អសហ ស្ដីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់

[81] ប្រការ ១២ នៃប្រកាសលេខ ១៩២ ប្រក.ដនស/អសហ ស្ដីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់

[82] ប្រការ ៦ថ្មី នៃប្រកាសលេខ០៣៥ ស្ដីពីការកែសម្រួលប្រការ៦ នៃប្រកាសលេខ ១៩២ ប្រក.ដនស/អសហ ស្ដីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់

[83] ប្រការ ១៣ និងមាត្រា ១៤ នៃប្រកាសលេខ ១៩២ ប្រក.ដនស/អសហ ស្ដីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់

ដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត។[84] ម៉្យាងវិញទៀតចំពោះសហគ្រាស ក្រុមហ៊ុន រូបវន្តបុគ្គល និងក្រុមជាងសំណង់ ដែលមានលិខិតអនុញ្ញាតពីស្ថាប័នណាផ្សេងហើយក៏ដោយ ក៏ត្រូវមានការចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត ដែរ។[85] លើសពីនេះប្រការ ៨ នៃប្រកាសលេខ៧៥ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ ក៏បានកំណត់បញ្ជាក់បន្ថែមទៅលើសហគ្រាស និងក្រុមហ៊ុនបរទេសដែលមានបំណងប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ ផ្តល់យោបល់ ពិគ្រោះបច្ចេកទេស និងសាងសង់ ឬកំពុងប្រកបអាជីកម្មក៏ដោយ ទោះបីជាមាន ឬមិនទាន់មានលិខិតអនុញ្ញាតពីស្ថាប័នណាផ្សេងក៏ដោយ ត្រូវមកចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់ផងដែរ។ រាល់ការបង់ពន្ធអាករផ្សេងៗពាក់ព័ន្ធនឹងការចុះបញ្ជី ការចេញលិខិតអនុញ្ញាត ជាកាតព្វកិច្ចរបស់សហគ្រាស ឬក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ និងរូបវន្តបុគ្គល ឬក្រុមជាងសំណង់ ស្របតាមការកំណត់នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[86]

ចំពោះលិខិតអនុញ្ញាតប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់មានសុពលភាពរយៈពេល ៣ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត។ សហគ្រាស និងក្រុមហ៊ុនដែលធ្វើអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ អាចដាក់ពាក្យស្នើសុំបន្តសុពលភាពនៃលិខិតប្រកបអាជីវកម្មរបស់ខ្លួនបាន ដោយគ្រាន់តែភ្ជាប់មកនូវលិខិតអនុញ្ញាតចាស់ និងបង្កាន់ដៃបង់ពន្ធអាករ ឬបណ្ណបប៉ាតង់ប្រចាំឆ្នាំចុងក្រោយ មកក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់។[87]

ទំរង់បែបបទនៃការសុំប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ ត្រូវមានលក្ខខណ្ឌដូចជា[88]៖

- ប្រធានសហគ្រាស និងក្រុមហ៊ុនត្រូវមកដាក់ពាក្យសុំដោយខ្លួនឯងផ្ទាល់
- នាយកបច្ចេកទេសនៃសហគ្រាស និងក្រុមហ៊ុនត្រូវមានសញ្ជាតិខ្មែរ
- សំណុំឯកសារដែលត្រូវបំពេញមាន៖
  - ✓ ពាក្យសុំប្រកបអាជីវកម្ម
  - ✓ ជីវប្រវត្តិសង្ខេបរបស់ប្រធានសហគ្រាស និងក្រុមហ៊ុន
  - ✓ ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនរបស់ប្រធានសហគ្រាស ឬក្រុមហ៊ុន
  - ✓ លិខិតបញ្ជាក់ទីលំនៅពីសាលាឃុំ សង្កាត់របស់ប្រធានសហគ្រាស ឬក្រុមហ៊ុន

[84] ប្រការ ៥ នៃប្រកាសលេខ៧៥ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់

[85] ប្រការ ៦ នៃប្រកាសលេខ៧៥ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់

[86] ប្រការ ៩ នៃប្រកាសលេខ៧៥ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់

[87] ប្រការ ១០ថ្មី នៃប្រកាសលេខ១៦៦ ស្តីពីការកែសម្រួលប្រការ៧ និងប្រការ១០ នៃប្រកាសលេខ៧៥ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់

[88] ប្រការ ៧ថ្មី នៃប្រកាសលេខ១៦៦ ស្តីពីការកែសម្រួលប្រការ៧ និងប្រការ១០ នៃប្រកាសលេខ៧៥ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់

- ✓ ជីវប្រវត្តិសង្ខេបរបស់នាយកបច្ចេកទេស
- ✓ លក្ខន្តិកៈរបស់សហគ្រាស ឬក្រុមហ៊ុន ដែលមានធ្វើនីត្យានុកូលកម្មនៅសាលាខេត្ត-ក្រុង
- ✓ កិច្ចសន្យាការងាររវាងសហគ្រាស និងក្រុមហ៊ុន និងសមត្ថកិច្ចចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ✓ កិច្ចសន្យាការងាររវាងសហគ្រាស ក្រុមហ៊ុន និងអ្នកបច្ចេកទេស ដែលជានាយកបច្ចេកទេស ឬជានាយកគម្រោង
- ✓ ច្បាប់ចម្លងសញ្ញាបត្ររបស់អ្នកបច្ចេកទេសដែលមានធ្វើនីត្យានុកូលកម្មនៅសាលាខេត្តក្រុង
- ✓ បញ្ជីរាយឈ្មោះអ្នកបច្ចេកទេស និងអង្គការលេខរបស់សហគ្រាស ឬក្រុមហ៊ុន
- ✓ បញ្ជីសម្ភារៈបរិក្ខាសិក្សាគម្រោងប្លង់ សម្រាប់សហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់
- ✓ បញ្ជីសម្ភារៈបរិក្ខាគ្រឿងចក្រសំណង់ សម្រាប់សហគ្រាស និងក្រុមហ៊ុនសាងសង់
- ✓ ឯកសារបញ្ជាក់ដើមទុនពីធនាគារ សម្រាប់សហគ្រាស និងក្រុមហ៊ុនចុះបញ្ជីលើកដំបូង
- ✓ បង្កាន់ដៃបង់ពន្ធអាករ ឬបណ្ណប៉ាតង់ សម្រាប់សហគ្រាស និងក្រុមហ៊ុនសុំបន្តសុពលភាព
- ✓ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម សម្រាប់សហគ្រាស និងក្រុមហ៊ុនចុះបញ្ជីលើកដំបូង
- ✓ ឯកសារស្នាដៃ សម្រាប់សហគ្រាស និងក្រុមហ៊ុនប្រភេទទី១ និងទី២។

សហគ្រាស និងក្រុមហ៊ុនដែលធ្វើអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ ត្រូវបានបែងចែកចេញជា៤ប្រភេទ ទៅតាមចំនួនបុគ្គលិក និងដើមទុន។[89] ក្នុងនោះប្រភេទទី៤ គឺជារូបវន្តបុគ្គល ចំពោះសហគ្រាស និងក្រុមហ៊ុនដែលធ្វើអាជីវកម្មសិក្សាគម្រោងប្លង់ និងជាក្រុមជាងសំណង់ ចំពោះសហគ្រាស និងក្រុមហ៊ុនដែលធ្វើអាជីវកម្មសាងសង់។ លើសពីនេះសហគ្រាស និងក្រុមហ៊ុនដែលធ្វើអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ អាចស្នើសុំតម្លើងឋានៈកំរិតរបស់ខ្លួនបាន នៅពេលដែលពួកគាត់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌដែលបានកំណត់តាមប្រភេទនីមួយៗ។

បន្ថែមពីលើប្រកាសស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់នេះ ក៏មានសារាចរណែនាំមួយផ្សេងទៀតលេខ ០០២ ដ.ន.ស/អ.ស.ណ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការចុះបញ្ជីប្រកបអាជីវកម្ម សិក្សាគម្រោងប្លង់ និងសាងសង់របស់សហគ្រាស ក្រុមហ៊ុន និងរូបវន្តបុគ្គលបរទេស ដែលបានចែងកំណត់អំពីទ្រង់ទ្រាយ ការចុះបញ្ជីប្រកបអាជីវកម្ម ប្រភេទសហគ្រាស ក្រុមហ៊ុន សិក្សាគម្រោងប្លង់និងសាងសង់ និងទំរង់បែបបទសុំប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់ផងដែរ។ សារាចរណែនាំនេះមានគោលបំណងបង្កើនការអនុវត្ត និងពង្រឹងទៅលើការចុះបញ្ជីរបស់ក្រុមហ៊ុន សហគ្រាស ដែលមានគោលដៅ

[89] មើលលំអិតអំពីប្រភេទនីមួយៗនៅក្នុងប្រការ២ និង៣ នៃប្រកាសលេខ៧៥ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធ១.

ប្រកបអាជីវកម្មក្នុងវិស័យសំណង់ និងកំណត់ឱ្យបានជាក់លាក់ពីលក្ខខណ្ឌតម្រូវនីមួយៗឱ្យមានភាពត្រឹមត្រូវតាមច្បាប់ ពិសេសគឺដើម្បីងាយស្រួលក្នុងការគ្រប់គ្រងទៅលើបុគ្គលទាំងនោះ។

### ២.១.៣. ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់

ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់នៅកម្ពុជាយើងនេះ គេបានធ្វើការបែងចែកទំនួលខុសត្រូវ ជា២ប្រភេទ គឺការទទួលខុសត្រូវរដ្ឋបាល និងការពិន័យអន្តរការណ៍។ ចំពោះការទទួលខុសត្រូវរដ្ឋបាលនេះ ច្បាប់បានកំណត់យ៉ាងជាក់លាក់អំពីទណ្ឌកម្មរដ្ឋបាលទៅលើបុគ្គលដែលបានប្រព្រឹត្តខុសទៅនឹងភារកិច្ចរបស់ខ្លួនដូចជា ការព្រមានជាលាយលក្ខណ៍អក្សរ ការដកហូតលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន ការព្យួរ ឬការដកវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់ ការបង្ខំឱ្យរុះរើ និងស្ដាបនាឡើងវិញឱ្យដូចស្ថានភាពដើមនូវអ្វីដែលបាត់បង់ ឬប្រែប្រួលនៃអំពើល្មើស និងចុងក្រោយគឺការហាមឃាត់មិនឱ្យប្រើប្រាស់អគារ ឬផ្អាកការធ្វើអាជីវកម្មលើអគារ។[90] ទណ្ឌកម្មរដ្ឋបាលខាងលើនេះបង្កើតឡើងដើម្បីឱ្យប្រជាពលរដ្ឋ អ្នកវិជ្ជាជីវៈ ឬក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ មានការយកចិត្តទុកដាក់ចំពោះការងារ និងកាតព្វកិច្ចរបស់ខ្លួននីមួយៗនៅក្នុងការងារសំណង់ ជាពិសេសគឺដើម្បីឱ្យពួកគាត់មានការទទួលខុសត្រូវខ្ពស់ និងកុំឱ្យមានការធ្វេសប្រហែស គេចវេសមិនទទួលខុសត្រូវនៅពេលដែលមានបញ្ហាកើតឡើង។

អ្វីដែលជាការគួរឱ្យកត់សម្គាល់ក្នុងការទទួលខុសត្រូវនៅក្នុងអនុក្រឹត្យលេខ៤២ នេះ គឺផ្ដោតសំខាន់ជាងគេទៅលើម្ចាស់សំណង់ ឬក្រុមហ៊ុនដែលប្រកបអាជីវកម្មសាងសង់ក្នុងវិស័យសំណង់។ ចំពោះម្ចាស់សំណង់ប្រសិនបើមានកំហុសធ្ងន់ធ្ងរក្នុងការមិនអនុវត្តតាមបទប្បញ្ញត្តិនៃអនុក្រឹត្យខាងលើនេះ នឹងត្រូវបានអាជ្ញាធរមានសមត្ថកិច្ចចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរ។[91] ម្យ៉ាងវិញទៀត ករណីដែលម្ចាស់សំណង់ សាងសង់សំណង់ គ្មានលិខិតអនុញ្ញាត ខុសលិខិតអនុញ្ញាត គ្មានលិខិតបើកការដ្ឋាននិងបិទការដ្ឋាន ឬប្រើប្រាស់លិខិតអនុញ្ញាតហួសសុពលភាព ឬបានធ្វើការផ្ទេរលិខិតអនុញ្ញាតសាងសង់ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនោះ នឹងត្រូវទទួលបានការពិន័យអន្តរការណ៍ និងអាចទទួលបន្ថែមពីលើការពិន័យនេះដូចជា មានការបង្ខំឱ្យរុះរើសំណង់ចេញទាំងស្រុង មានការដកហូតលិខិតអនុញ្ញាតសាងសង់ ការព្យួរ ឬការដកវិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់ ការបង្ខំឱ្យរុះរើ និងស្ដាបនាឡើងវិញឱ្យដូចស្ថានភាពដើមនូវអ្វីដែលបាត់បង់ ឬប្រែប្រួលនៃអំពើល្មើស និងការហាមឃាត់មិនឱ្យប្រើប្រាស់អគារ ឬផ្អាកការធ្វើអាជីវកម្មលើអគារ។[92] ដោយឡែកករណីដែលម្ចាស់សំណង់មិនព្រមបញ្ឈប់ការដ្ឋានសាងសង់តាមបញ្ជារបស់អាជ្ញាធរមានសមត្ថកិច្ច ឬរារាំងប្រកែកមិនព្រមឱ្យសមត្ថកិច្ចជំនាញចូលពិនិត្យការដ្ឋានសាងសង់ ឬប្រកែកមិនព្រមផ្ដល់ពត៌មាន បង្ហាញលិខិតដែលពាក់ព័ន្ធទៅដល់សមត្ថកិច្ចជំនាញក្នុងពេលចុះពិនិត្យការដ្ឋាន និងបានប្រើប្រាស់មធ្យោបាយណាមួយ ដើម្បីជា

[90] មាត្រា ៦៥ នៃអនុក្រឹត្យលេខ៤២ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

[91] មាត្រា ៦៨ នៃអនុក្រឹត្យលេខ៤២ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

[92] មាត្រា ៦៩,៧០,៧១,៧២,៧៣,៧៥ នៃអនុក្រឹត្យលេខ៤២ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

ឧបសគ្គដល់ការត្រួតពិនិត្យការដ្ឋានសំណង់របស់អង្គភាពជំនាញមានសមត្ថកិច្ច នឹងត្រូវពិន័យអន្តរការណ៍ជាប្រាក់ រួមទាំងអាចទទួលរងបន្ថែមនូវទណ្ឌកម្មមួយចំនួនដូចមានចែងក្នុងមាត្រា៧៤ថ្មីនៃអនុក្រឹត្យលេខ៨២ខាងលើ។[93]

ចំពោះក្រុមហ៊ុនសាងសង់ដែលធ្វើអាជីវកម្មម៉ៅការសំណង់ និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលធ្វើអាជីវកម្មសិក្សាគម្រោងប្លង់ បានប្រើប្រាស់វិញ្ញាបនបត្រប្រកបអាជីវកម្មផុតសុពលភាព នឹងត្រូវទទួលការពិន័យអន្តរការណ៍នៅតាមកម្រិតនីមួយៗនៃក្រុមហ៊ុនរបស់ខ្លួន។[94] ពិសេសប្រសិនបើការសាងសង់នោះនាំឱ្យមានការខូចខាត ប៉ះពាល់ដល់សោភ័ណភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងសុខដុមនីយកម្មនៃតំបន់ដូចជា៖

- ការដ្ឋានសាងសង់ ជួសជុល ឬរុះរើគ្មានរបងហ៊ុមព័ទ្ធ គ្មានសំណាញ់ការពារសុវត្ថិភាពបង្កសំឡេងរំខាន និងគ្មានប៉ាន់ណូសម្រាប់សំគាល់ការដ្ឋានសំណង់
- ការដ្ឋានសំណង់ពុំមានឧបករណ៍ការពារសុវត្ថិភាពគ្រប់គ្រាន់ដល់បុគ្គលិក អ្នកបច្ចេកទេសគ្រប់គ្រងការដ្ឋាន និងកម្មករ
- ការបំពុលបង្កឡើងពីការដ្ឋានសំណង់ ជួសជុល ឬរុះរើ និងការបំពុលបណ្តាលមកពីការធ្វេសប្រហែសធ្វើឱ្យធ្លុះធ្លាយឃ្លាំងស្តុកឧទង្គារនិងអាងប្រេងឥន្ទនៈ
- ការដ្ឋានសាងសង់ដែលប្រើគ្រឿងចក្រ បរិក្ខារលើកស្ទូច ហើយធ្វើឱ្យប៉ះពាល់ដល់ការធ្វើដំណើរលើផ្លូវសាធារណៈ ឬមិនបានបំពាក់ភ្លើងសញ្ញាសំគាល់នៅពេលយប់
- ការបង្ហូរទឹកបេតុងពីរថយន្តបូមបេតុង និងទឹកស៊ីម៉ងត៍ដែលបានបង្ហូរចេញពីការដ្ឋានសាងសង់លើចិញ្ចើមផ្លូវថ្នល់ លូសាធារណៈ និងទីតាំងសាធារណៈ
- ការដ្ឋានសាងសង់ដែលដែលគ្មានអ្នកបច្ចេកទេស ឬវិស្វករ ឬស្ថាបត្យករ ជាអ្នកគ្រប់គ្រងទទួលខុសត្រូវ
- ការខកខានមិនបានរុះរើ សំអាតនិងអនុវត្តតាមសេចក្តីជូនដំណឹងរបស់អាជ្ញាធរមានសមត្ថកិច្ច

នាំឱ្យក្រុមហ៊ុនសាងសង់នោះ អាចទទួលរងនូវការព្យួរ ឬដកវិញ្ញាបនបត្រប្រកបអាជីកម្មសាងសង់។[95]

ដោយឡែកចំពោះមន្ត្រីមានសមត្ថកិច្ចដែលប្រកែកមិនព្រមទទួលពិនិត្យលើសំណុំលិខិតស្នើសុំការអនុញ្ញាតសាងសង់ ជួសជុល រុះរើ ឬប្រឆាំងនឹងការចេញលិខិតអនុញ្ញាតសាងសង់ដោយគ្មានមូលហេតុត្រឹមត្រូវ និងចំពោះមន្ត្រីជំនាញនគរូបនីយកម្មនិងសំណង់ ឬមន្ត្រីដែលមានភារកិច្ចចុះត្រួតពិនិត្យការដ្ឋានសំណង់ ដែលពុំបានជំទាស់ទៅលើការអភិវឌ្ឍអចលនវត្ថុដែលមិនស្របទៅនឹងលិខិតអនុញ្ញាតសាងសង់ ត្រូវទទួលទណ្ឌកម្ម

[93] មាត្រា ៧៤ថ្មី នៃអនុក្រឹត្យលេខ៧៦ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ៨២ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

[94] មាត្រា ៧៦ និងមាត្រា ៧៨ នៃអនុក្រឹត្យលេខ៨២ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

[95] មាត្រា ៧៧ នៃអនុក្រឹត្យលេខ៨២ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

ខាងវិស័យរដ្ឋបាល ឬទណ្ឌកម្មព្រហ្មទណ្ឌប្រសិនបើមាន។ លើសពីនេះករណីដែលមន្ត្រីជំនាញណាដែលចុះត្រួតពិនិត្យការដ្ឋានសាងសង់ ជួសជុល ឬរុះរើ គ្មានលិខិតបេសកកម្ម ត្រូវទទួលទណ្ឌកម្មរដ្ឋបាល[96]។

ទំនួលខុសត្រូវទី២ គឺការទទួលពិន័យអន្តរការណ៍របស់ម្ចាស់សំណង់ ឬក្រុមហ៊ុនប្រកបអាជីវកម្មសាងសង់ដែលបានប្រព្រឹត្តបទល្មើសក្នុងវិស័យសំណង់។ ការពិន័យអន្តរការណ៍នេះ គឺគ្រាន់តែជាការពិន័យជាប្រាក់ប៉ុណ្ណោះ ហើយរាល់ការពិន័យនីមួយៗមានកំណត់យ៉ាងច្បាស់នៅក្នុងអនុក្រឹត្យលេខ៨២ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន។

## ២.២. ការគ្រប់គ្រងសំណង់ក្រោយច្បាប់ចូលជាធរមាន

### ២.២.១. ការគ្រប់គ្រងទូទៅ

#### ២.២.១.១. លិខិតអនុញ្ញាតសាងសង់ ជួលជុល ឬរុះរើ

ក្រោយច្បាប់សំណង់បានចូលជាធរមានកាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ នេះមក មានបទប្បញ្ញត្តិមួយចំនួនបានបំពេញបន្ថែមទៅអនុក្រឹត្យលេខ៨៦ អនក្រ.ប្រក ស្តីពីលិខិតអនុញ្ញាតសាងសង់។ បទប្បញ្ញត្តិទាំងនោះបានចែងអំពីកាលៈទេសៈខ្លះៗចំពោះការសាងសង់ ឬរុះរើសំណង់ ដែលពុំចាំបាច់ត្រូវមានលិខិតអនុញ្ញាតសាងសង់ជាមុន ពិសេសក៏បានចែងបន្ថែមអំពីប្រភេទសំណង់មួយចំនួនផ្សេងទៀតដែលពុំតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ឡើយ។

ជាទូទៅរាល់ការងារសាងសង់ឬរុះរើត្រូវមានការអនុញ្ញាតជាមុនដោយអាជ្ញាធរមានសមត្ថកិច្ច។[97] ប៉ុន្តែជាក់ស្តែងដូចជា ការងារសាងសង់ ឬរុះរើ ក្នុងស្ថានភាពអាសន្ន ឬគ្រោះមហន្តរាយណាមួយដែលមិនអាចព្យាករណ៍បាន ដើម្បីជួយសង្គ្រោះ ឬការពារអាយុជីវិត ឬបង្ការ មិនឱ្យមានផលប៉ះពាល់ ឬខូចធ្ងន់ធ្ងរដល់សុខភាព ឬទ្រព្យសម្បត្តិ ក្នុងកាលៈទេសៈបែបនោះ គឺមិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនឡើយ។ លើសពីនេះ ក្នុងរយៈពេល៣០ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលត្រូវបានសាងសង់សំណង់ក្នុងស្ថានភាពអាសន្នខាងលើនេះត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់តាមលក្ខខណ្ឌ និងនីតិវិធីដែលបានកំណត់។ រីឯចំពោះការរុះរើសំណង់នៅក្នុងស្ថានភាពខាងលើនេះវិញ ក្នុងរយៈពេល៣០ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់ដូចគ្នាដែរ ម្ចាស់សំណង់ដែលត្រូវបានរុះរើសំណង់ ត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមានសមត្ថកិច្ចអំពីការរុះរើនេះ។[98]

ដោយឡែក ចំពោះការងារសាងសង់ ឬរុះរើសំណង់ដែលមានទំហំតូចដែលជាប្រភេទសំណង់លំនៅឋានធ្វើពីឈើ ផ្ទះថ្មក្រោមឈើលើ ផ្ទះគៀមធ្វើពីឈើឬថ្មនៅទីជនបទ ឬស្រែចម្ការ ដែលមិនប៉ះពាល់ដល់រមណីយ

---

[96] មាត្រា ៨០ នៃអនុក្រឹត្យលេខ៨២ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

[97] មាត្រា ២៦ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[98] មាត្រា ២៧ នៃច្បាប់ស្តីពីសំណង់ និងប្រកាសលេខ១៧៧ ដនស/ប្រក ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន

ដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាពសាធារណៈ គឺមិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ទេ ពិសេសគឺប្រភេទសំណង់ដែលបម្រើដល់សន្តិសុខជាតិ និងការពារជាតិ ដូចជា បន្ទាយទាហាន ឬឃ្លាំងដាក់អាវុធយុទ្ធភណ្ឌជាដើម។[99]

ម្យ៉ាងវិញទៀត ការជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់ដែលមានកំណត់ក្នុងអនុក្រឹត្យមិនតម្រូវឱ្យមានការអនុញ្ញាតឡើយ ក្នុងករណីដែលការងារនោះមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រទម្ងន់ សោភ័ណភាពខាងក្រៅ ឬមុខងារប្រើប្រាស់ទាំងមូល ឬផ្នែកណាមួយនៃសំណង់ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ហើយចំពោះករណីនេះដែរ ម្ចាស់សំណង់គ្រាន់តែជូនដំណឹងជាមុនទៅអាជ្ញាធរមានសមត្ថកិច្ចជាការស្រេច[100]។

### ២.២.១.២. ការគ្រប់គ្រងគម្រោងប្លង់

ស្របតាមច្បាប់សំណង់របស់ប្រទេសកម្ពុជាដែលទើបចូលជាធរមានថ្មីៗនេះ គេបានបែងចែកទៅលើការគ្រប់គ្រងគម្រោងប្លង់ដោយ គ្រប់គ្រងទៅលើអ្នកសិក្សាគម្រោងប្លង់ កំណត់អំពីបទប្បញ្ញត្តិបច្ចេកទេស កម្មសិទ្ធិបញ្ញា និងការអនុវត្តគម្រោងប្លង់។ រាល់គម្រោងប្លង់ដែលបានសិក្សារួច ហើយសម្រាប់ដាក់ប្រើប្រាស់ក្នុងការងារសាងសង់ ឬរុះរើ អ្នកសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណ ត្រូវមានការចុះហត្ថលេខាទទួលខុសត្រូវនៅលើប្លង់នោះ ឬមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃគម្រោងប្លង់ដែលសាងសង់។[101]

ចំពោះបទប្បញ្ញត្តិបច្ចេកទេសគ្រប់យ៉ាងដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងបទដ្ឋានគតិយុត្តដទៃទៀត រាល់គម្រោងប្លង់ទាំងអស់ ត្រូវអនុលោមតាមបទប្បញ្ញត្តិដែលបានចែងរួច មានន័យថាត្រូវមានអ្នកត្រួតពិនិត្យ និងបញ្ជាក់អំពីអនុលោមភាពនោះ។ គម្រោងប្លង់ធំៗពីរហើយដែលកំពុងអនុវត្តសព្វថ្ងៃ គឺគម្រោងប្លង់ស្ថាបត្យកម្មសម្រាប់ស្នើសុំលិខិតអនុញ្ញាតសាងសង់ និងគម្រោងប្លង់គ្រឿងផ្គុំសំណង់ ដែលជាឯកសារសម្រាប់ជាមូលដ្ឋានក្នុងការសម្រេចឱ្យបើកការដ្ឋានសំណង់។ លើសពីនេះតាមរយៈមាត្រា ៣៣ នៃច្បាប់ស្តីពីសំណង់ នៅក្នុងគម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើសំណង់គ្រប់ប្រភេទ ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាសម្រាប់ជនមានពិការភាពដោយត្រូវមានផ្លូវ ឬជម្រាលសម្រាប់ផ្លាស់ទីឧបករណ៍ធ្លាក់ដៃ ជណ្តើរយន្ត បន្ទប់អនាម័យ ចំណតយានយន្តពិសេសសម្រាប់ជនពិការ និងផ្លាកសញ្ញានានា លើកលែងតែសំណង់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ពុំចាំបាច់ត្រូវរៀបចំបែបនេះឡើយ។

ចំពោះការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតម្ចាស់សំណង់ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។ ដោយឡែក

[99] មាត្រា ២៨ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[100] មាត្រា ២៩ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[101] មាត្រា ៣២ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

មុនការអនុវត្តការងារសាងសង់ឬរុះរើ ចំពោះគម្រោងប្លង់ដែលម្ចាស់សំណង់ចង់ស្នើសុំកែសម្រួល អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យកែសម្រួលគម្រោងប្លង់នោះបាន ទោះបីធ្លាប់បានទទួលការយល់ព្រមមុនការស្នើសុំរួចមកហើយក៏ដោយ។ ការអនុញ្ញាតកែសម្រួលគម្រោងប្លង់នោះ ត្រូវធ្វើឡើងតាមរយៈលិខិតអនុញ្ញាតកែសម្រួលគម្រោងប្លង់ និងត្រូវបំពេញតាមលក្ខខណ្ឌនិងនីតិវិធីនៃការអនុញ្ញាតកែសម្រួលគម្រោងប្លង់ដែលបានកំណត់ដោយអនុក្រឹត្យ។

ម្យ៉ាងវិញទៀតគម្រោងប្លង់មួយមិនអាចយកទៅអនុវត្តនៅទីតាំងផ្សេងបានឡើយ ករណីដែលគ្មានការអនុញ្ញាតពីអ្នកសិក្សាដែលបានចុះហត្ថលេខាលើគម្រោងប្លង់នោះ មានន័យថាគម្រោងប្លង់មួយដែលអ្នកសិក្សាបានចុះហត្ថលេខារួចហើយ ដែលជាស្នាដៃរបស់គាត់បានគូរនោះ ត្រូវបានការពារដោយពុំអាចយកគម្រោងប្លង់ដែលគាត់បានធ្វើនោះទៅកូពី ឬ ចម្លងដើម្បីទៅសាងសង់សំណង់ផ្សេងទៅទីតាំងផ្សេងបានឡើយ គឺចាំបាច់ត្រូវមានការយល់ព្រមពីអ្នកសិក្សាគម្រោងប្លង់ជាមុនសិន។ ចំពោះគម្រោងប្លង់ដែលមានតម្លៃពិសេសផ្នែកស្ថាបត្យកម្មវិញ គឺជាកម្មសិទ្ធិរបស់រដ្ឋ ដូចនេះរាល់ការចង់កូពី ឬចម្លង ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។

### ២.២.១.៣. ការគ្រប់គ្រងការងារសាងសង់ឬរុះរើ

ក្រឡេកមកមើលការគ្រប់គ្រងការងារសាងសង់ឬរុះរើវិញ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចែងអំពីការគ្រប់គ្រងនេះនៅក្នុងច្បាប់ស្តីពីសំណង់ ក្នុងជំពូកទី១០ ដែលមានចំនួន ៨ មាត្រា ដោយបានកំណត់យ៉ាងច្បាស់អំពីអ្នកណាជាអ្នកសាងសង់ ឬរុះរើ អ្នកណាដែលច្បាប់បានអនុញ្ញាតឱ្យសាងសង់។ ក្រៅពីនោះក៏មានចែងអំពីកាតព្វកិច្ចរបស់ម្ចាស់សំណង់នៅក្នុងដំណើរការនេះដែរ ដើម្បីរួមចំណែកក្នុងការទទួលខុសត្រូវទៅលើសំណង់របស់ខ្លួន។ ម្យ៉ាងវិញទៀតក៏មានចែងអំពីបទប្បញ្ញត្តិដែលត្រូវអនុវត្តដូចការសិក្សាគម្រោងប្លង់ដែរ ហើយនឹងចែងអំពីលិខិតបើកការដ្ឋានសំណង់ ការគ្រប់គ្រងការដ្ឋានសំណង់ ប្រព័ន្ធត្រួតពិនិត្យនិងបញ្ជាក់សំណង់ អាជ្ញាធរមានសមត្ថកិច្ចដែលជាអ្នកអនុញ្ញាតនៅក្នុងការសាងសង់ និងពិសេសបទប្បញ្ញត្តិដែលត្រូវអនុវត្ត។

ចំពោះអ្នកសាងសង់យើងកំណត់ថា អ្នកដែលសាងសង់ឬរុះរើបាន ត្រូវមានអាជ្ញាបណ្ណដែលជាគោលការណ៍ទីមួយ។[102] អ្នកសាងសង់ ឬអ្នកអនុវត្តការងារសំណង់(មិនមែនម្ចាស់សំណង់)ត្រូវមានអាជ្ញាបណ្ណ ដូចនេះអ្នកដែលសាងសង់បានមាន ៤ប្រភេទ គឺទី១ អ្នកវិជ្ជាជីវៈ ទី២គឺក្រុមហ៊ុន បន្ទាប់មកគឺ ជាងជំនាញ និងទី៤គឺក្រុមជាង។ អ្នកទាំងអស់នេះបើមិនមានអាជ្ញាបណ្ណ ក៏ត្រូវមានលិខិតអនុញ្ញាតដូចក្រុមជាងដែរ ប៉ុន្តែអនុក្រឹត្យមិនមានកំណត់លំអិតថាអ្នកណាមានសិទ្ធិធ្វើអ្វីហើយត្រឹមកម្រិតមណាឡើយ។ ករណីក្រុមហ៊ុនសាងសង់ គាត់ត្រូវមានសមត្ថកិច្ចអនុវត្តការងារសាងសង់គ្រប់ប្រភេទ ដែលជាការងារសាងសង់ទូទៅ ហើយវាមានទៅតាមប្រភេទ

[102] មាត្រា ៣៦ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

នៃក្រុមហ៊ុន នោះសំណង់ក៏ទៅតាមទំហំនៃសំណង់ដែរ។ ប៉ុន្តែបើអ្នកសាងសង់ជារូបវន្តបុគ្គលដែលទទួលការងារសាងសង់តែម្នាក់ឯងនោះ រូបវន្តបុគ្គលនោះមិនអាចអនុញ្ញាតឱ្យគាត់សាងសង់ទូទៅទាំងអស់បានទេ គឺក្រសួងឱ្យអាជ្ញាបណ្ណទៅតាមតែជំនាញរបស់គាត់ដោយផ្នែកប៉ុណ្ណោះ ដូចនេះប្រភេទនៃអាជ្ញាបណ្ណប្រែប្រួលទៅតាមនោះលើកលែងតែក្រុមជាងដែលគាត់ត្រូវអនុវត្តក្រោមការគ្រប់គ្រងរបស់អ្នកវិជ្ជាជីវៈសំណង់។ ដូចនេះការដ្ឋានណាដែលគ្មានអ្នកវិជ្ជាជីវៈសំណង់(វិស្វករ) ប្រចាំការដ្ឋាននៅមើល នាំឱ្យការដ្ឋាននោះជាការដ្ឋានខុសច្បាប់ ដែលជាហេតុនាំឱ្យមានការបិទការដ្ឋាន និងការពិន័យ។

ចំពោះម្ចាស់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាត ត្រូវផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ ឬរុះរើសំណង់ មានន័យថាបើយើងសាងសង់អ្វីមួយត្រូវរាយការណ៍មកអាជ្ញាធរមានសមត្ថកិច្ចតាមលំដាប់ថ្នាក់ចាប់ពីការងារចាប់ផ្តើមសាងសង់រហូតដល់បញ្ចប់ការងារសាងសង់ ហើយអាជ្ញាធរមានសមត្ថកិច្ចនឹងចេញប្រកាសកំណត់អំពីទម្រង់បែបបទ និងខ្លឹមសារដែលត្រូវរាយការណ៍នោះ ករណីនេះអ្នកសាងសង់ក៏មានកាតព្វកិច្ចបំពេញដោយភ្ជាប់ជាមួយនឹងហត្ថលេខារវាងខ្លួន និងម្ចាស់សំណង់ផងដែរ។[103]

ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ បុគ្គលដែលពាក់ព័ន្ធការងារសាងសង់រាប់បញ្ចូលទាំងអ្នកអភិវឌ្ឍអចលនវត្ថុ អ្នកសាងសង់ និងអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវផ្តល់កិច្ចសហការដល់មន្ត្រីត្រួតពិនិត្យសំណង់មានន័យថានៅពេលដែលរដ្ឋបញ្ជូនមន្ត្រីទៅត្រួតពិនិត្យសំណង់ ម្ចាស់សំណង់ ឬអ្នកតំណាង ត្រូវមានវត្តមាននៅទីតាំងការដ្ឋាននោះ។[104]

អាជ្ញាធរមានសមត្ថកិច្ចអាចសម្រេចផ្អាក កែតម្រូវ បញ្ឈប់ តម្រូវឱ្យរុះរើ ឬចាត់វិធានការចាំបាច់ផ្សេងទៀតក្នុងករណី រកឃើញថាការងារសាងសង់ឬរុះរើមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន ដទៃទៀត ក្នុងន័យនេះសំដៅទៅលើ អាជ្ញាធរមានសមត្ថកិច្ចអាចចេញលិខិតសម្រេចឱ្យរុះរើ ឬផ្អាកការដ្ឋានបាន ករណីបើរកឃើញថាសំណង់ដែលសាងសង់នោះគ្មានសុវត្ថិភាព ឬអាចនាំឱ្យមានគ្រោះថ្នាក់ ដែលជាហេតុពុំអាចឱ្យធ្វើការសាងសង់បន្តទៀតបាន។[105]

នៅក្នុងការងារគ្រប់គ្រងការដ្ឋាន អ្នកសាងសង់ទាំងអស់ត្រូវធានាអំពី សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាននៅក្នុងការដ្ឋានសំណង់របស់ខ្លួនឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ ជៀសវាងកុំឱ្យមានគ្រោះថ្នាក់កើតឡើង។[106] ម្យ៉ាងវិញទៀតនៅពេលដែលចាប់ផ្តើមដំណើរការសាងសង់ឬ រុះរើសំណង់ ម្ចាស់សំណង់ត្រូវមានលិខិតអនុញ្ញាតសាងសង់ជាមុនសិន បន្ទាប់មកគឺត្រូវមានលិខិតបើកការដ្ឋានមួយទៀត ដើម្បីអាចដំណើរការក្នុងការដ្ឋានបាន និងត្រូវមានការត្រួតពិនិត្យពីក្រុមអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលមាន

---

[103] មាត្រា ៤០ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[104] មាត្រា ៤២ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[105] កថាខណ្ឌទី៣ នៃមាត្រា ៤២ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[106] មាត្រា ៣៩ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

អាជ្ញាបណ្ណដែលសម្រេចដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[107] លើសពីនេះ ចំពោះការល្មើសទៅនឹងបទប្បញ្ញត្តិទាំងអស់ដែលបានចែង សុទ្ធតែត្រូវមានការទទួលខុសត្រូវតាមស្មារតី នៃច្បាប់ស្តីពីសំណង់។

### ២.២.១.៤. ការប្រើប្រាស់សំណង់

ជាមួយនឹងការរីកចម្រើនកាន់តែខ្លាំងនៃសំណង់នៅកម្ពុជាសព្វថ្ងៃនេះ តម្រូវការនៃភាពស្របច្បាប់នៃសំណង់ ពិតជាមានភាពចាំបាច់ក្នុងការគ្រប់គ្រងគុណភាព សុវត្ថិភាព និងសោភ័ណភាពនៃសំណង់។ ក្នុងនោះផងដែរ វិញ្ញាបនបត្រប្រើប្រាស់សំណង់ គឺជាឯកសារគតិយុត្តដ៏សំខាន់មួយក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិទៅតាមច្បាប់។ វាគឺជាឯកសារដែលចេញដោយអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានចេញប្រកាសលេខ ១៧៧ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ ២០១៩ ទាក់ទងនឹងបែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ សម្រាប់សំណង់ណាដែលបានសាងសង់រួចមុនច្បាប់សំណង់ចូលជាធរមាន។ គោលបំណងនៃប្រកាសលេខនេះ គឺដើម្បីធានាបាននូវគុណភាពរួមមាន សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព និងបរិយាកាសល្អ ដោយផ្អែកតាមទស្សនាទានរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់ និងសាធារណៈជន។ ប្រកាសនេះ ក៏មានគោលបំណងបង្ការការសាងសង់សំណង់ដែលមិនគោរពតាមបទដ្ឋានគុណភាព និងសុវត្ថិភាពដែលបានកំណត់ផងដែរ។

បន្ថែមពីលើនេះ ប្រកាសលេខ១៧៧នេះ បានចែងពីបែបបទ និងនីតិវិធីនៃការចេញ ការផ្អាក និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សម្រាប់សំណង់ណាដែលបានសាងសង់រួចហើយមុនពេលចូលជាធរមាននៃច្បាប់ស្តីពីសំណង់ដែលមានអនុម័តកាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ សំណង់ដែលត្រូវបានអនុម័តតាមសេចក្តីប្រកាសនេះ រួមមាន សំណង់ដែលគ្មានការអនុញ្ញាត សំណង់មិនស្របតាមការអនុញ្ញាត និងសំណង់ដែលសាងសង់មានលិខិតអនុញ្ញាតតែខ្វះវិញ្ញាបនបត្រអនុលោមភាព ឬលិខិតអនុញ្ញាតឱ្យសាងសង់។ ក្នុងរយៈពេល២ឆ្នាំក្រោយច្បាប់សំណង់ច្បាប់ស្តីពីសំណង់ចូលជាធរមាន ម្ចាស់សំណង់ដែលត្រូវការលិខិតអនុញ្ញាត ត្រូវតែដាក់ពាក្យសុំវិញ្ញាបនត្រប្រើប្រាស់សំណង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅថ្នាក់ជាតិ ខេត្ត ស្រុក ឬ ខណ្ឌ។ វិញ្ញាបនបត្រប្រើប្រាស់សំណង់ជាភស្តុតាងនៃការបញ្ចប់ការសាងសង់អគារតាមផែនការដែលបានយល់ព្រម និងបញ្ជាក់ពីអនុលោមភាពស្របទៅតាមច្បាប់ក្នុងស្រុក។ ការទទួលបានវិញ្ញាបនបត្រប្រើប្រាស់ គឺជាតម្រូវការចាំបាច់មួយដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្បិតថាអ្នកទិញនឹងមិនអាចប្រើប្រាស់សំណង់ដោយស្របទៅតាមច្បាប់បានទេ ប្រសិនណាបើអ្នកអភិវឌ្ឍឬម្ចាស់សំណង់មិនមានវិញ្ញាបនបត្រប្រើប្រាស់សំណង់ជាមុនសិន។

នេះជាការអនុវត្តប្រព័ន្ធចាស់ដែលប្រើប្រាស់ឈ្មោះថ្មី ដោយធ្វើការកែប្រែពីលិខិតបិទការដ្ឋាន ទៅជា

[107] មាត្រា ៣៨ និងមាត្រា៤១ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដោយចាប់ផ្ដើមអនុវត្តចំពោះសំណង់ចាស់មុនៗ ហើយចំពោះសំណង់ថ្មីក្រោយច្បាប់ស្តីពីសំណង់ចូលជាធរមាន ក្រសួងនឹងរៀបចំធ្វើសេចក្ដីព្រាងអនុក្រឹត្យថ្មីមួយស្ដីពីការគ្រប់គ្រងការប្រើប្រាស់សំណង់ទាំងនោះ។ ម្ចាស់សំណង់ដែលបានសាងសង់ហើយ ត្រូវធ្វើលិខិតស្នើសុំមកអាជ្ញាធរមានសមត្ថកិច្ចដើម្បីសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់មុនពេលប្រើប្រាស់សំណង់ ប៉ុន្តែជាមូលដ្ឋាននៃការសម្រេចចិត្តច្បាប់នេះតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់លើដំណើរការសាងសង់ពីដើមរហូតដល់ចប់ជាមុនសិន។

ចំពោះសំណង់ដែលគេបើកឱ្យសាធារណៈជនប្រើប្រាស់ដូចជា៖ ផ្សារ សណ្ឋាគារ ឬភោជនីយដ្ឋានជាដើម ករណីមិនមានវិញ្ញាបនបត្រប្រើប្រាស់សំណង់ គឺមិនឱ្យប្រកបអាជីវកម្មទេ។ ដូចនេះអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតក្រៅពីផ្នែកសំណង់នេះមានដូចជា៖ ខាងក្រសួងទេសចរណ៍ ឬខាងក្រសួងពាណិជ្ជកម្ម ក៏ឋិតនៅក្រោមច្បាប់នេះដែរ មានន័យថា ប្រសិនបើអាជ្ញាធររបស់ក្រសួងណាមួយចង់អនុញ្ញាតឱ្យគេប្រកបបើកដំណើរការសំណង់ឬអាជីវកម្មណាមួយ ត្រូវសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការពិនិត្យអំពីវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ឧទាហរណ៍ដូចជារឿងដែលកើតឡើងនៅខេត្តព្រះសីហនុ គឺនៅពេលដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានពិនិត្យឃើញថាសំណង់មួយចំនួនដូចជា សណ្ឋាគារ កាស៊ីណូដែលជាសំណង់សាងសង់ដោយមិនអនុលោមច្បាប់ និងមិនមានវិញ្ញាបនបត្រប្រើប្រាស់សំណង់ ក្រសួងបានស្នើសុំឱ្យក្រសួងទេសចរណ៍ ដកអាជ្ញាបណ្ណទេសចរណ៍ពីសំណង់ទាំងពីរប្រភេទនេះ ។ ក្រសួងធ្វើបែបនេះ គឺដើម្បីចូលរួមក្នុងការពង្រឹងការអនុវត្តច្បាប់ផងដែរ។

ចំនុចចុងក្រោយ គឺពាក់ព័ន្ធអ្នកប្រើប្រាស់ និងអ្នកដាក់ឱ្យគេប្រើប្រាស់សំណង់ យោងតាមមាត្រា១០២ នៃច្បាប់ស្តីពីសំណង់ អ្នកប្រើប្រាស់ ឬដាក់ឱ្យប្រើប្រាស់សំណង់ដោយគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ នឹងត្រូវពិន័យអន្តរការណ៍។ ជាក់ស្តែង ចំពោះអ្នកដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់ក្នុងគោលដៅអាជីវកម្មនូវសំណង់ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំ ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ ៤០ ០០០ ០០០(សែសិបលាន)រៀល។ ក្នុងន័យនេះ ប្រសិនបើដាក់ឱ្យគេប្រើទៅមានរឿងកើតឡើងដូចជា ករណីរលំអគារ ដែលនាំឱ្យមានរបួស ឬខូចសុខភាព អាចជាប់ពន្ធធនាគារពី១ឆ្នាំ ទៅ៣ឆ្នាំ។ តែបើករណីដាក់ឱ្យគេប្រើប្រាស់សំណង់ហើយអត់មានរឿងបាក់រលំកើតឡើងទេ ប៉ុន្តែសំណង់នោះបែរជាមិនមានវិញ្ញាបនបត្រប្រើប្រាស់សំណង់ទៅវិញ នាំឱ្យមានការពិន័យអន្តរការណ៍តាមច្បាប់ស្តីពីសំណង់។[108]

ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក៏បានចេញជាសេចក្ដីណែនាំលេខ០០២ ដនស/សណន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ ស្តីអំពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់ផងដែរ។ ការត្រួតពិនិត្យនិងបញ្ជាក់គុណភាពសំណង់បានអនុវត្តទៅតាមគោលការណ៍ និងវិធានការដូចជា ត្រូវពិនិត្យថាសំណង់មាន

[108] មាត្រា ១០២ ច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ លិខិតបើកការដ្ឋានសំណង់ ការរៀបចំការដ្ឋាន ដំណើរការការដ្ឋានសំណង់ និងការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់។[109] ចំពោះការងារត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់នេះ ក្រសួងត្រូវចេញសេចក្តីសម្រេចស្តីពីការចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់មួយទៀត ដើម្បីទៅលើការងារនេះ។[110] ការត្រួតពិនិត្យនេះត្រូវធ្វើឡើងរៀងរាល់ ៥ឆ្នាំម្តង និងចំពោះសំណង់លំនៅឋាន យ៉ាងយូរ ១០ឆ្នាំម្តង។[111]

រីឯការត្រួតពិនិត្យ និងការចេញសេចក្តីបញ្ជាក់អំពីគុណភាពសំណង់ ប្រសិទ្ធិភាពនៃប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យនៃសំណង់ យ៉ាងយូរ ២ឆ្នាំម្តង តាមគោលការណ៍ច្បាប់ស្តីពីការបង្ការ និងពន្លត់អគ្គិភ័យ និងតាមសំណើរបស់ក្រសួងមហាផ្ទៃ។ ចំពោះបរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់ (គ្រឿងភ្លើង ជណ្តើរយន្ត.... ) យ៉ាងយូរ ១ឆ្នាំ ត្រូវត្រួតពិនិត្យម្តង ដោយមានចេញវិញ្ញាបនបត្រមួយទុកឱ្យម្ចាស់សំណង់សម្រាប់ទុកបង្ហាញដល់អាជ្ញាធរមានសមត្ថកិច្ចដែលចុះត្រួតពិនិត្យលើកក្រោយទៀត។[112] តើត្រូវត្រួតពិនិត្យដើម្បីអ្វី? ជាធម្មតាសំណង់ដែលកំពុងប្រើប្រាស់ គឺមានវិញ្ញាបនបត្រប្រើប្រាស់សំណង់ហើយ ប៉ុន្តែករណីបើវិញ្ញាបនបត្រនោះត្រូវបានព្យួរ ឬដកហូតមកវិញនោះ មានន័យថាលែងប្រើប្រាស់បានទៀតហើយ។ ប្រសិនបើការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ ទទួលបានលទ្ធផលអវិជ្ជមាន មិនអាចប្រើប្រាស់បន្តទៀតបាន ដូចនេះក្រសួងត្រូវធ្វើការដកហូត ឬព្យួរ។ ប៉ុន្តែករណីបើម្ចាស់សំណង់បានធ្វើការកែសម្រួល ឬកែតម្រូវឱ្យមានការប្រសើរឡើងវិញ ហើយធានាគុណភាពមកវិញនោះ ក្រសួងនឹងចេញឱ្យនូវវិញ្ញាបនបត្រថ្មីមួយវិញដើម្បីប្រើប្រាស់ក្នុងករណីបានផ្អាក ឬដកហូត។ ចំពោះការព្យួរវិញ ក្រសួងនឹងប្រគល់វិញ្ញាបនបត្រចាស់ទៅវិញ ករណីម្ចាស់សំណង់បានធ្វើតាមការណែនាំរបស់ក្រុមចុះត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់។ អ្នកត្រួតពិនិត្យ និងបញ្ជាក់ ជាអ្នកផ្តល់លទ្ធផលនៃការត្រួតពិនិត្យអនុលោមភាពនៃការងារសាងសង់នេះ។

### ២.២.១.៥. អធិការកិច្ចសំណង់

យន្តការនៃការត្រួតពិនិត្យសំណង់ដែលរៀបចំដោយច្បាប់ស្តីពីសំណង់មាន ៣ គឺ៖ ទី១ ការត្រួតពិនិត្យបទល្មើស មានន័យថាសំណង់កំពុងសាងសង់ ឬក៏សំណង់ដែលសាងសង់ហើយ ត្រូវធ្វើទៅតាមក្បួនខ្នាត និងទៅតាមបទប្បញ្ញត្តិបច្ចេកទេស និងតាមច្បាប់ទម្លាប់។ ប្រសិនបើខុសចាត់ទុកថាវាមានមានបទល្មើសសំណង់កើតឡើង។ ដូចនេះ មន្ត្រីអធិការកិច្ចសំណង់មានតួនាទីក្នុងការបំពេញកិច្ចការងារទាំងនេះ។

មន្ត្រីអធិការកិច្ចសំណង់ ជាមន្ត្រីនគរបាលយុត្តិធម៌ដែលជួយដល់តុលាការនៅក្នុងការចាត់ចែងបទល្មើសសំណង់ដែលស្រាលជាងគេ និងមានសិទ្ធិក្នុងការដាក់ពិន័យអន្តរការណ៍ទៅលើបទល្មើសសំណង់ដែល

[109] សេចក្តីណែនាំលេខ០០២ ដនសស/សណន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ ស្តីអំពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់

[110] សេចក្តីសម្រេចលេខ០០៥ សសរ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០ ស្តីអំពីការចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់

[111] មាត្រា ៨៧ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[112] មាត្រា ៨៧ ច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

ទាំងនោះ។[113] មន្ត្រីអធិការកិច្ចសំណង់ទាំងអស់នៅពេលចុះបំពេញ ការងាររបស់ខ្លួននៅការដ្ឋានសំណង់ ត្រូវស្លៀកពាក់ឯកសណ្ឋាន មានសញ្ញាសម្គាល់ រួមទាំងត្រូវមានលិខិតបេសកកម្ម និងត្រូវអនុវត្តតាមក្រឹត្យក្រមនៃក្រមនីតិវិធីព្រហ្មទណ្ឌ។[114]

មន្ត្រីអធិការកិច្ចសំណង់មានសិទ្ធិ និងភារកិច្ចដូចជា៖[115]

- ត្រួតពិនិត្យ បញ្ឈប់ ចាត់វិធានការបណ្ដោះអាសន្ន និងពិន័យអន្តរការណ៍ចំពោះបទល្មើសសំណង់ដែលមានចែងក្នុងច្បាប់ស្ដីពីសំណង់
- ក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាក់ព័ន្ធ បានប្រព្រឹត្តល្មើសសំណង់ដូចជាការសាងសង់គ្មានលិខិតអនុញ្ញាត ឬការសាងសង់ខុសលក្ខខណ្ឌបច្ចេកទេសណាមួយនោះ មន្ត្រីអធិការកិច្ចសំណង់មានសិទ្ធិក្នុងការដកហូតជាបណ្ដោះអាសន្ននូវលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ ដែលពាក់ព័ន្ធ
- ចាប់យកវត្ថុតាង និងកសាងសំណុំរឿង ចំពោះបទល្មើសសំណង់
- ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់ស្ដីពីសំណង់នេះ
- មន្ត្រីអធិការកិច្ចសំណង់មានសិទ្ធិចូលទៅក្នុងការដ្ឋានសំណង់គ្រប់ពេលក្នុងពេលដែលការដ្ឋានកំពុងដំណើរការ ឬក្នុងម៉ោងធ្វើការដើម្បីបំពេញភារកិច្ចរបស់ខ្លួនបាន។

មន្ត្រីអធិការកិច្ចសំណង់អាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដូចមានចែងក្នុងច្បាប់ ប៉ុន្តែក្នុងករណីជាបទល្មើសជាក់ស្ដែង ឬមិនមានលិខិតអនុញ្ញាតសាងសង់ឬរុះរើ អាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវផ្ដល់ព័ត៌មាននេះជាបន្ទាន់ទៅដល់មន្ត្រីអធិការកិច្ចសំណង់ ដែលនៅជិតបំផុត ដើម្បីចាត់ការតាមនីតិវិធី។

### ២.២.១.៦. វិសមិតភាព

ដើម្បីធានាប្រសិទ្ធិភាពក្នុងការបំពេញការងារឱ្យបានត្រឹមត្រូវ ច្បាប់សំណង់បានកំណត់អំពីគោលការណ៍វិសមិតភាពនៃការអនុវត្តការងារសំណង់រវាងអ្នកដែលទទួលសមត្ថកិច្ច ឬក៏អ្នកដែលទទួលសម្បទាឱ្យអនុវត្តការងារនៃសំណង់ផ្សេងៗ។ ត្រង់ចំនុចនេះ ប្រសិនជាបុគ្គលណាម្នាក់ទៅអនុវត្តការងារសំណង់ច្រើនប្រភេទ ហើយធ្វើឱ្យប្រសិទ្ធិភាព ឬភាពត្រឹមត្រូវនៃការងារនោះវាក្លាយទៅជាខុសវិញនោះនាំឱ្យមានការហាមឃាត់ ។ ផ្អែកទៅលើករណីបែបនេះ ក្រសួងរៀបចំដែនដីនឹងមិនផ្ដល់អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈដោយឯករាជ ទៅមន្ត្រីរាជការដែលកំពុងប្រតិបត្តិការងារនៅក្នុងការងារសំណង់នោះបានទេ។

ក្រឡេកមកមើលមាត្រា ៦៣ ដែលមានចែងក្នុងច្បាប់ស្ដីពីសំណង់ បានហាមឃាត់ មន្ត្រីអធិការកិច្ចមន្ត្រីត្រួតពិនិត្យសំណង់ និងអ្នកត្រួតពិនិត្យនិងបញ្ជាក់ មិនឱ្យជា ម្ចាស់សំណង់ ជាសហព័ទ្ធ ជាញាតិលោហិត

[113] មាត្រា ៥៧ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីសំណង់ ឆ្នាំ២០១៩

[114] មាត្រា ៦១ និងមាត្រា ៥៨ នៃច្បាប់ស្ដីពីសំណង់ ឆ្នាំ២០១៩

[115] មាត្រា ៥៩ និងមាត្រា ៦០ នៃច្បាប់ស្ដីពីសំណង់ ឆ្នាំ២០១៩

ផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣ថ្នាក់ ឬញាតិពន្ធក្នុង៣ថ្នាក់ របស់ម្ចាស់សំណង់ដែលខ្លួនត្រួតពិនិត្យបានឡើយ ឬក៏មិនអាចជាអ្នកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់បានដែរ។ ដូចនេះប្រសិនបើមន្ត្រីអធិការកិច្ចសំណង់ មិនអាចចុះទៅត្រួតពិនិត្យសំណង់របស់ឪពុកម្តាយ ឬបងប្អូន ឬបុគ្គលដែលមានទំនាក់ទងផ្នែកហិរញ្ញវត្ថុជាមួយខ្លួនបានទេ ព្រោះវាអាចនាំឱ្យមានភាពមិនត្រឹមត្រូវ ឬមានភាពលំអៀងកើតឡើង។

ដូចគ្នានេះដែរ អ្នកដែលទៅត្រួតពិនិត្យ និងសម្រេចលើគម្រោងប្លង់ មិនអាចជាអ្នកសិក្សាគម្រោងប្លង់ អ្នកត្រួតពិនិត្យ និងបញ្ជាក់លើគម្រោងប្លង់ដែលខ្លួនបានសិក្សា ឬអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់បានឡើយ។ ករណីនេះអនុវត្តដូចគ្នាលើក្រុមហ៊ុនដែលមានអាជ្ញាបណ្ណសិក្សាគម្រោងប្លង់ អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់ និងអាជ្ញាបណ្ណសាងសង់ ដោយគាត់មិនអាចបញ្ជាក់លើប្លង់ដែលក្រុមហ៊ុនគាត់សិក្សាបានដែរ។[116]

ចំពោះការបំពេញមុខងារជាអ្នកសាងសង់ មានវិសមិតភាពជាមួយនឹង ការបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់លើការងារសាងសង់របស់ខ្លួន មានន័យថា ចំពោះសំណង់ដែលខ្លួនបានធ្វើការសាងសង់ នោះការត្រួតពិនិត្យ និងបញ្ជាក់លើការងារសាងសង់ គឺត្រូវតែជាក្រុមមន្ត្រីត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្សេង មិនអាចជាខ្លួនឯងបានឡើយ ទោះបីជាមានអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ក៏ដោយ។[117]

ដោយឡែកចំពោះ តួនាទីរបស់អ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ ឬការងារសាងសង់វិញ ទំនាក់ទំនងរបស់ពួកគាត់ជាមួយនឹងម្ចាស់សំណង់ មិនអាចជាសហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣ ថ្នាក់ នឹងម្ចាស់សំណង់បានដូចគ្នា ។ លើសពីនេះ ចំពោះសមាជិកភាគហ៊ុននៃក្រុមហ៊ុនដែលជាម្ចាស់សំណង់ បុគ្គលិកក្រុមហ៊ុនដែលជាម្ចាស់សំណង់ ឬអ្នកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់ មិនអាចបំពេញមុខងារជាអ្នកត្រួតពិនិត្យ និងបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់សំណង់នោះបានផងដែរ។[118]

### ២.២.២. បទប្បញ្ញត្តិបច្ចេកទេសសំណង់

បទប្បញ្ញត្តិបច្ចេកទេសសំណង់ ជាចំនុចថ្មីមួយ ហើយក៏ជាចំនុចសំខាន់មួយដែរ ដែលបានកំណត់នៅក្នុងច្បាប់ស្តីពីសំណង់។ បទប្បញ្ញត្តិបច្ចេកទេសសំណង់នេះ កំណត់ឱ្យរដ្ឋដាក់ចេញនូវបញ្ញត្តិក្នុងផ្នែកបច្ចេកទេសមួយចំនួន ដែលមានលក្ខណៈតាមច្បាប់ដោយចាប់ចង និងដាច់ខាតត្រូវអនុវត្ត។

បទប្បញ្ញត្តិបច្ចេកទេសក្នុងវិស័យសំណង់មាន ៣ គឺ៖ បទប្បញ្ញត្តិនគរូបនីយកម្ម (ពាក់ព័ន្ធនឹងគម្លាត កម្ពស់។ល។) បទប្បញ្ញត្តិបច្ចេកទេសសំណង់ (ការរៀបចំឱ្យចេញជាគ្រឿងផ្គុំ និងរាប់ចាប់ពីការងារសិក្សាគម្រោងប្លង់ រហូតដល់ការងារសាងសង់) និងចុងក្រោយ បទប្បញ្ញត្តិវិស្វកម្ម (ពាក់ព័ន្ធនឹងក្បួនធ្វើឱ្យរឹងមាំ)។

[116] មាត្រ ៦៤ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[117] មាត្រ ៦៥ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[118] មាត្រ ៦៦ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

បទប្បញ្ញត្តិបច្ចេកទេសសំណង់ អភិវឌ្ឍទៅដោយមានយន្តការ២ គឺ ការបង្កើតក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងការបង្កើតមន្ទីរជាតិពិសោធន៍សំណង់ ដើម្បីជួយក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ឱ្យអនុវត្តបេសកកម្មរបស់ខ្លួន។ ដើម្បីធានាថាបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវអនុវត្តបានត្រឹមត្រូវ ក្រសួងរៀបចំដែនដីមានយន្តការថ្មីមួយ គឺប្រព័ន្ធត្រួតពិនិត្យ និងបញ្ជាក់សំណង់ ដែលជាការងាររបស់អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់។ អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់មាន២ ប្រភេទ គឺ ក្រុមហ៊ុនឯកជន និងមន្ត្រីរាជការជំនាញ។ បុគ្គលទាំងពីរប្រភេទនេះ ត្រូវត្រួតពិនិត្យនិងបញ្ជាក់សំណង់ដោយអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។[119]

ចំពោះលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់រួមមានៈ

- រាល់ការងារសំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់[120]
- រាល់សំណង់ត្រូវមានគ្រឿងផ្គុំដែលអាចទ្រទ្រង់បន្ទុកបានប្រកបដោយសុវត្ថិភាពទៅតាមមុខងារប្រើប្រាស់ របស់សំណង់[121]
- រាល់សំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិសុវត្ថិភាពអគ្គិភ័យ។[122]

### ២.២.៣. ការគ្រប់គ្រងបុគ្គលពាក់ព័ន្ធក្នុងវិស័យសំណង់

នៅក្នុងវិស័យសំណង់ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងទៅលើបុគ្គលលដែលពាក់ព័ន្ធក្នុងវិស័យសំណង់នេះ ច្បាប់ស្តីសំណង់បានធ្វើការបែងចែកការគ្រប់គ្រងនេះជា ២ប្រភេទ គឺការគ្រប់គ្រងអ្នកវិជ្ជាជីវៈ និងការគ្រប់គ្រងទៅលើអ្នកប្រកបវិជ្ជាជីវៈ ឬអ្នកប្រកបអាជីវកម្មក្នុងវិស័យសំណង់។ ការបែងចែកនេះនាំឱ្យមានសំណួរចោទឡើងថា តើបុគ្គលទាំងពីរប្រភេទខាងលើនេះខុសគ្នាដូចម្តេច បានជាមានការបែងចែកក្នុងការគ្រប់គ្រងបែបនេះ?

#### ២.២.៣.១. អ្នកវិជ្ជាជីវៈ

អ្នកវិជ្ជាជីវៈ សំដៅដល់អ្នកជំនាញទាំងអស់ ដែលបានសិក្សារៀនសូត្រ មានបទពិសោធន៍ រហូតដល់មានភាពជំនាញ ហើយមានសញ្ញាបត្របញ្ជាក់បញ្ចប់ការសិក្សានៃជំនាញរបស់ខ្លួន។ អ្នកដែលមានសញ្ញាបត្រទាំងនេះ ត្រូវមកចុះបញ្ជីនៅក្នុងគណៈវិជ្ជាជីវៈទៅតាមតាមប្រភេទជំនាញរបស់ខ្លួន ឧទាហរណ៍ វិស្វករ ត្រូវចុះបញ្ជីនៅគណៈវិស្វករ រីឯស្ថាបត្យករ ត្រូវចុះបញ្ជីនៅគណៈស្ថាបត្យករ ទើបទទួលបានឈ្មោះជាអ្នកវិជ្ជាជីវៈ។[123] ករណីដែលវិស្វករ ឬស្ថាបត្យករដែលមានមានបទពិសោធន៍ ឬមានជំនាញរួចហើយក៏ដោយ ប្រសិនបើពុំបានធ្វើការចុះបញ្ជីទេ ពុំអាចក្លាយជាអ្នកវិជ្ជាជីវៈបានទេ។ អ្នកវិជ្ជាជីវៈអាចជាបុគ្គលឯកជន ឬមន្ត្រីរាជការដែលបានចុះបញ្ជី

[119] មាត្រា ៧ កថាខណ្ឌទី២ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[120] មាត្រា ៧ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[121] មាត្រា ៨ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[122] មាត្រា ៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[123] មាត្រា ១២ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

ហើយអ្នកវិជ្ជាជីវៈនេះ ច្បាប់តម្រូវឱ្យប្រតិបត្តិការងារដោយគោរពតាមក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។[124]

### ២.២.៣.២. ការប្រកបវិជ្ជាជីវៈនិងការប្រកបអាជីវកម្មក្នុងវិស័យសំណង់

ការប្រកបវិជ្ជាជីវៈ និងការប្រកបអាជីវកម្មក្នុងវិស័យសំណង់មានលក្ខណៈខុសគ្នា។ ការប្រកបវិជ្ជាជីវៈ សំដៅដល់អ្នកដែលប្រកបវិជ្ជាជីវៈតែម្នាក់ឯងដោយឯករាជ្យ និងយកកំរៃនៅក្នុងវិស័យឯកជន រីឯការប្រកបអាជីវកម្ម សំដៅដល់ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណក្នុងការប្រកបអាជីវកម្ម ឬក្រុមអ្នកប្រកបវិជ្ជាជីវៈ ឬក្រុមជាងជំនាញ ដែលធ្វើការងារជាក្រុម ឬនៅក្នុងក្រុមហ៊ុន ក្នុងគោលបំណងរកប្រាក់កំរៃដូចគ្នា។ អ្នកដែលប្រកបវិជ្ជាជីវៈដោយឯករាជ្យក្នុងវិស័យសំណង់ ខ្លួនមានសិទ្ធិសំរេចនៅក្នុងទិដ្ឋភាពបច្ចេកទេសដែលបម្រើឱ្យការងារសំណង់ទៅតាមកម្រិត និងជំនាញរបស់ខ្លួន ហើយត្រូវមានអាជ្ញាបណ្ណដែលផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ប៉ុន្តែចំពោះអ្នកវិជ្ជាជីវៈដែលបំពេញមុខងារជានាយកបច្ចេកទេសនៃក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ មិនតម្រូវឱ្យមានអាជ្ញាបណ្ណឡើយ[125]។ នៅពេលដែលការងារសំណង់អនុវត្តដោយក្រុមហ៊ុន អ្នកទទួលខុសត្រូវទីមួយខាងផ្នែកបច្ចេកទេសគឺ នាយកបច្ចេកទេស។ នាយកបច្ចេកទេសនេះត្រូវមានជំនាញទៅតាមប្រភេទនៃការងាររបស់ពួកគាត់ ហើយគាត់ជាអ្នកដែលចុះហត្ថលេខានៅលើឯកសារសាងសង់ដើម្បីបញ្ជាក់អំពីទិដ្ឋភាពបច្ចេកទេសរបស់ក្រុមហ៊ុន និងតម្រូវឱ្យមានបោះត្រាក្រុមហ៊ុននៅលើឯកសារដែលបានចុះហត្ថលេខានោះ។ ការធ្វើបែបនេះគឺដើម្បីធានានូវការទទួលខុសត្រូវរបស់ក្រុមហ៊ុនចំពោះរឿងក្តីរដ្ឋប្បវេណី និងការទទួលខុសត្រូវរបស់នាយកបច្ចេកទេសក្នុងរឿងក្តីព្រហ្មទណ្ឌ។

ម្យ៉ាងវិញទៀត ដើម្បីធានាអំពីការទទួលខុសត្រូវខាងលើនេះឱ្យអនុវត្តទៅបាន ច្បាប់ស្តីពីសំណង់បានចែងអំពីការដាក់ទោសទៅលើពួកគាត់ ដោយបញ្ញត្តិពីការបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈរបស់អ្នកប្រកបវិជ្ជាជីវៈ ឬក្រុមជាង ឬជាងជំនាញ ក្នុងមាត្រា ១៦ និងការបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈសម្រាប់ក្រុមហ៊ុនប្រកបអាជីវកម្ម ក្នុងមាត្រា ១៨។

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈ ក្នុងករណីដូចខាងក្រោម៖

- លែងបំពេញលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈ
- បានប្រព្រឹត្តកំហុសវិជ្ជាជីវៈដែលនាំទៅដល់ការផ្អាកឬការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ
- មានបញ្ហាសុខភាពដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈ ដោយការមានបញ្ជាក់ពីគ្រូពេទ្យជំនាញ ឬបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ឬការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភដោយតុលាការ
- បានទទួលការប្រកាសក្ស័យធនដោយតុលាការ
- ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់

[124] មាត្រា ១៣ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[125] មាត្រា ១៥ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

ស្នាក់នៅ។

ការផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់មិនត្រូវលើសពី៦ខែឡើយ គិតចាប់ពីថ្ងៃដែលផ្អាកអាជ្ញាបណ្ណ។ នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់នេះ អាចត្រូវបានផ្តល់ឡើងវិញ ក្រោយរយៈពេល៥ឆ្នាំ គិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។ ក្នុងករណីបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈ ដោយមូលហេតុត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈនោះ អាចត្រូវបានផ្តល់ឡើងវិញ បន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[126]

ក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងករណីដូចខាងក្រោមៈ

- លែងបំពេញលក្ខខណ្ឌតម្រូវណាមួយដែលអនុញ្ញាតឱ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្ម
- ត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម
- ត្រូវបានតុលាការប្រកាសរំលាយឬប្រកាសមោឃភាព
- ត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ
- អភិបាល ឬនាយកបច្ចេកទេសដែលបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ឬការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភដោយតុលាការ ប៉ុន្តែករណីនេះត្រូវបានលើកលែងប្រសិនបើអភិបាល ឬនាយកបច្ចេកទេសនោះ ត្រូវបានប្តូរក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- អភិបាល ឬនាយកបច្ចេកទេសដែលត្រូវបានតុលាការប្រកាសក្ស័យធន ឬការជម្រះបញ្ជីតាមផ្លូវតុលាការ ករណីនេះត្រូវបានលើកលែងដែរប្រសិនបើអភិបាល ឬនាយកបច្ចេកទេសនោះត្រូវបានប្តូរក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- អភិបាល ឬនាយកបច្ចេកទេសដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ ករណីលើកលែងបើអភិបាលឬនាយកបច្ចេកទេស នោះត្រូវបានប្តូរក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃមានសាលក្រមឬសាលដីកាស្ថាពរ។

ការផ្អាកអាជ្ញាបណ្ណប្រកបអាជីវកម្មក្នុងវិស័យសំណង់នេះមិនត្រូវមានរយៈពេលលើសពី១ឆ្នាំឡើយ គិតចាប់ពីថ្ងៃផ្អាកអាជ្ញាបណ្ណ។ នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងវិស័យសំណង់អាចត្រូវបានផ្តល់ឡើងវិញក្រោយរយៈពេល ៥ឆ្នាំ គិតចាប់ពីថ្ងៃដែលដកហូតអាជ្ញាបណ្ណ។ បុគ្គល ឬអ្នកវិជ្ជាជីវៈដែលត្រូវបានតុលាការប្រកាសក្ស័យធន ឬការជម្រះបញ្ជីតាមផ្លូវតុលាការ អាចទទួលបាននីតិសម្បទាធ្វើជាអភិបាល ឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ ក្រោយរយៈពេល៥ឆ្នាំ គិតចាប់ពីថ្ងៃប្រកាសក្ស័យធនឬ

[126] មាត្រា ១៦ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

ការជម្រះបញ្ជីតាមផ្លូវតុលាការ។ ម្យ៉ាងវិញទៀតចំពោះបុគ្គលឬអ្នកវិជ្ជាជីវៈដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ អាចទទួលបាននីតិសម្បទាធ្វើជាអភិបាល ឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ បន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។[127]

### ២.២.៤. ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់

ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់ច្បាប់នេះចែងអំពីទំនួលខុសត្រូវ ៣ ប្រភេទ។ ទំនួលខុសត្រូវទី១ គឺការទទួលខុសត្រូវរដ្ឋបាល ការទទួលខុសត្រូវនេះ ច្បាប់អនុញ្ញាតឱ្យអាជ្ញាធរអនុវត្ត ឬបង្កើតទណ្ឌកម្មរដ្ឋបាលទៅដល់ប្រជាពលរដ្ឋ អ្នកវិជ្ជាជីវៈ ឬក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់។ ពួកគេមានសិទ្ធិនៅក្នុងការអនុវត្តការងារសំណង់ទៅតាមច្បាប់ ហើយអាជ្ញាធរមានសិទ្ធិដកអាជ្ញាបណ្ណមកវិញ ដែលជាផ្នែកនៃទណ្ឌកម្ម ប៉ុន្តែមុននឹងធ្វើការដកអាជ្ញាបណ្ណ គាត់អាចព្រមានជាលាយលក្ខណ៍អក្សរជាមុនសិន។ លើសពីនេះអាជ្ញាធរមានសមត្ថកិច្ច អាចព្យួរអាជ្ញាបណ្ណរបស់ពួកគេបាន ហើយទន្ទឹមនឹងព្យួរនេះ គឺត្រូវធ្វើការណែនាំជាមុនសិន។ ករណីដែលណែនាំហើយមិនធ្វើតាម ទើបតម្រូវឱ្យមានការព្យួរ។ នៅពេលដែលអាជ្ញាបណ្ណត្រូវបានព្យួរ អាជ្ញាធរអនុវត្តតម្រូវឱ្យធ្វើការកែតម្រូវឡើងវិញម្តងទៀត ករណីដែលមិនកែ នោះគឺតម្រូវឱ្យត្រូវតែដកអាជ្ញាបណ្ណតែម្តង នេះសុទ្ធតែជាវិធានការរដ្ឋបាល ឬទណ្ឌកម្មរដ្ឋបាល ដែលច្បាប់បានបង្កើត និងផ្តល់សិទ្ធិអំណាចមកដល់អាជ្ញាធរមានសមត្ថកិច្ច។

ទំនួលខុសត្រូវទី២ គឺការទទួលខុសត្រូវរដ្ឋប្បវេណី មានន័យថាជាការទទួលខុសត្រូវស៊ីវិល នេះជាសញ្ញាណមួយដែលផ្សាភ្ជាប់ទៅនឹងសញ្ញាណវិការៈ ច្បាប់បានចែងយ៉ាងច្បាស់ ដើម្បីងាយស្រួលក្នុងការអនុវត្តនៅក្នុងវិស័យសំណង់ដោយឡែក។ ដូចនេះបានជាគេចែងបន្ថែមនូវគោលការណ៍មួយចំនួនទៅលើក្រមរដ្ឋប្បវេណី ដោយសារក្រមរដ្ឋប្បវេណីបាននិយាយអំពីការទទួលខុសត្រូវស៊ីវិលនេះច្រើនណាស់។ ប៉ុន្តែដោយវាជាបញ្ហានៃការសាងសង់ ការអនុវត្តការងារសំណង់ច្បាប់សំណង់បានចែងបន្ថែមពីលើនេះទៀត។ អ្វីដែលសំខាន់ជាងគេនោះគឺ៖ កាតព្វកិច្ចរវាងគូភាគី និងសញ្ញាណនៃវិការៈ។ មាត្រា ៧៩ នៃច្បាប់ស្តីពីសំណង់ចែងថា *"ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការប្រើប្រាស់ឬការគ្រប់គ្រងសំណង់នោះមានវិការៈ។"* ជាឧទាហរណ៍ ករណីរូបវន្តបុគ្គលម្នាក់បានសាងសង់ផ្ទះ ឬអគារមួយ ហើយនៅពេលដែលយើងប្រើប្រាស់ស្រាប់តែមានការបាក់រលំអគារកើតឡើង សំណួរចោទឡើងថា តើជនរងគ្រោះត្រូវប្តឹងទៅអ្នកណាជាអ្នកសងចំពោះការខូតខាតនេះ? ដូចនេះទើបច្បាប់ចែងអំពីការទទួលខុសត្រូវរបស់ម្ចាស់សំណង់ដោយការសាមគ្គីភាព។ ពាក្យថាទទួលខុសត្រូវដោយសាមគ្គីភាពនេះ ជាសញ្ញាណដែលច្បាប់សំដៅការពារជនរងគ្រោះ ដើម្បីធានាក្នុងការទទួល

[127] មាត្រា ១៨ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

បានការទទួលខុសត្រូវ ពីបុគ្គលដែលត្រូវមានកាតព្វកិច្ចទទួលខុសត្រូវចំពោះហេតុដែលបានកើតឡើង ដោយគ្មានការគេចវេស។

រីឯការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានចែងក្នុងជំពូកទី២០ ស្តីពីទោសប្បញ្ញត្តិ មានដូចជា៖ ទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធធនាគារចំពោះអ្នកពាក់ព័ន្ធ មានដូចជាម្ចាស់សំណង់ និងអ្នកអនុវត្តការងារសំណង់ (មានដូចជា៖ ក្រុមអ្នកវិជ្ជាជីវៈ អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់ អ្នកសិក្សាគម្រោងប្លង់ អ្នកសាងសង់។ល។) ជាដើម។

បន្ថែមពីលើនេះ ច្បាប់សំណង់ក៏បានបញ្ញត្តិបញ្ជាក់យ៉ាងច្បាស់អំពីសិទ្ធិក្នុងការទាមទារសំណងរបស់ជនរងគ្រោះ។ សិទ្ធិទាមទារសំណង់នៃការខូចខាតដែលបង្កឡើងដោយវិការៈនៃការសិក្សាគម្រោងប្លង់ ការសាងសង់ឬរុះរើ ឬការគ្រប់គ្រងការដ្ឋានសំណង់ ការត្រួតពិនិត្យនិងបញ្ជាក់សំណង់ ការប្រើប្រាស់សំណង់ ការគ្រប់គ្រងសំណង់ និងវិការៈនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ ត្រូវរលត់ដោយអាជ្ញាយុកាល។ [128] ចំពោះការរលត់ដោយអាជ្ញាយុកាល គឺបានកំណត់រយៈពេល ៣ឆ្នាំ ១០ឆ្នាំ និង២០ឆ្នាំ ដែលជារយៈពេលមួយកំណត់អំពីការទទួលខុសត្រូវរបស់បុគ្គលដែលត្រូវទទួលខុសត្រូវ ហើយក៏ជារយៈពេលដែលជនរងគ្រោះអស់សិទ្ធិក្នុងការទាមទារសំណងផងដែរ។ ជនរងគ្រោះមិនអាចទាមទារសំណងបានឡើយប្រសិនបើហួសរយៈពេល ៣ឆ្នាំ បន្ទាប់ពីពេលដែលជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់បានដឹងថាអាចទាមទារសំណងការខូចខាតបាន។ ឧទាហរណ៍ ជនរងគ្រោះទទួលរងគ្រោះថ្នាក់ក្នុងឆ្នាំ២០១៩ ដោយគាត់ដឹងថា ខ្លួនគាត់មានសិទ្ធិក្នុងការទាមទារសំណងខូចខាតពីម្ចាស់សំណង់ ប៉ុន្តែ៣ឆ្នាំកន្លងផុតទៅ ដែលនៅឆ្នាំ២០២២ ទើបគាត់នឹងចង់ទាមទារសំណង់ខូចខាត ករណីនេះហើយដែលគាត់ពុំអាចទាមទារសំណងបានឡើយ ព្រោះបានផុតអាជ្ញាយុកាលបាត់ទៅហើយ។ រីឯរយៈពេល ១០ឆ្នាំ វិញ គឺរាប់ចាប់ពីសម្ភារៈសំណង់បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវបានប្រគល់លើកដំបូងដោយផលិតករ។ ក្នុងករណីសម្ភារៈសំណង់ បរិក្ខារសំណង់ និង ផលិតផលសំណង់មានសារធាតុបង្កឱ្យមានការប៉ះពាល់ដល់សុខភាពមនុស្ស រយៈពេលនេះត្រូវបន្ថែម២០(ម្ភៃ)ឆ្នាំទៀត។ ដូចនេះជនរងគ្រោះមានសិទ្ធិក្នុងការទាមទារសំណងក្នុងចន្លោះពេលមិនលើសពី៣០ឆ្នាំ។

សរុបមកវិញ ការទទួលខុសត្រូវរបស់បុគ្គលដែលពាក់ព័ន្ធនឹងសំណង់ មានដូចជា អ្នកសិក្សាគម្រោងប្លង់ត្រូវទទួលខុសត្រូវលើការងាររបស់ខ្លួន ករណីដែលគម្រោងប្លង់នៃសំណង់មានវិការៈ។[129] ម្ចាស់សំណង់ និងអ្នកសាងសង់ ឬរុះរើ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះការងារសាងសង់ឬរុះរើ ឬការងារការដ្ឋានសំណង់មានវិការៈ។[130] អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់ ត្រូវទទួលខុសត្រូវលើការងារខ្លួន ករណីដែលការត្រួតពិនិត្យ និងបញ្ជាក់ មានភាពមិនត្រឹមត្រូវ និងមិនច្បាស់លាស់នាំឱ្យមានគ្រោះថ្នាក់កើតឡើង។ ចុងក្រោយ គឺអ្នកគ្រប់គ្រង

[128] មាត្រា ៨០ និង ៨២ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[129] មាត្រា ៧៦ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[130] មាត្រា ៧៧ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

សំណង់ អ្នកជួសសំណង់ រួមទាំងម្ចាស់សំណង់ ត្រូវទទួលខុសត្រូវ ទៅលើការប្រើប្រាស់ ឬការគ្រប់គ្រងសំណង់មានវិការៈ ដែលជាហេតុនាំឱ្យមានការបាក់រលំ ឬគ្រោះថ្នាក់សំណង់កើតឡើង។[131] ទន្ទឹមនឹងការទទួលខុសត្រូវនេះដែរ មាត្រា ៨២ នៃច្បាប់នេះក៏បានចែងអំពីការលើកលែងការទទួលខុសត្រូវរបស់ ផលិតករនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ ករណីដែលសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ ត្រូវបានដាក់លក់ ឬចែកចាយចំណេះដឹងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេសហើយដែលពុំអាចរកឃើញថាមានវិការៈដែលបង្កឱ្យមានការខូចខាត និងសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានផលិតឡើងដោយអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសតម្រូវ។

[131] មាត្រា ៧៨ និងមាត្រា ៧៩ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

តាមរយៈការស្វែងយល់និងបកស្រាយលើប្រធានបទស្តីពី ការគ្រប់គ្រងសំណង់នៅកម្ពុជា នៃសារណានេះចប់សព្វគ្រប់មក ក្រុមយើងខ្ញុំបានសង្កេតឃើញថា សំណង់មួយអាចសាងសង់ទៅបានដោយស្របច្បាប់ចាំបាច់ត្រូវគោរពនូវគោលការណ៍ទាំងប្រាំដែលបានកំណត់ដោយច្បាប់ ដើម្បីធានាថាសំណង់ដែលបានសាងសង់មានរបៀបរៀបរយ និងធានាបាននូវការអភិវឌ្ឍនគរូបនីយកម្មរបស់ប្រទេសប្រកបដោយចីរភាព។ បន្ថែមពីនេះ ការសាងសង់សំណង់នីមួយត្រូវឆ្លងកាត់នូវដំណាក់កាលអំៗចំនួន ៣ រួមមាន៖ ការស្នើសុំការអនុញ្ញាតសាងសង់ ការស្នើសុំការអនុញ្ញាតបើកការដ្ឋានដោយមានការតាមដាននិងត្រួតពិនិត្យដំណើរការសាងសង់ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច និងចុងក្រោយគឺការស្នើសុំអនុញ្ញាតប្រើប្រាស់សំណង់នៅមុនពេលប្រើប្រាស់សំណង់ដើម្បីធានាដល់សុវត្ថិភាពរបស់អ្នកប្រើប្រាស់។ យ៉ាងណាមិញ ចំពោះការអនុវត្តច្បាប់ក្នុងវិស័យសំណង់នេះយើងឃើញថា មុនពេលច្បាប់សំណង់មិនទាន់លេចចេញជារូបរាង ការគ្រប់គ្រងស្ថានភាពសំណង់មិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយទេ បើសង្កេតឱ្យច្បាស់លាស់ទៅគឺ សំណង់អនាធិបតេយ្យបានសាងសង់ជាហូរហែកន្លងមក ពិសេសគឺការតាមដានត្រួតពិនិត្យសំណង់របស់មន្ត្រីមានសមត្ថកិច្ចនៅមានភាពខ្វះខាត និងអ្នកបច្ចេកទេសក៏ពុំសូវមានច្រើន។ ម្យ៉ាងវិញទៀតសំណង់ជាច្រើនបានសាងសង់មិនគោរពទៅតាមច្បាប់ និងតាមបទប្បញ្ញត្តិបច្ចេកទេស ជាហេតុនាំឱ្យពុំសូវមានគុណភាពរឹងមាំ ហើយចំពោះការទទួលខុសត្រូវរបស់ម្ចាស់សំណង់និងអ្នកពាក់ព័ន្ធក៏នៅមានកម្រិតនៅឡើយ។ ប៉ុន្តែនៅក្រោយពេលដែលច្បាប់ស្តីពីសំណង់បានអនុម័តប្រកាសឱ្យប្រើមក យើងសង្កេតឃើញថា សំណង់ស្ទើរតែទាំងស្រុងត្រូវបានគ្រប់គ្រង។ ចំពោះការគ្រប់គ្រងនេះសំណង់នីមួយៗដែលសាងសង់សុទ្ធតែគោរពទៅតាមគោលការណ៍ដែលច្បាប់កំណត់ មិនថាទាំងការស្នើសុំលិខិតអនុញ្ញាតសាងសង់ ដំណើរការក្នុងការសាងសង់ រហូតដល់បញ្ចប់ការសាងសង់ សុទ្ធតែស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់អាជ្ញាធរមានសមត្ថកិច្ច ពិសេសគឺគុណភាពសំណង់ បច្ចេកទេសក្នុងការសាងសង់ បូករួមទាំងបុគ្គលដែលពាក់ព័ន្ធទាំងអស់ក្នុងការងារសំណង់ មិនថាម្ចាស់សំណង់ អ្នកសាងសង់ អ្នកវិជ្ជាជីវៈ ឬក្រុមហ៊ុនដែលប្រកបអាជីវកម្មសំណង់នោះទេ។ បុគ្គលដែលពាក់ព័ន្ធនៅក្នុងវិស័យនេះ សុទ្ធតែមានវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណត្រឹមត្រូវ ស្របតាមគោលការណ៍ និងលក្ខខណ្ឌនៃច្បាប់ស្តីពីសំណង់។ ម្យ៉ាងវិញទៀត ច្បាប់នេះក៏បានដាក់ទោសព្រហ្មទណ្ឌទៅលើបុគ្គលដែលពាក់ព័ន្ធក្នុងវិស័យសំណង់ ចំពោះអំពើដែលប្រព្រឹត្តខុសទៅនឹងបទប្បញ្ញត្តិដែលច្បាប់កំណត់ ដែលការដាក់ទោសនេះមានទាំងការពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារផងដែរ។ ជារួមយើងឃើញថា ការគ្រប់គ្រងសំណង់នៅកម្ពុជានៅក្នុងពេលបច្ចុប្បន្នរាប់ចាប់ពីការចូលជាធរមាននៃច្បាប់សំណង់ឆ្នាំ២០១៩មក បានកំណត់យ៉ាងច្បាស់អំពីគ្រប់គ្រងសំណង់ព្រមទាំងអ្នកវិជ្ជាជីវៈក្នុងសិស័យនេះ នីតិវិធីទាក់ទងនឹងការងារសំណង់ និងពិសេសការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធទាំងឡាយក្នុងករណីសំណង់មានបញ្ហាកើតឡើង ដែលនេះជាកត្តាដ៏ចំបងក្នុងការអភិវឌ្ឍវិស័យមួយនេះ។

# អនុសាសន៍

# អនុសាសន៍

ដោយមើលឃើញពីវឌ្ឍនភាពនៃវិស័យនេះ និងដើម្បីចូលរួមជាចំណែកមួយនៅក្នុងការជម្រុញឱ្យការគ្រប់គ្រងក្នុងវិស័យនេះកាន់តែមានប្រសិទ្ធិភាព យើងខ្ញុំមានគំនិតស្ទួចស្ទើងក្នុងការបញ្ចេញជាយោបល់ និងសំណូមពរទៅដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក៏ដូចជាសមត្ថកិច្ចពាក់ព័ន្ធដូចជាៈ

១. ពង្រឹងនូវការអនុវត្តច្បាប់ស្តីពីសំណង់ឱ្យប្រើឱ្យបានកាន់តែតឹងរឹងដើម្បីធានាឱ្យបាននូវការគ្រប់គ្រងសំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជាកាន់តែមានប្រសិទ្ធិភាព

២. ធានាឱ្យបាននូវការត្រួតពិនិត្យដំណើរការសាងសង់រាល់សំណង់ទាំងអស់ប្រកបដោយប្រសិទ្ធិភាព ក្នុងគោលដៅធានានូវគុណភាពនិងសុវត្ថិភាពសំណង់

៣. ធានាឱ្យបាននូវដំណើរការគ្រប់គ្រងសំណង់ប្រកបដោយតម្លាភាព និងត្រឹមត្រូវតាមច្បាប់ ដោយធ្វើការចាត់វិធានការតឹងរឹងលើរាល់អំពើកេញប្រវ័ញ្ច បក្សពួកនិយម ការបំពានអំណាច និងការផ្តល់កម្រៃក្រៅផ្លូវការ ព្រមទាំងអំពើផ្សេងៗទៀតដែលប៉ះពាល់ដល់ការងាររបស់អាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងសំណង់ និងសិទ្ធិស្មើគ្នាក្នុងការទទួលបានសេវាសាធារណៈរបស់ប្រជាពលរដ្ឋគ្រប់រូប

៤. បង្កើតនូវវគ្គបណ្តុះបណ្តាលដើម្បីឱ្យសាធារណៈជនចូលរួមស្វែងយល់ និងយល់ដឹងអំពីការងារនានានៃវិស័យមួយនេះ ដោយអាចធ្វើឡើងជាលក្ខណៈអនឡាញ ឬអហ្វឡាញ

៥. ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការងារនៅក្នុងវិស័យសំណង់នេះតាមគ្រប់មធ្យោបាយ ដើម្បីបង្កើននូវការយល់ដឹងរបស់ប្រជាពលរដ្ឋទូទៅព្រមទាំងអ្នកវិនិយោគ

៦. ចែករំលែកឱ្យបានទូលាយនូវរាល់ពត៌មាននិងការវិវឌ្ឍថ្មីៗជាប្រចាំអំពីវិស័យនេះដែលមានដូចជាការវិវឌ្ឍសំខាន់ៗ បញ្ញាតតិយុត្តិ និងលិខិតបទដ្ឋានគតិយុត្តិទាំងឡាយពាក់ព័ន្ធនឹងសំណង់។

យើងខ្ញុំសង្ឃឹមថា សំណូមពរទាំងប្រាំមួយចំនុចខាងលើរបស់យើងខ្ញុំនឹងអាចជួយដល់ការងារគ្រប់គ្រងសំណង់នៅព្រះរាជាណាចក្រមកម្ពុជាកាន់តែប្រសើរឡើង និងកាន់តែមានប្រសិទ្ធភាពដើម្បីឆ្លើយតបយ៉ាងទាន់ពេលស្របទៅនឹងការវិវឌ្ឍន៍យ៉ាងខ្លាំងនៅពេលបច្ចុប្បន្ននឹងនាពេលអនាគតលើវិស័យសំណង់នេះ។ យើងខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំថាយោបល់ខាងលើនឹងត្រូវបានយកទៅពិនិត្យនិងពិភាក្សាដោយអាជ្ញាធរពាក់ព័ន្ធផងដែរ៕

# ឯកសារយោង

# ឯកសារយោង

## ក. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩
- ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៩
- ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤
- **អនុក្រឹត្យ**
  - អនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ
  - អនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
  - អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
  - អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
  - អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- **ប្រកាស**
  - ប្រកាសលេខ ១៧៧ ដនស/ប្រក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន
  - ប្រកាសលេខ ០៣៥ ប្រក.ដនស/អសណ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៦នៃប្រកាសលេខ ១៩២ ប្រ.ដនស/អសហ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់
  - ប្រកាសលេខ ៩៣ ប្រក.ដនស/អសហ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ ស្តីពីការកែសំរួលប្រការ ២ និង ប្រការ ៣ នៃប្រកាសលេខ ៣២ ប្រក/សហ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់
  - ប្រកាសលេខ ១៩២ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលសិក្សាគម្រោងប្លង់
  - ប្រកាសលេខ ១៦៦ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលប្រការ ៧ និងប្រការ ១០ នៃប្រកាសលេខ ៧៥ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់

- ប្រកាសលេខ ៣២ ប្រក/សហ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់
- ប្រកាសលេខ ៧៦ ប្រក/ដនស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីតួនាទី ភារកិច្ច និង រចនាសម្ព័ន្ធរបស់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានី-ខេត្ត និងតួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- ប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់

- **លិខិតបទដ្ឋានគតិយុត្តិផ្សេងទៀត**
  - សេចក្តីណែនាំលេខ ០០២ ដនស/សណន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ ស្តីអំពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់
  - សេចក្តីសម្រេចលេខ០០៥ សសរ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០ ស្តីអំពីការចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់
  - សេចក្តីជូនដំណឹងលេខ ៩៤៨ សជណ ចុះថ្ងៃទី៥ កក្កដា ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
  - លិខិតលេខ ១៩៨១ ដនស/អរប ចុះថ្ងៃទី២៧ មិថុនា ២០១៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
  - សេចក្តីណែនាំលេខ ០៣ ដនស/សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៤ ស្តីពីអនុវត្តប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន
  - សារាចរណែនាំលេខ ០០២ ដនស/អសណ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការចុះបញ្ជីប្រកបអាជីវកម្ម សិក្សាគម្រោងប្លង់ និងសាងសង់របស់សហគ្រាស ក្រុមហ៊ុន និងរូបវន្តបុគ្គលបរទេស

## ខ. ប្រភពពីសៀវភៅ

- បណ្ឌិត អ៊ុន សកក្កដា, *នីតិនគរូបនីយវិទ្យា*, បោះពុម្ពឆ្នាំ២០១៩

## គ. ប្រភពពីគេហទំព័រ

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, *វិស័យសំណង់*, http://www.mlmupc.gov.kh/?page=detail&menu1=373&menu2=424&menu3=440&ctype=article&id=440&lg=kh
- ព័ត៌មានសំណង់និងអចលនទ្រព្យ, *មនុស្សស្លាប់និងរបួសចំនួន៥៩នាក់ក្នុងគ្រោះថ្នាក់បាក់រលំអគារក្នុងខេត្តកែបបណ្តាលមកពីហេតុផល២* (០៥ មករា ២០២០), https://construction-property.com/km/59-died-and-injured-in-the-building-collapse-in-kep/

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធ១ រូបភាព**

ឧបសម្ព័ន្ធ១.ក អង្គការលេខក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ឧបសម្ព័ន្ធ១.ខ រចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ

ឧបសម្ព័ន្ធ១.គ បណ្តុំរូបភាពសំណង់អគារដួលរលំនៅខេត្តព្រះសីហនុ នាថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩

ឧបសម្ព័ន្ធ១.ឃ បណ្តុំរូបភាពសំណង់អគារដួលរលំនៅខេត្តកែប នាថ្ងៃទី៣ ខែមករា ឆ្នាំ២០២០

**ឧបសម្ព័ន្ធ២ គំរូឯកសារ**

ឧបសម្ព័ន្ធ២.ក ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់

ឧបសម្ព័ន្ធ២.ខ តារាងត្រួតពិនិត្យឯកសារ និងគម្រោងប្លង់ ស្នើសុំលិខិតអនុញ្ញាតសាងសង់

ឧបសម្ព័ន្ធ២.គ ពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋាន

ឧបសម្ព័ន្ធ២.ឃ តារាងត្រួតពិនិត្យឯកសារសុំលិខិតអនុញ្ញាតបើកការដ្ឋាន

ឧបសម្ព័ន្ធ២.ង ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ (សម្រាប់សមត្ថកិច្ចរបស់ក្រសួង)

ឧបសម្ព័ន្ធ២.ច វិញ្ញាបនបត្រប្រើប្រាស់សំណង់ (សម្រាប់សមត្ថកិច្ចរបស់ក្រសួង)

ឧបសម្ព័ន្ធ២.ឆ របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់

**ឧបសម្ព័ន្ធ៣ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ**

ឧបសម្ព័ន្ធ៣.ក ច្បាប់ស្តីពីសំណង់ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១៧/០១៩ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០១៩

ឧបសម្ព័ន្ធ៣.ខ ប្រកាសលេខ ១៦៦ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលប្រការ ៧ និង ប្រការ ១០ នៃប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់

ឧបសម្ព័ន្ធ៣.គ ប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់

ឧបសម្ព័ន្ធ១.ច សេចក្តីជូនដំណឹងលេខ ៩៤៨ សជណ ចុះថ្ងៃទី៥ កក្កដា ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

ឧបសម្ព័ន្ធ១.ឆ សារាចរណែនាំលេខ ០០២ ដនស/អសណ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការចុះបញ្ជីប្រកបអាជីវកម្ម សិក្សាគម្រោងប្លង់ និងសាងសង់របស់សហគ្រាស ក្រុមហ៊ុន និងរូបវន្តបុគ្គលបរទេស

# ឧបសម្ព័ន្ធ១

## រូបភាព

# ឧបសម្ព័ន្ធ១.ក

អង្គការលេខក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់



# ឧបសម្ព័ន្ធ១.ខ

រចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ



# ឧបសម្ព័ន្ធ១.គ

បណ្តុំរូបភាពសំណង់អគារដួលរលំនៅខេត្តព្រះសីហនុ នាថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩





# ឧបសម្ព័ន្ធ១.ឃ

បណ្តុំរូបភាពសំណង់អគារដួលរលំនៅខេត្តកែប នាថ្ងៃទី៣ ខែមករា ឆ្នាំ២០២០





# ឧបសម្ព័ន្ធ២

## គំរូឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ច្រកចេញ-ចូលតែមួយ

## ពាក្យសុំលិខិតអនុញ្ញាតសាងសង់

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.......................................................ភេទ........ឆ្នាំកំណើត.................សញ្ជាតិ............. មុខរបរ.............................បច្ចុប្បន្នស្នាក់នៅផ្ទះលេខ........ផ្លូវលេខ........ក្រុមទី..........សង្កាត់................................. ខណ្ឌ.........................................រាជធានីភ្នំពេញ។

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.......................................................ភេទ........ឆ្នាំកំណើត.................សញ្ជាតិ............. មុខរបរ.............................បច្ចុប្បន្នស្នាក់នៅផ្ទះលេខ........ផ្លូវលេខ........ក្រុមទី..........សង្កាត់................................. ខណ្ឌ.........................................រាជធានីភ្នំពេញ។

**សូមគោរពជូន**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**តាមរយៈ** : - ចៅសង្កាត់...............................................................................
- អភិបាលខណ្ឌ...............................................................................
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ

**កម្មវត្ថុ** : សំណើសុំ.................................................................. លើដីឡូត៍លេខ......................ផ្លូវលេខ................ ភូមិ.....................សង្កាត់.......................................ខណ្ឌ.......................................រាជធានីភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំ សូមជម្រាបជូន ឯកឧត្តម មេត្តាជ្រាបថា:

..........................................................................................................................................

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូមឯកឧត្តម មេត្តាអនុញ្ញាតច្បាប់អោយដល់ខ្ញុំបាទ-នាងខ្ញុំ កាន់កាប់ ..................................................................................................ដោយអនុគ្រោះ ។

សូម ឯកឧត្តម មេត្តាទទួលនូវការគោរព ដ៏ខ្ពង់ខ្ពស់បំផុត អំពីខ្ញុំបាទ-នាងខ្ញុំ។

**សូមជូនភ្ជាប់មកជាមួយនូវ :**

- ច្បាប់ថតចំលងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចំនួន.................ច្បាប់
- ប្លង់ស្ថាបត្យកម្ម ចំនួន.................ច្បាប់
- សលាកប័ត្រដីឡូត៍ ចំនួន.................ច្បាប់
- កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន ចំនួន.................ច្បាប់
- កិច្ចសន្យាសាងសង់ ចំនួន.................ច្បាប់
- ច្បាប់ថតចំលងអត្តសញ្ញាណប័ណ្ណ ចំនួន.................ច្បាប់

ភ្នំពេញ,ថ្ងៃទី..........ខែ..............ឆ្នាំ២០.....
**ស្នាមមេដៃស្តាំអ្នកស្នើសុំ**

លេខ:.....................
បានឃើញ និង បញ្ជូនមក
លោកអភិបាលខណ្ឌ.............................
"ដើម្បីពិនិត្យ និងជួយសម្រួលដោយក្តីអនុគ្រោះ"
ភ្នំពេញ, ថ្ងៃទី..........ខែ...............ឆ្នាំ២០.......
**ចៅសង្កាត់**..........................

លេខ:.....................
បានឃើញ និង បញ្ជូនមក
លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម
សំណង់ និងសុរិយោដីរាជធានីភ្នំពេញ។
"ដើម្បីពិនិត្យ និងជួយសម្រួលដោយក្តីអនុគ្រោះ"
ភ្នំពេញ, ថ្ងៃទី..........ខែ...............ឆ្នាំ២០.......
**អភិបាលខណ្ឌ**...........................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ច្រកចេញ-ចូលតែមួយ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## តារាងត្រួតពិនិត្យឯកសារ និងគម្រោងប្លង់ ស្នើសុំលិខិតអនុញ្ញាតសាងសង់

សំណុំលិខិតស្នើសុំលិខិតអនុញ្ញាតសាងសង់ទាំងអស់របស់សាមីសំណើត្រូវធ្វើជាភាសាខ្មែរ ក្នុងករណីបើមានភាសាបរទេសអាចភ្ជាប់មកជាមួយ ដែលមានដូចតទៅ ៖

ក.សំណុំលិខិតសុំអនុញ្ញាតសាងសង់

១-សំណុំលិខិតអនុញ្ញាតសាងសង់មាន ៖

- ពាក្យស្នើសុំ ត្រូវមានការចុះហត្ថលេខា ឬស្នាមមេដៃរបស់សាមីសំណើ ☐
- កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន ត្រូវមានការចុះហត្ថលេខា ឬស្នាមមេដៃរបស់សាមីសំណើ ☐
- រូបថតបង្ហាញទីតាំងដីឡូត៍ស្នើសុំសាងសង់ ☐
- សលាកប័ត្រដីឡូត៍ រៀបចំដោយមន្ទីរ ដនសស រាជធានី/ខេត្ត ☐
- **ក្នុងករណីសំណង់មានផ្ទៃក្រឡាធំជាង ៥០០ម$^2$ (ប្រាំរយម៉ែត្រក្រឡា) ត្រូវមានបន្ថែមនូវ** កិច្ចសន្យារវាងម្ចាស់សំណង់ជាមួយអ្នកសិក្សាគម្រោងប្លង់ស្ថាបត្យកម្ម ដោយភ្ជាប់មកជាមួយនូវ វិញ្ញាបនប័ត្រ ប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ ☐
- **ក្នុងករណីបើសំណង់សាងសង់ជាប់ជញ្ជាំងអឌ្ឍសិទ្ធិ សំណុំលិខិតអនុញ្ញាតសាងសង់ត្រូវភ្ជាប់បន្ថែមនូវ** កិច្ចសន្យាសាងសង់ជាប់ជញ្ជាំងអឌ្ឍសិទ្ធិ ☐
- ផ្សេងៗ.................................................................................................. ☐

២-ឯកសារកាន់កាប់ដីស្របច្បាប់ ថតចម្លង ដែលមានធ្វើនិត្យានុកូលកម្មនៅសាលារាជធានី/ខេត្ត ក្រុង

- ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ☐
- វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ ☐
- ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬ ☐
- កិច្ចសន្យាជួលដី ឬ ☐
- វិញ្ញាបនប័ត្រជួលរយៈពេលវែង ☐
- ផ្សេងៗ.................................................................................................. ☐

៣-អត្តសញ្ញាណសាមីសំណើ

**៣.១ ករណីរូបវន្តបុគ្គល**

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ(ធ្វើនិត្យានុកូលកម្មនៅអាជ្ញាធរមានសមត្ថកិច្ច)ឬ ☐
- លិខិតឆ្លងដែន ឬ ☐
- សៀវភៅគ្រួសារ ☐

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ច្រកចេញ-ចូលតែមួយ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ................................................ភេទ..............អាយុ.........ឆ្នាំ សញ្ជាតិ..................
ថ្ងៃ ខែ ឆ្នាំកំណើត......................................អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនលេខ..........................................
ចុះថ្ងៃទី...........ខែ...............ឆ្នាំ..............មុខរបរ...................................................................................
អាស័យដ្ឋានទាក់ទងផ្ទះលេខ............ផ្លូវ...................ឃុំ/សង្កាត់...........................ក្រុង/ស្រុក/ខណ្ឌ.................
ខេត្ត/រាជធានី.......................... ទូរស័ព្ទទំនាក់ទំនង ....................................... ។

**សូមគោរពជូន**

**ឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់**

**តាមរយៈ :** ប្រធាននាយកដ្ឋានសំណង់

**កម្មវត្ថុ :** សំណើសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់.......................................................................
ដែលមានទីតាំងស្ថិតនៅដីឡូត៍លេខ.................ផ្លូវ.......................ភូមិ...............................................
ឃុំ-សង្កាត់.............................ក្រុង-ស្រុក-ខណ្ឌ.............................រាជធានី-ខេត្ត..........................។

**យោង :** លិខិតអនុញ្ញាតសាងសង់លេខ......................................ចុះថ្ងៃទី............ ខែ..............ឆ្នាំ............ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមឯកឧត្តមមេត្តាអនុញ្ញាតផ្តល់ឲ្យខ្ញុំបាទ-នាងខ្ញុំ នូវលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់.............................................................................. ដែលមានទីតាំងដូចខាងលើដោយអនុគ្រោះ ។

ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាថា អនុវត្តទៅតាមបទបញ្ញាដូចបានចែងក្នុងគម្រោងប្លង់ ប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ បទប្បញ្ញត្តិបច្ចេកទេសសំណង់ និងច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

សូមឯកឧត្តម ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ ។

.................. ថ្ងៃទី............ ខែ..............ឆ្នាំ២០......
ហត្ថលេខា ឬស្នាមមេស្តាំដៃម្ចាស់សំណង់

លេខ :.....................ន/សណ
បានពិនិត្យ និងបញ្ជូនមក
ឯកឧត្តមអគ្គនាយក ដើម្បីពិនិត្យ និងសម្រេច ។
...............ថ្ងៃទី...........ខែ...........ឆ្នាំ២០.....
ប្រធាននាយកដ្ឋានសំណង់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ច្រកចេញ-ចូលតែមួយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## តារាងត្រួតពិនិត្យឯកសារសុំលិខិតអនុញ្ញាតបើកការដ្ឋាន

| ល.រ | រាយឈ្មោះឯកសារ | ចំនួន (ច្បាប់) | លក្ខណៈសម្គាល់ | |
|---|---|---|---|---|
| | | | មាន✓ | គ្មាន× |
| ឯកសារសុំលិខិតអនុញ្ញាតបើកការដ្ឋាន | | | | |
| ១- | លិខិតសុំអនុញ្ញាតបើកការដ្ឋាន (ពាក្យសុំ កិច្ចសន្យារបស់ម្ចាស់សំណង់ កិច្ចសន្យាទទួលខុសត្រូវការដ្ឋាន លិខិតប្រគល់ប្លង់គ្រឿងផ្គុំសំណង់) | ០១ | | |
| ២- | ប្លង់ស្ថាបត្យកម្មបានអនុញ្ញាតដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬដោយសាលារាជធានី ខេត្ត (ផ្អែកតាមសមត្ថកិច្ចចេញលិខិត) | ០២ | | |
| ៣- | លិខិតអនុញ្ញាតសាងសង់របស់សាលារាជធានី ខេត្ត (បើសំណង់ជាសមត្ថកិច្ចរបស់សាលារាជធានី ខេត្ត) ឬរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (បើសំណង់ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់) | ០១ | | |
| ៤- | ប្លង់គ្រឿងផ្គុំសំណង់ ៖ | ០៤ | | |
| | • ស្នាមមេដៃឬហត្ថលេខានិងឈ្មោះរបស់ម្ចាស់សំណើនៅលើគ្រប់សន្លឹកប្លង់ | | | |
| | • ហត្ថលេខា និងឈ្មោះរបស់វិស្វករគណនា និង/ឬហត្ថលេខា និងត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់នៅលើគ្រប់សន្លឹកប្លង់ | | | |
| | -បញ្ជីសន្លឹកប្លង់ | | | |
| | -ប្លង់គ្រឹះ | | | |
| | -លម្អិតគ្រឹះ | | | |
| | -ធ្នឹមគ្រឹះ | | | |
| | -លម្អិតធ្នឹមគ្រឹះ | | | |
| | -ប្លង់សសរ | | | |
| | -លម្អិតសសរ | | | |
| | -ប្លង់ធ្នឹម | | | |
| | -លម្អិតធ្នឹម | | | |
| | -ប្លង់កម្រាល | | | |
| | -លម្អិតកម្រាល | | | |
| | -ប្លង់ជណ្តើរ | | | |
| | -លម្អិតគ្រឿងផ្គុំជណ្តើរ | | | |
| | -ប្លង់ដំបូល | | | |
| | -ធ្នឹមដំបូល | | | |

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ច្រកចេញ-ចូលតែមួយ

| | | | | |
|---|---|---|---|---|
| | •លម្អិតគ្រឿងផ្គុំផ្សេងៗ | | | |
| ៥- | អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ម្ចាស់សំណើ | ០១ | | |
| ៦- | អត្តសញ្ញាណប័ណ្ណរបស់វិស្វករគណនាគ្រឿងផ្គុំសំណង់ | ០១ | | |
| ៧- | វិញ្ញាបនប័ត្រប្រកបអាជីវកម្មសិក្សាគម្រោងប្លង់របស់រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ និង/ឬ ក្រុមហ៊ុនសិក្សាគម្រោងប្លង់ចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០១ | | |
| ៨- | របាយការណ៍សិក្សាពិសោធន៍ដី (ចំពោះគម្រោងធំ ឬអគារខ្ពស់) | ០១ | | |
| ៩- | ឯកសារចាំបាច់ផ្សេងទៀត (បើមាន) | | | |

**ការសន្និដ្ឋានលើឯកសារ**

☐ គ្រប់គ្រាន់ ☐ មិនគ្រប់គ្រាន់ ☐ ចាំបាច់លិខិត ឬឯកសារបន្ថែម

បញ្ជាក់ ៖ ក្នុងករណីសំណុំឯកសារមិនគ្រប់គ្រាន់ អ្នកត្រួតពិនិត្យត្រូវជូនដំណឹងទៅអ្នកស្នើសុំ ឲ្យផ្តល់ឯកសារ បន្ថែម ។

................. ថ្ងៃទី..........ខែ..............ឆ្នាំ២០......

ហត្ថលេខាអ្នកត្រួតពិនិត្យ

*ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ.១៧៧ ដនស/ប្រក.ចុះថ្ងៃទី...០៦.....ខែ..ធ្នូ.........ឆ្នាំ២០១៩....ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់*

*វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

***គំរូទម្រង់***

*សម្រាប់សមត្ថកិច្ចរបស់ក្រសួង*

## ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ........................ភេទ...... សញ្ជាតិ.........ថ្ងៃខែឆ្នាំកំណើត............... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ....................... និងប្រពន្ធ/ ប្តីឈ្មោះ.................. សញ្ជាតិ........ថ្ងៃខែឆ្នាំកំណើត............ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ................ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......ផ្លូវ........ភូមិ..........ឃុំ/ សង្កាត់................ក្រុង/ ស្រុក/ ខណ្ឌ.............. រាជធានី/ ខេត្ត................ តំណាងឱ្យក្រុមហ៊ុន.............................. ចុះបញ្ជីលេខ............. ចុះថ្ងៃទី.... ខែ........ឆ្នាំ......... ទីស្នាក់ការស្ថិតនៅអគារលេខ.................. ភូមិ...............ឃុំ/ សង្កាត់..................... ក្រុង/ ស្រុក/ ខណ្ឌ.................រាជធានី/ ខេត្ត......................។

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**តាមរយៈ**÷ -ប្រធានច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់

**កម្មវត្ថុ** ÷ សំណើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាអនុញ្ញាតផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដល់ខ្ញុំបាទ/ នាងខ្ញុំ ដែលបានសាងសង់រួចរាល់ កាលពីថ្ងៃទី....ខែ......ឆ្នាំ....... ជាប្រភេទសំណង់......................... សាងសង់អំពី................ កំពស់............ ម៉ែត្រ ស្មើនឹង...........ជាន់ ផ្ទៃក្រឡាសំណង់សរុប......................ម² មានទីតាំងស្ថិតនៅលើដីឡូត៍លេខ............... ផ្លូវលេខ............. ភូមិ............... ឃុំ/ សង្កាត់...................... ក្រុង/ ស្រុក/ ខណ្ឌ............... រាជធានី/ ខេត្ត..................។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យនិងសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដល់ខ្ញុំបាទ/ នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/ នាងខ្ញុំ។

**<u>សូមគោរពជូនភ្ជាប់ជាមួយនូវ÷</u>**

១. ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់ម្ចាស់សំណង់ ឬអ្នកតំណាង ចំនួន ០៣ ច្បាប់

២. ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន (ករណីក្រុមហ៊ុន) ចំនួន ០៣ ច្បាប់

៣. លិខិតប្រគល់សិទ្ធិរបស់ក្រុមហ៊ុន (ករណីក្រុមហ៊ុន) ចំនួន ០៣ ច្បាប់

៤. ច្បាប់ចម្លងឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់ ចំនួន ០៣ ច្បាប់

៥. សលាកបត្រក្បាលដីផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំនួន ០៣ ច្បាប់

៦. សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង ចំនួន ០៣ ច្បាប់

៧. របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់(បើមាន) ចំនួន ០៣ ច្បាប់

៨. ច្បាប់ចម្លងកិច្ចសន្យាម៉ៅការសាងសង់(បើមាន) ចំនួន ០៣ ច្បាប់

៩. ច្បាប់ចម្លងឯកសារពាក់ព័ន្ធអ្នកម៉ៅការសាងសង់(បើមាន) ចំនួន ០៣ ច្បាប់

១០. ច្បាប់ចម្លងរបាយការណ៍សិក្សាពិសោធន៍ដីនិងសំភារៈសំណង់(បើមាន) ចំនួន ០៣ ច្បាប់

១១. ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ (បើមាន) ចំនួន ០៣ ច្បាប់

១២. ច្បាប់ចម្លងលិខិតអនុញ្ញាតបើកការដ្ឋាន (បើមាន) ចំនួន ០៣ ច្បាប់

ថ្ងៃ..................... ខែ.......... ឆ្នាំ.................... ព.ស. .........

ធ្វើនៅ............. ថ្ងៃទី...... ខែ.......... ឆ្នាំ.........

**ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកស្នើសុំ**

<u>**បញ្ជាក់:**</u> រាល់ឯកសារថតចម្លង ត្រូវធ្វើនីត្យានុកូលកម្ម នៅអាជ្ញាធរមានសមត្ថកិច្ច ឬមន្ទីរសារការី។

ឧបសម្ព័ន្ធទី ២ នៃប្រកាសលេខ ១៧៧៧ ដ.នសប/ប្រក ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០១៥
ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**
MINISTRY OF LAND MANAGEMENT, URBAN PLANNING AND CONSTRUCTION
លេខ/N°: ....................................

**ព្រះរាជាណាចក្រកម្ពុជា**
KINGDOM OF CAMBODIA
**ជាតិ សាសនា ព្រះមហាក្សត្រ**
NATION RELIGION KING

# វិញ្ញាបនបត្រប្រើប្រាស់សំណង់
# CERTIFICATE OF OCCUPANCY

- សំណង់អំពី................................... កម្ពស់...................... ម៉ែត្រ ស្មើនឹង...................... ជាន់ ផ្ទៃក្រឡាកម្រាលសំណង់សរុប.................................................. ម²
  CONSTRUCTION BUILT OF...........; HEIGHT.................M, ...................STORIES, TOTAL AREA .................................................. M²
- ទីតាំងសំណង់÷ ក្បាលដីលេខ................... ផ្លូវ............ ភូមិ.................... ឃុំ/សង្កាត់................. ក្រុង/ស្រុក/ខណ្ឌ.................. រាជធានី/ខេត្ត..................
  LOCATION: LAND TITLE N°:........, ST.::........VILLAGE:........., COMMUNE/SANGKAT:..............., KRONG/SROK/KHAN:..............., CAPITAL/PROVINCE:...............
- ម្ចាស់សំណង់÷.................................................................................... -មុខងារប្រើប្រាស់សំណង់ ..........................................................
  OWNER: .................................................................................... USE OF THE CONSTRUCTION: ..........................................
- ថ្ងៃចាប់ផ្តើមសាងសង់.................... ថ្ងៃបញ្ចប់ការសាងសង់......................... -សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែងលេខ.................. ចុះថ្ងៃទី..... ខែ........ ឆ្នាំ...........
  CONSTRUCTION DATE: STARTED:.......................; COMPLETED:.......................AS BUILT DRAWING N°......................DATED:..........................................
- របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ចុះថ្ងៃទី............ ខែ................ ឆ្នាំ.......... អនុវត្តដោយ ..........................................................
  CONSTRUCTION QUALITY AND SAFETY INSPECTION REPORT DATED:........................ DONE BY:..................................................................

សម្គាល់÷ នៅពេលមានការផ្លាស់ប្តូរមុខងារប្រើប្រាស់សំណង់ និង/ឬការកែប្រែគ្រឿងផ្គុំសំណង់ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។
REMARK: WHEN THERE IS A CHANGE OF THE USE OF THE CONSTRUCTION AND/OR A CHANGE OF THE CONSTRUCTION STRUCTURE, THE OWNER SHALL SUBMIT REQUEST FOR A NEW CERTIFICATE OF OCCUPANCY.

ថ្ងៃ................................ ខែ.............. ឆ្នាំ................. ព.ស. ..........

រាជធានីភ្នំពេញ ថ្ងៃទី ............ ខែ ............ ឆ្នាំ ..............
PHNOM PENH, DATE ...............................................

**ជ.រដ្ឋមន្ត្រី**
**FOR THE MINISTER**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**និមិត្តសញ្ញាស្ថាប័នឬក្រុមហ៊ុន**
**អ្នកត្រួតពិនិត្យនិងបញ្ជាក់**

# របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់

## ១. ព័ត៌មានទូទៅ

ម្ចាស់សំណង់ឈ្មោះ.................................ភេទ....... សញ្ជាតិ........ថ្ងៃខែឆ្នាំកំណើត.................. កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ....................... និងប្រពន្ធ/ ប្តីឈ្មោះ.............. សញ្ជាតិ................ថ្ងៃខែឆ្នាំកំណើត.................... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ ...................... មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.........ផ្លូវ.............ភូមិ.............ឃុំ/ សង្កាត់................ ក្រុង/ ស្រុក/ ខណ្ឌ........................រាជធានី/ ខេត្ត..........................តំណាងឱ្យក្រុមហ៊ុន.....................

............................................... ចុះបញ្ជីលេខ....................... ចុះថ្ងៃទី...... ខែ...........ឆ្នាំ.......... ទីស្នាក់ការស្ថិតនៅអគារលេខ................. ភូមិ......................ឃុំ/ សង្កាត់..................................ក្រុង/ ស្រុក/ ខណ្ឌ.................រាជធានី/ ខេត្ត............................លេខទូរស័ព្ទ...............................។

ក- ទីតាំងស្នើសុំប្រើប្រាស់ផ្ទះលេខ.........ផ្លូវ................ភូមិ...................ឃុំ/ សង្កាត់............................. ក្រុង/ ស្រុក/ ខណ្ឌ...................រាជធានី/ ខេត្ត.................... (ករណីបើខុសពីអាសយដ្ឋានរបស់ម្ចាស់សំណង់)

ខ- ប្រភេទសំណង់៖ □ភូមិគ្រឹះ □ផ្ទះល្វែង □សណ្ឋាគារ ឬផ្ទះសំណាក់ □អគារស្នាក់នៅរួម □គ្រឹះស្ថានសាធារណៈ □រោងចក្រ □ផ្សេងៗ.........................................................................................

គ- មុខងារប្រើប្រាស់អគារបច្ចុប្បន្ន៖.................................................................................................

ឃ- ប្រភេទគ្រឿងផ្គុំសំណង់៖ □បេតុងសរសៃដែក □បេតុងដែក □ដែក □ឈើ □ផ្សេងៗ
...............................................................................................................................

ង- ឯកសារគតិយុត្ត៖

– លិខិតអនុញ្ញាតសាងសង់លេខ...................................ចុះថ្ងៃទី.........ខែ.............ឆ្នាំ..........
– លិខិតអនុញ្ញាតបើកការដ្ឋានសាងសង់លេខ...........................ចុះថ្ងៃទី.........ខែ.........ឆ្នាំ..........
– លិខិតអនុញ្ញាតផ្សេងៗ ........................................................................................

## ២. លទ្ធផលនៃការត្រួតពិនិត្យសំណង់

### ក. ព័ត៌មានក្បាលដី

– វិញ្ញាបនបត្រ/ បណ្ណ ......................លេខ........................ចុះថ្ងៃទី..........ខែ...........ឆ្នាំ.........
– សលាកបត្រក្បាលដីលេខ.......................................ចុះថ្ងៃទី.........ខែ.............ឆ្នាំ............
– ទំហំដី ..............................ម$^2$
– កិច្ចសន្យាជួលដី ចុះថ្ងៃទី.........ខែ...........ឆ្នាំ..........

## ខ. ផ្នែករៀបចំដែនដីនិងនគរូបនីយកម្ម

### ខ.១- ប្លាគម្លាត

| ប្លាគម្លាតជាក់ស្តែង | ប្លាគម្លាតក្នុងលិខិតអនុញ្ញាត |
|---|---|
| គម្លាតខាងមុខ ៖ឆ្វេង...............ម ស្តាំ................ម | គម្លាតខាងមុខ ៖ឆ្វេង.................ម ស្តាំ.................ម |
| គម្លាតខាងក្រោយ ៖ឆ្វេង...............ម ស្តាំ................ម | គម្លាតខាងក្រោយ ៖ឆ្វេង.................ម ស្តាំ.................ម |
| គម្លាតចំហៀងខាងឆ្វេង៖មុខ................ម ក្រោយ............ម | គម្លាតចំហៀងខាងឆ្វេង៖មុខ.................ម ក្រោយ............ម |
| គម្លាតចំហៀងខាងស្តាំ ៖មុខ................ម ក្រោយ............ម | គម្លាតចំហៀងខាងស្តាំ ៖មុខ.................ម ក្រោយ.............ម |

### ខ.២- ផ្ទៃក្រឡាកម្រាលសំណង់

| ផ្ទៃក្រឡាកម្រាលសំណង់ជាក់ស្តែង | ផ្ទៃក្រឡាកម្រាលសំណង់ក្នុងលិខិតអនុញ្ញាត |
|---|---|
| ជាន់ក្រោមដី.............ជាន់<br>ផ្ទៃក្រឡាសំណង់...........................................ម$^{២}$ ក្នុង១ជាន់ | ជាន់ក្រោមដី..............ជាន់<br>ផ្ទៃក្រឡាសំណង់.............................................ម$^{២}$ ក្នុង១ជាន់ |
| ជាន់ផ្ទាល់ដី ផ្ទៃក្រឡាសំណង់.......................................ម$^{២}$ | ជាន់ផ្ទាល់ដី ផ្ទៃក្រឡាសំណង់..........................................ម$^{២}$ |
| ជាន់ឡៅតឿ ផ្ទៃក្រឡាសំណង់.......................................ម$^{២}$ | ជាន់ឡៅតឿ ផ្ទៃក្រឡាសំណង់..........................................ម$^{២}$ |
| ជាន់ទី............ដល់ជាន់ទី.............<br>ផ្ទៃក្រឡាសំណង់...........................................ម$^{២}$ ក្នុង១ជាន់ | ជាន់ទី..............ដល់ជាន់ទី...............<br>ផ្ទៃក្រឡាសំណង់.............................................ម$^{២}$ ក្នុង១ជាន់ |
| ជាន់ទី............ដល់ជាន់ទី.............<br>ផ្ទៃក្រឡាសំណង់...........................................ម$^{២}$ ក្នុង១ជាន់ | ជាន់ទី..............ដល់ជាន់ទី..............<br>ផ្ទៃក្រឡាសំណង់.............................................ម$^{២}$ ក្នុង១ជាន់ |
| ជាន់ទី............ដល់ជាន់ទី.............<br>ផ្ទៃក្រឡាសំណង់...........................................ម$^{២}$ ក្នុង១ជាន់ | ជាន់ទី..............ដល់ជាន់ទី.............<br>ផ្ទៃក្រឡាសំណង់.............................................ម$^{២}$ ក្នុង១ជាន់ |
| ជាន់ទី............ដល់ជាន់ទី............<br>ផ្ទៃក្រឡាសំណង់...........................................ម$^{២}$ ក្នុង១ជាន់ | ជាន់ទី..............ដល់ជាន់ទី............<br>ផ្ទៃក្រឡាសំណង់.............................................ម$^{២}$ ក្នុង១ជាន់ |
| ផ្ទៃក្រឡាកម្រាលសំណង់សរុប........................................ម$^{២}$ | ផ្ទៃក្រឡាកម្រាលសំណង់សរុប..........................................ម$^{២}$ |
| ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍.....................ម$^{២}$ | ផ្ទៃក្រឡាកម្រាលសំណង់លើកលែងសន្ទស្សន៍.....................ម$^{២}$ |
| ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ............................ម$^{២}$ | ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ..............................ម$^{២}$ |

### ខ.៣- កម្ពស់

| កម្ពស់ជាក់ស្តែង | កម្ពស់ក្នុងលិខិតអនុញ្ញាត |
|---|---|
| ជាន់ក្រោមដីចំនួន............ជាន់ កម្ពស់................ម ក្នុង១ជាន់ | ជាន់ក្រោមដីចំនួន.......ជាន់ កម្ពស់........ម ក្នុង១ជាន់ |
| ជាន់ផ្ទាល់ដីកម្ពស់................ម | ជាន់ផ្ទាល់ដីកម្ពស់................ម |
| ជាន់ទី.........ដល់ជាន់ទី...........កម្ពស់...............ម ក្នុង១ជាន់ | ជាន់ទី.........ដល់ជាន់ទី...........កម្ពស់................ម ក្នុង១ជាន់ |
| ជាន់ទី.........ដល់ជាន់ទី...........កម្ពស់...............ម ក្នុង១ជាន់ | ជាន់ទី.........ដល់ជាន់ទី...........កម្ពស់................ម ក្នុង១ជាន់ |
| ជាន់ទី.........ដល់ជាន់ទី...........កម្ពស់...............ម ក្នុង១ជាន់ | ជាន់ទី.........ដល់ជាន់ទី...........កម្ពស់................ម ក្នុង១ជាន់ |
| ជាន់ទី.........ដល់ជាន់ទី...........កម្ពស់...............ម ក្នុង១ជាន់ | ជាន់ទី.........ដល់ជាន់ទី...........កម្ពស់................ម ក្នុង១ជាន់ |
| កម្ពស់សរុប ...........................ម | កម្ពស់សរុប ...........................ម |

ខ.៤-ផ្សេងៗ

| ជាក់ស្តែង | ក្នុងលិខិតអនុញ្ញាត |
|---|---|
| ផលធៀបក្រឡាផ្ទៃបាតសំណង់ (BCR) ៖ .............% | ផលធៀបក្រឡាផ្ទៃបាតសំណង់ (BCR) ៖ ..............% |
| សន្ទស្សន៍ប្រើប្រាស់ដី (FAR) ៖..........................% | សន្ទស្សន៍ប្រើប្រាស់ដី (FAR) ៖......................% |
| សន្ទស្សន៍ប្រើប្រាស់ដី (FAR) ៖..........................% | សន្ទស្សន៍ប្រើប្រាស់ដី (FAR) ៖ .....................% |
| **ការប្រើប្រាស់លំហសាធារណៈ**<br>ផ្លូវ □គ្មាន □មាន ទទឹងផ្លូវ............ម បណ្តោយផ្លូវ............ម<br>សួន □គ្មាន □មាន ផ្ទៃក្រឡាសរុប................................ម²<br>លំហផ្សេងៗ.............................................................. | **ការប្រើប្រាស់លំហសាធារណៈ**<br>ផ្លូវ □គ្មាន □មាន ទទឹងផ្លូវ............ម បណ្តោយផ្លូវ............ម<br>សួន □គ្មាន □មាន ផ្ទៃក្រឡាសរុប..................................ម²<br>លំហផ្សេងៗ................................................................ |

**គ. ផ្នែកស្ថាបត្យកម្មនិងសំណង់**

**គ.១-គម្រោងប្លង់ស្ថាបត្យកម្ម** □មាន □គ្មាន អ្នកសិក្សាគម្រោងប្លង់.....................................................

□គ្មានអាជ្ញាប័ណ្ណ□មានអាជ្ញាប័ណ្ណលេខ.......................ចុះថ្ងៃទី......ខែ............ឆ្នាំ........

**គ.២-ការសិក្សាពិសោធន៍ភូគព្ភសាស្ត្រ** ថ្ងៃទី....... ខែ............ឆ្នាំ ............

សិក្សាដោយ..................................មន្ទីរពិសោធន៍..............................................

**គ.៣- គម្រោងប្លង់គ្រឿងផ្គុំសំណង់**

**គ.៣.១-ប្លង់គ្រឿងផ្គុំសំណង់៖** □គ្មាន □មាន អ្នកសិក្សាគម្រោងប្លង់ ...................................

□គ្មានអាជ្ញាប័ណ្ណ □មានអាជ្ញាប័ណ្ណ លេខ......................ចុះថ្ងៃទី......ខែ.........ឆ្នាំ......

**គ.៣.២-បទដ្ឋានបច្ចេកទេសសំណង់ជាមូលដ្ឋាន៖**.......................................................

**គ.៣.៣-សសរគ្រឹះ៖**

- **សសរគ្រឹះជាក់ស្តែង**

| ប្រភេទ | កម្លាំងបេតុង (MPA) | ប្រវែង(ម) | មុខកាត់( ស.ម) | | ដែក ( ម.ម) |
|---|---|---|---|---|---|
| | | | បណ្តោយ | ទទឹង | |
| | | | | | -ដែកមេ៖មុខកាត់...........កម្លាំង:...........<br>-ដែកកង៖មុខកាត់...........កម្លាំង:..........<br>-គម្លាតដែកកង៖............... |
| | | | | | -ដែកមេ៖មុខកាត់...........កម្លាំង:...........<br>-ដែកកង៖មុខកាត់...........កម្លាំង:..........<br>-គម្លាតដែកកង៖............... |

- សសរគ្រឹះក្នុងលិខិតអនុញ្ញាតសាងសង់

| ប្រភេទ | កម្លាំងបេតុង (MPA) | ប្រវែង(ម) | មុខកាត់(ស.ម) | | ដែក (ម.ម) |
|---|---|---|---|---|---|
| | | | បណ្ដោយ | ទទឹង | |
| | | | | | -ដែកមេ៖មុខកាត់...........កម្លាំង:............<br>-ដែកកង៖មុខកាត់...........កម្លាំង:............<br>-គម្លាតដែកកង៖.............. |
| | | | | | -ដែកមេ៖មុខកាត់...........កម្លាំង:...........<br>-ដែកកង៖មុខកាត់...........កម្លាំង:...........<br>-គម្លាតដែកកង៖............... |

គ.៣.៤-គ្រឹះ៖

- គ្រឹះជាក់ស្ដែង

| ប្រភេទ | កម្លាំងបេតុង (MPA) | ទំហំ (មxម) | មុខកាត់(ស.ម) | | ដែក |
|---|---|---|---|---|---|
| | | | បណ្ដោយ | ទទឹង | |
| | | | | | -ដែកមេ៖មុខកាត់...........កម្លាំង:...........<br>-ដែកកង៖មុខកាត់...........កម្លាំង:...........<br>-គម្លាតដែកកង៖............... |
| | | | | | -ដែកមេ៖មុខកាត់...........កម្លាំង:...........<br>-ដែកកង៖មុខកាត់...........កម្លាំង:..........<br>-គម្លាតដែកកង៖............... |

- គ្រឹះក្នុងលិខិតអនុញ្ញាតសាងសង់

| ប្រភេទ | កម្លាំងបេតុង (MPA) | ទំហំ (មxម) | មុខកាត់(ស.ម) | | ដែក |
|---|---|---|---|---|---|
| | | | បណ្ដោយ | ទទឹង | |
| | | | | | -ដែកមេ៖មុខកាត់...........កម្លាំង:...........<br>-ដែកកង៖មុខកាត់...........កម្លាំង:...........<br>-គម្លាតដែកកង៖............... |
| | | | | | -ដែកមេ៖មុខកាត់...........កម្លាំង:............<br>-ដែកកង៖មុខកាត់...........កម្លាំង:............<br>-គម្លាតដែកកង៖.............. |

គ.៣.៥-ធ្នឹមគ្រឹះ៖

- **ធ្នឹមគ្រឹះជាក់ស្ដែង**

| ជាន់ | ប្រភេទ | កម្លាំងបេតុង (MPA) | ប្រវែង(ម) | មុខកាត់(ស.ម) | | ដែក និងកម្រាស់បេតុងការពារដែក |
|---|---|---|---|---|---|---|
| | | | | បណ្ដោយ | ទទឹង | |
| | | | | | | -មុខកាត់ដែកមេ៖........................<br>-មុខកាត់ដែកកង៖.......................<br>-គម្លាតដែកកង៖.........................<br>-កម្រាស់បេតុងការពារដែក:........... |
| | | | | | | -មុខកាត់ដែកមេ៖........................<br>-មុខកាត់ដែកកង៖.......................<br>-គម្លាតដែកកង៖.........................<br>-កម្រាស់បេតុងការពារដែក៖........... |
| | | | | | | -មុខកាត់ដែកមេ៖..........................<br>-មុខកាត់ដែកកង៖.........................<br>-គម្លាតដែកកង៖............................<br>-កម្រាស់បេតុងការពារដែក៖.............. |

- **ធ្នឹមគ្រឹះក្នុងលិខិតអនុញ្ញាតសាងសង់**

| ជាន់ | ប្រភេទ | កម្លាំងបេតុង (MPA) | ប្រវែង(ម) | មុខកាត់(ស.ម) | | ដែក និងកម្រាស់បេតុងការពារដែក |
|---|---|---|---|---|---|---|
| | | | | បណ្ដោយ | ទទឹង | |
| | | | | | | -មុខកាត់ដែកមេ៖..........................<br>-មុខកាត់ដែកកង៖.........................<br>-គម្លាតដែកកង៖............................<br>-កម្រាស់បេតុងការពារដែក៖.............. |
| | | | | | | -មុខកាត់ដែកមេ៖..........................<br>-មុខកាត់ដែកកង៖.........................<br>-គម្លាតដែកកង៖............................<br>-កម្រាស់បេតុងការពារដែក៖............. |
| | | | | | | -មុខកាត់ដែកមេ៖.......................... |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | -មុខកាត់ដែកកង៖........................<br>-គម្លាតដែកកង៖..........................<br>-កម្រាស់បេតុងការពារដែក៖.............. |

 គ.៣.៦-សសរ

- សសរជាក់ស្តែង

| ជាន់ | ប្រភេទ | កម្លាំងបេតុង (MPA) | កម្ពស់ (ម) | បណ្តោយ (ម) | ទទឹង (ម) | ដែក និងកម្រាស់បេតុងការពារដែក |
|---|---|---|---|---|---|---|
| | | | | | | -មុខកាត់ដែកមេ៖.......................<br>-មុខកាត់ដែកកង៖.......................<br>-គម្លាតដែកកង៖.........................<br>-កម្រាស់បេតុងការពារដែក៖........... |
| | | | | | | -មុខកាត់ដែកមេ៖.......................<br>-មុខកាត់ដែកកង៖.......................<br>-គម្លាតដែកកង៖.........................<br>-កម្រាស់បេតុងការពារដែក៖........... |
| | | | | | | -មុខកាត់ដែកមេ៖.......................<br>-មុខកាត់ដែកកង៖.......................<br>-គម្លាតដែកកង៖.........................<br>-កម្រាស់បេតុងការពារដែក៖........... |

- សសរក្នុងលិខិតអនុញ្ញាត

| ជាន់ | ប្រភេទ | កម្លាំងបេតុង (MPA) | ប្រវែង(ម) | មុខកាត់(ស.ម) | | ដែក និងកម្រាស់បេតុងការពារដែក |
|---|---|---|---|---|---|---|
| | | | | បណ្តោយ | ទទឹង | |
| | | | | | | -មុខកាត់ដែកមេ៖.........................<br>-មុខកាត់ដែកកង៖.........................<br>-គម្លាតដែកកង៖...........................<br>-កម្រាស់បេតុងការពារដែក៖............. |
| | | | | | | -មុខកាត់ដែកមេ៖.........................<br>-មុខកាត់ដែកកង៖.........................<br>-គម្លាតដែកកង៖........................... |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | -កម្រាស់បេតុងការពារដែក៖............. |
| | | | | | | -មុខកាត់ដែកមេ៖.........................<br>-មុខកាត់ដែកកង៖.........................<br>-គម្លាតដែកកង៖..........................<br>-កម្រាស់បេតុងការពារដែក៖............. |

គ.៣.៧- ប្លង់កម្រាល ៖

- **ប្លង់កម្រាលជាក់ស្តែង**

| ជាន់ | ប្រភេទ | កម្លាំងបេតុង (MPA) | កម្រាស់ (ម) | បណ្តោយ (ម) | ទទឹង (ម) | ដែក និងកម្រាស់បេតុងការពារដែក |
|---|---|---|---|---|---|---|
| | | | | | | -មុខកាត់ដែកមេ៖.........................<br>-មុខកាត់ដែកកង៖.......................<br>-គម្លាតដែកកង៖.........................<br>-កម្រាស់បេតុងការពារដែក៖........... |
| | | | | | | -មុខកាត់ដែកមេ៖.........................<br>-មុខកាត់ដែកកង៖.......................<br>-គម្លាតដែកកង៖.........................<br>-កម្រាស់បេតុងការពារដែក៖........... |
| | | | | | | -មុខកាត់ដែកមេ៖.........................<br>-មុខកាត់ដែកកង៖.......................<br>-គម្លាតដែកកង៖.........................<br>-កម្រាស់បេតុងការពារដែក៖........... |

- **ប្លង់កម្រាលក្នុងលិខិតអនុញ្ញាត**

| ជាន់ | ប្រភេទ | កម្លាំងបេតុង (MPA) | កម្រាស់ (ម) | បណ្តោយ (ម) | ទទឹង (ម) | ដែក និងកម្រាស់បេតុងការពារដែក |
|---|---|---|---|---|---|---|
| | | | | | | -មុខកាត់ដែកមេ៖.........................<br>-មុខកាត់ដែកកង៖.......................<br>-គម្លាតដែកកង៖.........................<br>-កម្រាស់បេតុងការពារដែក៖........... |
| | | | | | | -មុខកាត់ដែកមេ៖......................... |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | -មុខកាត់ដែកកង៖.......................<br>-គម្លាតដែកកង៖........................<br>-កម្រាស់បេតុងការពារដែក៖............ |
| | | | | | | -មុខកាត់ដែកមេ៖.......................<br>-មុខកាត់ដែកកង៖.......................<br>-គម្លាតដែកកង៖........................<br>-កម្រាស់បេតុងការពារដែក៖............ |

**គ.៣.៤-ប្រភេទដំបូល ៖** ☐កម្រាលបេតុង ☐ក្បឿង ☐ហ្វីប្រូ ☐ស័ង្កសី
☐ផ្សេងៗ ...................................................

- **ប្រភេទគ្រឿងផ្ដុំដំបូល ៖** ☐បេតុង ☐ដែក ☐ឈើ

**២. សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់**

- **ដែក (ម៉ាក** ........................................... **ស្តង់ដា** .................................. )
- **បេតុង** .................................................................................................
- **ស៊ីម៉ងត៍ (ឆ្នាំផលិត** ................................. **ម៉ាក** .....................................)
- **ថ្ម** ..........................................................................................................
- **ខ្សាច់ (ប្រភេទ)** .......................................................................................
- **កញ្ចក់**.....................................................................................................
- **ផ្សេងៗ**...................................................................................................

**៣. សុវត្ថិភាពអគ្គិភ័យ**

**-ប្រព័ន្ធពន្លត់អគ្គិភ័យ** ☐មានប្លង់ ☐គ្មានប្លង់

- ទុយោពន្លត់អគ្គិភ័យ ☐មាន ☐គ្មាន ☐ត្រឹមត្រូវ ☐មិនត្រឹមត្រូវ
- ក្បាលបាញ់ទឹកពិដាន ☐មាន ☐គ្មាន ☐ត្រឹមត្រូវ ☐មិនត្រឹមត្រូវ
- ទ្វារការពារអគ្គិភ័យ ☐មាន ☐គ្មាន ☐ត្រឹមត្រូវ ☐មិនត្រឹមត្រូវ
- បំពង់ពន្លត់អគ្គិភ័យ ☐មាន ☐គ្មាន ☐ត្រឹមត្រូវ ☐មិនត្រឹមត្រូវ
- Smoke Sensor ☐មាន ☐គ្មាន ☐ត្រឹមត្រូវ ☐មិនត្រឹមត្រូវ
- កណ្ដឹងប្រកាសអាសន្ន ☐មាន ☐គ្មាន ☐ត្រឹមត្រូវ ☐មិនត្រឹមត្រូវ
- អាងស្តុកទឹកក្រោមដី ☐មាន ☐គ្មាន ☐ត្រឹមត្រូវ ☐មិនត្រឹមត្រូវ
- ក្បាលបំពង់បូមពន្លត់អគ្គិភ័យ ☐មាន ☐គ្មាន ☐ត្រឹមត្រូវ ☐មិនត្រឹមត្រូវ
- ជណ្ដើរអាសន្ន ☐មាន ☐គ្មាន ☐ត្រឹមត្រូវ ☐មិនត្រឹមត្រូវ
- ច្រកសុវត្ថិភាព ☐មាន ☐គ្មាន ☐ត្រឹមត្រូវ ☐មិនត្រឹមត្រូវ

- សញ្ញាសម្គាល់ច្រកសុវត្ថិភាព ☐មាន ☐គ្មាន ☐ត្រឹមត្រូវ ☐មិនត្រឹមត្រូវ

៤-ប្រព័ន្ធបច្ចេកទេស

- លំហពន្លឺ និងខ្យល់ ☐មាន ☐គ្មាន ☐ត្រឹមត្រូវ ☐មិនត្រឹមត្រូវ
- ប្រព័ន្ធមេកានិកនិងអគ្គិសនី ☐មានប្លង់ ☐គ្មានប្លង់ សិក្សាដោយ៖..........................
  ☐មានអាជ្ញាប័ណ្ណលេខ.................................ចុះថ្ងៃទី.........ខែ...........ឆ្នាំ...........
  ☐គ្មានអាជ្ញាប័ណ្ណ
- ប្រព័ន្ធទឹកស្អាត☐គ្មានប្លង់☐មានប្លង់ សិក្សាដោយ÷..............................................
  ☐មានអាជ្ញាប័ណ្ណ លេខ..............................ចុះថ្ងៃទី.........ខែ..............ឆ្នាំ.........
  ☐គ្មានអាជ្ញាប័ណ្ណ
- ប្រព័ន្ធលូទឹកភ្លៀង ទឹកកខ្វក់ ☐មានប្លង់ ☐គ្មានប្លង់
  ☐មានអាជ្ញាប័ណ្ណលេខ.............................ចុះថ្ងៃទី.......ខែ..............ឆ្នាំ.............
  ☐គ្មានអាជ្ញាប័ណ្ណ
- ប្រព័ន្ធការពាររន្ទះ ☐មាន ☐គ្មាន ☐ត្រឹមត្រូវ ☐មិនត្រឹមត្រូវ

ថ្ងៃ........................ ខែ................... ឆ្នាំ................... ព.ស. .........

........................ថ្ងៃទី ...........ខែ...............ឆ្នាំ............

**ស្នាមមេដៃស្តាំម្ចាស់សំណង់ឬតំណាង**

ឈ្មោះ .................

**ហត្ថលេខានិងឈ្មោះអ្នកត្រួតពិនិត្យ**

ប្រធាន ..................

សមាជិក ..................

សមាជិក ..................

សមាជិក ..................

សមាជិក ..................

**ការវាយតម្លៃ**

ផ្នែកសុរិយោដី

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

ផ្នែករៀបចំដែនដីនិងនគរូបនីយកម្ម

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

ផ្នែកស្ថាបត្យកម្មនិងគ្រឿងផ្គុំសំណង់

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

**សេចក្តីសន្និដ្ឋាន**

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

ថ្ងៃ.......................... ខែ..................... ឆ្នាំ................... ព.ស. .........

.......................... ថ្ងៃទី .........ខែ.............ឆ្នាំ.............

ប្រធានក្រុមត្រួតពិនិត្យសំណង់/នាយកបច្ចេកទេស

__**សម្គាល់ ÷**__

- ម្ចាស់សំណង់ឬតំណាងត្រូវផ្តិតមេដៃស្តាំលើគ្រប់ទំព័រនៃរបាយការណ៍
- អ្នកធ្វើរបាយការណ៍មានសិទ្ធិបន្ថែមព័ត៌មានផ្សេងទៀតក្នុងករណីចាំបាច់
- របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពត្រូវមានភ្ជាប់ឯកសារបច្ចេកទេសពាក់ព័ន្ធ
- ករណីរបាយការណ៍ផ្តល់ដោយក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ឬក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ នាយកបច្ចេកទេសរបស់ក្រុមហ៊ុនត្រូវចុះហត្ថលេខាដោយផ្ទាល់ និងមានបោះត្រាក្រុមហ៊ុន។

# ឧបសម្ព័ន្ធ៣

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ

# ឧបសម្ព័ន្ធ៣.ក

ច្បាប់ស្តីពីសំណង់ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១៧/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

## ព្រះរាជក្រម

នស/រកម/១១១៩/ ០១៩

### យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីសំណង់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# សំណង់

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះមានគោលបំណងធានា៖

- គុណភាព សន្តិសុខ សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិនិងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន
- សោភណភាពនិងបរិស្ថានល្អសម្រាប់ការរស់នៅប្រកបដោយចីរភាព សំដៅលើកកម្ពស់សុខុមាលភាពសាធារណៈ
- គណនេយ្យភាពនិងប្រសិទ្ធភាពក្នុងការប្រកបការងារនិងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់
- ការបង្កើនការជឿទុកចិត្តរបស់វិនិយោគិននៅក្នុងវិស័យសំណង់ និងជំរុញទីផ្សារអចលនទ្រព្យប្រកបដោយប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនិងសង្គម។

**មាត្រា២ .-**

ច្បាប់នេះមានគោលដៅកំណត់គោលការណ៍ បទប្បញ្ញត្តិបច្ចេកទេសសំណង់ វិធាន និងនីតិវិធីក្នុងការគ្រប់គ្រងវិស័យសំណង់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះវិស័យសំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែប្រភេទសំណង់ដែលកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៤ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥ .-**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់ដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៣
## គោលការណ៍

**មាត្រា៦ .-**

រាល់ការងារសំណង់ត្រូវគោរពគោលការណ៍៖

- ការពារផលប្រយោជន៍សាធារណៈនិងសិទ្ធិបុគ្គល
- ប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន
- រៀបចំដែនដីនិងនគរូបនីយកម្ម
- អភិវឌ្ឍបៃតង ការពារធនធានធម្មជាតិ និងបរិស្ថាន
- រក្សានិងលើកកម្ពស់អត្តសញ្ញាណជាតិ។

## ជំពូកទី៤

## បទប្បញ្ញត្តិបច្ចេកទេសសំណង់

**មាត្រា៧ .-**

រាល់ការងារសំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ការត្រួតពិនិត្យអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវអនុវត្តដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

លក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨ .-**

រាល់សំណង់ត្រូវមានគ្រឿងផ្គុំដែលអាចទ្ររាល់បន្ទុកបានប្រកបដោយសុវត្ថិភាព ទៅតាមមុខងារប្រើប្រាស់របស់សំណង់ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពគ្រឿងផ្គុំត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៩ .-**

រាល់សំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិសុវត្ថិភាពអគ្គិភ័យ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពអគ្គិភ័យលើសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១០ .-**

បទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់ត្រូវដាក់ឱ្យប្រើប្រាស់ដោយអនុក្រឹត្យតាមសំណើរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់។

បទប្បញ្ញត្តិបច្ចេកទេសសំណង់ដទៃទៀតក្រៅពីបទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់ ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលតម្រូវឱ្យអនុវត្តតាមស្តង់ដារណាមួយជាកំណត់ ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យ

ឧស្សាហកម្ម តាមសំណើរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងតាមការសម្រេចរបស់ក្រុមប្រឹក្សាស្តង់ដាជាតិ។

បទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដទៃទៀតដែលមិនទាន់ត្រូវបានកំណត់ជាស្តង់ដាកម្ពុជា ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១១ .-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ដែលមានរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាននិងមានតំណាងក្រសួងស្ថាប័ននិងវិស័យឯកជនពាក់ព័ន្ធជាសមាជិក។

ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥
## ការគ្រប់គ្រងអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់

**មាត្រា១២ .-**

រូបវន្តបុគ្គលដែលអាចបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ត្រូវចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធនីមួយៗនៃវិស័យសំណង់។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈវិជ្ជាជីវៈនីមួយៗពាក់ព័ន្ធនឹងវិស័យសំណង់ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

**មាត្រា១៣ .-**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។

ក្រមសីលធម៌សម្រាប់អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៤ .-**

ការគ្រប់គ្រងអ្នកជំនាញក្នុងវិស័យសំណង់ផ្សេងទៀតដែលមិនទាន់បានបង្កើតគណៈវិជ្ជាជីវៈត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦
## ការគ្រប់គ្រងការប្រកបវិជ្ជាជីវៈនិងការប្រកបអាជីវកម្មក្នុងវិស័យសំណង់

**មាត្រា១៥ .-**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ដែលអាចប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ដោយឯករាជ្យបាន ត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ដែលបំពេញមុខងារជានាយកបច្ចេកទេសនៃក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ មិនតម្រូវឱ្យមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឡើយ។

នាយកបច្ចេកទេសនៃក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវបំពេញមុខងារដោយឯករាជ្យស្របតាមក្រមសីលធម៌វិជ្ជាជីវៈនិងបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

**មាត្រា១៦ .-**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈ ក្នុងករណីណាមួយដូចខាងក្រោម៖

- លែងបំពេញលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈ
- បានប្រព្រឹត្តកំហុសវិជ្ជាជីវៈដែលនាំទៅដល់ការផ្អាកឬការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ
- មានបញ្ហាសុខភាពដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈ ដោយមានបញ្ជាក់ពីគ្រូពេទ្យជំនាញឬបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភដោយតុលាការ
- បានទទួលការប្រកាសក្ស័យធនដោយតុលាការ
- ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ។

ការផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់មិនត្រូវលើសពី៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃផ្អាកអាជ្ញាបណ្ណ។

នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់អាចត្រូវបានផ្តល់ឡើងវិញ ក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។

ក្នុងករណីបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈដោយមូលហេតុត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈនេះ អាចត្រូវបានផ្តល់ឡើងវិញ បន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា១៧ .-**

រាល់ការប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ឬលិខិតអនុញ្ញាតរបស់រដ្ឋបាលរាជធានី ខេត្តទៅតាមប្រភេទអាជីវកម្ម។

**មាត្រា១៨ .-**

ក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងករណីណាមួយដូចខាងក្រោម៖

- លែងបំពេញលក្ខខណ្ឌតម្រូវណាមួយដែលអនុញ្ញាតឱ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្ម
- ត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម
- ត្រូវបានតុលាការប្រកាសរំលាយឬប្រកាសមោឃភាព
- ត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្តើមហិត្ធបត្ថម្ភដោយតុលាការ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្តូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្តូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្តូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃមានសាលក្រមឬសាលដីកាស្ថាពរ។

ការផ្អាកអាជ្ញាបណ្ណប្រកបអាជីវកម្មក្នុងវិស័យសំណង់មិនត្រូវមានរយៈពេលលើសពី១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃផ្អាកអាជ្ញាបណ្ណ។

នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងវិស័យសំណង់អាចត្រូវបានផ្តល់ឡើងវិញក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។

បុគ្គលឬអ្នកវិជ្ជាជីវៈដែលត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ អាចទទួលបាននីតិសម្បទាធ្វើជាអភិបាលឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ ក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ។

បុគ្គលឬអ្នកវិជ្ជាជីវៈដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ អាចទទួលបាននីតិសម្បទាធ្វើជាអភិបាលឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ បន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា១៩ .-**

បុគ្គលដែលមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជានិងមានវិញ្ញាបនបត្រធានារ៉ាប់រង ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន។

កម្មវត្ថុនៃកិច្ចសន្យាធានារ៉ាប់រង សំដៅធានាការបំពេញកាតព្វកិច្ចដែលបានចែងក្នុងកិច្ចសន្យារវាងអ្នកប្រកបវិជ្ជាជីវៈឬអ្នកប្រកបអាជីវកម្មនិងអតិថិជនរបស់ខ្លួន។

ចំនួនទឹកប្រាក់អប្បបរមាដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២០ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈនិងអាជ្ញាបណ្ណឬការអនុញ្ញាតផ្សេងទៀតឱ្យប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២១ .-**

ការស្នើសុំអាជ្ញាបណ្ណឬការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវបង់កម្រៃសេវា។

កម្រៃសេវាអាជ្ញាបណ្ណនិងការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

កម្រៃសេវាអាជ្ញាបណ្ណនិងការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវបានជាប្រយោជន៍ដល់ថវិកាជាតិនិងថវិកាថ្នាក់ក្រោមជាតិ។

## ជំពូកទី៧

## ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ និងមន្ទីរពិសោធន៍សំណង់

**មាត្រា២២ .-**

សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ត្រូវមានការបញ្ជាក់ទទួលស្គាល់ឬការបញ្ជាក់អនុលោមភាពដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬតាមស្តង់ដាកម្ពុជាដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដាជាតិ ដោយត្រូវមានបិទឬបោះពុម្ពសញ្ញាស្តង់ដាកម្ពុជានិងត្រូវមានអាជ្ញាបណ្ណប្រើសញ្ញាស្តង់ដាកម្ពុជា។

បែបបទនិងនីតិវិធីនៃការបញ្ជាក់ទទួលស្គាល់ឬការបញ្ជាក់អនុលោមភាពនិងប្រភេទនៃសម្ភារៈសំណង់បរិក្ខារសំណង់ និងផលិតផលសំណង់ដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៣ .-**

ការផលិត ការចែកចាយ ការនាំចូល ការដាក់លក់ ការផ្គត់ផ្គង់ ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ដែលគ្មានបិទសញ្ញាស្តង់ដាកម្ពុជា ឬគ្មានការបញ្ជាក់ទទួលស្គាល់ ឬគ្មានការបញ្ជាក់អនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវហាមឃាត់ក្នុងករណីសម្ភារៈសំណង់ បរិក្ខារសំណង់

ឬផលិតផលសំណង់នោះ តម្រូវឱ្យមានបិទសញ្ញាស្តង់ដាកម្ពុជា ឬការបញ្ជាក់ទទួលស្គាល់ ឬការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវហាមឃាត់។

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យអនុលោមភាពនៃការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៤ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវរៀបចំឱ្យមានមន្ទីរពិសោធន៍ជាតិសំណង់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៥ .-**

មន្ទីរពិសោធន៍សំណង់ក្នុងគោលដៅអាជីវកម្មត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ការបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាលត្រូវមានលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតលិខិតអនុញ្ញាតបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាល ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៨

## លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ

**មាត្រា២៦ .-**

រាល់ការងារសាងសង់ឬរុះរើត្រូវមានការអនុញ្ញាតជាមុនដោយអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា២៧ .-**

ការងារសាងសង់ឬរុះរើក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះឬការពារអាយុជីវិតឬបង្ការ មិនឱ្យមានការប៉ះពាល់ឬខូចខាតធ្ងន់ធ្ងរដល់សុខភាពឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនឡើយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលត្រូវបានសាងសង់ក្នុងស្ថានភាពអាសន្នត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់តាមលក្ខខណ្ឌនិងនីតិវិធីជាធរមាន។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលបានរុះរើក្នុងភាពអាសន្នត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា២៨ .-**

រាល់ការងារសាងសង់ឬរុះរើដែលមិនតម្រូវឱ្យមានការអនុញ្ញាតមានដូចខាងក្រោម៖

- សំណង់ទំហំតូចដែលមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ
- លំនៅឋានធ្វើពីឈើ ផ្ទះថ្មក្រោមឈើលើ ផ្ទះតៀមធ្វើពីឈើឬថ្មនៅទីជនបទឬស្រែចម្ការ ដែលមិនប៉ះពាល់ដល់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ
- សំណង់បម្រើដល់សន្តិសុខជាតិនិងការពារជាតិ។

ប្រភេទនិងទំហំនៃការងារសាងសង់ឬរុះរើដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៩ .-**

រាល់ការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់មិនតម្រូវឱ្យមានការអនុញ្ញាតឡើយ ក្នុងករណីដែលការងារនោះមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រទម្ងន់ សោភណភាពខាងក្រៅ ឬមុខងារប្រើប្រាស់ទាំងមូល ឬផ្នែកណាមួយនៃសំណង់ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវជូនដំណឹងជាមុនទៅអាជ្ញាធរមានសមត្ថកិច្ច។

ប្រភេទនិងទំហំការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់ដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយអនុក្រឹត្យ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់ដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣០ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣១ .-**

លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើមិននាំឱ្យបុគ្គលដែលទទួលបានលិខិតអនុញ្ញាតនោះរួចផុតពីកាតព្វកិច្ចនិងការទទួលខុសត្រូវ តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ។

ការអនុវត្តការងារសាងសង់ឬរុះរើចំពោះសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតមិននាំឱ្យម្ចាស់សំណង់រួចផុតពីកាតព្វកិច្ចនិងការទទួលខុសត្រូវតាមច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ។

## ជំពូកទី៩
## ការគ្រប់គ្រងគម្រោងប្លង់

**មាត្រា៣២ .-**

រាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើត្រូវចុះហត្ថលេខាទទួលខុសត្រូវដោយអ្នកសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៣ .-**

រាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម។

គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើសំណង់គ្រប់ប្រភេទ លើកលែងតែសំណង់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាសម្រាប់ជនមានពិការភាពជាអាទិ៍ ផ្លូវនិងជម្រាលសម្រាប់ផ្លាស់ទី ឧបករណ៍ផ្ទាក់ដៃ ជណ្តើរយន្ត បន្ទប់អនាម័យ ចំណតយានយន្តពិសេសសម្រាប់ជនពិការ និងផ្លាកសញ្ញានានា។

អនុលោមភាពនៃគម្រោងប្លង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម ត្រូវបញ្ជាក់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

គម្រោងប្លង់សាងសង់ឬរុះរើសំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៤ .-**

ម្ចាស់សំណង់ត្រូវធានាថាការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវបានអនុវត្តត្រឹមត្រូវតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។

មុនការអនុវត្តការងារសាងសង់ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យកែសម្រួលគម្រោងប្លង់ដែលបានទទួលការយល់ព្រមរួចហើយ។

ការអនុញ្ញាតកែសម្រួលគម្រោងប្លង់ត្រូវធ្វើឡើងតាមរយៈលិខិតអនុញ្ញាតកែសម្រួលគម្រោងប្លង់។

លក្ខខណ្ឌនិងនីតិវិធីនៃការអនុញ្ញាតកែសម្រួលគម្រោងប្លង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៥ .-**

រាល់ស្នាដៃរបស់អ្នកសិក្សាគម្រោងប្លង់ដែលមានលក្ខណៈដើមទាំងមូលឬដោយផ្នែកដែលបានទទួលការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាតសាងសង់ ត្រូវបានការពារពីការលួចចម្លងស្របតាមបទប្បញ្ញត្តិជាធរមាន។

គម្រោងប្លង់មួយមិនអាចយកទៅអនុវត្តនៅទីតាំងផ្សេងទៀតដោយគ្មានការអនុញ្ញាតពីអ្នកសិក្សាដែលបានចុះហត្ថលេខាលើគម្រោងប្លង់នោះនិងម្ចាស់សំណង់បានឡើយ។

រាល់ការអនុវត្តគម្រោងប្លង់ដែលមានតម្លៃពិសេសផ្នែកស្ថាបត្យកម្មនៅទីតាំងផ្សេងទៀតត្រូវបានហាមឃាត់។ គម្រោងប្លង់ដែលមានតម្លៃពិសេសផ្នែកស្ថាបត្យកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១០

## ការគ្រប់គ្រងការងារសាងសង់ឬរុះរើ

**មាត្រា៣៦ .-**

រាល់ការងារសាងសង់ឬរុះរើត្រូវអនុវត្តដោយអ្នកសាងសង់ដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត។

អ្នកសាងសង់មិនតម្រូវឱ្យមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត លុះត្រាតែអ្នកសាងសង់នោះបានបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម៖

- ជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់
- សាងសង់ឬរុះរើសំណង់ដែលជាលំនៅឋានផ្ទាល់ខ្លួន និង
- សាងសង់ឬរុះរើសំណង់តាមជំនាញវិជ្ជាជីវៈរបស់ខ្លួន។

**មាត្រា៣៧ .-**

រាល់ការងារសាងសង់ឬរុះរើត្រូវអនុវត្តស្របតាម៖

- គម្រោងប្លង់
- បទប្បញ្ញត្តិបច្ចេកទេសសំណង់
- បទប្បញ្ញត្តិជាធរមានដទៃទៀត។

រាល់ការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាត ត្រូវអនុវត្តតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។

**មាត្រា៣៨ .-**

រាល់ការងារសាងសង់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ជាមុន។

លក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៩ .-**

អ្នកសាងសង់ត្រូវធានាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាននៅការដ្ឋានសំណង់របស់ខ្លួន។

**មាត្រា៤០ .-**

ម្ចាស់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើជូនអាជ្ញាធរមានសមត្ថកិច្ច។

របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើត្រូវរៀបចំដោយអ្នកសាងសង់និងមានការឯកភាពពីម្ចាស់សំណង់។

បែបបទនិងនីតិវិធីនៃការផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៤១ .-**

នៅពេលដំណើរការការដ្ឋាន រាល់ការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានការត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើត្រូវធ្វើរបាយការណ៍និងចេញលិខិតបញ្ជាក់ពីអនុលោមភាពនៃការងារតាមគម្រោងប្លង់ដែលបានយល់ព្រមដោយអាជ្ញាធរមានសមត្ថកិច្ចនិងតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

**មាត្រា៤២ .-**

ក្នុងករណីចាំបាច់ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ អាជ្ញាធរមានសមត្ថកិច្ចអាចចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីត្រួតពិនិត្យការងារសាងសង់ឬរុះរើ។

ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ បុគ្គលដែលពាក់ព័ន្ធការងារសាងសង់ រាប់បញ្ចូលទាំងអ្នកអភិវឌ្ឍអចលនវត្ថុ អ្នកសាងសង់ និងអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវផ្តល់កិច្ចសហការដល់មន្ត្រីត្រួតពិនិត្យសំណង់។

អាជ្ញាធរមានសមត្ថកិច្ចអាចសម្រេចផ្អាក កែតម្រូវ បញ្ឈប់ តម្រូវឱ្យរុះរើ ឬចាត់វិធានការចាំបាច់ផ្សេងទៀត ក្នុងករណី រកឃើញថាការងារសាងសង់ឬរុះរើមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន ដទៃទៀត។

**មាត្រា៤៣ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការគ្រប់គ្រងនិងត្រួតពិនិត្យការងារសាងសង់ឬរុះរើត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១១

## ការប្រើប្រាស់សំណង់

**មាត្រា៤៤ .-**

ការប្រើប្រាស់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ត្រូវអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចតាមរយៈវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ម្ចាស់សំណង់ត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ មុននឹងប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់នោះ។

រាល់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ត្រូវមានការត្រួតពិនិត្យនិងបញ្ជាក់អនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មុននឹងអាជ្ញាធរមានសមត្ថកិច្ចអនុញ្ញាតឱ្យចូលប្រើប្រាស់សំណង់។

**មាត្រា៤៥ .-**

អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យចូលប្រើប្រាស់សំណង់ក្នុងរយៈពេលណាមួយជាបណ្តោះអាសន្នបាន ចំពោះសំណង់ទាំងមូលឬផ្នែកណាមួយនៃគម្រោងសាងសង់ ក្នុងករណីដែលសំណង់ទាំងមូលឬផ្នែកណាមួយនៃគម្រោងសាងសង់នោះអាចប្រើប្រាស់បានដោយសុវត្ថិភាព។

**មាត្រា៤៦ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤៧ .-**

សំណង់ដែលប្រើប្រាស់ក្នុងគោលដៅក្រៅពីលំនៅឋានតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពនេះត្រូវបន្តអនុវត្តជាទៀងទាត់រៀងរាល់៥(ប្រាំ)ឆ្នាំម្តងយ៉ាងយូរ។

សំណង់ដែលប្រើប្រាស់ក្នុងគោលដៅលំនៅឋានតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពនេះត្រូវបន្តអនុវត្តជាទៀងទាត់ក្នុងរយៈពេលរៀងរាល់១០(ដប់)ឆ្នាំម្តងយ៉ាងយូរ។

ការត្រួតពិនិត្យនិងការចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យនៃសំណង់ត្រូវធ្វើឡើងសម្រាប់រយៈពេល២(ពីរ)ឆ្នាំម្តង។

បរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់តម្រូវឱ្យមានការត្រួតពិនិត្យរៀងរាល់១(មួយ)ឆ្នាំម្តង។ ប្រភេទបរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ម្ចាស់សំណង់ឬអ្នកគ្រប់គ្រងសំណង់មានកាតព្វកិច្ចប្រគល់លទ្ធផលនៃការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជូនអាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេល១(មួយ)ខែក្រោយថ្ងៃផុតកំណត់រយៈពេលដែលតម្រូវឱ្យអនុវត្តការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

**មាត្រា៤៨ .-**

អាជ្ញាធរមានសមត្ថកិច្ចអាចតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ក្នុងករណីមានហានិភ័យចំពោះជីវិតមនុស្ស ទ្រព្យសម្បត្តិ ឬការប៉ះពាល់ដល់សន្តិសុខឬសណ្តាប់ធ្នាប់សាធារណៈ។

**មាត្រា៤៩ .-**

ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវអនុវត្តដោយមន្ត្រីត្រួតពិនិត្យសំណង់ ឬដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រាល់ចំណាយសម្រាប់ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជាបន្ទុករបស់ម្ចាស់សំណង់។

ចំពោះអគារសហកម្មសិទ្ធិ ម្ចាស់នៃចំណែកឯកជនទាំងអស់ត្រូវទទួលបន្ទុករួមគ្នាលើរាល់ចំណាយសម្រាប់ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ស្របតាមសមាមាត្រទៅនឹងទំហំនៃចំណែកឯកជន។

**មាត្រា៥០ .-**

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី១២

## សំណង់ដែលមានសភាពគ្រោះថ្នាក់

**មាត្រា៥១ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចត្រួតពិនិត្យ តាមដានរាល់សំណង់ ទាំងឡាយណាដែលមានសភាពគ្រោះថ្នាក់ដើម្បីចាត់វិធានការចាំបាច់នានាក្នុងការធានាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

**មាត្រា៥២ .-**

ចំពោះសំណង់ដែលមានសភាពគ្រោះថ្នាក់ ម្ចាស់សំណង់និងអ្នកគ្រប់គ្រងសំណង់មានកាតព្វកិច្ចរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចនិងអនុវត្តតាមវិធានការបញ្ចៀសគ្រោះថ្នាក់ទាំងឡាយដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងករណីចាំបាច់ដើម្បីបញ្ចៀសគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបន្ទាន់ជាអាទិ៍ ហ៊ុំព័ទ្ធ ហាមចូល ហាមប្រើប្រាស់ និងតម្រូវឱ្យរុះរើសំណង់។

រាល់ការចំណាយក្នុងការបញ្ចៀសគ្រោះថ្នាក់ជាបន្ទុករបស់ម្ចាស់សំណង់។

**មាត្រា៥៣ .-**

កម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ជំពូកទី១៣
## សំណង់ដែលសាងសង់ឬរុះរើដោយគ្មានឬខុសពីលិខិតអនុញ្ញាត

**មាត្រា៥៤ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ការងារសាងសង់ឬរុះរើដែលគ្មានលិខិតអនុញ្ញាត ក្នុងករណីការសាងសង់ឬរុះរើនោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

**មាត្រា៥៥ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការផ្អាកការងារសាងសង់ឬរុះរើដែលបានធ្វើឡើងខុសពីលិខិតអនុញ្ញាត និងតម្រូវឱ្យម្ចាស់សំណង់កែតម្រូវឱ្យស្របតាមលិខិតអនុញ្ញាត។

**មាត្រា៥៦ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការកែសម្រួលឬរុះរើរាល់សំណង់ដែលសាងសង់ដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាត ក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការហាមឃាត់រាល់ការប្រើប្រាស់ ការប្រកបអាជីវកម្ម ការចាត់ចែង និងការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់គ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាត ក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

## ជំពូកទី១៤
## អធិការកិច្ចសំណង់

**មាត្រា៥៧ .-**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តែងតាំងមន្ត្រីអធិការកិច្ចសំណង់ ដើម្បីចុះតាមដាន អង្កេត ស្រាវជ្រាវ ត្រួតពិនិត្យ ប្រមូលភស្តុតាង និងជំរុញការអនុវត្តច្បាប់នេះ។

មន្ត្រីអធិការកិច្ចសំណង់ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដូចមានចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៥៨ .-**

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចសំណង់ត្រូវស្លៀកពាក់ឯកសណ្ឋាន មានសញ្ញាសម្គាល់ និងលិខិតបញ្ជាបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥៩ .-**

មន្ត្រីអធិការកិច្ចសំណង់មានភារកិច្ចនិងសិទ្ធិដូចខាងក្រោម៖

- ត្រួតពិនិត្យ បញ្ឈប់ ចាត់វិធានការបណ្តោះអាសន្ន និងពិន័យអន្តរការណ៍ចំពោះបទល្មើសសំណង់ដែលមានចែងក្នុងច្បាប់នេះ
- ដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាតឬអាជ្ញាបណ្ណពាក់ព័ន្ធក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ
- ចាប់យកវត្ថុតាងនិងកសាងសំណុំរឿងនៃបទល្មើសសំណង់
- ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់នេះ។

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចសំណង់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៦០ .-**

មន្ត្រីអធិការកិច្ចសំណង់អាចចូលទៅក្នុងការដ្ឋានសំណង់គ្រប់ពេលវេលាក្នុងពេលការដ្ឋានកំពុងដំណើរការ ឬក្នុងអគារនៅក្នុងម៉ោងធ្វើការដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

**មាត្រា៦១ .-**

រាល់ប្រតិបត្តិការអធិការកិច្ចសំណង់ក្នុងការពិនិត្យបទល្មើសត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីអធិការកិច្ចសំណង់អាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដូចមានចែងក្នុងច្បាប់នេះ។

ក្នុងករណីបទល្មើសជាក់ស្តែងឬមិនមានលិខិតអនុញ្ញាតសាងសង់ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីអធិការកិច្ចសំណង់មានសមត្ថកិច្ចដែលនៅជិតបំផុត ដើម្បីចាត់ការតាមនីតិវិធី។

## ជំពូកទី១៥
## វិសមិតភាព

**មាត្រា៦២ .-**

មន្ត្រីរាជការដែលមានសមត្ថកិច្ចត្រួតពិនិត្យនិង/ឬសម្រេចលើគម្រោងប្លង់មិនអាចជាអ្នកសិក្សាគម្រោងប្លង់ឬអ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ដែលខ្លួនបានសិក្សាឬត្រួតពិនិត្យនិងបញ្ជាក់បានឡើយ។

**មាត្រា៦៣ .-**

មន្ត្រីអធិការកិច្ចសំណង់ មន្ត្រីត្រួតពិនិត្យសំណង់ និងអ្នកត្រួតពិនិត្យនិងបញ្ជាក់ មិនអាចជាម្ចាស់សំណង់ ឬជាសហព័ទ្ធ ឬជាញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣(បី)ថ្នាក់ ឬញាតិពន្ធក្នុង៣(បី)ថ្នាក់របស់ម្ចាស់សំណង់ ឬជាអ្នកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់បានឡើយ។

**មាត្រា៦៤ .-**

ការបំពេញមុខងារជាអ្នកសិក្សាគម្រោងប្លង់មានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់របស់ខ្លួន។

**មាត្រា៦៥ .-**

ការបំពេញមុខងារជាអ្នកសាងសង់មានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់លើការងារសាងសង់របស់ខ្លួន។

**មាត្រា៦៦ .-**

អ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់មិនអាចជាសហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣ (បី)ថ្នាក់របស់ម្ចាស់សំណង់បានឡើយ។

សមាជិកភាគហ៊ុននៃក្រុមហ៊ុនដែលជាម្ចាស់សំណង់ បុគ្គលិកក្រុមហ៊ុនដែលជាម្ចាស់សំណង់ ឬអ្នកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់ មិនអាចបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់សំណង់នោះបានឡើយ។

## ជំពូកទី១៦

## កិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ

**មាត្រា៦៧ .-**

កិច្ចសន្យាម៉ៅការសាងសង់ឬរុះរើត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងត្រូវមានចែងខអប្បបរមាដូចខាងក្រោម៖

- អត្តសញ្ញាណរបស់ភាគីនៃកិច្ចសន្យា
- ទីតាំង ទំហំ និងប្រភេទការងារ
- តម្លៃនៃកិច្ចសន្យានិងកាលបរិច្ឆេទនិងរបៀបនៃការទូទាត់
- ការធានារបស់ភាគីនៃកិច្ចសន្យាចំពោះការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា
- លក្ខខណ្ឌបច្ចេកទេសនិងលក្ខខណ្ឌសុវត្ថិភាពនៃការងារ
- លក្ខខណ្ឌពាក់ព័ន្ធនឹងការផ្គត់ផ្គង់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬឧបករណ៍និងគ្រឿងចក្រសម្រាប់បម្រើឱ្យការងារសាងសង់ឬរុះរើនិងសម្រាប់បំពាក់លើសំណង់
- លក្ខខណ្ឌនៃការកែប្រែនិងរំលាយកិច្ចសន្យា
- ការធានារ៉ាប់រងឬបញ្ញត្តិផ្សេងទៀតពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះការខូចខាតដែលបង្កឡើងដោយការងារ
- ការអះអាងអំពីអនុលោមភាពនៃគម្រោងប្លង់ដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើតាមបទប្បញ្ញត្តិជាធរមាន
- កាលបរិច្ឆេទចាប់ផ្តើមនិងបញ្ចប់ការងារនិងកាលបរិច្ឆេទប្រគល់ទទួល

- លក្ខខណ្ឌពាក់ព័ន្ធនឹងករណីប្រធានសក្តិ
- ការដោះស្រាយវិវាទពាក់ព័ន្ធនឹងកិច្ចសន្យា។

**មាត្រា៦៨ .-**

ចំពោះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើសំណង់លំនៅឋានឯកជន ខដែលរំលោភបំពានត្រូវទុកជាមោឃៈ។

ខដែលរំលោភបំពាននៅក្នុងកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើសំណង់លំនៅឋានឯកជន មានដូចខាងក្រោម៖

១- ខដែលតម្រូវឱ្យម្ចាស់សំណង់ផ្តល់អាណត្តិឱ្យអ្នកម៉ៅការស្វែងរកកម្ចីចាំបាច់សម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការសាងសង់។

២- ខដែលតម្រូវឱ្យម្ចាស់សំណង់ធ្វើការទូទាត់តម្លៃនៃកិច្ចសន្យាទាំងស្រុងជាមុនដើម្បីឱ្យអ្នកម៉ៅការប្រគល់សំណង់មកម្ចាស់សំណង់។

៣- ខដែលហាមឃាត់ម្ចាស់សំណង់ឬតំណាងមិនឱ្យចូលពិនិត្យក្នុងការដ្ឋាន មុនការទូទាត់តម្លៃនៃកិច្ចសន្យាក្នុងដំណាក់កាលនីមួយៗនិងមុនការប្រគល់ទទួល។

៤- ខដែលតម្រូវឱ្យអ្នកម៉ៅការអនុវត្តការងារសាងសង់ឬរុះរើ តាមលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ដែលលក្ខខណ្ឌបច្ចេកទេសមានការប្រែប្រួលធ្ងន់ធ្ងរខុសពីលក្ខខណ្ឌបច្ចេកទេសនៃគម្រោងសាងសង់ ជួសជុល ឬរុះរើដែលជាកម្មវត្ថុនៃកិច្ចសន្យា។

៥- ខដែលដោះបន្ទុកអ្នកម៉ៅការពីកាតព្វកិច្ចអនុវត្តការងារពេញលេញតាមពេលកំណត់ក្នុងកិច្ចសន្យាដោយទទួលស្គាល់មូលហេតុនៃការយឺតយ៉ាវផ្សេងៗ លើកលែងតែមូលហេតុប្រធានសក្តិនិងមូលហេតុដែលបង្កដោយម្ចាស់សំណង់ផ្ទាល់។

**មាត្រា៦៩ .-**

ភាគីនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើអាចដាក់លក្ខខណ្ឌបង្អង់លើកាតព្វកិច្ចឬសិទ្ធិដែលកើតឡើងដោយកិច្ចសន្យា ដូចខាងក្រោម៖

១- លទ្ធកម្មដីឬសិទ្ធិប្រត្យក្សដែលអនុញ្ញាតឱ្យសាងសង់ ក្នុងករណីដែលម្ចាស់សំណង់ទទួលបានការសន្យាលក់។

២- ការទទួលបានលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ឬការអនុញ្ញាតផ្សេងទៀតរបស់អាជ្ញាធរមានសមត្ថកិច្ច។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវបញ្ជាក់កាលបរិច្ឆេទដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតឱ្យបានច្បាស់លាស់។

៣- ការទទួលបានកម្ចីដើម្បីធ្វើហិរញ្ញប្បទានដល់ការងារសាងសង់ឬរុះរើ។

៤- ការទទួលបាននូវការធានារ៉ាប់រងចំពោះការខូចខាតបង្កដោយការងារសាងសង់ឬរុះរើ។

៥- ការទទួលបាននូវការធានាការផ្គត់ផ្គង់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ការដ្ឋានសំណង់។

**មាត្រា៧០ ៈ-**

ករណីយកិច្ចសម្រេចការងារដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរះរើដោយគ្មានវិការៈមានដូចខាងក្រោម៖

១- ការងារសាងសង់ត្រូវបានអនុវត្តស្របតាមលិខិតអនុញ្ញាត បទប្បញ្ញត្តិបច្ចេកទេសសំណង់ បទប្បញ្ញត្តិ និងសេចក្តីណែនាំជាធរមានដទៃទៀត។

២- ការងារសាងសង់ត្រូវបានអនុវត្តដោយប្រើវិធីសាស្ត្រសមស្របនិងប្រកបដោយសមត្ថភាពជំនាញ។

៣- សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ផ្គត់ផ្គង់ដល់ការងារត្រូវសមស្របតាមមុខងារប្រើប្រាស់អនុលោមតាមគម្រោងប្លង់និងមានគុណភាពត្រឹមត្រូវតាមបទប្បញ្ញត្តិបច្ចេកទេស។

៤- សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ផ្គត់ផ្គង់ដល់ការងារត្រូវតែជាសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ថ្មី លើកលែងតែមានការកំណត់ផ្សេងនៅក្នុងកិច្ចសន្យា។

**មាត្រា៧១ ៈ-**

រយៈពេលនៃការធានាចំពោះវិការៈនៃការងារដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ គិតចាប់ពីថ្ងៃប្រគល់ទទួលសំណង់ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- ១០(ដប់)ឆ្នាំយ៉ាងតិច ចំពោះគ្រឿងផ្គុំសំណង់ធ្វើពីបេតុងសរសៃដែក បេតុងដែក ឬដែក។

ខ- ៥(ប្រាំ)ឆ្នាំយ៉ាងតិច ចំពោះជញ្ជាំងខាងក្រៅ បង្អួច ទ្វារ និងដំបូលអគារ។

គ- ២(ពីរ)ឆ្នាំយ៉ាងតិច ចំពោះការងារផ្នែកអគ្គិសនី ទឹក មេកានិក និងការងារពាក់ព័ន្ធផ្សេងទៀត។

គូភាគីនៃកិច្ចសន្យាម៉ៅការសាងសង់អាចព្រមព្រៀងគ្នាកំណត់រយៈពេលនៃការធានាចំពោះវិការៈនៃការងារវែងជាងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ។

ការកំណត់រយៈពេលនៃការធានាចំពោះវិការៈនៃការងារខ្លីជាងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ត្រូវចាត់ទុកជាមោឃៈ។

## ជំពូកទី១៧

## ការធានារ៉ាប់រង

**មាត្រា៧២ ៈ-**

អ្នកម៉ៅការសាងសង់ឬរះរើត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានចំពោះការងារសាងសង់ឬរះរើដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរះរើ ដើម្បីផ្តល់សំណងដល់ការខូចខាត ការបាត់បង់ទ្រព្យសម្បត្តិ ការមានរបួស ការមានពិការភាព ឬការបាត់បង់ជីវិត ដែលបង្កឡើងដោយការងារនោះដល់អ្នកដែលប្រតិបត្តិការងារនិងតតិយជន។

អាជ្ញាធរមានសមត្ថកិច្ចត្រូវធានាថាអ្នកម៉ៅការសាងសង់បានចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយរួចហើយ មុននឹងអនុញ្ញាតឱ្យបើកការដ្ឋាន។

**មាត្រា៧៣ .-**

ក្នុងករណីអ្នកម៉ៅការសាងសង់ចុះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើបន្ត កាតព្វកិច្ចចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានគឺជាបន្ទុករបស់អ្នកម៉ៅការសាងសង់ឬរុះរើនោះ។ ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានត្រូវគ្របដណ្តប់លើប្រតិបត្តិការការងាររបស់អ្នកម៉ៅការសាងសង់ឬរុះរើបន្តទាំងអស់។

ក្នុងករណីម្ចាស់សំណង់ចុះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើជាមួយអ្នកម៉ៅការសាងសង់ឬរុះរើច្រើនសម្រាប់ប្រតិបត្តិការការងារសាងសង់ឬរុះរើសំណង់តែមួយ អ្នកម៉ៅការសាងសង់ឬរុះរើទាំងអស់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានរៀងៗខ្លួន។

**មាត្រា៧៤ .-**

ក្នុងករណីប្រតិបត្តិការការងារសាងសង់ឬរុះរើរបស់គម្រោងអភិវឌ្ឍអចលនវត្ថុ អ្នកអភិវឌ្ឍអចលនវត្ថុត្រូវចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានជាមួយក្រុមហ៊ុនធានារ៉ាប់រងដោយផ្ទាល់។

**មាត្រា៧៥ .-**

ប្រភេទនិងទំហំសំណង់ដែលតម្រូវឱ្យមានការធានារ៉ាប់រងចំពោះការងារសាងសង់ឬរុះរើ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១៨

## ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់

**មាត្រា៧៦ .-**

អ្នកសិក្សាគម្រោងប្លង់ត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាតដែលកើតមានឡើងដល់អ្នកដទៃប្រសិនបើគម្រោងប្លង់នៃសំណង់នោះមានវិការៈ លើកលែងតែករណីដែលអ្នកសិក្សាគម្រោងប្លង់អាចបង្ហាញភស្តុតាងថាគម្រោងប្លង់របស់ខ្លួនបានអនុលោមតាមបទប្បញ្ញត្តិតម្រូវជាធរមាន។

**មាត្រា៧៧ .-**

នៅក្នុងពេលអនុវត្តការងារសាងសង់ឬរុះរើ ម្ចាស់សំណង់និងអ្នកសាងសង់ឬរុះរើត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការងារសាងសង់ឬរុះរើ ឬការងារគ្រប់គ្រងការដ្ឋានសំណង់នោះមានវិការៈ។

**មាត្រា៧៨ .-**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ដោយសារវិការៈនៃការងារត្រួតពិនិត្យនិងបញ្ជាក់របស់ខ្លួន។

**មាត្រា៧៩ .-**

ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការប្រើប្រាស់ឬការគ្រប់គ្រងសំណង់នោះមានវិការៈ។

**មាត្រា៨០ .-**

សិទ្ធិទាមទារសំណងនៃការខូចខាតបង្កឡើងដោយវិការៈនៃការសិក្សាគម្រោងប្លង់ ការសាងសង់ឬរុះរើ ឬការគ្រប់គ្រងការដ្ឋានសំណង់ ការត្រួតពិនិត្យនិងបញ្ជាក់សំណង់ ការប្រើប្រាស់សំណង់ និងការគ្រប់គ្រងសំណង់ ត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើ៖

- រយៈពេល៣(បី)ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះបានដឹងថាអាចទាមទារសំណងការខូចខាត ឬ
- រយៈពេល១០(ដប់)ឆ្នាំបានកន្លងហួស បន្ទាប់ពីការខូចខាតបានកើតឡើង។

**មាត្រា៨១ .-**

ផលិតករនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់អ្នកដទៃដែលបង្កឡើងដោយវិការៈនៃផលិតផលរបស់ខ្លួន លើកលែងតែផលិតករនោះអាចបង្ហាញភស្តុតាងណាមួយដូចខាងក្រោម៖

១- នៅខណៈដែលសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានដាក់លក់ឬចែកចាយ ចំណេះដឹងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេសពុំអាចរកឃើញវិការៈដែលបង្កឱ្យមានការខូចខាត។

២- សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានផលិតឡើងដោយអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសតម្រូវ។

**មាត្រា៨២ .-**

សិទ្ធិទាមទារសំណងនៃការខូចខាតបង្កឡើងដោយវិការៈនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើ៖

១- រយៈពេល៣(បី)ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះឬអ្នកតំណាងស្របច្បាប់បានដឹងថាអាចទាមទារសំណងការខូចខាត ឬ

២- រយៈពេល១០(ដប់)ឆ្នាំបានកន្លងហួស បន្ទាប់ពីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវបានប្រគល់លើកដំបូងដោយផលិតករ។ ក្នុងករណីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់មានសារធាតុបង្កឱ្យមានការប៉ះពាល់ដល់សុខភាពមនុស្ស រយៈពេលនេះត្រូវបន្ថែម២០(ម្ភៃ)ឆ្នាំទៀត។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## ជំពូកទី១៩
## ការដោះស្រាយវិវាទក្នុងវិស័យសំណង់
### ផ្នែកទី១
### ការប្តឹងតវ៉ាក្នុងវិស័យសំណង់

**មាត្រា៨៣ .-**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ មានសិទ្ធិតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ ទៅអាជ្ញាធរមានសមត្ថកិច្ចដែលបានចេញសេចក្តីសម្រេចនោះ ឬទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អាជ្ញាធរមានសមត្ថកិច្ចដែលទទួលបណ្តឹងត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើបណ្តឹងតវ៉ាដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចទទួលបណ្តឹង មិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេល៦០ (ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

បុគ្គលដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចលើបណ្តឹងតវ៉ាមានសិទ្ធិប្តឹងទៅតុលាការក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

**មាត្រា៨៤ .-**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ ត្រូវប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាមុន មុននឹងប្តឹងទៅតុលាការ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

ក្នុងករណីបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បុគ្គលនោះមានសិទ្ធិប្ដឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្ដីសម្រេចនោះ។

**មាត្រា៨៥ .-**

បុគ្គលដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចសំណង់អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីវិធានការនោះ ឬអាចប្ដឹងទៅតុលាការតាមនីតិវិធីជាធរមានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីវិធានការនោះ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្ដីសម្រេចលើបណ្ដឹងតវ៉ាដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានបណ្ដឹងតវ៉ា។

ក្នុងករណីបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បុគ្គលនោះមានសិទ្ធិប្ដឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្ដីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្ដឹងអាចប្ដឹងទៅតុលាការក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

## ផ្នែកទី២
## ការដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិបុគ្គលក្នុងវិស័យសំណង់ និងកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ

**មាត្រា៨៦ .-**

បុគ្គលដែលរងការខូចខាតឬមានការបារម្ភជាក់ស្ដែងថានឹងរងការខូចខាតដោយសារការអនុវត្តសិទ្ធិឬកាតព្វកិច្ចរបស់បុគ្គលណាម្នាក់ក្នុងវិស័យសំណង់ អាចធ្វើសំណើទៅគណៈកម្មការដោះស្រាយវិវាទសំណង់ដើម្បីធ្វើការសម្រុះសម្រួល មុននឹងប្ដឹងទៅតុលាការ។

សំណើសុំសម្រុះសម្រួលត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃគិតចាប់ពីថ្ងៃទទួលរងផលប៉ះពាល់។

គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើការសម្រុះសម្រួលជាមួយភាគីនៃវិវាទក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

ក្នុងករណីគណៈកម្មការដោះស្រាយវិវាទសំណង់សម្រេចបដិសេធសំណើសុំសម្រុះសម្រួល គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើ។ ក្នុងករណីនេះម្ចាស់សំណើមានសិទ្ធិប្ដឹងទៅតុលាការតាមនីតិវិធីជាធរមាន។

ក្នុងករណីគណៈកម្មការដោះស្រាយវិវាទសំណង់មិនអនុវត្តនីតិវិធីសម្រុះសម្រួលក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់សំណើមានសិទ្ធិប្ដឹងទៅតុលាការតាមនីតិវិធីជាធរមាន។

ក្នុងករណីភាគីវិវាទពុំអាចព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទដើម្បីបញ្ចប់វិវាទតាមការសម្រុះសម្រួលរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ ម្ចាស់សំណើមានសិទ្ធិប្ដឹងទៅតុលាការតាមនីតិវិធីជាធរមាន គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

**មាត្រា៨៧ .-**

ភាគីឬគូភាគីនៃកិច្ចសន្យាម៉ៅការសាងសង់ឬរះរើអាចធ្វើសំណើមកគណៈកម្មការដោះស្រាយវិវាទសំណង់ ដើម្បីសម្រុះសម្រួលនិងដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យាម៉ៅការសាងសង់ឬរះរើនោះ។

សំណើសុំការសម្រុះសម្រួលត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលវិវាទបានកើតឡើង។

គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើការសម្រុះសម្រួលជាមួយគូភាគីនៃវិវាទនិងចេញសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណើសុំការសម្រុះសម្រួល។

ភាគីនៃវិវាទអាចសម្រេចចិត្តឈប់ទទួលយកការសម្រុះសម្រួលនិងដោះស្រាយវិវាទរបស់គណៈកម្មការដោះស្រាយវិវាទសំណង់នៅគ្រប់ដំណាក់កាលនៃការសម្រុះសម្រួល ប៉ុន្តែភាគីនៃវិវាទត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគណៈកម្មការដោះស្រាយវិវាទសំណង់អំពីការឈប់ទទួលយកការសម្រុះសម្រួលនិងដោះស្រាយវិវាទរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ មុននឹងប្ដឹងទៅតុលាការ។

**មាត្រា៨៨ .-**

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវផ្អាក ក្នុងករណីមានសំណើសុំសម្រុះសម្រួលទៅគណៈកម្មការដោះស្រាយវិវាទសំណង់។

**មាត្រា៨៩ .-**

គណៈកម្មការដោះស្រាយវិវាទសំណង់មានរចនាសម្ព័ន្ធដូចតទៅ៖

១- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់ជាតិ

២- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់រាជធានី ខេត្ត

៣- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់ក្រុង ស្រុក ខណ្ឌ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី២០
## ទោសប្បញ្ញត្តិ

**មាត្រា៩០ .-**

ទណ្ឌកម្មក្នុងច្បាប់នេះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរឬការដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ការពិន័យអន្តរការណ៍ ការហាមឃាត់ការប្រកបវិជ្ជាជីវៈ ការបង្ខំឱ្យរុះរើនិង/ឬសាងសង់ឡើងវិញឱ្យដូចសភាពដើម ទោសពិន័យជាប្រាក់និងទោសដាក់ពន្ធនាគារ។

**មាត្រា៩១ .-**

ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរឬការដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចដូចមានចែងក្នុងមាត្រានេះជូនដល់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា៩២ .-**

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចសំណង់។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរំលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចសំណង់អាចកសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការមានសមត្ថកិច្ច។

បទល្មើសដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ត្រូវកំណត់ដោយអនុក្រឹត្យ។

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការពិន័យចំពោះអំពើល្មើស ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសក្នុងវិស័យសំណង់។

**មាត្រា៩៣ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀលចំពោះជនណាដែលមិនមែនជាវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀតក្នុងវិស័យសំណង់ដែលបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៤ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀតដែលបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ដោយមិនបានចុះបញ្ជីនៅគណៈវិជ្ជាជីវៈ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៥ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ដោយឯករាជ្យដោយគ្មានអាជ្ញាបណ្ណ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៦ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះជនណាដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ដោយគ្មានលិខិតអនុញ្ញាត ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា៩៧ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រឆាំងនឹងសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចឱ្យផ្អាក កែតម្រូវ បញ្ឈប់ ឬរុះរើសំណង់ ឬហាមប្រើប្រាស់សំណង់។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ៣(បី)ខែ និងពិន័យជាប្រាក់ទ្វេដង ចំពោះជនណាដែលប្រឆាំងនឹងសេចក្តីសម្រេចជាលើកទីពីររបស់អាជ្ញាធរមានសមត្ថកិច្ចឱ្យផ្អាក កែតម្រូវ បញ្ឈប់ ឬរុះរើសំណង់ ឬហាមប្រើប្រាស់សំណង់។

**មាត្រា៩៨ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលបានប្រើឬបំពាក់ក្នុងការសាងសង់នូវសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលតម្រូវឱ្យអនុវត្តតាមស្តង់ដាណាមួយជាកំណត់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា៩៩ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះអ្នកសិក្សាគម្រោងប្លង់ណាដែលបានសិក្សាគម្រោងប្លង់ដោយមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ហើយការអនុវត្តតាមគម្រោងប្លង់នោះបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០០ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះអ្នកសាងសង់ដែលបានសាងសង់ឬរុះរើមិនអនុលោមតាមគម្រោងប្លង់និងតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០១ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៣០ ០០០ ០០០(សាមសិបលាន)រៀលទៅ៦០ ០០០ ០០០(ហុកសិបលាន)រៀល ចំពោះអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលបានបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់ឬរុះរើថាត្រឹមត្រូវ ដែលតាមជាក់ស្តែង គម្រោងប្លង់ឬការងារសាងសង់ឬរុះរើនោះមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និង/ឬតាមគម្រោងប្លង់ដែលបានអនុញ្ញាត ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០២ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់ក្នុងគោលដៅអាជីវកម្មនូវសំណង់ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០៣ .-**

អំពើល្មើសដែលមានចែងក្នុងមាត្រា៩៥ មាត្រា៩៦ មាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ និងមាត្រា១០២នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំទៅ១០(ដប់)ឆ្នាំ កាលបើអំពើនេះបណ្តាលឱ្យមានការកាត់អវយវៈឬនាំឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ។

អំពើល្មើសដែលមានចែងក្នុងមាត្រា៩៥ មាត្រា៩៦ មាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ និងមាត្រា១០២នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំទៅ១៥(ដប់ប្រាំ)ឆ្នាំ កាលបើអំពើនេះបណ្តាលឱ្យមានមនុស្សស្លាប់។

**មាត្រា១០៤ .-**

ត្រូវផ្តន្ទាទោសដូចមាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ មាត្រា១០២ និងមាត្រា១០៣ នៃច្បាប់នេះ កាលបើអំពើល្មើសដូចមានចែងក្នុងមាត្រាទាំងនោះ ប្រព្រឹត្តដោយនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់។

**មាត្រា១០៥ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៤០ ០០០ ០០០(សែសិបលាន)រៀលទៅ៨០ ០០០ ០០០(ប៉ែតសិបលាន)រៀល ចំពោះនីតិបុគ្គលណាដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ដោយគ្មានអាជ្ញាបណ្ណ។

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ មាត្រា១០២ និងមាត្រា១០៣នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៦០ ០០០ ០០០(ហុកសិបលាន)រៀលទៅ១០០ ០០០ ០០០ (មួយរយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើនដូចតទៅនេះ៖

១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនីតិបុគ្គលនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

២- ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន តាមបែបបទកំណត់ដោយមាត្រា១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា១៧៣(ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ)នៃក្រមព្រហ្មទណ្ឌ។

៥- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយសេចក្តីសម្រេច)នៃក្រមព្រហ្មទណ្ឌ។

៦- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយតាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

## ជំពូកទី២១

## អន្តរប្បញ្ញត្តិ

**មាត្រា១០៦ .-**

ក្នុងរយៈពេល២(ពីរ)ឆ្នាំ ក្រោយច្បាប់នេះចូលជាធរមាន ម្ចាស់សំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន ត្រូវមកដាក់ពាក្យស្នើសុំ

វិញ្ញាបនបត្រប្រើប្រាស់សំណង់របស់ខ្លួនពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីសំណង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

ក្នុងរយៈពេលកំណត់ខាងលើ រាល់ទោសប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងវិស័យសំណង់ត្រូវបន្តអនុវត្តចំពោះសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន។

**មាត្រា១០៧ .-**

អាជ្ញាធរមានសមត្ថកិច្ចអាចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ចំពោះសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន ក្នុងករណីសំណង់នោះមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់និងសាធារណជន និងមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់នេះចូលជាធរមាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១០៨ .-**

ក្រោយច្បាប់នេះចូលជាធរមានក្នុងរយៈពេល២(ពីរ)ឆ្នាំ មន្ទីរពិសោធន៍សំណង់ដែលបាននិងកំពុងប្រតិបត្តិការឬប្រកបអាជីវកម្មត្រូវស្នើសុំលិខិតអនុញ្ញាតឬអាជ្ញាបណ្ណប្រកបអាជីវកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា១០៩ .-**

ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចតម្រូវឱ្យអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់តម្កល់ប្រាក់នៅធនាគារជាតិនៃកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន។ អ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់អាចដកយកប្រាក់តម្កល់វិញនៅពេលឈប់ប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មនោះ និងនៅពេលអាជ្ញាបណ្ណផុតសុពលភាពឬត្រូវបានដកហូតដោយអាជ្ញាធរមានសមត្ថកិច្ច។

អ្នកទទួលសេវាពីអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ ដែលទទួលរងការខូចខាតមានឯកសិទ្ធិលំដាប់ទី២បន្ទាប់ពីប្រាក់ឈ្នួលរបស់កម្មករនិយោជិត ចំពោះប្រាក់តម្កល់ដូចមានចែងក្នុងកថាខណ្ឌខាងលើ។

លក្ខខណ្ឌនិងនីតិវិធីនៃការតម្កល់ប្រាក់ ការដកប្រាក់តម្កល់ និងចំនួនទឹកប្រាក់អប្បបរមាដែលត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា ទៅតាមប្រភេទនៃអាជ្ញាបណ្ណដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

ជំពូកទី២២

**អវសានប្បញ្ញត្តិ**

**មាត្រា១១០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

**មាត្រា១១១ .-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ៦កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៩

នស/រកម.១១១៩.០១៩

ន សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

## ឧបសម្ព័ន្ធនៃច្បាប់ស្តីពីសំណង់

## សទ្ទានុក្រម

១. **ការងារសំណង់**(construction work) សំដៅដល់ការងារសិក្សាគម្រោងប្លង់ ការងារវាស់វែង ការងារសាងសង់(building work) ការងាររុះរើ ការងារគ្រប់គ្រងការដ្ឋាន ការងារត្រួតពិនិត្យនិងបញ្ជាក់ ការងារសិក្សាពិសោធ ការងារគ្រប់គ្រងគម្រោងសាងសង់ ឬការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

២. **ការងារសិក្សាគម្រោងប្លង់**(design work) សំដៅដល់ការងារគូរប្លង់ ការងារសិក្សាស្រាវជ្រាវនិងវិភាគទិន្នន័យសម្រាប់ការងារស្ថាបត្យកម្មនិងវិស្វកម្ម ការងារផែនការ ការងាររៀបចំបញ្ជីប៉ាន់តម្លៃ ការងាររៀបចំសេចក្តីណែនាំបច្ចេកទេស និងការងារគូរប្លង់លម្អិត។

៣. **ការងារវាស់វែង**(surveying work) សំដៅដល់ការសិក្សានិងវិភាគទិន្នន័យនិងព័ត៌មានដែលបានពីការវាស់ ការស្ទង់ ការធ្វើឋានលេខា និងការសង្កេត សម្រាប់បម្រើដល់ការធ្វើផែនការ ការសិក្សាគម្រោងប្លង់ និងការងារសាងសង់។

៤. **ការងារសាងសង់**(building work) សំដៅដល់ការងារដី ការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ និងការដំឡើង។

៥. **ការងារជួសជុល**(repair work) សំដៅដល់ការជួសជុលផ្នែកណាមួយនៃសំណង់ឬការជួសជុលទាំងស្រុងដែលមានការខូចខាតដោយប្រការណាមួយ រួមទាំងការផ្លាស់ប្តូរចំណែកចាស់ទ្រុឌទ្រោមដែលអាចបង្កនូវគ្រោះថ្នាក់ជាយថាហេតុ និងការកែលម្អ ការបំពាក់សម្ភារៈបរិក្ខារផ្នែកផ្សេងទៀតនៅខាងក្នុងដោយរក្សាសោភណភាព ទ្រង់ទ្រាយដើម និងមិនប៉ះពាល់ដល់គ្រឿងផ្គុំសំណង់។

៦. **ការងារកែប្រែ**(modification work) សំដៅដល់ការផ្លាស់ប្តូរមុខងារទ្រង់ទ្រាយទាំងស្រុងឬផ្នែកណាមួយនៃសំណង់។

៧. **ការងាររុះរើ**(demolition work) សំដៅដល់ការងារដោះឬដកចេញនូវចំណែកណាមួយ ឬដកចេញសំណង់ទាំងមូល ឬការងារវាយកម្ទេចសំណង់។

៨. **ការងារត្រួតពិនិត្យនិងបញ្ជាក់**(certification work) សំដៅដល់ការត្រួតពិនិត្យ ការវិភាគ និងការបញ្ជាក់ លើគម្រោងប្លង់ ការគណនា សេចក្តីណែនាំបច្ចេកទេសសម្រាប់ការងារសាងសង់ឬរុះរើ និងប្រតិបត្តិការការងារសាងសង់ឬរុះរើ អំពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត ដើម្បីធានាសុវត្ថិភាព សុខុមាលភាពក្នុងការសាងសង់ឬរុះរើ និងក្នុងការប្រើប្រាស់សំណង់។

៩. **ការងារសិក្សាពិសោធ**(testing work) សំដៅដល់ការសិក្សា ការវិភាគ និងការងារគណនាផ្នែកភូគព្ភសាស្ត្រ ផ្នែកគ្រឿងផ្គុំសំណង់ ផ្នែកឧបករណ៍និងគ្រឿងចក្រសំណង់ និងផ្នែកសម្ភារៈ បរិក្ខារ និងផលិតផលសំណង់។

១០. **ការងារគ្រប់គ្រងគម្រោងសាងសង់**(construction project management) សំដៅដល់ការងារដែលអ្នកគ្រប់គ្រងគម្រោងសាងសង់អនុវត្តក្នុងនាមម្ចាស់សំណង់ ដើម្បីធានាឱ្យគម្រោងសាងសង់ឬរុះរើដំណើរការទៅប្រកបដោយប្រសិទ្ធភាពលើពេលវេលា តម្លៃ គុណភាព និងសុវត្ថិភាព។

**១១. ការដកហូត**(revocation) សំដៅដល់ការសម្រេចនិរាករអាជ្ញាបណ្ណឬលិខិតអនុញ្ញាតក្នុងវិស័យសំណង់ដោយអាជ្ញាធរឬមន្ត្រីមានសមត្ថកិច្ច។

**១២. កិច្ចសន្យាម៉ៅការសាងសង់**(construction contract) សំដៅដល់កិច្ចសន្យារវាងម្ចាស់សំណង់និងអ្នកសាងសង់ និងកិច្ចសន្យារវាងអ្នកសាងសង់និងអ្នកម៉ៅការសាងសង់ឬរះរើបន្តដើម្បីអនុវត្តការងារសាងសង់ឬរះរើ។

**១៣. គម្រោងប្លង់**(design document) សំដៅដល់ឯកសារបច្ចេកទេសសម្រាប់បម្រើដល់ការងារសំណង់ មានជាអាទិ៍ ប្លង់ស្ថាបត្យកម្ម ប្លង់គ្រឿងផ្គុំសំណង់ ប្លង់ប្រព័ន្ធមេកានិក ប្លង់ប្រព័ន្ធអគ្គិសនី ប្លង់ប្រព័ន្ធទឹកស្អាត ទឹកកខ្វក់ ប្លង់ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ ឬប្លង់ ឯកសារ និងសេចក្តីណែនាំបច្ចេកទេសដទៃទៀត សម្រាប់ការងារសាងសង់ឬរះរើនិងការប្រើប្រាស់សំណង់។

**១៤. តម្លៃនៃកិច្ចសន្យា**(contract fee) សំដៅដល់កម្រៃឬតម្លៃថ្នូរដទៃទៀតដែលម្ចាស់សំណង់ត្រូវបង់ជូនអ្នកសាងសង់តាមការកំណត់ក្នុងកិច្ចសន្យាសាងសង់។

**១៥. ប្រធានសក្តិ**(force majeure) សំដៅដល់ព្រឹត្តិការណ៍ដែលកើតឡើងក្រៅឆន្ទៈ មិនអាចប៉ាន់ស្មានជាមុន និងមិនអាចជម្នះបាន។

**១៦. បទប្បញ្ញត្តិបច្ចេកទេសសំណង់**(building technical regulations) សំដៅដល់បទដ្ឋានបច្ចេកទេស លក្ខខណ្ឌបច្ចេកទេស វិធានបច្ចេកទេសដែលមានលក្ខណៈបញ្ញា សម្រាប់អនុវត្តការងារសំណង់ដែលត្រូវបានអនុម័តដោយស្ថាប័នមានសមត្ថកិច្ច។

**១៧. បទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម**(spatial and urban regulations) សំដៅដល់បទប្បញ្ញត្តិដែលមានចែងក្នុងបទដ្ឋានគតិយុត្តរៀបចំដែនដីនិងនគរូបនីយកម្ម ផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។

**១៨. បន្ទុក**(load) សំដៅដល់ទម្ងន់ សំពាធ ឬកម្លាំងទាំងឡាយដែលសង្កត់ឬមានឥទ្ធិពលលើគ្រឿងផ្គុំសំណង់។

**១៩. បរិក្ខារសំណង់**(construction equipment) សំដៅដល់បរិក្ខារដែលត្រូវបានផ្គុំ បង្កើត ឬផលិតឡើងដើម្បីប្រើប្រាស់ឬបំពាក់ភ្ជាប់នឹងសំណង់ដើម្បីបង្កើនគុណភាព ផាសុកភាព និងភាពងាយស្រួលនៃការប្រើប្រាស់សំណង់ មានជាអាទិ៍ អំពូលភ្លើង ខ្សែភ្លើង ខ្សែអុបទិក ឡាវ៉ាបូ រ៉ូប៊ីណេ ជើងងូតទឹក ម៉ាស៊ីនត្រជាក់ ជណ្តើរយន្ត ទុយោ។

**២០. ផលិតផលសំណង់**(construction product) សំដៅដល់ផលិតផលសម្រេចឬពាក់កណ្តាលសម្រេចដែលកើតចេញពីការបង្កើតឬការផលិតដោយប្រើប្រាស់សម្ភារៈសំណង់និងសម្រាប់យកទៅប្រើជាគ្រឿងផ្គុំសំណង់ មានជាអាទិ៍ ក្បឿង ឥដ្ឋ បាយអរ បេតុង សសរ ជញ្ជាំង ជហ្វា កម្រាលបេតុង បំពង់លូបេតុង ម្នាងសិលា ស័ង្កសី ស្នាតបត ក្រដាសជញ្ជាំង ថ្នាំលាប ជ័រស្អិតកាវ៉ូ។

**២១. ផលិតករ**(producer) សំដៅដល់អ្នកផលិត អ្នកនាំចូល ឬបុគ្គលដែលបានដាក់សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករឬជាអ្នកលក់។

**២២. ម្ចាស់សំណង់**(construction owner) សំដៅដល់កម្មសិទ្ធិករនៃសំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុដែលបានសាងសង់នៅលើដីរបស់ខ្លួនផ្ទាល់ឬនៅលើដីរបស់អ្នកដទៃដោយមានការអនុញ្ញាតពីម្ចាស់ដី ឬអ្នកជួលអចិន្ត្រៃយ៍ដែលបានសាងសង់លើដីរបស់អ្នកឱ្យជួលអចិន្ត្រៃយ៍។

**២៣. មន្ត្រីត្រួតពិនិត្យសំណង់**(construction controller) សំដៅដល់មន្ត្រីជំនាញដែលត្រូវបានចាត់តាំងដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចុះត្រួតពិនិត្យការងារសាងសង់ឬរុះរើនិងត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

**២៤. វិការៈ**(defect) សំដៅដល់ការប្រែប្រួលចាកពីភាពប្រក្រតី។

**២៥. វិញ្ញាបនបត្រប្រើប្រាស់សំណង់**(occupancy certificate) សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។

**២៦. សំណង់ដែលមានសភាពគ្រោះថ្នាក់**(dangerous building) សំដៅដល់សំណង់ឬផ្នែកណាមួយនៃសំណង់ ឬសម្ភារៈសំណង់ បរិក្ខារដែលបំពាក់លើសំណង់ ដែលអាចបង្កគ្រោះថ្នាក់ដល់សំណង់ជិតខាង ដល់អាយុជីវិត រាងកាយ សុខភាពរបស់អ្នកប្រើប្រាស់សំណង់ អ្នកជិតខាង និងសាធារណជន។

**២៧. សំណង់**(construction) សំដៅដល់ដំណើរការនៃការងារសំណង់ ដល់អគារ គ្រឿងផ្គុំ ស្ថាបត្យការទាំងឡាយដែលមានលក្ខណៈជាអចិន្ត្រៃយ៍ឬបណ្តោះអាសន្ន ធ្វើឡើងដោយប្រើប្រាស់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់។

**២៨. សម្ភារៈសំណង់**(construction material) សំដៅដល់វត្ថុធាតុដើមសម្រាប់ធ្វើការលាយ ផ្សំ ផ្គុំ ឬប្រើប្រាស់ជាគ្រឿងផ្គុំសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ មានជាអាទិ៍ ខ្សាច់ ថ្ម ក្រួស ស៊ីម៉ងត៍ ដែក កញ្ចក់ ដីឥដ្ឋ សេរ៉ាមិក ឈើ។

**២៩. អ្នកសាងសង់**(builder) សំដៅដល់អ្នកទទួលម៉ៅការសាងសង់ឬរុះរើ អ្នកសាងសង់ឬរុះរើតាមជំនាញ ឬក្រុមជាងសំណង់។

**៣០. អ្នកអភិវឌ្ឍអចលនវត្ថុ**(real estate developer) សំដៅដល់ពាណិជ្ជករ វិនិយោគិន ឬក្រុមហ៊ុនដែលប្រកបអាជីវកម្មសាងសង់សំណង់សម្រាប់លក់ដើម្បីស្វែងរកផលចំណេញ។

**៣១. អាជ្ញាធរមានសមត្ថកិច្ច**(competent authority) សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**៣២. អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់**(construction professional) សំដៅដល់ស្ថាបត្យករឬវិស្វករដែលបានចុះបញ្ជីនៅគណៈស្ថាបត្យករកម្ពុជាឬគណៈវិស្វករកម្ពុជា ឬអ្នកជំនាញដែលបានចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យសំណង់។

**៣៣. អ្នកជំនាញក្នុងវិស័យសំណង់**(tradesperson) សំដៅដល់អ្នកបច្ចេកទេសសំណង់(កម្មករជំនាញ/ជាង) ដែលបានទទួលការបណ្តុះបណ្តាលដោយសាលាបច្ចេកទេសជំនាញពាក់ព័ន្ធឬដែលមានជំនាញនិងបទពិសោធក្នុងការអនុវត្តការងារសាងសង់ឬអ្នកជំនាញក្នុងវិស័យសំណង់ដែលពុំទាន់មានបង្កើតគណៈវិជ្ជាជីវៈ។

៣៤. **អ្នកគ្រប់គ្រងសំណង់**(building manager) សំដៅដល់អ្នកដែលបានទទួលអាណត្តិឬសិទ្ធិគ្រប់គ្រងសំណង់ពីម្ចាស់សំណង់ក្នុងរយៈពេលកំណត់។

# ឧបសម្ព័ន្ធ៣.ខ

ប្រកាសលេខ ១៦៦ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលប្រការ ៧ និងប្រការ ១០ នៃប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
លេខ ១៦៦......ប្រក.ដនស/អសណ

ប្រកាស
ស្តីពី

ការកែសំរួល ប្រការ៧ និង ប្រការ១០ នៃប្រកាសលេខ ៧៥ប្រក/ដនស
ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/ន.ស/៩៤ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- យោងប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់
- យោងតាមការចាំបាច់របស់ក្រសួង

# <u>សំរេច</u>

**ប្រការ ១.-**

ត្រូវបានកែសំរួលប្រការ ៧ និងប្រការ ១០ នៃប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញាឆ្នាំ ... ការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ ដូចខាងក្រោម :

ប្រការ ៧ថ្មី.-

ទំរង់បែបបទសុំប្រកបអាជីវកម្មសិក្សាគំរោងប្លង់ និងសាងសង់ត្រូវមានលក្ខខណ្ឌដូចតទៅ :

១- ប្រធានសហគ្រាស និងក្រុមហ៊ុនត្រូវមកដាក់ពាក្យសុំដោយខ្លួនឯងផ្ទាល់ ។

២- នាយកបច្ចេកទេសនៃសហគ្រាស និងក្រុមហ៊ុនត្រូវមានសញ្ជាតិខ្មែរ ។

៣- សំណុំឯកសារដែលត្រូវបំពេញរួមមាន :

- ពាក្យសុំប្រកបអាជីវកម្ម ៣ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់ប្រធានសហគ្រាស និងក្រុមហ៊ុនដោយមានបិទរូបថតទំហំ ៤X ៦ ៣ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ប្រធានសហគ្រាស និងក្រុមហ៊ុន ៣ច្បាប់
- លិខិតបញ្ជាក់ទីលំនៅរបស់ប្រធានសហគ្រាស និងក្រុមហ៊ុន ពីសាលាឃុំ សង្កាត់ ១ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់នាយកបច្ចេកទេសដោយមានបិទរូបថតទំហំ ៤X ៦ ៣ច្បាប់
- លក្ខន្តិកៈរបស់សហគ្រាស និងក្រុមហ៊ុន ដែលមានធ្វើនីត្យានុកូលកម្មនៅសាលាខេត្ត ក្រុង ៣ច្បាប់
- កិច្ចសន្យាការងាររវាងសហគ្រាស និងក្រុមហ៊ុន និងសមត្ថកិច្ចចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម ៣ច្បាប់
- កិច្ចសន្យាការងាររវាងសហគ្រាស ក្រុមហ៊ុន និងអ្នកបច្ចេកទេស ដែលជានាយកបច្ចេកទេស ឬជានាយកគំរោង ៣ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្ររបស់អ្នកបច្ចេកទេសដែលមានធ្វើនីត្យានុកូលកម្មនៅសាលាខេត្ត ក្រុង ៣ច្បាប់
- បញ្ជីរាយឈ្មោះអ្នកបច្ចេកទេស និងអង្គការលេខរបស់សហគ្រាស និងក្រុមហ៊ុន ៣ច្បាប់
- បញ្ជីសំភារៈបរិក្ខារសិក្សាគំរោងប្លង់ សំរាប់សហគ្រាស និងក្រុមហ៊ុនសិក្សាគំរោងប្លង់ ៣ច្បាប់
- បញ្ជីសំភារៈបរិក្ខារគ្រឿងចក្រសំណង់ សំរាប់សហគ្រាស និងក្រុមហ៊ុនសាងសង់ ៣ច្បាប់
- ឯកសារបញ្ជាក់ដើមទុនពីធនាគារ សំរាប់សហគ្រាស និងក្រុមហ៊ុនចុះបញ្ជីលើកដំបូង ១ច្បាប់
- បង្កាន់ដៃបង់ពន្ធអាករ ឬ ប័ណ្ណប៉ាតង់ សំរាប់សហគ្រាស និងក្រុមហ៊ុនសុំបន្តសុពលភាព ១ច្បាប់
- វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម សំរាប់សហគ្រាស និងក្រុមហ៊ុនចុះបញ្ជីលើកដំបូង ១ច្បាប់
- ឯកសារស្នាដៃ សំរាប់សហគ្រាស និងក្រុមហ៊ុនប្រភេទទី១ និងទី២ ៣ច្បាប់

ប្រការ ១០ថ្មី.-

លិខិតអនុញ្ញាតប្រកបអាជីវកម្មសិក្សាគំរោងប្លង់ និងសាងសង់មានសុពលភាព ៣ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត ។

រយៈពេល៣០ថ្ងៃមុនផុតកំណត់សុពលភាព សហគ្រាស និងក្រុមហ៊ុនធ្វើអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតសាជាថ្មីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ក្នុងករណីសុំបន្តសុពលភាពនៃលិខិតអនុញ្ញាតប្រកបអាជីវកម្ម សហគ្រាស និងក្រុមហ៊ុនត្រូវធ្វើពាក្យសុំទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយភ្ជាប់ជាមួយនូវលិខិតអនុញ្ញាតចាស់ និងបង្កាន់ដៃបង់ពន្ធអាករ ឬប័ណ្ណប៉ាតង់ប្រចាំឆ្នាំចុងក្រោយ ។

ក្នុងករណីសុំតម្លើងឋានៈប្រភេទ សហគ្រាស និងក្រុមហ៊ុនត្រូវធ្វើបែបបទស្នើសុំទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យសំរេច ។

សហគ្រាស និង ក្រុមហ៊ុនត្រូវតំកល់ទុករបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**ប្រការ ២.-**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

<u>កន្លែងទទួល</u>

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -គ្រប់ក្រសួង ស្ថាប័ន
- -គ្រប់សាលាខេត្ត ក្រុង
- -ដូចប្រការ២
- -ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ៣.គ

ប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ៧៥ ប្រក/ដ.ន.ស

# ប្រកាស

ស្តីពី

# ការគ្រប់គ្រងសហគ្រាស និង ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់

* * * * *

## រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤ /នស ៩៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រមលេខ នស /រកម /០៦៩៩ /០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ . បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ . បក ចុះថ្ងៃទី១៩ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- តាមការចាំបាច់របស់ក្រសួង :

## សម្រេច

អាស័យដ្ឋាន : លេខ ៧៧១ - ៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខ័ណ្ឌ ចំការមន ក្រុង ភ្នំពេញ
Tel : (855) 023 215 659 - 215 660 , Fax : (855) 023 215 277 , e-mail : im. c lim. @ Camnet. Com. Kh

## ប្រការ ១.-

សហគ្រាស និង ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់ទាំងអស់ដែលធ្វើសកម្មភាពនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

## ប្រការ ២.-

សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ ត្រូវបានបែងចែកជាបួន ប្រភេទ :

ក-ប្រភេទទី១ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

ក.១ ស្ថាបត្យករយ៉ាងតិច ៣ នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៥ ឆ្នាំ ។

ក.២ វិស្វករយ៉ាងតិច ៥ នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញផ្សេង១ យ៉ាង តិច ៥ ឆ្នាំ ។

ក.៣ វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ឬ ស្ថាបត្យករ ១នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ ឆ្នាំ មានតួនាទីជានាយកបច្ចេកទេសនៅក្នុងសហគ្រាស និង ក្រុមហ៊ុន ។

ក.៤ អ្នកបច្ចេកទេសថ្នាក់មធ្យមមួយចំនួនសមស្រប ។

ក.៥ បទពិសោធន៍លើការងារសិក្សាគំរោងដែលធ្លាប់បានអនុវត្តកន្លងមក ហើយដែលមានតម្លៃសិក្សាគំរោងយ៉ាងតិចចំនួន ៨០០.០០០.០០០ រៀល ។

ក.៦ ដើមទុនយ៉ាងតិចចំនួន ២០០.០០០.០០០រៀល ដែលទទួលស្គាល់ ដោយ ធនាគារស្របច្បាប់ ។

ខ-ប្រភេទទី២ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

ខ.១ ស្ថាបត្យករយ៉ាងតិច ២ នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៤ ឆ្នាំ ។

ខ.២ វិស្វករយ៉ាងតិច ៤នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញផ្សេង១ យ៉ាងតិច ៤ ឆ្នាំ ។

ខ.៣ វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ឬ ស្ថាបត្យករ ១នាក់ ដែលមានបទពិសោធន៍លើការងារមុខជំនាញយ៉ាងតិច ៦ឆ្នាំ មានតួនាទីជានាយកបច្ចេកទេសនៅក្នុងសហគ្រាស និង ក្រុមហ៊ុន ។

ខ.៤ អ្នកបច្ចេកទេសថ្នាក់មធ្យមមួយចំនួនសមស្រប ។

ខ.៥ បទពិសោធន៍លើការងារសិក្សាគំរោង ដែលធ្លាប់បានអនុវត្តកន្លងមក ហើយដែលមានតំលៃសិក្សាគំរោងយ៉ាងតិចចំនួន ២០០.០០០.០០០រៀល ។

ខ.៦ ដើមទុនយ៉ាងតិចចំនួន ៨០.០០០.០០០រៀល ដែលទទួលស្គាល់ដោយ ធនាគារស្របច្បាប់ ។

គ-ប្រភេទទី៣ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

គ.១ ស្ថាបត្យករយ៉ាងតិច ២ នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៣ឆ្នាំ ។

គ.២ វិស្វករយ៉ាងតិច ៣នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញផ្សេង១យ៉ាងតិច ៣ឆ្នាំ ។

គ.៣ វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ឬ ស្ថាបត្យករ ១នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៥ឆ្នាំ មានតួនាទីជានាយកបច្ចេកទេសនៅក្នុង សហគ្រាស និង ក្រុមហ៊ុន ។

គ.៤ អ្នកបច្ចេកទេសថ្នាក់មធ្យមមួយចំនួនសមស្រប ។

គ.៥ ដើមទុនយ៉ាងតិចចំនួន ២០.០០០.០០០ រៀល ដែលទទួលស្គាល់ដោយ ធនាគារស្របច្បាប់ ។

ឃ-ប្រភេទទី៤ : ជារូបវន្តបុគ្គល :

ឃ.១ ស្ថាបត្យករ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ឆ្នាំដោយមានការទទួលស្គាល់ពីរាជរដ្ឋាភិបាល ។

ឃ.២ ស្ថាបត្យករ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញផ្សេង១ យ៉ាងតិច ៥ឆ្នាំ ។

ឃ.៣ ស្ថាបត្យករ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៣ឆ្នាំ ។

ឃ.៤ វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៧ឆ្នាំ។

ឃ.៥ វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៣ ឆ្នាំ ។

ឃ.៦ វិស្វករស្ថិតនៅខេត្តក្រុង ដែលគ្មានស្ថាបត្យករ និង អ្នកបច្ចេកទេសសំណង់អគារ ឬ សំណង់ស៊ីវិល ។

ឃ.៧ អ្នកបច្ចេកទេសថ្នាក់មធ្យមសំណង់អគារ ឬ សំណង់ស៊ីវិលស្ថិតនៅខេត្ត ក្រុង ដែលគ្មានស្ថាបត្យករ និង វិស្វករផ្នែកសំណង់អគារ ឬ សំណង់ស៊ីវិល ។

សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ អាចសុំតម្លើងឋានៈរបស់ខ្លួនទៅពេលណាដែលសហគ្រាស និង ក្រុមហ៊ុនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការ ២ខាងលើ និង មានលិខិតបញ្ជាក់ពីការបង់ពន្ធនៀងទាត់ជូនរដ្ឋ ។

## ប្រការ ៣.-

សហគ្រាស និង ក្រុមហ៊ុនសាងសង់ ត្រូវបានបែងចែកជាបួនប្រភេទ :

ក-ប្រភេទទី១ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

ក.១ ចំនួនវិស្វករ ២នាក់ និង ស្ថាបត្យករ ២នាក់ មានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ១០ឆ្នាំ នៅក្នុងនោះវិស្វករ ១នាក់ ទទួលបន្ទុកជានាយកបច្ចេកទេស និង ស្ថាបត្យករ ១នាក់ ជានាយកគំរោង ។

ក.២ វិស្វករយ៉ាងតិច ៦នាក់ ទទួលបន្ទុកជំនាញផ្សេង១ ( អគ្គិសនី មេកានិច ទឹក ភូគព្ភសាស្ត្រ ឋានលេខា )

ក.៣ ដើមទុនយ៉ាងតិចចំនួន ៤០០.០០០.០០០រៀល ដែលទទួលស្គាល់ដោយ ធនាគារស្របច្បាប់ ។

ក.៤ បទពិសោធន៍ការងារសាងសង់ដែលធ្លាប់បានអនុវត្តកន្លងមក ហើយដែលមានតម្លៃយ៉ាងតិចចំនួន ២០.០០០.០០០.០០០រៀល ។

ខ-ប្រភេទទី២ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

ខ.១ ចំនួនវិស្វករ ១នាក់ និង ស្ថាបត្យករ ១នាក់ មានបទពិសោធន៍ការងារក្នុងមុខជំនាញ យ៉ាងតិច ៨ឆ្នាំ នៅក្នុងនោះវិស្វករមានតួនាទីជានាយកបច្ចេកទេស និង ស្ថាបត្យករ ជានាយកគំរោង នៅក្នុងសហគ្រាស និង ក្រុមហ៊ុន ។

ខ.២ វិស្វករយ៉ាងតិច ៤នាក់ ទទួលបន្ទុកជំនាញផ្សេងៗ (អគ្គិសនី មេកានិច ទឹក ភូគព្ភសាស្ត្រ ប៉ាន់លេខា)

ខ.៣ ដើមទុនយ៉ាងតិចចំនួន ១២០.០០០.០០០រៀល ដោយមានការទទួលស្គាល់ពីធនាគារស្របច្បាប់ ។

ខ.៤ បទពិសោធន៍លើការងារសាងសង់ដែលធ្លាប់បានអនុវត្តកន្លងមក ហើយដែលមានតម្លៃយ៉ាងតិច ចំនួន ៤.០០០.០០០.០០០រៀល ។

គ-ប្រភេទទី៣ : ជាសហគ្រាស និង ក្រុមហ៊ុន ដែលមាន :

គ.១ ចំនួនវិស្វករ ១នាក់ ដែលមានបទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ៥ឆ្នាំ មានតួនាទីជានាយកបច្ចេកទេសនៃសហគ្រាស និង ក្រុមហ៊ុន ។

គ.២ វិស្វករ ២នាក់ ដែលទទួលបន្ទុកជំនាញផ្សេងៗ ។

គ.៣ ដើមទុនយ៉ាងតិច ២០.០០០.០០០រៀល ដោយមានការទទួលស្គាល់ពីធនាគារស្របច្បាប់ ។

ឃ-ប្រភេទទី៤ : ជាក្រុមជាងសំណង់ :

ឃ.១ មេជាងដែលមានស្នាដៃ និង បទពិសោធន៍ការងារក្នុងមុខជំនាញយ៉ាងតិច ១០ឆ្នាំ ។

ឃ.២ ជាងសំណង់មួយចំនួនសមស្រប ។

សហគ្រាស និង ក្រុមហ៊ុនសាងសង់ អាចសុំតម្លើងឋានៈប្រភេទ របស់ខ្លួនទៅពេលណាដែលសហគ្រាស និង ក្រុមហ៊ុនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការ ៣នេះ និង មានលិខិតបញ្ជាក់ពីការបង់ពន្ធទៀងទាត់ជូនរដ្ឋ ។

## ប្រការ ៤.-

អាជ្ញាធរដែលមានសមត្ថកិច្ចបើក បិទ ផ្អាក តាមដាន និង ត្រួតពិនិត្យសកម្មភាពអាជីវកម្មរបស់សហគ្រាស និង ក្រុមហ៊ុន សិក្សាគំរោងប្លង់ និងសាងសង់ មាន :

១-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- ចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មរបស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់
- ប្រកាសបិទ ផ្អាកអាជីវកម្មរបស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់
- តាមដាន ត្រួតពិនិត្យគ្រប់សកម្មភាពអាជីវកម្មរបស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ ។

២-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង

- ទទួលបន្ទុកសំរបសំរួល ដើម្បីលើកសំណើជូនក្រសួងធ្វើសេចក្តីសំរេចក្នុងការចេញលិខិតអនុញ្ញាត បើក បិទ ផ្អាក ការប្រកបអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់របស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់

- តាមដាន ត្រួតពិនិត្យសកម្មភាពរបស់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់ នៅក្នុងមូលដ្ឋានរបស់ខ្លួន និងរាយការណ៍ជូនក្រសួងដើម្បីពិនិត្យដោះស្រាយ ។

## ប្រការ ៥ .-

សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ទាំងអស់ ដែលមានបំណងធ្វើអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់ ត្រូវដាក់ពាក្យសុំប្រកបអាជីវកម្ម នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

រូបវន្តបុគ្គល (ឃ៦-ឃ៧) និង ក្រុមជាងសំណង់ ត្រូវដាក់ពាក្យសុំប្រកបអាជីវកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង ។

## ប្រការ ៦ .-

ចំពោះ :

១- សហគ្រាស និង ក្រុមហ៊ុនដែលមានលិខិតអនុញ្ញាតពីស្ថាប័នផ្សេងៗកន្លងមក ត្រូវដាក់ពាក្យសុំប្តូរយកលិខិតអនុញ្ញាតថ្មីពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

២- រូបវន្តបុគ្គល ( ឃ៦-ឃ៧ ) និង ក្រុមជាងសំណង់ ដែលមានលិខិតអនុញ្ញាតពីស្ថាប័នផ្សេងៗកន្លងមក ត្រូវដាក់ពាក្យសុំប្តូរយកលិខិតអនុញ្ញាតថ្មីពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង ។

## ប្រការ ៧.-

ទម្រង់បែបបទសុំប្រកបអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់ត្រូវមានល័ក្ខខណ្ឌដូចតទៅ :

១- ប្រធានសហគ្រាស និង ក្រុមហ៊ុនត្រូវមានសញ្ជាតិខ្មែរ ។

២- ប្រធានសហគ្រាស និង ក្រុមហ៊ុនត្រូវមកដាក់ពាក្យសុំដោយខ្លួនឯងផ្ទាល់ ។

៣- នាយកបច្ចេកទេសនៃសហគ្រាស និង ក្រុមហ៊ុនត្រូវមានសញ្ជាតិខ្មែរ ។

៤- សំណុំឯកសារដែលត្រូវបំពេញរួមមាន :

- ពាក្យសុំប្រកបអាជីវកម្ម
- ជីវប្រវត្តិសង្ខេបរបស់ប្រធានសហគ្រាស និង ក្រុមហ៊ុន ដោយមានបិទរូបថត ទំហំ ៤ x ៦

- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណរបស់ប្រធានសហគ្រាស និង ក្រុមហ៊ុនដែលមានធ្វើទិឝ្យានុកូលកម្មនៅសាលា ខេត្ត ក្រុង — ២ ច្បាប់
- លិខិតថ្កោលទោសរបស់ប្រធានសហគ្រាស និង ក្រុមហ៊ុន ( ច្បាប់ដើម ) — ១ ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់នាយកបច្ចេកទេសដោយមានបិទរូបថតទំហំ ៤ x ៦ — ៤ ច្បាប់
- លក្ខន្តិកៈរបស់សហគ្រាស និង ក្រុមហ៊ុន — ៤ ច្បាប់
- កិច្ចសន្យាការងាររវាងសហគ្រាសនិងក្រុមហ៊ុន និងអាជ្ញាធរសមត្ថកិច្ចចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម — ៤ ច្បាប់
- កិច្ចសន្យាការងាររវាងសហគ្រាសនិងក្រុមហ៊ុនៈ និងវិស្វករដែលជានាយកបច្ចេកទេស — ៤ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្ររបស់អ្នកបច្ចេកទេសដែលមានធ្វើទិឝ្យានុកូលកម្មនៅសាលាខេត្ត ក្រុង — ៤ ច្បាប់
- បញ្ជីរាយឈ្មោះអ្នកបច្ចេកទេស និង អង្គការលេខរបស់សហគ្រាស និង ក្រុះហ៊ុន — ៤ ច្បាប់
- ឯកសារស្នាដៃ — ២ ច្បាប់
- បញ្ជីសម្ភារៈ បរិក្ខារសិក្សាគំរោងប្លង់ ( *សំរាប់សហគ្រាស និង ក្រុមហ៊ុនសិក្សាគំរោងប្លង់* ) — ៤ ច្បាប់
- បញ្ជីសម្ភារៈ បរិក្ខារគ្រឿងសំណង់ ( *សំរាប់សហគ្រាស និង ក្រុមហ៊ុនសាងសង់* ) — ២ ច្បាប់
- ឯកសារធនាគារ — ៤ ច្បាប់
- បង្កាន់ដៃបង់ពន្ធអាករ ( ច្បាប់ដើម ) — ១ ច្បាប់
- វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម — ១ ច្បាប់

## ប្រការ ៨.-

រាល់សហគ្រាស និង ក្រុមហ៊ុនបរទេសដែលមានបំណងប្រកបអាជីវកម្មសិក្សាគំរោងប្លង់ ឬ ផ្តល់យោបល់ ពិគ្រោះបច្ចេកទេស និងសាងសង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមកចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។

រាល់សហគ្រាស និង ក្រុមហ៊ុនបរទេសដែលកំពុងប្រកបអាជីវកម្មសិក្សាគំរោងប្លង់ឬ ផ្តល់យោបល់ពិគ្រោះបច្ចេកទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីមានលិខិតអនុញ្ញាតពីស្ថាប័នណាផ្សេងហើយក៏ដោយ ក៏ត្រូវមកចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ដែរ ។

## ប្រការ ៩.-

រាល់ការចុះបញ្ជី ការចេញលិខិតអនុញ្ញាត សហគ្រាសនិងក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ រូបវន្តបុគ្គល និង ក្រុមជាងសំណង់ ត្រូវបង់ពន្ធអាករផ្សេងៗ ស្របតាមការកំណត់នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ប្រការ ១០.-

លិខិតអនុញ្ញាតប្រកបអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់មានសុពលភាពរយៈពេល ៣ឆ្នាំគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត ។ ៘

រយៈពេល៣០ថ្ងៃមុនផុតកំណត់សុពលភាព សហគ្រាស និង ក្រុមហ៊ុន ធ្វើអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតសាជាថ្មីមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

ក្នុងករណីសុំបន្តសុពលភាពនៃលិខិតអនុញ្ញាតប្រកបអាជីវកម្ម សហគ្រាស និង ក្រុមហ៊ុនត្រូវធ្វើពាក្យសុំមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដោយភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតចាស់ និង បង្កាន់ដៃបង់ពន្ធអាករថ្មី ។

ក្នុងករណីសុំតម្លើងឋានៈប្រភេទ សហគ្រាស និង ក្រុមហ៊ុនត្រូវធ្វើបែបបទស្នើសុំមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យ សំរេច។

សហគ្រាស និង ក្រុមហ៊ុនត្រូវតែកល់ទុករបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រាល់ដំណាច់ឆ្នាំទីមួយ ១ ។

## ប្រការ ១១.-

ត្រូវប្រកាសផ្អាក ឬ បិទ ចំពោះសហគ្រាស ឬ ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ទាំងឡាយណាដែលប្រកបអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់ដោយគ្មានលិខិតអនុញ្ញាតពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។

## ប្រការ ១២ .-

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល អគ្គនាយកសំណង់ អគ្គនាយករៀបចំដែនដីនិងនគរូបនីយកម្ម អគ្គនាយកសុរិយោដីនិងភូមិសាស្ត្រ អធិការ និង ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាស នេះតាមភារកិច្ចរៀងៗខ្លួន ។

## ប្រការ ១៣.-

ប្រកាសនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ១៩៩៩

អ៊ឹម ឈុនលឹម

<u>ចម្លងជូន</u>

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ១២
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ៣.ឃ

សេចក្តីណែនាំលេខ ០០២ ដនស/សណន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ ស្តីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ០០២ ដនស/សណន

**សេចក្តីណែនាំ**
**ស្តីពី**
**ការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំសំដៅពង្រឹងការអនុវត្តច្បាប់ស្តីពីសំណង់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ អគ្គនាយកដ្ឋានសំណង់ អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម៖

- ហាមដាច់ខាតការសាងសង់សំណង់ដែលគ្មានលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់។
- ហាមដាច់ខាតការអនុវត្តការងារសាងសង់ឬរុះរើ ដោយអ្នកសាងសង់ដែលគ្មានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- ហាមដាច់ខាតការដ្ឋានសំណង់ដែលដំណើរការសាងសង់ឬរុះរើដោយគ្មានវិស្វករប្រចាំការដ្ឋានជាអ្នកទទួលខុសត្រូវ។
- ហាមដាច់ខាតការស្នាក់នៅក្នុងអគារដែលកំពុងសាងសង់ ទោះបីជាលក្ខណៈបណ្តោះអាសន្នក៏ដោយ និងហាមដាច់ខាតអ្នកគ្មានភារកិច្ចចូលក្នុងការដ្ឋានសំណង់។
- ហាមការប្រើប្រាស់សំណង់គ្រប់ប្រភេទ ដោយគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ឬលិខិតបិទការដ្ឋានផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងករណីពិនិត្យឃើញអំពើល្មើសនឹងបម្រាមខាងលើ អាជ្ញាធរមានសមត្ថកិច្ចត្រូវចេញលិខិតផ្អាកការសាងសង់ជាបន្ទាន់។ ក្នុងករណីការសាងសង់នៅតែបន្ត អាជ្ញាធរមានសមត្ថកិច្ចត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធីជាធរមាន។

ដើម្បីធានាសន្តិសុខនិងសុវត្ថិភាពនៃការដ្ឋានសំណង់ អាជ្ញាធរមានសមត្ថកិច្ច ត្រូវយកចិត្តទុកដាក់អនុវត្តគោលការណ៍និងវិធានការដូចខាងក្រោម÷

**១) លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ**



អាសយដ្ឋាន: ផ្លូវលេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

- គម្រោងប្លង់ស្ថាបត្យកម្មត្រូវសិក្សានិងចុះហត្ថលេខាដោយរូបវ័ន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាស្ថាបត្យករ និងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- គម្រោងប្លង់រុះរើត្រូវសិក្សានិងចុះហត្ថលេខាដោយរូបវ័ន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាវិស្វករនិងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- ការប្រើប្រាស់ ការប្រកបអាជីវកម្ម ការតាក់តែង និងការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់គ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីគម្រោងប្លង់អនុញ្ញាត មិនត្រូវបានអនុញ្ញាតឡើយក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

## ២) លិខិតអនុញ្ញាតបើកការដ្ឋានសំណង់

- គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងគម្រោងប្លង់បច្ចេកទេសផ្សេងទៀតត្រូវសិក្សា និងចុះហត្ថលេខាដោយរូបវ័ន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាវិស្វករនិងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងគម្រោងប្លង់បច្ចេកទេសផ្សេងទៀត ត្រូវមានការបញ្ជាក់អនុលោមភាពតាមបទដ្ឋានបច្ចេកទេសសំណង់ ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលទទួលស្គាល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវមានបញ្ជាក់អំពីអត្តសញ្ញាណរបស់អ្នកសាងសង់ វិស្វករប្រចាំការដ្ឋាន វិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន និងគម្រោងប្លង់រៀបចំការដ្ឋានសំណង់ដែលមានហត្ថលេខារបស់នាយកបច្ចេកទេស។

## ៣) ការរៀបចំការដ្ឋាន

- មន្ត្រីត្រួតពិនិត្យសំណង់ត្រូវចុះវាស់វែងនិងបោះបង្គោលព្រំកំណត់ទីតាំងដែលត្រូវសាងសង់ស្របតាមគម្រោងប្លង់ស្ថាបត្យកម្មដែលទទួលបានការយល់ព្រមតាមរយៈលិខិតអនុញ្ញាតសាងសង់។
- ការដ្ឋានសំណង់ត្រូវមានផ្ទាំងព័ត៌មានអំពីគម្រោងសាងសង់នៅពីមុខការដ្ឋានសំណង់ ជាអាទិ៍ ឈ្មោះគម្រោងសាងសង់ ឈ្មោះក្រុមហ៊ុនសាងសង់ ឈ្មោះមេក្រុមជាង ឈ្មោះម្ចាស់សំណង់ ឈ្មោះរបស់វិស្វករប្រចាំការដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ រូបភាពទេព្រាទស្សន៍នៃគម្រោងសាងសង់ និងអាសយដ្ឋានទីតាំងសំណង់។
- ត្រូវយកចិត្តទុកដាក់ប្រតិបត្តិតាមវិធានសុវត្ថិភាពដូចមានកំណត់ក្នុងប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ និងសៀវភៅណែនាំអំពីសុវត្ថិភាពក្នុងការដ្ឋានសំណង់ (ឆ្នាំ២០១៨) របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

### ៤) ដំណើរការការដ្ឋានសំណង់

- មានតែក្រុមហ៊ុនសាងសង់ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទើបអាចទទួលម៉ៅការសាងសង់បាន។ ក្រុមហ៊ុនសាងសង់អាចចុះកិច្ចសន្យាបន្តដើម្បីប្រគល់ការងារមួយផ្នែកឬច្រើនទៅឱ្យក្រុមជាងសំណង់។ ក្នុងករណីនេះ ក្រុមជាងសំណង់ត្រូវអនុវត្តការងារក្រោមការទទួលខុសត្រូវរបស់ក្រុមហ៊ុននោះ។ វិស្វករប្រចាំការដ្ឋានត្រូវចាត់តាំងដោយក្រុមហ៊ុនសាងសង់។
- ក្រុមជាងដែលមានវិញ្ញាបនបត្រក្រុមជាងសំណង់ ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អាចទទួលម៉ៅការសាងសង់សំណង់ស្ថិតក្រោមសមត្ថកិច្ចអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។ ការងាររបស់ក្រុមជាងសំណង់ត្រូវស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់វិស្វករប្រចាំការដ្ឋានយ៉ាងតិច ០១ (មួយ) រូប ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងដែលបានចុះកិច្ចសន្យាជាមួយម្ចាស់សំណង់។
- គ្រប់ការដ្ឋានសំណង់ ត្រូវមានសៀវភៅតាមដានការងារសាងសង់ដើម្បីកត់ត្រាអំពីការងារសាងសង់ឬវិះរើជាប្រចាំ និងត្រូវដាក់ជូនមន្ត្រីត្រួតពិនិត្យសំណង់រាល់ពេលចុះត្រួតពិនិត្យ។
- អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់មន្ត្រីត្រួតពិនិត្យសំណង់ឱ្យចុះបំពេញការងារត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ជាប្រចាំ។ មន្ត្រីត្រួតពិនិត្យសំណង់មាន មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ។
- ក្រុមហ៊ុនសាងសង់ឬវិស្វករប្រចាំការដ្ឋាន ត្រូវជូនដំណឹងមកមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះពិនិត្យលើការងារសាងសង់តាមដំណាក់កាលដូចខាងក្រោម÷
    - ក្នុងពេលកំណត់ទីតាំងសាងសង់
    - ក្នុងពេលអនុវត្តការងារគ្រឹះ
    - ក្នុងពេលអនុវត្តការងារសសរជាន់ផ្ទាល់ដី
    - ក្នុងពេលអនុវត្តការងារគ្រឿងឆ្អឹងបន្តបន្ទាប់ទៀត។
- នៅរាល់ពេលចុះត្រួតពិនិត្យការដ្ឋាន មន្ត្រីត្រួតពិនិត្យសំណង់ត្រូវចុះហត្ថលេខាលើសៀវភៅតាមដានការងារសាងសង់ និងធ្វើកំណត់ហេតុត្រួតពិនិត្យសំណង់ដោយមានហត្ថលេខារបស់មន្ត្រីត្រួតពិនិត្យសំណង់ និងវិស្វករប្រចាំការដ្ឋាន និងស្នាមមេដៃរបស់ម្ចាស់សំណង់ និងអ្នកពាក់ព័ន្ធ។
- ក្នុងករណីពិនិត្យឃើញថា ការងារសាងសង់ឬវិះរើមិនអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់ គម្រោងប្លង់ស្ថាបត្យកម្មដែលបានអនុញ្ញាតហើយ និងបទប្បញ្ញត្តិជាធរមានដទៃទៀត អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការផ្អាក កែតម្រូវ បញ្ឈប់ តម្រូវឱ្យវិះរើឬវិធានការចាំបាច់ផ្សេងទៀត។

- អគ្គនាយកដ្ឋានសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវចងក្រងនិងរក្សាពល់កំណត់ហេតុ របាយការណ៍ត្រួតពិនិត្យសំណង់ រូបថត និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការដ្ឋានសំណង់នីមួយៗ ទាំងជាឯកសាររឹងនិងទាំងជាឯកសារអេឡិចត្រូនិក សម្រាប់ប្រើប្រាស់ក្នុងករណីចាំបាច់។

**៥) ការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់**

- គម្រោងប្លង់គ្រឿងផ្គុំសំណង់និងការងារសាងសង់ ត្រូវមានការត្រួតពិនិត្យនិងបញ្ជាក់អនុលោមភាពតាមបទដ្ឋានបច្ចេកទេសសំណង់ ដែលអនុវត្តដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ ដែលជាក្រុមហ៊ុនសិក្សាគម្រោងប្លង់ឬក្រុមហ៊ុនសាងសង់ដែលកំណត់ដោយសេចក្ដីសម្រេចរបស់ក្រសួង។
- ការត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់គ្រឿងផ្គុំសំណង់ ត្រូវអនុវត្តដាច់ខាតលើគម្រោងប្លង់ផ្នែកគ្រឹះ ជើងតាង សសរ ធ្នឹម កម្រាលខណ្ឌ និងជញ្ជាំងទ្រទម្ងន់។ ការត្រួតពិនិត្យនិងបញ្ជាក់លើការងារសាងសង់ ត្រូវអនុវត្តដាច់ខាតនៅតាមដំណាក់កាលសំខាន់ៗនៃការងារគ្រឿងផ្គុំ ជាអាទិ៍ ផ្នែកគ្រឹះ សសរ ធ្នឹម កម្រាលខណ្ឌ និងជញ្ជាំងទ្រទម្ងន់។
- វិញ្ញាបនបត្រត្រួតពិនិត្យនិងបញ្ជាក់សំណង់ចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ គឺជាឯកសារដែលអាជ្ញាធរមានសមត្ថកិច្ចប្រើប្រាស់ក្នុងការសម្រេចផ្ដល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលមានតម្លៃសម្រាប់ការចូលប្រើប្រាស់ ការដាក់ជួល ការលក់ ឬប្រតិបត្តិការពាណិជ្ជកម្មផ្សេងទៀតពាក់ព័ន្ធនឹងសំណង់។
- ក្នុងករណីពិនិត្យឃើញការងារសាងសង់មិនអនុវត្តតាមបទដ្ឋានបច្ចេកទេសសំណង់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវជូនដំណឹងជាបន្ទាន់ទៅមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចាត់វិធានការសមស្រប។

ទទួលបានសេចក្ដីណែនាំនេះ អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ អគ្គនាយកដ្ឋានសំណង់ អគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១ រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ជា សុផារ៉ា

**កន្លែងទទួល ៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យ **សម្ដេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ៣.ខ

សេចក្ដីណែនាំលេខ ០៣ ដនស/សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៤ ស្ដីពីអនុវត្តប្រកាសអន្តរក្រសួងស្ដីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន

(464) ៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ:......[illegible]............ដនស/សណន

ភ្នំពេញ . ថ្ងៃទី...៩...ខែ...សីហា...ឆ្នាំ ២០០៤

## សេចក្ដីណែនាំ

### អនុវត្តប្រកាសអន្តរក្រសួងស្ដីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន

កន្លងមកក្រសួងបានពិនិត្យឃើញថា នៅតាមបណ្ដាការដ្ឋានការអនុវត្តប្រកាសអន្តរក្រសួងលេខ៦៥៥ ប្រក សហវ.ដនស.មផ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០២ ស្ដីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន នៅពុំទាន់បានល្អ និងសព្វគ្រប់នៅឡើយ ។ ដូច្នេះដើម្បីឱ្យការអនុវត្តប្រកាសអន្តរក្រសួងនេះមានប្រសិទ្ធភាពខ្ពស់ ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំដល់គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ដូចតទៅ:

១-ត្រូវផ្សព្វផ្សាយ និងណែនាំដល់ក្រុមហ៊ុន សហគ្រាសសំណង់ ឬម្ចាស់សំណង់ឱ្យយល់ច្បាស់អំពីអត្ថប្រយោជន៍នៃការធានារ៉ាប់រង ហើយជំរុញឱ្យមានការទិញវិញ្ញាបនប័ត្រធានារ៉ាប់រង ។

២-សំណុំឯកសារ ដែលភ្ជាប់ជាមួយពាក្យសុំលិខិតបើកការដ្ឋាន ត្រូវមានរួមទាំងវិញ្ញាបនប័ត្រធានារ៉ាប់រងផង ។

៣-នៅពេលចុះត្រួតពិនិត្យការដ្ឋានសំណង់ ត្រូវត្រួតពិនិត្យលិខិតស្នាមផ្សេងៗរួមទាំងវិញ្ញាបនប័ត្រធានារ៉ាប់រងផងដែរ ។ ត្រូវឃាត់សកម្មភាពការដ្ឋានជាបណ្ដោះអាសន្ន ក្នុងករណីដែលការដ្ឋានណាមួយពុំមានវិញ្ញាបនប័ត្រធានារ៉ាប់រង ។ ត្រូវណែនាំម្ចាស់សំណង់ឱ្យទទួលតែសហគ្រិន អ្នកម៉ៅការ ឬអ្នកម៉ៅការបន្តដែលមានវិញ្ញាបនប័ត្រធានារ៉ាប់រងការដ្ឋាន ។ ប្រសិនបើម្ចាស់សំណង់នៅតែមិនអនុវត្តតាមការណែនាំត្រូវរាយការណ៍ទៅអាជ្ញាធរស្រុក ខណ្ឌ ដើម្បីមានវិធានការ ។

៤-ត្រូវចាត់មន្ត្រីចូលរួមក្នុងក្រុមការងារដូចមានចែងក្នុងប្រការ ៧ នៃប្រកាសអន្តរក្រសួងលេខ ៦៥៥ ប្រក សហវ.ដនស.មផ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០២ ដើម្បីត្រួតពិនិត្យការដ្ឋានដែលពុំមានវិញ្ញាបនប័ត្រធានារ៉ាប់រង ។

ទទួលបានសេចក្ដីណែនាំនេះ គ្រប់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

កន្លែងទទួល

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់សាលាខេត្តក្រុង
- គ្រប់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួង ដ.ន.ស
- គ្រប់មន្ទីរដ.ន.ស.ស ខេត្តក្រុង
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ៣.ច

សេចក្ដីជូនដំណឹងលេខ ៩៤៨ សជណ ចុះថ្ងៃទី៥ កក្កដា ២០១៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី

ក្រសួង.រ.ន.ស.
លេខ 3009
ទទួលថ្ងៃ 05.07.19 18:18

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**លេខ :** ៩៤៨ សជណ

ថ្ងៃសុក្រ ៤កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែកក្កដា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**ជម្រាបជូន**

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់**
- **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន**

**កម្មវត្ថុ៖** ករណីសំណើសុំគោលការណ៍សម្រេចលើវិធានការចាំបាច់សំដៅទប់ស្កាត់ការដ្ឋានសំណង់ខុសច្បាប់ ដើម្បីធានាអាយុជីវិតមនុស្ស ទ្រព្យសម្បត្តិ សុវត្ថិភាព និងគុណភាពសំណង់ទូទាំងប្រទេស។

**យោង ៖**
- លិខិតលេខ១៩៨១ ដនស/អរប. ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ៤២៧ ខន/០១៩ សជណ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៩ របស់ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការចាំបាច់មួយចំនួន ចំពោះការដ្ឋានសំណង់សណ្ឋាគារ អគារស្នាក់នៅរួម អគារពាណិជ្ជកម្ម អគាររោងចក្រ អគារសិប្បកម្ម និងសំណង់ផ្សេងទៀត ដែលគ្មានលិខិតអនុញ្ញាតនិង/ឬសាងសង់ខុសលក្ខណៈបច្ចេកទេសលើកលែងតែសំណង់លំនៅឋានផ្ទាល់ខ្លួនរបស់ប្រជាពលរដ្ឋដូចខាងក្រោម៖

១. ក្រសួងរ៉ែ និងថាមពល ចាត់វិធានការមិនឱ្យមានការផ្គត់ផ្គង់ថាមពលអគ្គិសនីដល់ការដ្ឋានសំណង់។

២. ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ចាត់វិធានការមិនឱ្យមានការផ្គត់ផ្គង់ទឹកស្អាតដល់ការដ្ឋានសំណង់។

៣. ក្រសួងសាធារណការ និងដឹកជញ្ជូន មិនត្រូវអនុញ្ញាតឱ្យតភ្ជាប់លូចូលបណ្ដាញលូសាធារណៈ។

៤. ក្រសួង ស្ថាប័ន និងអង្គភាពមានសមត្ថកិច្ច មិនត្រូវផ្ដល់លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្ម។

៥. ក្រសួងព័ត៌មាន និងអង្គភាពមានសមត្ថកិច្ច មិនត្រូវអនុញ្ញាតឱ្យផ្សព្វផ្សាយពាណិជ្ជកម្ម។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**

**ចម្លងជូន៖**
- ក្រសួង ស្ថាប័ន និងអង្គភាពមានសមត្ថកិច្ច
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ៣.ឆ

សារាចរណែនាំលេខ ០០២ ដនស/អសណ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការចុះបញ្ជីប្រកបអាជីវកម្ម សិក្សាគម្រោងប្លង់ និងសាងសង់របស់សហគ្រាស ក្រុមហ៊ុន និងរូបវន្តបុគ្គល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ០០២ ដ.ន.ស / អ.ស.ណ

ភ្នំពេញ, ថ្ងៃទី ៤ ខែ០៧ ឆ្នាំ២០០០

### សារាចរណែនាំ

### ស្តីពី

### ការចុះបញ្ជីប្រកបអាជីវកម្ម សិក្សាគំរោងប្លង់ និង សាងសង់

### របស់សហគ្រាស ក្រុមហ៊ុន និង រូបវ័ន្តបុគ្គលបរទេស

យោងមាត្រាទី ១៩ ត្រង់ផ្នែកទី ៤ នៃច្បាប់ស្តីពី "វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម " ដែលចែងពីក្រុមហ៊ុនបរទេស ដែលមានតែសាខា ឬ ទីភ្នាក់ងារនៅព្រះរាជាណាចក្រកម្ពុជា និង យោងតាមប្រកាសលេខ ៧៥ ប្រក / ដ.ន.ស ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស ក្រុអហ៊ុនសិក្សាគំរោងប្លង់ និងសាងសង់ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សូមធ្វើការណែនាំ ស្តីពីការចុះបញ្ជីប្រកបអាជីវកម្មរបស់បណ្តាសហគ្រាស ក្រុមហ៊ុន និងរូបវ័ន្តបុគ្គលបរទេសដូចតទៅ :

I ការកំណត់ទ្រង់ទ្រាយ

សហគ្រាស ក្រុមហ៊ុន រូបវ័ន្តបុគ្គលបរមេស ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានបែងចែកតាមទ្រង់ទ្រាយអាជីវកម្មដូចតទៅ :

១-សហគ្រាស ក្រុមហ៊ុនបរទេស ដែលមានការិយាល័យតំណាង ឬទីភ្នាក់ងារ និងសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា

២-សហគ្រាស ក្រុមហ៊ុនបរទេស ដែលមានទីស្នាក់ការធំនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៣-រូបវ័ន្តបុគ្គលបរទេសសិក្សាគំរោងប្លង់

II ការចុះបញ្ជីប្រកបអាជីវកម្ម

ចំពោះ :

១- អភិបាលការិយាល័យតំណាង ឬ ទីភ្នាក់ងារ និង សាខាក្រុមហ៊ុន ឬ អាណត្តិគាហកនៃ សហគ្រាស ក្រុមហ៊ុនបរទេស ដែលមានការិយាល័យតំណាង ទីភ្នាក់ងារ និង សាខាក្នុងព្រះរាជាណាចក្រកម្ពុជា

២- អភិបាល ឬ សមាជិកនៃសហគ្រាស ក្រុមហ៊ុនបរទេស ដែលមានទីស្នាក់ការធំនៅព្រះរាជាណាចក្រកម្ពុជា

៣- រូបវន្តបុគ្គលបរទេសសិក្សាគំរោងប្លង់

ត្រូវមកបំពេញដោយផ្ទាល់នូវបែបបទសុំចុះឈ្មោះការិយាល័យតំណាងទីភ្នាក់ងារ ឬ សាខាក្រុមហ៊ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និង ចុះឈ្មោះសហគ្រាស ក្រុមហ៊ុន រូបវន្តបុគ្គលបរទេសសិក្សាគំរោងប្លង់ក្នុងបញ្ជីអាជីវកម្មនៅនាយកដ្ឋានសិក្សាគំរោងប្លង់ចំណុះអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

អភិបាល ឬ អាណត្តិគាហក ត្រូវចុះហត្ថលេខាដោយផ្ទាល់ដៃនៅចំពោះមុខមន្ត្រីនាយកដ្ឋានសិក្សាគំរោងប្លង់ ដើម្បីធានាអះអាងទទួលខុសត្រូវលើរាល់សំណុំលិខិត ដែលខ្លួនបានយកមកតម្កល់ទុក នៅនាយកដ្ឋានសិក្សាគំរោងប្លង់ ថាពិតជាគ្រប់គ្រាន់ និង ត្រឹមត្រូវមិនមានក្លែងបន្លំលើប្រការណាមួយឡើយ ។

ក្នុងករណីដែលពិនិត្យឃើញថា លិខិត ឬ ឯកសារណាមួយនៃសំណុំឯកសារសុំចុះបញ្ជីប្រកបអាជីវកម្មមានភាពមិនច្បាស់លាស់ អភិបាលការិយាល័យតំណាង ទីភ្នាក់ងារ សាខាក្រុមហ៊ុន ឬ ប្រធានក្រុមប្រឹក្សាអភិបាលក្រុមហ៊ុន ឬ អភិបាលណោម្នាក់ ឬ អាណត្តិគាហក ត្រូវមកបំភ្លឺ និង ដោះស្រាយទៅតាមករណីនីមួយៗតាមក្បួនកោះអញ្ជើញរបស់ប្រធាននាយកដ្ឋានសិក្សាគំរោងប្លង់ ។

កាលបើពិនិត្យឃើញថា សំណុំលិខិត និង ពត៌មានមានលក្ខណៈគ្រប់គ្រាន់ និង ត្រឹមត្រូវតាមការណែនាំ ( បញ្ញត្តិ ) ហើយនោះមន្ត្រីចុះបញ្ជីនៅនាយកដ្ឋានសិក្សាគំរោងប្លង់ត្រូវធ្វើការចុះបញ្ជីប្រកបអាជីវកម្ម ហើយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ នឹងប្រគល់ជូនវិញ្ញាបនប័ត្រ និង ប្រកាស ដែលអនុញ្ញាតអោយប្រកបអាជីវកម្មដល់អ្នកស្នើសុំក្នុងរយៈពេលយ៉ាងយូរមិនអោយហួសពី ១ខែ ដោយគិតចាប់ពីថ្ងៃទទួលពាក្យសុំ ដែលមានលក្ខណៈត្រឹមត្រូវ និង គ្រប់គ្រាន់ ។

## III ប្រភេទ សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់

១-១- សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ ដែលមានការិយាល័យតំណាង ឬទីភ្នាក់ងារ និង សាខា

ក្នុងព្រះរាជាណាចក្រកម្ពុជា ជាសហគ្រាស ក្រុមហ៊ុន បានបែងចែកដូចសេចក្តីប្រកាស លេខ ៧៥ ប្រក / ដ.ន.ស ចុះថ្ងៃ ទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការគ្រប់គ្រង សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់ ប៉ុន្តែត្រូវបន្ថែមនូវ :

១-លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្មសិក្សាគំរោងប្លង់នៃសាមីដើមប្រទេស

២-ឯកសារស្តីពីការចុះបញ្ជីពាណិជ្ជកម្មរបស់សាមីដើមប្រទេស

៣-ឯកសារស្តីពីលក្ខន្តិកៈ របស់សហគ្រាស និង ក្រុមហ៊ុន របស់សាមីដើមប្រទេស ។

១-២- សហគ្រាស ក្រុមហ៊ុនសាងសង់ ដែលមានការិយាល័យតំណាង ឬ ទីភ្នាក់ងារ

និងសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាសហគ្រាស ក្រុមហ៊ុន បានបែងចែកដូចប្រកាសលេខ ៧៥ ប្រក / ដ.ន.ស ចុះថ្ងៃ ទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្ដីពីការគ្រប់គ្រង សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់ ត្រង់ ចំណុច ក ខ ក្នុងប្រការ ៣ ប៉ុន្តែត្រូវបន្ថែមនូវ :

១-លិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្មសាងសង់របស់សាមីដើមប្រទេស

២-ឯកសារស្ដីពីការចុះបញ្ជីពាណិជ្ជកម្មរបស់សាមីដើមប្រទេស

៣-ឯកសារស្ដីពីលក្ខន្តិកៈ របស់សហគ្រាស និង ក្រុមហ៊ុនរបស់សាមីដើមប្រទេស ។

២-១ សហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ ដែលមានទីស្នាក់ការធំនៅព្រះរាជាណាចក្រកម្ពុជា ជាសហគ្រាស ក្រុមហ៊ុនបានបែងចែកជា ៣ប្រភេទ ដូចប្រកាសលេខ ៧៥ ប្រក/ដ.ន.ស ចុះថ្ងៃ ទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្ដីពីការគ្រប់គ្រង សហគ្រាស និង ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់ ត្រង់ ចំណុច ក ខ គ ក្នុងប្រការ២ ។

២-២- សហគ្រាស ក្រុមហ៊ុនសាងសង់ ដែលមានទីស្នាក់ការធំនៅព្រះរាជាណាចក្រកម្ពុជា ជាសហគ្រាស ក្រុមហ៊ុន សាងសង់បានបែងចែកជា ៣ប្រភេទ ដូចប្រកាសលេខ ៧៥ ប្រក/ដ.ន.ស ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្ដីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ ត្រង់ចំណុច ក ខ គ ក្នុង ប្រការ ៣ ។

៣-១- រូបវន្តបុគ្គលបរទេសសិក្សាគំរោងប្លង់ បានបែងចែកដូចប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្ដីពីការគ្រប់ គ្រង សហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់ត្រង់ចំណុច ឃ១ ឃ២ ឃ៣ ឃ៤ ឃ៥ ក្នុងប្រការ២ ។

## IV ទំរង់បែបបទសុំប្រកបអាជីវកម្មសិក្សាគំរោងប្លង់ និង សាងសង់

ទំរង់បែបបទសុំប្រកបអាជីវកម្ម មានលក្ខខ័ណ្ឌកំណត់ដូចប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ២ ខែកញ្ញា ឆ្នាំ ១៩៩៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្ដីពីការគ្រប់ គ្រង សហគ្រាស ក្រុមហ៊ុនសិក្សាគំរោងប្លង់ និង សាងសង់ប៉ុន្តែចំពោះ :

១- នាយកបច្ចេកទេស នាយកគំរោង និង អ្នកបច្ចេកទេសនៃសហគ្រាស ក្រុមហ៊ុនបរទេសដែលមាន ការិយាល័យតំណាង ឬទីភ្នាក់ងារ និង សាខា ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានសញ្ជាតិ បរទេស ឬ ខ្មែរ

២- ការអនុវត្តការងារសិក្សាគំរោងប្លង់ និង សាងសង់ត្រូវអនុវត្តតាមលិខិតបទដ្ឋានបច្ចេកទេសរបស់ ព្រះរាជាណាចក្រកម្ពុជា ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់អគ្គនាយកដ្ឋាន និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារខាងលើ និងតាមភារកិច្ចរៀង១ខ្លួនដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់

រដ្ឋមន្ត្រី

អ៊ឹម ឈុនលឹម

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- គ្រប់អគ្គនាយកដ្ឋាន
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរ ដ.ន.ស.ស ខេត្ត ក្រុង
- ឯកសារ- កាលប្បវត្តិ